# យុទ្ធសាស្ត្រជាតិ
# ស្តីពី
# វិស័យផ្គត់ផ្គង់ទឹកស្អាត
# និង អនាម័យជនបទ ២០១១-២០២៥



ខែមេសា ឆ្នាំ២០១១







# បុព្វកថា

រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា នៅតែចាត់ទុកថា ការកាត់បន្ថយភាពក្រីក្រ តាមរបៀបមួយដ៏ឆាប់តាមដែលអាចធ្វើបាន គឺជាអាទិភាពដ៏ចម្បងមួយ ។ ការអភិវឌ្ឍជនបទ គឺមានសារៈសំខាន់បំផុតសម្រាប់ការកាត់បន្ថយភាពក្រីក្រ ដោយហេតុថា ៨៥ ភាគរយ នៃប្រជាជនក្រីក្ររស់នៅតំបន់ជនបទ ។ រាជរដ្ឋាភិបាល នឹងបន្តជំរុញការអនុវត្តកម្មវិធីអភិវឌ្ឍន៍ជនបទចម្រុះ ដែលផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើកត្តាដែលមានផលប៉ះពាល់ជាវិជ្ជមាន ទៅលើប្រជាពលរដ្ឋក្រីក្រនៅតំបន់ជនបទ ដូចជា ការពង្រឹងសមត្ថភាពស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស ការអនុវត្តផែនការមូលដ្ឋានចម្រុះ ការកសាងផ្លូវជនបទ ការផ្គត់ផ្គង់ទឹកនៅជនបទ ការថែទាំសុខភាពបឋម និងការងារអនាម័យជនបទ ការអភិវឌ្ឍសហគមន៍ និងការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ដើម្បីលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជនកម្ពុជាឲ្យមានភាពប្រសើរជាងមុន ជាពិសេស ប្រជាជននៅជនបទ ។

ដោយឡែក សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ គឺជាតម្រូវការបន្ទាន់បំផុតសម្រាប់ការពារ និងលើកស្ទួយសុខភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមទីជនបទ និងធ្វើឲ្យប្រសើរនូវស្ថានភាពសេដ្ឋកិច្ចទៀតផង។ គោលដៅអភិវឌ្ឍន៍សហស្សវត្សរកម្ពុជា បានកំណត់រួចហើយថានៅឆ្នាំ ២០១៥ " ប្រជាពលរដ្ឋ ៥០% ដែលរស់នៅតំបន់ជនបទមានសេវាទឹកស្អាតប្រើប្រាស់ និងប្រជាពលរដ្ឋ ៣០% ដែលរស់នៅតំបន់ជនបទមានសេវាអនាម័យល្អ" ។

ផ្អែកលើតម្រូវការចាំបាច់ជាមូលដ្ឋាននេះ ក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្រោមការសម្របសម្រួលរបស់ក្រសួងអភិវឌ្ឍន៍ជនបទ បានរៀបចំយុទ្ធសាស្ត្រជាតិស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទនេះឡើង សម្រាប់អនុវត្តរយៈពេល ១៥ ឆ្នាំ ពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០២៥ ដោយបានកំណត់យ៉ាងប្រាកដប្រជាថា "មនុស្សគ្រប់រូបត្រូវមានសេវាផ្តល់ទឹកស្អាត និងរស់នៅក្នុងបរិស្ថានប្រកបដោយអនាម័យនៅឆ្នាំ ២០២៥ " ។ យុទ្ធសាស្ត្រនេះ បានកំណត់វិធានការនានាក្នុងនោះមានការរៀបចំពង្រឹងស្ថាប័ន ការទទួលខុសត្រូវរបស់ស្ថាប័នពាក់ព័ន្ធគ្រប់កម្រិត ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការលើកកម្ពស់ការចូលរួមរបស់សហគមន៍ ដែលជាអ្នកទទួលផលពីសេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ការពង្រឹងគុណភាពសេវាកម្ម និងការចូលរួមរបស់វិស័យឯកជន ។ល។ ផ្អែកលើទស្សនៈនេះ ខ្ញុំសូមអំពាវនាវរាល់ស្ថាប័នពាក់ព័ន្ធទាំងអស់ រួមគ្នាអនុវត្តយុទ្ធសាស្ត្រនេះឲ្យមានប្រសិទ្ធភាព និងបំពេញតួនាទីការទទួលខុសត្រូវ ដូចដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រដ៏មានសារៈសំខាន់នេះ។ ក្រសួងអភិវឌ្ឍន៍ជនបទ ដែលជាស្ថាប័នមានសមត្ថកិច្ចរៀបចំ សម្របសម្រួល អនុវត្ត និងតាមដាន វាយតម្លៃការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រជាតិ ស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និង

អនាម័យជនបទ នឹងខិតខំធ្វើការសហការឲ្យបានជិតស្និទ្ធជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីសម្រេចគោលដៅរួមទាំងអស់គ្នា គឺបម្រើផលប្រយោជន៍ដល់ប្រជាជននៅជនបទ ។

ការផ្តល់លទ្ធភាពជូនប្រជាពលរដ្ឋប្រើប្រាស់ និងទទួលបានសេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ មានសារៈប្រយោជន៍ដ៏ធំធេង ទាំងលើទិដ្ឋភាពសេដ្ឋកិច្ច និងសង្គម ។ តាមការសិក្សាថ្មីៗនេះបានបង្ហាញថា នៅប្រទេសកម្ពុជា ការវិនិយោគ ០១ ដុល្លារអាមេរិក សម្រាប់កែលម្អអនាម័យ កម្ពុជានឹងទទួលផលចំណេញមកវិញប្រហែល ១០ ដុល្លារអាមេរិក ។ ដោយឡែកការវិនិយោគ ០១ ដុល្លារអាមេរិក ក្នុងសេវាផ្គត់ផ្គង់ទឹកស្អាត នឹងផ្តល់ផលចំណេញមកវិញបានចំនួន ០៨ ដុល្លារអាមេរិក ចំពោះសេដ្ឋកិច្ចជាតិ ។ ដោយសារប្រការនេះហើយ ទើបក្រសួងអភិវឌ្ឍន៍ជនបទ បានខិតខំធ្វើការយ៉ាងសកម្ម និងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីជំរុញសកម្មភាព និងអនុវត្តនូវការផ្តល់សេវាទឹកស្អាត និងអនាម័យជនបទ សម្រាប់បម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ជាពិសេសប្រជាជននៅតាមទីជនបទ ដែលខ្វះអនាម័យ និងខ្វះប្រភពទឹកសម្រាប់ប្រើប្រាស់ ។ នេះគឺជាផលប្រយោជន៍ដោយផ្ទាល់បានទៅប្រជាជន និងជាការរួមចំណែកលើកស្ទួយជីវភាពរស់នៅរបស់ប្រជាជននៅតាមជនបទ។ ផលប្រយោជន៍រួមទាំងអស់នេះ មានទំហំធំធេងណាស់សម្រាប់ប្រទេសកម្ពុជា។ ឈរលើផលចំណេញផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ចនេះ វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ បានជួយសន្សំថវិកាចំណាយយ៉ាងច្រើនសម្រាប់វិស័យពាក់ព័ន្ធមួយចំនួន ដូចជាវិស័យសុខាភិបាលជាដើម និងបានចូលរួមចំណែកធ្វើឲ្យសម្រេចនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ជាច្រើនចំណុច ដូចជា ការកាត់បន្ថយភាពក្រីក្រ ការកាត់បន្ថយជំងឺរាក បង្កើនលទ្ធភាពទទួលបានការអប់រំ កាត់បន្ថយមរណភាពកុមារ និងកែលម្អការថែទាំសុខភាពមាតា ។

ខ្ញុំមានក្តីសង្ឃឹមយ៉ាងមុតមាំថា ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ និងដៃគូអភិវឌ្ឍន៍នានា ដែលធ្វើការក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ នឹងស្វែងយល់ពីយុទ្ធសាស្រ្តនេះឲ្យបានស៊ីជម្រៅ ព្រមទាំងយកទៅប្រើប្រាស់ជាមគ្គុទ្ទេសក៍ក្នុងការងារផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ដើម្បីជាប្រយោជន៍ដល់ប្រជាជនរស់នៅជនបទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១១

រដ្ឋមន្ត្រី

ជា សុផារ៉ា

# មាតិកា


អក្សរកាត់....................vi

១ .សេចក្តីផ្តើម....................10

២ .ក្របខណ្ឌសម្រាប់គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ....................13

៣. គោលដៅយុទ្ធសាស្ត្រ....................15

៤. ទិសាលភាព....................19

៥. គោលការណ៍....................21

និរន្តរភាព....................21

ការគ្រប់គ្រងដោយសហគមន៍....................22

វិធីសាស្ត្រឆ្លើយតបទៅនឹងតម្រូវការ....................22

ការចូលរួមបដិភាគ សម្រាប់សេវាផ្គត់ផ្គង់ទឹកស្អាត....................23

ការផ្តល់ហិរញ្ញប្បទានផ្នែកអនាម័យ....................23

ប្រតិបត្តិការ និងការថែទាំ....................24

វិមជ្ឈការ និងវិសហមជ្ឈការ នៃការផ្តល់សេវា និងការគ្រប់គ្រង....................24

គណនេយ្យភាព....................24

ការបញ្ជ្រាបយេនឌ័រ....................24

ការបញ្ជ្រាបបញ្ហាពិការភាព....................25

៦. ការវិភាគស្ថានភាព....................26

**បញ្ហាប្រឈមសំខាន់ៗ**....................26

**ហិរញ្ញប្បទាន**....................31

**គោលនយោបាយ**....................33

បទដ្ឋានគតិយុត្តិ....................36

**វិមជ្ឈការ និងវិសហមជ្ឈការ**....................39

**យុទ្ធសាស្ត្រ និងផែនការពាក់ព័ន្ធផ្សេងៗ**....................39

**តួនាទី និងការទទួលខុសត្រូវ**....................41

ការសម្របសម្រួល ........ 44

ការគ្រប់ដណ្តប់ និងចំណុចគោលដៅ ........ 44

ភាពក្រីក្រ និងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ........ 47

៧ .សេចក្តីសង្ខេបគោលដៅយុទ្ធសាស្រ្ត និងសមាសភាគ........ 51

**សមាសភាគ ១.១ ÷ ការទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត** ........ 77

**សមាសភាគ ១.៣ ÷ ប្រតិបត្តិការ និងការថែទាំ**........ 88

គោលដៅយុទ្ធសាស្រ្តទី២ ÷ ការទទួលបានអនាម័យដែលមានការកែលម្អ ........ 92

**សមាសភាគ ២.១ ÷ ការបង្កើនលទ្ធភាពទទួលបានអនាម័យ**........ 92

**សមាសភាគ២.២. ÷ ប្រតិបត្តិការ និងការថែទាំ** ........ 96

**សមាសភាគ ២.៣ ÷ អនាម័យនៅតាមសាលារៀន គ្រឹះស្ថានសុខាភិបាល និងស្ថាប័នដទៃទៀត នៅតាមជនបទ**........ 97

គោលដៅយុទ្ធសាស្រ្តទី ៣ ÷ ការផ្លាស់ប្តូរឥរិយាបថផ្នែកអនាម័យផ្ទាល់ខ្លួន ........ 102

**សមាសភាគ ៣.១ ÷ ការលើកកម្ពស់អនាម័យផ្ទាល់ខ្លួន**........ 102

គោលដៅយុទ្ធសាស្រ្តទី៤ ÷ ការអភិវឌ្ឍ និងការប្រតិបត្តិលើមធ្យោបាយនានាដើម្បីសម្រេច ឱ្យបានសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទប្រកបដោយនិរន្តរភាព........ 103

**សមាសភាគ ៤.១ ÷ ការគ្រប់គ្រងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ**........ 103

សមាសភាគ ៤.៣ ការអភិវឌ្ឍវិស័យឯកជន........ 114

សមាសភាគ ៤.៤ ការធ្វើផែនការ និងប្រព័ន្ធគ្រប់គ្រងព័ត៌មាន........ 120

សមាសភាគ ៤.៥ ការវាយតម្លៃ និងការរៀនសូត្រ........ 121

សមាសភាគ៤.៧ . ទំនាក់ទំនង ........ 123

សមាសភាគ ៤.៨ ភាពក្រីក្រ ជនជាតិភាគតិច ភាពងាយរងគ្រោះ ........ 124

សមាសភាគ ៤.៩ ការបញ្ជ្រាបយេនឌ័រ........ 126

សមាសភាគ ៤.១០ បរិស្ថាន........ 128

សមាសភាគ៤.១១ .ការគ្រប់គ្រង និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ........ 129

គោលដៅយុទ្ធសាស្រ្តទី៥ ÷ ហិរញ្ញប្បទានសម្រាប់វិស័យ ........ 130

សមាសភាគ៥.១ .ហិរញ្ញប្បទាននៃចំណាយទុនដើម........ 130

សមាសភាគ៥.២ . ហិរញ្ញប្បទានលើចំណាយចរន្ត ................................................. 137

**៩. តារាងពេលវេលា** .................................................................................... 139

៩.១. អន្តរកាល ............................................................................................ 139

៩.២. ការពិនិត្យឡើងវិញ .................................................................................. 139

**ឧបសម្ព័ន្ធទី១ ÷ និយមន័យ** ............................................................................ 140

**ឧបសម្ព័ន្ធទី២÷ សាវតានៃគោលការណ៍** ................................................................ 148

១.១. និរន្តរភាព ............................................................................................ 148

១.២. ការគ្រប់គ្រងដោយសហគមន៍ ........................................................................ 150

១.៣ វិធីសាស្ត្រឆ្លើយតបទៅនឹងតម្រូវការ ............................................................... 152

១.៤. ការចូលរួមក្នុងការចំណាយ .......................................................................... 153

១.៥. ការផ្តល់ហិរញ្ញប្បទានផ្នែកអនាម័យ .................................................................. 154

១.៦ សមាហរណកម្ម ឬ ការធ្វើដោយឡែកពីគ្នា នៃវិស័យផ្គត់ផ្គង់ទឹកស្អាត អនាម័យ និងការលើកកម្ពស់អនាម័យផ្ទាល់ខ្លួន ............................................................................................ 157

១.៧. ប្រតិបត្តិការ និងថែទាំ .............................................................................. 157

១.៨. កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ........................................................... 158

១.៩. គណនេយ្យភាព ....................................................................................... 160

១.១០. ការបញ្ជ្រាបយេន័រ .................................................................................. 163

១.១១. ការបញ្ជ្រាបពិការភាព ............................................................................... 164

**ឧបសម្ព័ន្ធទី៣ ÷ គោលការណ៍ណែនាំដើម្បីគាំទ្រទ្រង់សកម្មភាព** ........................................ 166

យន្តការផ្តល់ហិរញ្ញប្បទានផ្នែកអនាម័យ ................................................................... 166

ប្រព័ន្ធគាំទ្រការថែទាំ ..................................................................................... 168

ប្រព័ន្ធត្រួតពិនិត្យគុណភាពទឹក ............................................................................ 170

ការអភិវឌ្ឍខ្សែសង្វាក់ផ្គត់ផ្គង់ ............................................................................. 172

តម្រូវការសមត្ថភាពសម្រាប់ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក .......................................... 180

ប្រព័ន្ធគ្រប់គ្រងព័ត៌មាន ................................................................................... 181

ការសិក្សាស្រាវជ្រាវ អភិវឌ្ឍ និងការច្នៃប្រឌិត ........................................................................ 184
**ឧបសម្ព័ន្ធទី៥ ÷ តួនាទីនៅក្នុងការផ្តល់សេវាកម្ម និងបរិយាកាសសមស្រប**................................ 188
**ឧបសម្ព័ន្ធទី៦ ÷ ឯកសារយោង**.................................................................................. 203

# អក្សរកាត់

| Acronym | English | Khmer |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| AISC | Arsenic Inter-ministerial Sub-Committee | អនុគណៈកម្មការអន្តរក្រសួងសម្រាប់ត្រួតពិនិត្យសារធាតុអាសេនិក |
| AMK | Angkor Mikroheranhvatho (Kampuchea) Co. Ltd (Angkor Microfinance Kampuchea | អង្គរមីក្រូហិរញ្ញវត្ថុកម្ពុជា ( អេអឹមខេ ) |
| CC | Commune Council | ក្រុមប្រឹក្សាឃុំសង្កាត់ |
| CCWC | Commune Councillor for Women and Children | គណៈកម្មការទទួលបន្ទុកស្ត្រី និងកុមារឃុំ |
| CDC | Council for Development of Cambodia | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CDRI | Cambodia Development Resource Institute | វិទ្យាស្ថានអភិវឌ្ឍន៍ធនធានកម្ពុជា |
| CLTS | Community Led Total Sanitation | សហគមន៍ដឹកនាំអនុវត្តន៍អនាម័យទាំងស្រុង |
| CMDG | Cambodian Millennium Development Goal | គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា |
| D&D | decentralisation and deconcentration | វិមជ្ឈការ និងវិសហមជ្ឈការ |
| DFID | Department for International Development (official British aid) | ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ<br>នៃចក្រភពអង់គ្លេស( DFID ) |
| DAC | Disability Action Council | ក្រុមប្រឹក្សាសកម្មភាពជនពិការ |
| DORD | District Office of Rural Development | ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក |
| DPO | Disabled people's organizations | អង្គការជនពិការ |

| | | |
|---|---|---|
| DRHC | Department of Rural Health Care (in MRD) | នាយកដ្ឋានថែទាំសុខភាពជនបទ (ក្នុងក្រសួងអភិវឌ្ឍន៍ជនបទ) |
| DRWS | Department of Rural Water Supply (in MRD) | នាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ (ក្នុងក្រសួងអភិវឌ្ឍន៍ជនបទ) |
| ERW | Explosive Remnants of War | សំណល់គ្រាប់មិនទាន់ផ្ទុះ |
| ETV | Environmental Technology Verification | ការត្រួតពិនិត្យបច្ចេកវិទ្យាបរិស្ថាន |
| HR | Human Resources | ធនធានមនុស្ស |
| IDPoor | Identification of Poor Households Program | កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ |
| IFC | International Finance Corporation of the World Bank | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិនៃធនាគារពិភពលោក |
| INGO | International Non-governmental organisation | អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ |
| IRC | International Reference Centre for Water Supply and Sanitation (in the Netherlands) | មជ្ឈមណ្ឌលស្រាវជ្រាវអន្តរជាតិ សម្រាប់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ (នៅប្រទេសហូឡង់) |
| IWRM | Integrated water resources management | ការគ្រប់គ្រងធនធានទឹកចម្រុះ |
| MAFF | Ministry of Agriculture, Fisheries and Forests | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MDG | Millennium Development Goal | គោលដៅអភិវឌ្ឍន៍សហសវត្សរ៍ |
| MEF | Ministry of Economics and Finance | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| mg/L | milligrams per litre | មីលីក្រាមក្នុងមួយលីត្រ |
| MIME | Ministry of Industry Mines & Energy | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |

| | | |
|---|---|---|
| MIS | management information system | ប្រព័ន្ធគ្រប់គ្រងព័ត៌មាន |
| mL | Millilitres | មីលីលីត្រ |
| MoEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| MOH | Ministry of Health | ក្រសួងសុខាភិបាល |
| MoSVY | Ministry of Social Affairs, Veterans and Youth Rehabilitation | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| MOWA | Ministry of Women's Affairs | ក្រសួងកិច្ចការនារី |
| MOWRAM | Ministry of Water Resources and Meteorology | ក្រសួងធនធានទឹក និងឧតុនិយម |
| MRD | Ministry of Rural Development | ក្រសួងអភិវឌ្ឍន៍ជនបទ |
| NCDD | National Committee for Sub-National Democratic Development | គណៈកម្មការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ (គជអប) |
| NCDDS | National Committee for Sub-National Democratic Development Secretariat | លេខាធិការដ្ឋាននៃគណៈកម្មការសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NCDM | National Committee for Disaster Management | គណៈកម្មការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |
| NGO | Non-governmental organisation | អង្គការមិនមែនរដ្ឋាភិបាល |
| NIS | National Institute of Statistics | វិទ្យាស្ថានជាតិស្ថិតិ |
| NSDP | National Strategic Development Plan | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) |
| NTU | Nephelometric Turbidity Units – a physical measurement of turbidity in water quality | កម្រិតភាពល្អក់ សម្រាប់គុណភាពទឹក |
| OBA | output based aid | ជំនួយផ្អែកតាមលទ្ធផល |

| | | |
|---|---|---|
| ODF | Open defecation free | បញ្ឈប់ការបន្ទោបង់លាមកពាសវាលពាសកាល |
| O&M | operation and maintenance | ប្រតិបត្តិការ និងការថែទាំ |
| Organic Law | Law on Administrative Management of Capital, Provinces, Municipalities, Districts and Khans | ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ |
| PDRD | Provincial Department of Rural Development | មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត (មអជខ) |
| PFMRP | Public Financial Management Reform Program | កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| pH | In chemistry , pH is a measure of the acidity or basicity of a solution on scale of 0 to 14 (7 is neutral) | សន្ទស្សន៍អាស៊ីត និង បាស (PH ប៉េហាស់ ខ្នាតវាស់ សូលុយស្យុងអាស៊ីត ឬបាស ពី 0 ដល់ ១៤ ដែល ៧ ជាកម្រិតកណ្តាល) |
| PIF | Provincial Investment Fund | មូលនិធិវិនិយោគខេត្ត |
| PLAU | Provincial Local Administration Unit | អង្គភាពរដ្ឋបាលមូលដ្ឋាន |
| PRDC | Provincial Rural Development Committee | គណៈកម្មការអភិវឌ្ឍន៍ជនបទខេត្ត |
| RGC | Royal Government of Cambodia | រាជរដ្ឋាភិបាលកម្ពុជា |
| RWSSH | Rural water supply, sanitation and hygiene | វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ |
| Sani-FOAM | framework for Sanitation Focus, Opportunity, Ability, Motivation | របាយការណ៍ក្របខ័ណ្ឌផ្តោតលើអនាម័យ ឱកាស សមត្ថភាព ការលើកទឹកចិត្ត |
| SME | small and medium enterprises | សហគ្រាសធុនតូច និងមធ្យម |
| TDS | Total Dissolved Solids (in water quality) | សារធាតុមិនរលាយក្នុងទឹក (គុណភាពទឹក) |
| TWG | Technical Working Group | ក្រុមការងារបច្ចេកទេស |

| | | |
|---|---|---|
| TWG-RWSSH | Technical Working Group for Rural Water Supply, Sanitation and Hygiene | ក្រុមការងារបច្ចេកទេសសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាត និង  អនាម័យជនបទ |
| UNDP | United Nations Development Program | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| UNICEF | United Nations Children's Fund | មូលនិធិអង្គការសហប្រជាជាតិសម្រាប់កុមារ |
| USD | United States dollars | ដុល្លារអាមេរិក |
| VIP | Ventilated Improved Pit (latrine) | បង្គន់អនាម័យដែលបានកែលំអឱ្យមានខ្យល់ចេញចូល ក្នុងរណ្តៅ |
| WASH | water, sanitation and hygiene | ទឹកស្អាត និងអនាម័យ |
| WELL | resource centre for water, sanitation and environmental health | មជ្ឈមណ្ឌលធនធានសម្រាប់ទឹកស្អាត អនាម័យ និងសុខភាព  បរិស្ថាន នៅអង់គ្លេស |
| WHO | World Health Organisation | អង្គការសុខភាពពិភពលោក |
| WSP | Water & Sanitation Program | កម្មវិធីទឹកស្អាត និងអនាម័យ |
| WSS | Water supply and sanitation | ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ |
| WSSCC | Water Supply and Sanitation Collaborative Council | ក្រុមប្រឹក្សាសហប្រតិបត្តិការវិស័យទឹកស្អាត និងអនាម័យ |
| WSUG | Water & Sanitation User Group | ក្រុមប្រើប្រាស់ទឹក និងអនាម័យ |

# ១. សេចក្ដីផ្ដើម

តម្រូវការយុទ្ធសាស្ត្រជាតិស្ដីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ត្រូវបានទទួលស្គាល់ពីភាគីពាក់ព័ន្ធជាយូរមកហើយ ដែលមានគោលបំណងកំណត់ឱ្យបាននូវសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ សម្រាប់ប្រជាពលរដ្ឋរស់នៅតាមតំបន់ជនបទ និងកំណត់ឱ្យមានការរៀបចំស្ថាប័ន ធនធានហិរញ្ញវត្ថុ ធនធានមនុស្ស ព្រមទាំងធនធានផ្សេងៗទៀត ដែលចាំបាច់ដើម្បីផ្ដល់សេវាកម្មទាំងនេះប្រកបដោយនិរន្តរភាព ។ គោលបំណងសំខាន់ គឺដើម្បីពន្លឿនដំណើរការនេះឆ្ពោះទៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ឆ្នាំ២០១៥ និងសម្រេចបាននូវទស្សនវិស័យរបស់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ឆ្នាំ២០២៥ ។

ក្រសួងអភិវឌ្ឍន៍ជនបទ មានការទទួលខុសត្រូវទាំងស្រុងលើយុទ្ធសាស្ត្រ និងការអនុវត្តស្របតាមគោលការណ៍ណែនាំរបស់ក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ។

យុទ្ធសាស្ត្រនេះ ត្រូវបានប្រើប្រាស់ដោយស្ថាប័នគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធ រួមទាំងស្ថាប័នថ្នាក់ជាតិថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ និងវិស័យឯកជន ។ ចំពោះឯកសារយុទ្ធសាស្ត្រសង្ខេប និងផ្ទាំងក្រដាសព័ត៌មាននឹងត្រូវបានរៀបចំសម្រាប់ស្ថាប័នថ្នាក់ក្រោមជាតិ ។

វិស័យនេះ មានដំណើរការទៅតាមលំដាប់ថ្នាក់ខុសៗគ្នាមួយចំនួនដូចជាកម្រិតគ្រួសារ និងសហគមន៍ កម្រិតថ្នាក់ឃុំ ថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិ នៅតាមលំដាប់ថ្នាក់នីមួយៗ មានអ្នកអនុវត្ត ភាគីពាក់ព័ន្ធ ព្រមទាំងបុគ្គលផ្សេងៗគ្នាជាច្រើន ដែលពួកគេម្នាក់ៗមានទស្សនៈ និងមតិយោបល់ផ្សេងៗគ្នា ។ ទស្សនៈ និងមតិយោបល់ផ្សេងៗទាំងអស់នេះ បូកបញ្ចូលគ្នាបានធ្វើឲ្យវិស័យនេះជាវិស័យដែលមានលក្ខណៈស្មុគ្រស្មាញ ទាំងគុណតម្លៃ ទាំងការយល់ដឹងពីបញ្ហាប្រឈមប្រព័ន្ធ និងដំណើរការក៏ដូចជា ការយល់ដឹងពីមធ្យោបាយក្នុងការដោះស្រាយបញ្ហាប្រឈមទាំងមូល ក្នុងការជួយឱ្យប្រជាពលរដ្ឋតាមជនបទទទួលបាននូវសេវាទឹកស្អាត និងអនាម័យប្រកបដោយនិរន្តរភាព។

យុទ្ធសាស្ត្រដោះស្រាយបញ្ហាប្រឈមទាំងនេះ ក៏មានលក្ខណៈស្មុគស្មាញស្រដៀងគ្នាដែរ ។ យើងត្រូវមានសកម្មភាពយុទ្ធសាស្ត្រ និងសកម្មភាពពិស្ដារជាច្រើន នៅតាមលំដាប់ថ្នាក់ខុសៗគ្នាដើម្បីដោះស្រាយបញ្ហាប្រឈមនីមួយៗ ។ គ្រប់សកម្មភាពទាំងអស់នេះ ទាមទារឱ្យមានកិច្ចសម្របសម្រួលដើម្បី សម្រេចបាននូវគោលបំណងរួមរបស់យុទ្ធសាស្ត្រនេះ ។

ក្រសួងអភិវឌ្ឍន៍ជនបទ បានជ្រើសរើសយកវិធីសាស្ត្រតាមបែបចូលរួមដើម្បីអភិវឌ្ឍយុទ្ធសាស្ត្រនេះ ដោយបានជ្រើសរើសទីប្រឹក្សាឯកទេសមួយរូប ដើម្បីដឹកនាំដំណើរការនេះ និងបានបង្កើតក្រុមស្នូលមួយ ដោយមានការចូលរួមពីរដ្ឋលេខាធិការ ប្រធាននាយកដ្ឋានពាក់ព័ន្ធ និងតំណាងដៃគូអភិវឌ្ឍន៍ដើម្បីដឹកនាំការអភិវឌ្ឍយុទ្ធសាស្ត្រនេះ ។ ការពិគ្រោះយោបល់ រួមបញ្ចូលទាំងការងារចុះផ្ទាល់ក្នុងខេត្តមួយចំនួន ព្រមទាំងសិក្ខាសាលាស្ដីពីការវិភាគស្ថានភាពដោយមានការចូលរួមពីតំណាងក្រុមប្រឹក្សាឃុំ-សង្កាត់ (CC) គណៈកម្មការទទួលបន្ទុកស្ត្រី និងកុមារឃុំ (CCWC) អភិបាលស្រុក មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត និងអង្គភាពរដ្ឋបាលមូលដ្ឋាន (PLAU) គ្រប់ខេត្ត ក្រសួងពាក់ព័ន្ធ

ដៃគូអភិវឌ្ឍន៍អង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងវិស័យឯកជន។ ការពិគ្រោះយោបល់ ក៏បានរួមបញ្ចូលនូវសិក្ខាសាលាមួយចំនួន ដោយមានការចូលរួមពីអ្នកជំនាញខាងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ សំខាន់ៗជាច្រើនរូប ដើម្បីដោះស្រាយបញ្ហាជាក់លាក់មួយចំនួន ។ ការពិគ្រោះយោបល់ក៏បានរួមបញ្ចូលផងដែរនូវការរាយការណ៍សង្ខេបជូនក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ( TWG-RWSSH ) ។

## យុទ្ធសាស្ត្រ មានរចនាសម្ព័ន្ធដូចខាងក្រោម ៖

- **ផ្នែកទី១** សេចក្តីផ្តើម ។
- **ផ្នែកទី២** បង្ហាញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រ និងការបន្សុីគ្នារវាងយុទ្ធសាស្ត្រនេះ ទៅនឹងគោលនយោបាយ និងផែនការផ្សេងៗ ។
- **ផ្នែកទី៣** ការរៀបចំគោលដៅយុទ្ធសាស្ត្រនេះ គឺផ្អែកលើទស្សនវិស័យរបស់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ និងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ។
- **ផ្នែកទី៤** កំណត់នូវវិសាលភាពយុទ្ធសាស្ត្រនេះ (អ្វីដែលត្រូវបញ្ចូល និងអ្វីដែលមិនត្រូវបញ្ចូល )។
- **ផ្នែកទី៥** ផ្តល់នូវគោលការណ៍មួយចំនួន ដែលយុទ្ធសាស្ត្រនេះត្រូវបានពឹងផ្អែកលើ និងណែនាំស្ថាប័នទទួលខុសត្រូវវិស័យនេះ ក្នុងការងារផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ។
- **ផ្នែកទី៦** ផ្តល់នូវការវិភាគស្ថានភាពពីបញ្ហាប្រឈមសំខាន់ៗនៅក្នុងវិស័យនេះនិងគោលនយោបាយបទដ្ឋានគតិយុត្តិ យុទ្ធសាស្ត្រដែលបានមកពីវិស័យផ្សេងៗព្រមទាំងព័ត៌មានមួយចំនួនផ្សេងទៀត ដោយរួមបញ្ចូលទាំងតួលេខគ្របដណ្តប់នៃវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទផងដែរ ។
- **ផ្នែកទី៧** មានតារាងនៃគោលដៅយុទ្ធសាស្ត្រ សមាសភាគ និងសកម្មភាព ។
- **ផ្នែកទី៨** ផ្តល់នូវសមាសភាគយុទ្ធសាស្ត្រ ជាមួយនឹងគោលដៅជាក់លាក់ និងសមាសភាគមួយចំនួនដែលចាំបាច់ដើម្បីសម្រេចបានគោលដៅទាំងនេះ ។ ផ្នែកនេះ មានព័ត៌មានសង្ខេប និងការពន្យល់ពីសេចក្តីត្រូវការសម្រាប់សមាសភាគណាដែលចាំបាច់ ។

- **ផ្នែកទី៩** រៀបចំតារាងពេលវេលាសម្រាប់យុទ្ធសាស្ត្រ និងដំណាក់កាលអន្តរកាលដែលមាននៅក្នុងយុទ្ធសាស្ត្រ ។

- **ឧបសម្ព័ន្ធទី១** ផ្តល់នូវនិយមន័យសម្រាប់ពាក្យគន្លឹះជាច្រើនដែលត្រូវ បានយកមកប្រើប្រាស់នៅក្នុងវិស័យ និងយុទ្ធសាស្ត្រនេះ ។ និយមន័យនៃពាក្យទាំងនេះ មានសារៈសំខាន់ណាស់ ព្រោះវាផ្តល់នូវចំណុចមូលដ្ឋានសម្រាប់ភាសាដែលបានឯកភាពរួមគ្នា និងផ្តល់នូវការយល់ដឹងពីពាក្យបច្ចេកទេស ជាពិសេសនៅពេលធ្វើការងារដោយប្រើពីរភាសា គឺភាសាខ្មែរ និងភាសាអង់គ្លេស ។ ប្រសិនបើបុគ្គលគ្រប់រូប ប្រើប្រាស់ពាក្យទាំងនេះក្នុងអត្ថន័យដូចគ្នា នោះឱកាសភ័ន្តច្រឡំនឹងមានតិចជាងមុន ។

- **ឧបសម្ព័ន្ធទី២** ផ្តល់នូវហេតុផល និងការពន្យល់បន្ថែមទៅលើគោលការណ៍នានានៅក្នុងផ្នែកទី៥ ។

- **ឧបសម្ព័ន្ធទី៣** ផ្តល់នូវការណែនាំបន្ថែមដើម្បីគាំទ្រដល់សមាសភាគនិងសកម្មភាពក្នុងផ្នែកទី៨ ។

- **ឧបសម្ព័ន្ធទី៤** បង្កើតជាតារាងដែលបង្ហាញពីតួនាទីលម្អិតតាមលំដាប់ថ្នាក់ខុសៗគ្នាក្នុងការផ្តល់ សេវាកម្ម និងការផ្តល់បរិយាកាសសមស្រប ( Enabling Enviroment ) ។ ឧបសម្ព័ន្ធនេះគាំទ្រ និងផ្តល់ព័ត៌មានបន្ថែមអំពីសកម្មភាព ដែលបានរៀបរាប់ក្នុងសមាសភាគ៤.១.២ ។

- **ឧបសម្ព័ន្ធទី៥** ផ្តល់នូវឯកសារយោង និងប្រភពនៃព័ត៌មាន ដែលបានប្រើប្រាស់នៅក្នុងយុទ្ធសាស្ត្រ នេះ ។

## ២. ក្របខណ្ឌសម្រាប់គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ

តារាងទី១ បង្ហាញនូវក្របខណ្ឌសម្រាប់គោលនយោបាយវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទនិងបរិស្ថានយុទ្ធសាស្ត្រដែលរួមមានការប្រើប្រាស់ឯកសារមួយចំនួនដូចជាគោលនយោបាយយុទ្ធសាស្ត្រ និងផែនការ ។ ពាក្យ "ផែនការយុទ្ធសាស្ត្រ" មិនត្រូវបានប្រើប្រាស់ទេ ដើម្បីជៀសវាងការភ័ន្តច្រឡំជាមួយនឹងពាក្យ "យុទ្ធសាស្ត្រ" ។

### តារាងទី១ ៖ ក្របខណ្ឌយុទ្ធសាស្ត្រ

| | | |
|---|---|---|
| **គោលនយោបាយ**<br>◆ អភិវឌ្ឍទស្សនវិស័យ រយៈពេល ២៥ ឆ្នាំ សម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាត និង អនាម័យជនបទ ។<br>◆ កំណត់តួនាទីវិធាននិង វិធីសាស្ត្រ (approaches) ផ្សេងៗ ដែលនឹងត្រូវផ្សារភ្ជាប់ដើម្បីសម្រេចបានគោលដៅ ។ | | **បរិយាយទស្សនវិស័យ**<br>◆ ការប្រកាសពីទិសដៅ ដែលវិស័យនេះត្រូវធ្វើដំណើរសម្រាប់ស្ថានភាពអនាគត<br>◆ បង្កើតឲ្យមានទិដ្ឋភាពមួយដែលពិពណ៌នាពីអនាគត និងទិសដៅរបស់វិស័យនេះ ។<br><br>**គោលការណ៍** |
| **យុទ្ធសាស្ត្រ**<br>◆ មធ្យោបាយដែលជួយឲ្យគោលនយោបាយមានប្រសិទ្ធភាពខ្ពស់ (ជាស្ពានចម្លងរវាងគោលនយោបាយ ឬគោលដៅកម្រិតខ្ពស់ និងសកម្មភាពលម្អិត) ។<br>◆ យុទ្ធសាស្ត្រនេះ រួមមានទាំងគោលដៅរយៈពេលមធ្យម និងរយៈពេលវែង និងសមាសភាគរួមផ្សំមួយចំនួនទៀត ដើម្បីគាំទ្រនូវការសម្រេចបានគោលដៅអភិវឌ្ឍន៍ និងដើម្បីអនុវត្តគោលនយោបាយ ។ | | **គោលដៅយុទ្ធសាស្ត្រ**<br>◆ គោលដៅរយៈពេលមធ្យម និងរយៈពេលវែង របស់យុទ្ធសាស្ត្រ រួមបញ្ចូលគ្នាដើម្បីសម្រេចបានទស្សនវិស័យរួម ។ |
| **គោលការណ៍ណែនាំ** | | គោលការណ៍ណែនាំសម្រាប់អនុវត្ត<br>គោលការណ៍ណែនាំបច្ចេកទេស<br>បទដ្ឋានផ្សេងៗ |

| | | |
|---|---|---|
| **ផែនការរំកិលរយៈពេលវែង** | ➡ | ផែនការសម្រាប់រយៈពេលច្រើនឆ្នាំ |
| ⬇ | | |
| **ផែនការប្រតិបត្តិការប្រចាំឆ្នាំ**<br>◆ បង្កើតកន្សោមភារកិច្ច ហើយចាត់តាំងឱ្យទៅបុគ្គល ឬ ក្រុមនីមួយៗដែលកំណត់បញ្ជីគោលដៅសម្រាប់ភារកិច្ចនីមួយៗ ក៏ដូចជាកាលបរិច្ឆេទ អ្នកទទួល ខុសត្រូវ និងការវាស់វែងសម្រាប់ភាពជោគជ័យ ។<br>◆ ផែនការសកម្មភាព បង្ហាញទៅបុគ្គល ឬ ក្រុមនោះ ពីរបៀបដែលពួកគេនឹងត្រូវធ្វើដើម្បីសម្រេចគោលបំណងរបស់ស្ថាប័នទាំងមូល ។ | | **ផែនការប្រចាំឆ្នាំ**<br>◆ សកម្មភាព<br>◆ លទ្ធផល<br>◆ សូចនាករ<br>◆ ធាតុចូល ( input )<br>- បុគ្គលិក<br>- ថវិកា<br>- ធនធានផ្សេងៗទៀត |

## ៣. គោលដៅយុទ្ធសាស្ត្រ

ទស្សនវិស័យរបស់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ កំណត់គោលដៅរួម រីឯគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា កំណត់គោលដៅរយៈពេលមធ្យម សម្រាប់ស្ថាប័នដែលធ្វើការក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ៖

### ទស្សនវិស័យរបស់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ

នៅឆ្នាំ ២០២៥ ប្រជាពលរដ្ឋគ្រប់រូបនៅសហគមន៍ជនបទ ត្រូវមានសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ ព្រមទាំងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយនិរន្តរភាព ។

### គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា

គោលដៅទី៧ នៃគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ៖ ធានាឱ្យបាននូវនិរន្តរភាពបរិស្ថាន

ចំណុចគោលដៅទី៧.១០៖ បង្កើនភាគរយប្រជាពលរដ្ឋជនបទឲ្យទទួលបានប្រភពទឹកដែលបាន កែលម្អ ពី ២៤% នៅឆ្នាំ១៩៩៨ ឱ្យកើនដល់ ៥០% នៅឆ្នាំ២០១៥ ។

ចំណុចគោលដៅទី៧.១២៖ បង្កើនភាគរយប្រជាពលរដ្ឋជនបទឲ្យទទួលបានអនាម័យដែលមានការកែលម្អ ពី៨.៦% នៅឆ្នាំ ១៩៩៦ ឱ្យកើនដល់ ៣០% នៅឆ្នាំ ២០១៥ ។

### យុទ្ធសាស្ត្រ

ឯកសារយុទ្ធសាស្ត្រនេះ កំណត់អត្ថន័យ នៃសេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យដែលអាចឲ្យប្រជាពលរដ្ឋរស់នៅតាមតំបន់ជនបទទទួលយកបានព្រមទាំងការរៀបចំស្ថាប័ន ហិរញ្ញវត្ថុ ធនធានមនុស្ស និងធនធានផ្សេងៗទៀតដែលចាំបាច់សម្រាប់ការផ្តល់សេវាទាំងនេះឲ្យមាននិរន្តរភាព ។

### គោលដៅយុទ្ធសាស្ត្រចំនួនប្រាំ

ត្រូវបានបង្កើតឡើងដើម្បីសម្រេចនូវគោលដៅរយៈពេលមធ្យម និង គោលដៅរួម។

### គោលដៅយុទ្ធសាស្ត្រ

១. ផ្នែកផ្គត់ផ្គង់ទឹកៈ នៅឆ្នាំ ២០១៥ ប្រជាជនជនបទ ៥០% និងនៅឆ្នាំ ២០២៥ ប្រជាជនជនបទ ១០០% នឹងទទួលបានការផ្គត់ផ្គង់ទឹកដែលមានការកែលម្អប្រកបដោយនិរន្តរភាព ។

២. ផ្នែកអនាម័យៈ នៅឆ្នាំ ២០១៥ ប្រជាជនជនបទ ៣០% និងនៅឆ្នាំ ២០២៥ ប្រជាជនជនបទ ១០០% នឹងទទួលបាន សេវាអនាម័យដែលមានការកែលម្អ ប្រកបដោយនិរន្តរភាព និងរស់នៅក្នុងបរិស្ថានដែលមានអនាម័យល្អ ។

៣. ការលើកកម្ពស់អនាម័យៈ នៅឆ្នាំ ២០១៥ ប្រជាជនជនបទ ៣០% និងនៅឆ្នាំ ២០២៥ ប្រជាជនជនបទ ១០០% នឹងអនុវត្តទម្លាប់អនាម័យផ្ទាល់ខ្លួនទាក់ទងនឹងការប្រើប្រាស់ទឹកស្អាត និងអនាម័យ ។

៤. បរិយាកាសសមស្រប: នៅឆ្នាំ ២០១៥ ស្ថាប័ន លិខិតបទដ្ឋានគតិយុត្ត និងធនធានមនុស្ស ត្រូវបានរៀបចំអភិវឌ្ឍឲ្យមានលក្ខណៈសមស្រប ដើម្បីបង្កើន និងធ្វើឲ្យមាននិរន្តរភាពនូវការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ និងការលើកកម្ពស់អនាម័យផ្ទាល់ខ្លួនជូនដល់ប្រជាពលរដ្ឋតាមជនបទ ។

៥. ហិរញ្ញប្បទាន: ធនធានហិរញ្ញវត្ថុសម្រាប់ចំណាយលើថ្លៃទុនដើម និងលើចំណាយចរន្តនឹងអាចរកបាន ។

គោលដៅយុទ្ធសាស្ត្រ ចែកចេញជាពីរក្រុម ៖

ក. សេវាកម្មជាក់ស្តែងក្នុងការផ្គត់ផ្គង់ទឹកស្អាត អនាម័យ និងការលើកកម្ពស់អនាម័យផ្ទាល់ខ្លួនត្រូវផ្តល់ឱ្យចាប់តាំងពីការបង្កើតតម្រូវការ រហូតដល់ប្រតិបត្តិការសេវាកម្មរយៈពេលវែង ។ សេវាកម្មទាំងនេះ ត្រូវបានពិពណ៌នានៅផ្នែកទី៧.១ ។

ខ. មធ្យោបាយផ្តល់សេវាទាំងនេះ រួមមានតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នពាក់ព័ន្ធវិស័យឯកជន និងសមត្ថភាព ។ មធ្យោបាយទាំងនេះ ត្រូវបានពិពណ៌នានៅផ្នែកទី៧.២។

ក្រុមទាំងពីរមានមុខងារផ្សេងៗគ្នាជាមួយនឹងតួនាទីខុសៗគ្នាសម្រាប់ក្រុមនីមួយៗ។តួនាទីទាំងនេះមាន ៖

- ការប្រគល់ការងារ ៖ ការរៀបចំកិច្ចការត្រូវបានអនុវត្ត តាមរយៈការចាត់តាំង ឬ ការផ្ទេរសិទ្ធិការងារ ទៅឱ្យផ្នែក ឬ ស្ថាប័នរដ្ឋាភិបាលដទៃទៀត ឬ តាមរយៈការចុះកិច្ចសន្យាផ្ទេរការងារទៅឱ្យស្ថាប័ន ខាងក្រៅ ដូចជាវិស័យឯកជន ឬ អង្គការមិនមែនរដ្ឋាភិបាលណាមួយ។
- ការផ្តល់ជូន ៖ ការផ្តល់សេវាជាក់ស្តែង ឬ ភារកិច្ច ។
- ការគ្រប់គ្រងនិងសម្របសម្រួល៖មានតួនាទីទូទៅមួយធានាថាដំណើរការត្រូវបានអនុវត្តដោយស្ថាប័នដែលទទួលបន្ទុកផ្តល់សេវាកម្មនោះ ។
- បទបញ្ញត្តិ ៖ មានតួនាទីឯករាជ្យមួយធានាថា អ្នកប្រើប្រាស់សេវាទទួលបានសេវាដែលមានគុណភាព និងបទដ្ឋានពីសេវាឯកជនក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ហើយអ្នកផ្តល់សេវា ក៏ទទួលបានផលដ៏សមរម្យមួយពីអ្នកប្រើប្រាស់មកវិញផងដែរ ។
- ការតាមដាន ៖ ការប្រមូល ការរៀបចំ និងការប្រើប្រាស់ព័ត៌មានពីស្ថានភាពជាក់ស្តែង និងការប្រៀបធៀបស្ថានភាពនោះ ទៅនឹងស្ថានភាពផែនការ ឬ ការរំពឹងទុក ។ ការតាមដានមានរួមទាំងការប្រើប្រាស់ព័ត៌មាន សម្រាប់ការតាមដានត្រួតពិនិត្យ សម្រាប់ការដោះស្រាយបញ្ហា និងការរៀបចំផែនការ ហើយវាក៏ជាឧបករណ៍សម្រាប់ការគ្រប់គ្រង ដែលប្រើដោយសមាជិកសហគមន៍ បុគ្គលិក និងអ្នកគ្រប់គ្រងកម្មវិធី[1] ។
- ការណែនាំផ្នែកបច្ចេកទេស ៖ ការផ្តល់ការណែនាំពីអ្នកជំនាញ ទៅលើទិដ្ឋភាពបច្ចេកទេសសង្គម ស្ថាប័ន ហិរញ្ញវត្ថុ និងបរិស្ថាន នៃការផ្គត់ផ្គង់ទឹកស្អាត អនាម័យ និងអនាម័យផ្ទាល់ខ្លួន។
- អ្នកប្រើប្រាស់ ៖ អ្នកប្រើសេវាដែលបានផ្តល់ជូន ។

[1] (Shordt, 2000)

- **ហិរញ្ញប្បទាន ៖** ការផ្តល់មូលនិធិ សម្រាប់ចំណាយលើការវិនិយោគលើទុនដើម និងចំណាយចរន្ត។

ទិសដៅជាសកល គឺមានការកែប្រែពីការផ្តល់ហេដ្ឋារចនាសម្ព័ន្ធទៅជាការផ្តល់សេវាកម្មវិញ ។ នៅប្រទេសកម្ពុជា ទោះបីជាទស្សនវិស័យរបស់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទបានផ្តោតសំខាន់ទៅលើការទទួលបានសេវាកម្មទឹកស្អាតនិងអនាម័យយ៉ាងណាក៏ដោយក៏វិធីសាស្ត្រនានាដែលបានអនុវត្តភាគច្រើន នៅក្នុងការបង្កើត និងអនុវត្តគម្រោងប៉ុណ្ណោះ។ វាជាការចាំបាច់ត្រូវដកចេញពីការផ្តោតទៅលើគម្រោង និងកម្មវិធី ដែលជាសកម្មភាពមានរយៈពេលកំណត់ ទៅជាការផ្តល់នូវសមាសធាតុជាក់លាក់មួយ ឬច្រើនដែលមិនកំណត់ពេលវេលានៃការផ្តល់សេវាកម្ម។ សមាសធាតុនីមួយៗក្នុងប្រព័ន្ធ តម្រូវឲ្យបង្កើតឡើងដោយពិចារណាទៅលើគ្រប់សមាសធាតុដទៃទៀតទាំងអស់ក្នុងប្រព័ន្ធទាំងមូល ។

ក្នុងន័យនេះ យុទ្ធសាស្ត្រត្រូវជៀសវាងប្រើពាក្យថា "ការអនុវត្ត" ដែលជាប់ពាក់ព័ន្ធនឹងគម្រោង និងសកម្មភាពដែលបានកើតឡើងតែម្តង ហើយបញ្ចប់ ដោយមិនទាក់ទងជាមួយនឹងនិរន្តរភាពគម្រោង ។ ផ្ទុយទៅវិញ គោលគំនិតនៃការផ្តល់សេវាកម្ម នឹងត្រូវបានប្រើជំនួសវិញ ដើម្បីផ្សារភ្ជាប់នឹងនិរន្តរភាពរបស់សេវាកម្មទាំងនោះ។ ឧទាហរណ៍ គម្រោងសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរួមមានផ្នែកទន់ (software) សម្រាប់ការគ្រប់គ្រងសហគមន៍ គឺជាការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ ដែលគ្រាន់តែជាផ្នែកមួយដែលចាំបាច់ សម្រាប់សេវាកម្មផ្គត់ផ្គង់ទឹកប្រកបដោយនិរន្តរភាពតែប៉ុណ្ណោះ។

នៅក្នុងគោលដៅយុទ្ធសាស្ត្រទី៤ សមត្ថភាពស្ថាប័នពាក់ព័ន្ធសម្រាប់តម្រូវការផ្សេងៗនៅក្នុងវិស័យនេះ នឹងត្រូវបានផ្លាស់ប្តូរទៅតាមពេលវេលា ៖

**ពីឆ្នាំ ២០១១ ដល់ឆ្នាំ២០១៥** សមត្ថភាពស្ថាប័នក្នុងការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ គួរតែត្រូវបានបង្កើនឲ្យបានឆាប់ និងពេញលេញដើម្បីសម្រេចគោលដៅ ។ សមត្ថភាពនៃប្រតិបត្តិការ និងការថែទាំដែលមានកំរិតទាបនាពេលបច្ចុប្បន្នគួរតែត្រូវបានរៀបចំដើម្បីឲ្យហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់អាចត្រូវបានថែរក្សាឲ្យមានដំណើរការល្អ ។

**នៅឆ្នាំ២០១៥** ការបង្កើនការគ្របដណ្តប់សេវាកម្ម ត្រូវតែធ្វើឲ្យសម្រេចបានតាមគោលដៅពោលគឺការសាងសង់ និងការផ្តល់នូវសេវាកម្មទៅដល់ប្រជាជននៅតាមតំបន់ជនបទដែលមិនធ្លាប់មានសេវានេះពីមុន ប៉ុន្តែក្នុងពេលជាមួយគ្នានេះ សមត្ថភាពដើម្បីដំណើរការ ការធ្វើឲ្យមាននិរន្តរភាព និងការទ្រទ្រង់សេវាកម្មដែលមានស្រាប់ ត្រូវបន្តឲ្យមានដំណើរការតទៅទៀត។

**នៅឆ្នាំ២០២៥** ជាមួយនឹងការគ្របដណ្តប់ដែលសម្រេចបាន ១០០% សមត្ថភាពក្នុងការផ្តល់ហេដ្ឋារចនាសម្ព័ន្ធថ្មី នឹងលែងត្រូវការឲ្យមានកម្រិតដូចមុនទៀតហើយ ។ ការសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតថ្មីណាមួយ នឹងត្រូវកម្រិតមកនៅត្រឹមការផ្លាស់ប្តូរ ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ ការកែលម្អ និងការសាងសង់ថ្មីមួយចំនួនទៀត ដើម្បីឆ្លើយតបទៅនឹងកំណើនប្រជាជន ។ ហេតុនេះតម្រូវការសមត្ថភាពក្នុងការកសាងថ្មីនឹងថយចុះ ។ សមត្ថភាពដែលត្រូវការភាគច្រើនគឺសម្រាប់ប្រើទៅលើដំណើរការ និងការធ្វើឲ្យមាននិរន្តរភាពនៃសេវាកម្មដែលមានស្រាប់ ព្រមទាំងទ្រទ្រង់សេវាកម្មរបស់វិស័យនេះតាមរយៈរដ្ឋបាលមូលដ្ឋាន ។

## ៤. វិសាលភាព

### រយៈពេល

យុទ្ធសាស្ត្រនេះគ្របដណ្តប់ពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០២៥ ។

### តំបន់ភូមិសាស្ត្រ

តំបន់ទីប្រជុំជននៅប្រទេសកម្ពុជា ត្រូវបានចាត់ថ្នាក់ឡើងវិញ នៅឆ្នាំ ២០០៤ ។ យោងទៅតាមនិយមន័យថ្មីដែលត្រូវបានអនុវត្តពីឃុំមួយទៅឃុំមួយ បានកំណត់ថា ឃុំទាំងឡាយណាដែលមានលក្ខណៈវិនិច្ឆ័យទាំងអស់ដូចខាងក្រោម ត្រូវបានកំណត់ជាតំបន់ទីប្រជុំជន ៖

(I) មានដង់ស៊ីតេប្រជាជនយ៉ាងហោចណាស់ ២០០នាក់ ក្នុងមួយគីឡូម៉ែត្រការ៉េ និង

(II) មានប្រជាជនយ៉ាងហោចណាស់ ២.០០០នាក់ និង

(III) មានអត្រាបុរសធ្វើការក្នុងវិស័យកសិកម្មតិចជាង ៥០ភាគរយ

តំបន់នានាដែលមិនមានលក្ខណៈវិនិច្ឆ័យដូចខាងលើនេះ គឺជាតំបន់ជនបទ និងស្ថិតនៅក្នុងវិសាលភាពរបស់យុទ្ធសាស្ត្រនេះ ។ មានករណីលើកលែងមួយចំនួន ចំពោះតំបន់ដែលមានការបង្កើតប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតសម្រាប់ប្រតិបត្តិការអាជីវកម្ម ដោយមានអាជ្ញាប័ណ្ណពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ក្នុងករណីនេះ ឃុំនោះត្រូវបានចាត់ចូលក្នុងតំបន់ទីប្រជុំជននៅពេលដែលមានសេវាផ្គត់ផ្គង់ទឹកស្អាត ហើយស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

នៅក្នុងពេលអនុវត្តយុទ្ធសាស្ត្រនេះ គឺស្របពេលដែលចំនួនប្រជាជនមានការកើនឡើង ដូច្នេះ ឃុំមួយចំនួនធំនឹងប្រែក្លាយពីតំបន់ជនបទទៅជាតំបន់ទីប្រជុំជន ។

### ការផ្គត់ផ្គង់ទឹកតាមផ្ទះ

ការផ្គត់ផ្គង់ទឹកតាមផ្ទះសំដៅដល់ទឹកសម្រាប់បរិភោគ ចម្អិនអាហារ បោកគក់ខោអាវ និងទឹកសម្រាប់ងូត ។ ការផ្គត់ផ្គង់ទឹកតាមផ្ទះ មិនបានសំដៅដល់ទឹកសម្រាប់ធ្វើកសិកម្មនោះទេ ។

### អនាម័យតាមផ្ទះ

អនាម័យតាមផ្ទះផ្តោតទៅលើអនាម័យនៅតាមសហគមន៍ និងតាមគ្រួសារដោយរាប់បញ្ចូលទាំងការផ្លាស់ប្តូរទម្លាប់ផ្នែកអនាម័យ ដើម្បីបញ្ឈប់ការបន្ទោបង់ពាសវាលពាសកាល ។

### ទឹកស្អាត និងអនាម័យតាមសាលារៀន និងតាមស្ថាប័ននានា

ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យតាមសាលារៀន គ្រឹះស្ថានសុខាភិបាល (មន្ទីរពេទ្យ មណ្ឌលសុខភាព គ្លីនិក) និងគ្រឹះស្ថានសាធារណៈនានាមួយចំនួនទៀត ដែលបម្រើសាធារណជនក្នុងតំបន់ជនបទ ។

## ការផ្លាស់ប្តូរទម្លាប់អនាម័យ

ការផ្លាស់ប្តូរទម្លាប់អនាម័យ សំដៅដល់ការលើកកម្ពស់អនាម័យ និងសកម្មភាពមួយចំនួនដែលចាំបាច់ ដើម្បីសម្រេចបាននូវទម្លាប់អនាម័យផ្ទាល់ខ្លួន ដែលពាក់ព័ន្ធនឹងទឹកស្អាត និងអនាម័យ ។

## អនាម័យបរិស្ថាន

ការគ្រប់គ្រងកាកសំណល់រឹង និងរាវ ត្រូវបានរាប់បញ្ចូល ប៉ុន្តែមិនបានរាប់បញ្ចូលការគ្រប់គ្រងសត្វល្អិតបង្កជំងឺនោះទេ (ពពួកសត្វល្អិត និងសត្វកកេរ) ។

## ការគ្រប់គ្រងសមាហរណកម្មធនធានទឹក

ត្រូវបានដាក់បញ្ចូលក្នុងការទទួលបានការផ្គត់ផ្គង់ទឹកស្អាត ។

## ៥. គោលការណ៍

គោលនយោបាយជាតិស្តីពីវិស័យទឹកស្អាត និងអនាម័យ ដែលត្រូវបានអនុម័តដោយរាជរដ្ឋាភិបាលនាឆ្នាំ២០០៣ បានបង្កើតគោលនយោបាយទូលំទូលាយមួយ សម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ដោយរួមបញ្ចូលទាំងគោលការណ៍ណែនាំទូទៅចំនួនបួនផងដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ ចំណុចលម្អិតនៃគោលនយោបាយ និងគោលការណ៍មួយចំនួនទៀត ត្រូវការបង្កើតឡើងដើម្បីជាមូលដ្ឋានសម្រាប់យុទ្ធសាស្ត្រនេះ ។ គោលនយោបាយ និងគោលការណ៍ មាននៅក្នុងផ្នែកនេះ ហើយការពន្យល់បង្ហាញអំពីគោលការណ៍ទាំងនោះ និងព័ត៌មាននានា មាននៅក្នុងឧបសម្ព័ន្ធទី២ ។

### និរន្តរភាព

និរន្តរភាព នៃសំណង់ផ្គត់ផ្គត់ទឹកស្អាត និងអនាម័យជនបទ និងទម្លាប់អនាម័យផ្ទាល់ខ្លួន គឺជាគោលដៅចម្បងនៃការផ្តល់សេវាកម្ម ។ នៅពេលដែលប្រព័ន្ធនេះបានបង្កើតរួច វាត្រូវផ្តល់សេវាជាអចិន្ត្រៃយ៍ដល់អ្នកប្រើប្រាស់ ទាំងក្នុងពេលបច្ចុប្បន្ន និងអនាគត។ អត្ថប្រយោជន៍ ដែលបានមកពីសំណង់ផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ និងការលើកកម្ពស់អនាម័យផ្ទាល់ខ្លួន គួរតែបន្តឲ្យមានសម្រាប់រយៈពេលយូរអង្វែង ។ កត្តាសំខាន់ៗមួយចំនួន មានដូចជា ៖

- ធនធានទឹក មិនត្រូវប្រើប្រាស់ឱ្យហួសកម្រិតនោះទេ
- ការបំពុលធនធានទឹក ត្រូវតែទប់ស្កាត់ ជាពិសេសកើតចេញពីបញ្ហាកង្វះអនាម័យ
- ការផ្តល់សេវាប្រើប្រាស់ និងថែទាំប្រកបដោយប្រសិទ្ធភាព ដើម្បីធ្វើឱ្យសំណង់ផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទបានដំណើរការនិងថែទាំប្រកបដោយនិរន្តរភាពដែលធានានូវសេវាកម្មជឿទុកចិត្តបាន ។
- បរិយាកាសសមស្របប្រកបដោយប្រសិទ្ធភាព រួមមានបទបញ្ញត្តិ ព័ត៌មាន ស្ថាប័នរឹងមាំ ជាមួយនឹងការទទួលខុសត្រូវច្បាស់លាស់តាមកម្រិតថ្នាក់ដែលសមស្រប រួមទាំងឥរិយាបថគាំទ្រ និងឆន្ទៈនយោបាយ ។
- ការពេញចិត្តចំពោះ អត្ថប្រយោជន៍សេដ្ឋកិច្ច សង្គម និងសុខភាពដែលទទួលបានពីសេវានេះ ជម្រើសនៃកម្រិតសេវាកម្មសមស្រប និងបច្ចេកវិទ្យាត្រឹមត្រូវ
- សមត្ថភាពហិរញ្ញវត្ថុ ដោយផ្អែកលើលទ្ធភាពដែលអាចចំណាយបាន សមត្ថភាព និងឆន្ទៈក្នុងការចំណាយ និងជំនាញគ្រប់គ្រងហិរញ្ញវត្ថុ
- ប្រព័ន្ធគ្រប់គ្រងព័ត៌មានប្រកបដោយប្រសិទ្ធភាព ។

### ការគ្រប់គ្រងដោយសហគមន៍

សហគមន៍ត្រូវគ្រប់គ្រងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យដោយខ្លួនឯង ។ សហគមន៍គួរតែមានអំណាចសម្រេច លើសមាសភាគផ្សេងៗ ដែលសហគមន៍ទទួលខុសត្រូវ ។ ប្រការនេះរួមបញ្ចូល ការសម្រេចចិត្តថាតើគួរប្រតិបត្តិលើសេវាកម្មទាំងនេះដោយខ្លួនឯង ឬក៏ចុះកិច្ចសន្យាជាមួយអ្នកផ្តល់សេវាកម្ម ។ គោលគំនិតសំខាន់ៗក្នុងការគ្រប់គ្រងដោយសហគមន៍ រួមមាន ៖

- **ការចូលរួម ៖** គ្រប់សមាជិកក្នុងសហគមន៍ទាំងអស់ គួរតែមានឱកាសស្មើៗគ្នា ក្នុងការចូលរួមដំណើរការអភិវឌ្ឍ និងគ្រប់គ្រង ហើយត្រូវមានការគាំទ្រពីសហគមន៍ឱ្យបានទូលំទូលាយ សម្រាប់ការអនុវត្តការគ្រប់គ្រងដោយសហគមន៍ ។
- **ការទទួលខុសត្រូវ ៖** សហគមន៍មានភាពម្ចាស់ការ និងទទួលយកកាតព្វកិច្ចចូលរួមក្នុងការថែទាំប្រព័ន្ធទាំងនេះ ។
- **សិទ្ធិអំណាច ៖** សហគមន៍មានសិទ្ធិស្របច្បាប់ ដើម្បីសម្រេចចិត្ត ពាក់ព័ន្ធទៅនឹងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ តំណាងឲ្យអ្នកប្រើប្រាស់ទាំងអស់ ។
- **ការត្រួតពិនិត្យ ៖** សហគមន៍អាចអនុវត្ត និងកំណត់នូវលទ្ធផលនៃសេចក្តីសម្រេចចិត្តរបស់ខ្លួន ។
- **គណនេយ្យភាព៖** សហគមន៍ត្រូវទទួលយកផលវិបាកនានា ដែលកើតចេញមកពីការសម្រេចចិត្តរបស់ខ្លួន និងទទួលស្គាល់ថាពួកគេគឺជាម្ចាស់សកម្មភាពទាំងនោះផ្ទាល់ ។

## វិធីសាស្ត្រឆ្លើយតបទៅនឹងតម្រូវការ

វិធីសាស្ត្រឆ្លើយតបទៅនឹងតម្រូវការ គឺជាមូលដ្ឋានគ្រឹះសម្រាប់ការគ្រប់គ្រងដោយសហគមន៍ ។ សហគមន៍ជាអ្នកផ្តួចផ្តើមដំណើរការបង្កើតសេវាកម្ម តាមរយៈការស្នើសុំឲ្យមានការគាំទ្រពីអាជ្ញាធរ ឬអ្នកផ្តល់សេវាពាក់ព័ន្ធ ។ បន្ទាប់មក សហគមន៍ ធ្វើការជ្រើសរើសសេវាកម្មទាំងឡាយដោយផ្អែកលើព័ត៌មានជាក់លាក់ស្របទៅតាមឆន្ទៈ របស់ពួកគេក្នុងការចំណាយ និងការទទួលយកនូវការទទួលខុសត្រូវលើប្រតិបត្តិការ និងការថែទាំនៅពេលបន្តបន្ទាប់ ។ ចំណុចសំខាន់ៗ រួមមាន ៖

- ជម្រើសនានាដែលមានព័ត៌មានជាក់លាក់ ចេញពីសហគមន៍ តាមរយៈការរៀបចំផែនការតាមបែបចូលរួម និងការចូលរួមអនុវត្តរបស់សហគមន៍ ដើម្បីធានាបាននូវភាពជាម្ចាស់ការ ។
- ការទទួលខុសត្រូវពេញលេញ របស់សហគមន៍ក្នុងប្រតិបត្តិការ និងការថែទាំ ។
- សហគមន៍ត្រូវចូលរួមបដិភាគថវិកាថ្លៃទុនដើម និងត្រូវចំណាយលើថ្លៃប្រតិបត្តិការ និងការថែទាំដោយខ្លួនឯងទាំងស្រុង។
- ផ្សព្វផ្សាយជម្រើសព័ត៌មាន និងបច្ចេកវិទ្យាបន្ថែមទៀត សម្រាប់ការបម្រើសេវាកម្ម ។

## ការចូលរួមបដិភាគ សម្រាប់សេវាផ្គត់ផ្គង់ទឹកស្អាត

សហគមន៍ត្រូវចូលរួមបដិភាគលើការចំណាយថ្លៃទុនដើម (Capital cost) នៃការផ្គត់ផ្គង់ទឹក ហើយត្រូវចំណាយទាំងស្រុងលើប្រតិបត្តិការ និងការថែទាំ។ សហគមន៍ ក៏ត្រូវចូលរួមការចំណាយមួយផ្នែកទៀតទៅលើថ្លៃសេវាទ្រទ្រង់ការថែទាំដែលផ្តល់ដោយការិយាល័យអភិវឌ្ឍន៍ជនបទស្រុក។ ក្រសួងអភិវឌ្ឍន៍ជនបទ ជាអ្នករៀបចំគោលការណ៍ណែនាំ ហើយអាជ្ញាធរមូលដ្ឋានជាអ្នកកំណត់នូវការចូលរួមបដិភាគឱ្យបានច្បាស់លាស់ទៅលើចំណាយថ្លៃចំណាយទុនដើម និងចំណាយលើការគាំទ្រលើថ្លៃសេវាថែទាំ ឲ្យស្របទៅតាមលក្ខខណ្ឌសេដ្ឋកិច្ចក្នុងមូលដ្ឋាន។

## ការផ្តល់ហិរញ្ញប្បទានផ្នែកអនាម័យ

ថវិកាសាធារណៈសម្រាប់អនាម័យគួរតែត្រូវបានប្រើប្រាស់ សម្រាប់ជំរុញឲ្យមានតម្រូវការ និងបង្កើតឲ្យមានបរិយាកាសសមស្រប (រួមទាំងលទ្ធភាពនៃការរកទិញបានផលិតផលបង្គន់អនាម័យដែលមានតម្លៃសមស្រប) ដូចនេះ គ្រួសារនីមួយៗនឹងចំណាយថវិកាផ្ទាល់របស់គេដើម្បីសង់បង្គន់។ សម្រាប់គ្រួសារដែលមានលទ្ធភាពគួរត្រូវចំណាយ។ ការឧបត្ថម្ភធនផ្ទាល់សម្រាប់ការសាងសង់បង្គន់អនាម័យ ការឧបត្ថម្ភធនអាចត្រូវបានអនុវត្តចំពោះគ្រួសារក្រីក្រឲ្យមានបង្គន់ប្រើប្រាស់ ដើម្បីសម្រេចឲ្យបាននូវចក្ខុវិស័យ។ ការឧបត្ថម្ភធនលើសំណង់ (Hardware subsidy) គួរធ្វើឡើងដោយប្រយ័ត្នប្រយែង និងជាជម្រើសចុងក្រោយប៉ុណ្ណោះ ។ យន្តការផ្សេងទៀតដែលមានមែនជាការឧបត្ថម្ភធនគួរចាត់ទុកជាអាទិភាព ។

## សមាហរណកម្ម នៃសេវាផ្គត់ផ្គង់ទឹកស្អាត អនាម័យ និងការលើកកម្ពស់អនាម័យផ្ទាល់ខ្លួន

ទីណាដែលសហគមន៍និងគ្រួសារមិនបានទទួលសេវាទឹកស្អាតនិងអនាម័យនោះការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត អនាម័យ និងការលើកកម្ពស់អនាម័យផ្ទាល់ខ្លួន ត្រូវដាក់បញ្ចូលគ្នាក្នុងសមាសភាគតែមួយ។ ប៉ុន្តែដោយមានលក្ខណៈខុសគ្នាច្រើន ដូចនេះត្រូវមានវិធីសាស្ត្រផ្សេងៗគ្នា ដើម្បីដំណើរការការផ្តល់សេវាកម្មទាំងនោះឲ្យបានល្អ ។ កន្លែងណាដែលមានការផ្គត់ផ្គង់ទឹកស្អាតរួចហើយនោះ ចាំបាច់គ្រាន់តែផ្តល់សេវាអនាម័យ និងការលើកកម្ពស់អនាម័យផ្ទាល់ខ្លួនតែប៉ុណ្ណោះ។

## ប្រតិបត្តិការ និងការថែទាំ

សហគមន៍អ្នកប្រើប្រាស់សេវា គឺជាអ្នកទទួលខុសត្រូវលើប្រតិបត្តិការ និងការថែទាំសេវាផ្គត់ផ្គង់ទឹក តាមរយៈអ្នកតំណាងក្រុមប្រើប្រាស់ទឹក និងអនាម័យ (WSUG) ដោយទទួលបានការគាំទ្រពីសេវាកម្មទ្រទ្រង់ប្រតិបត្តិការ និងការថែទាំ នៅថ្នាក់ស្រុក ។ ប្រតិបត្តិការ និងការថែទាំបង្គន់តាមផ្ទះ គឺជាការទទួលខុសត្រូវរបស់គ្រួសារនីមួយៗ ។ ប្រតិបត្តិការ និងការថែទាំបង្គន់របស់ស្ថាប័នសាធារណៈណាមួយ គឺជាការទទួលខុសត្រូវរបស់ស្ថាប័ននោះផ្ទាល់ ។

## វិមជ្ឈការ និងវិសហមជ្ឈការ នៃការផ្តល់សេវា និងការគ្រប់គ្រង

ការផ្តល់ និងគ្រប់គ្រងសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ និងការលើកកម្ពស់អនាម័យផ្ទាល់ខ្លួននៅតាមតំបន់ជនបទ គួរតែអនុលោមទៅតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីវិមជ្ឈការ និងវិសហមជ្ឈការ ដូចបានចែងក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (ឆ្នាំ២០០៥) និងចែងក្នុងបទបញ្ញត្តិ ដូចជាច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ឆ្នាំ២០០៨) ។

## គណនេយ្យភាព

ស្ថាប័នទាំងអស់ត្រូវមានគណនេយ្យភាពចំពោះអ្នកខាងក្រោម និងអ្នកខាងលើ ។ គណនេយ្យភាពចំពោះអ្នកខាងក្រោម គឺសំដៅទៅលើគណនេយ្យភាពចំពោះម្ចាស់ឆ្នោត អ្នកទទួលផល ដៃគូក្នុងវិស័យ និងបុគ្គលិករបស់ខ្លួន។ គណនេយ្យភាពចំពោះអ្នកខាងលើ គឺសំដៅទៅលើ គណនេយ្យ

ភាពចំពោះរាជរដ្ឋាភិបាល និងម្ចាស់ជំនួយ។ នៅពេលបង្កើតវាកម្ម ពេលដំណើរការ និងពេលតាមដាន ក៏ដូចជាពេលរៀបចំគម្រោង កម្មវិធី ឬ សកម្មភាពផ្សេងៗទៀតក្នុងវិស័យនេះ ស្ថាប័នទាំងអស់គួរតែពិចារណាថា តើការងាររបស់ពួកគេ និងលទ្ធផលទទួលបាន នឹងមានផលប៉ះពាល់លើអ្នកទាំងនោះយ៉ាងដូចម្តេច និងគួរពិចារណាពីការទទួលខុសត្រូវរបស់ពួកគេចំពោះសកម្មភាពទាំងនោះ ទាំងរយៈពេលខ្លី និងរយៈពេលវែង ។

## ការបញ្ជ្រាបយេនឌ័រ

គ្រប់ស្ថាប័នទាំងអស់ត្រូវបញ្ជ្រាបយេនឌ័រក្នុងពេលកំពុងអភិវឌ្ឍ និងផ្តល់សេវាកម្ម រួមបញ្ចូលទាំងការគ្រប់គ្រង ការតាមដាន និងការវាយតម្លៃ។ ស្ថាប័នត្រូវយកចិត្តទុកដាក់ចំពោះស្ត្រី និងបុរសសម្រាប់ជាទិដ្ឋភាពរួមមួយនៃការរៀបចំ អនុវត្ត តាមដាន និងវាយតម្លៃ លើគោលនយោបាយ និងការផ្តល់សេវា ដោយពិនិត្យមើលពីទិដ្ឋភាពនយោបាយ សេដ្ឋកិច្ច និងសង្គមដើម្បីឲ្យបុរស និងស្ត្រីទទួលបានផលប្រយោជន៍ស្មើគ្នា ហើយវិសមភាពនឹងមិនមានតទៅទៀតឡើយ ។

## ការបញ្ជ្រាបបញ្ហាពិការភាព

ការអភិវឌ្ឍ និងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ត្រូវអនុលោមទៅតាមច្បាប់ស្តីពីការគាំពារ និងលើកកម្ពស់សិទ្ធិជនពិការ (ឆ្នាំ២០០៩) ។ នៅអំឡុងពេលអភិវឌ្ឍ និងផ្តល់សេវារួមមានការគ្រប់គ្រង ការតាមដាន និងការវាយតម្លៃ គ្រប់ស្ថាប័នទាំងអស់គួរតែបញ្ជ្រាបបញ្ហាពិការភាព ។ ការបញ្ជ្រាបនេះ រួមមានដំណើរការវាយតម្លៃលើផលប៉ះពាល់ដល់ជនពិការ បណ្តាលមកពីសកម្មភាពដែលត្រូវរៀបចំធ្វើក្នុងនោះរួមមាន បទបញ្ញត្តិ គោលនយោបាយ ឬកម្មវិធីនៅក្នុងតំបន់ណាក៏ដោយនៅគ្រប់កម្រិតទាំងអស់ ។ ហេតុដូច្នេះហើយ គ្រប់ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងសេវាកម្មអនាម័យព្រមទាំងការលើកកម្ពស់អនាម័យផ្ទាល់ខ្លួន ត្រូវពិចារណាពីតម្រូវការ របស់ជនពិការ នៅគ្រប់ដំណាក់កាលនៃវដ្តគម្រោងរបស់ស្ថាប័នទាំងនោះ។

## ៦. ការវិភាគស្ថានភាព

### បញ្ហាប្រឈមសំខាន់ៗ

សិក្ខាសាលាពិគ្រោះយោបល់ដែលមានការចូលរួមពីក្រសួងពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អ្នកតំណាងមកពីស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រុមប្រឹក្សាឃុំ ព្រមទាំងគណៈកម្មការទទួលបន្ទុកស្ត្រីនិងកុមារឃុំ-សង្កាត់ ត្រូវបានអញ្ជើញចូលរួមផ្ដល់យោបល់ នៃការបង្កើតយុទ្ធសាស្ត្រវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ។ តាមរយៈសិក្ខាសាលានេះ និងការសិក្សាដទៃទៀត បានឱ្យដឹងថា មានបញ្ហាប្រឈមជាច្រើន ក្នុងការបង្កើន និងធ្វើឱ្យមាននិរន្តរភាពនៃការផ្ដល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ក៏ដូចជាក្នុងការកែលម្អទម្លាប់អនាម័យផ្ទាល់ខ្លួន ។ ដើម្បីកុំឲ្យមានការបាត់បង់ទស្សនៈមួយចំនួនពីអ្នកចូលរួមដែលមានការយល់ដឹងខុសៗគ្នាលើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ និងភាពពាក់ព័ន្ធគ្នា នៃបញ្ហាទាំងឡាយ។ បញ្ហាទាំងនោះត្រូវបានប្រមូលផ្ដុំគ្នាជាចំណងជើងសំខាន់ៗ ហើយការឆ្លើយតបជាយុទ្ធសាស្ត្រចំពោះបញ្ហាប្រឈមទាំងនេះ និងបញ្ហាដទៃទៀត ដែលបានលើកឡើងនៅក្នុងការវិភាគស្ថានភាព មានបង្ហាញនៅក្នុងតារាងទី២ ។

### ការគ្រប់គ្រងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ

សមត្ថភាពមានកម្រិតក្នុងការគ្រប់គ្រងវិស័យនេះ គឺជាក្ដីបារម្ភមួយនៅគ្រប់លំដាប់ថ្នាក់ដែលពាក់ព័ន្ធទាំងអស់ ។ គេត្រូវការឱ្យមានដំណោះស្រាយលើការងារសម្របសម្រួលដែលមិនទាន់មានដំណើរការល្អ រវាងស្ថាប័នពាក់ព័ន្ធនៅក្នុងរដ្ឋាភិបាល និងស្ថាប័នដែលធ្វើការផ្ទាល់ក្នុងវិស័យនេះ ។

### វិមជ្ឈការ និងវិសហមជ្ឈការ ដែលទាក់ទងនឹងតួនាទី និងការទទួលខុសត្រូវ

ស្របតាមដំណើរការវិវឌ្ឍន៍នៃប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ និងការរៀបចំរចនាសម្ព័ន្ធថ្មី តួនាទី និងការទទួលខុសត្រូវនាពេលអនាគតរបស់វិស័យនេះ បានធ្វើឲ្យមានភាពមិនច្បាស់លាស់នៅក្នុងស្ថាប័នពាក់ព័ន្ធ ។ ដូចនេះតម្រូវឲ្យមានការចូលរួមពិភាក្សាដ៏សកម្មពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្នុងប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ ។

### សេវាកម្ម និងសមត្ថភាពផ្ដល់សេវា

ការផ្ដល់សេវាផ្គត់ផ្គង់ទឹកដល់ប្រជាពលរដ្ឋ ១០លាននាក់បន្ថែមទៀត ការធានានិរន្តភាពនៃការបន្តសេវាផ្គត់ផ្គង់ទឹកដែលមានស្រាប់ និងការផ្គត់ផ្គង់ទឹកនាពេលអនាគត ហើយនិងការផ្ដល់លទ្ធភាពឱ្យប្រជាពលរដ្ឋចំនួន ០២លានគ្រួសារ បានប្រើប្រាស់បង្គន់អនាម័យគឺជាបញ្ហាប្រឈមដ៏ធំមួយ ។ ការបង្កើតរចនាសម្ព័ន្ធស្ថាប័ន និងការបង្កើនសមត្ថភាពធនធានមនុស្ស ដើម្បីសម្របសម្រួល និងផ្ដល់សេវាកម្មទាំងនេះ គឺជាបញ្ហាប្រឈមមួយផងដែរ ។ បន្ថែមពីលើនេះ ប្រជាពលរដ្ឋតាមជនបទស្ទើរតែទាំងអស់ទាមទារឱ្យមានការណែនាំឡើងវិញ ក្នុងការអនុវត្តអនាម័យ នៃសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ដូចដែលក្រុមប្រឹក្សាឃុំមួយចំនួនបានកត់សម្គាល់ថាការផ្លាស់ប្ដូរទម្លាប់អនាម័យទាមទារនូវកិច្ចខិតខំប្រឹងប្រែងរយៈពេលវែង ដោយមិនមែនគ្រាន់តែផ្ដល់ការបណ្ដុះបណ្ដាលតែមួយដងគឺគ្រប់គ្រាន់នោះទេ ។

## វិស័យឯកជន

ការរួមចំណែករបស់វិស័យឯកជនក្នុងការផ្តល់សេវាលើវិស័យនេះ នៅមានកម្រិតនៅឡើយ ដោយសារមានកត្តាមួយចំនួន ដូចជាកង្វះឥណទាន ហានិភ័យនៃការវិនិយោគ កង្វះការអភិវឌ្ឍជំនាញអាជីវកម្ម ការប្រកួតប្រជែងមិនទាន់បានរលូន ព្រមទាំងប្រព័ន្ធនិយ័តកម្មទន់ខ្សោយ ។

## ការតាមដាន

ប្រព័ន្ធអង្កេតតាមដានសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទគ្មានការប្រើប្រាស់បទដ្ឋានតែមួយសម្រាប់ស្ថាប័នពាក់ព័ន្ធដែលបានចូលរួមក្នុងវិស័យនេះទេ ។ ករណីនេះបង្កឱ្យមានការពិបាកក្នុងការអង្កេតតាមដាន លើដំណើរការឆ្ពោះទៅរកគោលដៅរបស់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ។

## បច្ចេកវិទ្យា

មានជម្រើសតិចតួចសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតជាពិសេសនៅតំបន់ស្ងួតហួតហែង ។ រីឯបង្គន់អនាម័យ ក៏មានគំរូបង្គន់តម្លៃថោកតិចតួចប៉ុណ្ណោះ ដែលអាចឱ្យប្រជាពលរដ្ឋក្រីក្រមានលទ្ធភាពទិញប្រើប្រាស់ដោយខ្លួនឯងបាន ។ រហូតមកដល់ពេលនេះ នៅពុំទាន់មានដំណោះស្រាយទៅលើការប្រើប្រាស់បង្គន់ប្រកបដោយនិរន្តរភាព នៅតំបន់ដែលមានទឹកជំនន់នៅរដូវវស្សា និងនៅតាមភូមិដែលរស់នៅលើទឹកជាប្រចាំនៅឡើយទេ ។

## សង្គម -វប្បធម៌

ភាពក្រីក្រ កង្វះការចូលរួម កង្វះភាពជាម្ចាស់ និងកង្វះការផ្លាស់ប្តូរទម្លាប់ គឺជាវដ្តមួយ ដូចបានបង្ហាញនៅរូបភាពទី១ ដែលបញ្ហាប្រឈម គឺត្រូវបំបែកវដ្តនេះ ។

### រូបភាពទី១ ៖ វដ្តនៃបញ្ហាប្រឈមផ្សេងៗខាងសង្គម និងវប្បធម៌



**តារាងទី២ ៖ ការឆ្លើយតបជាយុទ្ធសាស្ត្រចំពោះបញ្ហាប្រឈម**

| **បញ្ហាប្រឈម** | **ការឆ្លើយតបជាយុទ្ធសាស្ត្រ** |
|---|---|
| **ការគ្រប់គ្រងលើវិស័យនេះ** | **គោលដៅយុទ្ធសាស្ត្រទី៤ ៖**<br>សមាសភាគ៤.១ ការគ្រប់គ្រងលើវិស័យនេះ<br>៤.១.១ ការរៀបចំស្ថាប័ន (Organisational arrangement) និងការរៀបចំរចនាសម្ព័ន្ធឡើងវិញ តាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ<br>៤.១.២ តួនាទី និងការទទួលខុសត្រូវ តាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ<br>៤.១.៣ អភិបាលកិច្ច និងគណនេយ្យភាព<br>៤.១.៤ គោលការណ៍ណែនាំ និងនីតិវិធី |
| **វិមជ្ឈការ និងវិសហមជ្ឈការពាក់ព័ន្ធនឹងតួនាទី និងការទទួលខុសត្រូវ** | **គោលដៅយុទ្ធសាស្ត្រទី៤ ៖**<br>សមាសភាគ៤.១ ការគ្រប់គ្រងលើវិស័យនេះ<br>៤.១.១ ការរៀបចំស្ថាប័ន (Organisational arrangement) និងការរៀបចំរចនាសម្ព័ន្ធឡើងវិញ តាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ<br>៤.១.២ តួនាទី និងការទទួលខុសត្រូវ តាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ |
| **សេវាកម្ម និងសមត្ថភាពផ្តល់សេវា** | **គោលដៅយុទ្ធសាស្ត្រទី៤ ៖**<br>សមាសភាគ៤.២ ការអភិវឌ្ឍធនធានមនុស្ស និងសមត្ថភាព<br>៤.២.១. រដ្ឋបាលថ្នាក់ក្រោមជាតិ |
| **ការគ្របដណ្តប់ និងចំណុចគោលដៅ** | **គោលដៅយុទ្ធសាស្ត្រទី១ ៖**<br>សមាសភាគ១.១ ការទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត<br>១.១.១ ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធថ្មី<br>១.១.២ ការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់<br>សមាសភាគ ១.៣ ប្រតិបត្តិការ និងការថែទាំ<br>១.៣.២ ប្រព័ន្ធទ្រទ្រង់ការថែទាំ<br>សមាសភាគ១.៤ ទីផ្សារសម្រាប់ផលិតផលទឹកស្អាត និងអនាម័យ<br>១.៤.១ ខ្សែសង្វាក់ផ្គត់ផ្គង់<br>**គោលដៅយុទ្ធសាស្ត្រទី ២ ៖**<br>សមាសភាគ ២.១ ការបង្កើនលទ្ធភាពទទួលបានអនាម័យ |

| | |
|---|---|
| **វិស័យឯកជន** | **គោលដៅយុទ្ធសាស្ត្រទី៤ ៖**<br>សមាសភាគ៤.៣. ការអភិវឌ្ឍវិស័យឯកជន<br>៤.៣.១. ការបង្កើតបរិយាកាសប្រកួតប្រជែង<br>៤.៣.២ លទ្ធភាពទទួលបានការវិនិយោគ និងប្រាក់កម្ចី<br>៤.៣.៣. ការអភិវឌ្ឍមុខរបរ និងជំនាញបច្ចេកទេស |
| **ការតាមដាន** | **គោលដៅយុទ្ធសាស្ត្រទី៤ ៖**<br>សមាសភាគ៤.៤. ការធ្វើផែនការ និងប្រព័ន្ធគ្រប់គ្រងព័ត៌មាន |
| **បច្ចេកវិទ្យា** | **គោលដៅយុទ្ធសាស្ត្រទី១ ៖**<br>សមាសភាគ១.១ ការទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត<br>១.១.៣ បច្ចេកវិទ្យាផ្គត់ផ្គង់ទឹកស្អាត<br>១.១.៤ ការអភិវឌ្ឍបច្ចេកវិទ្យា និងសេវាកម្មសមស្រប<br>**គោលដៅយុទ្ធសាស្ត្រទី២ ៖**<br>សមាសភាគ២.១ ការបង្កើនលទ្ធភាពទទួលបានអនាម័យ<br>២.១.១ ការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា និងជម្រើសបង្គន់អនាម័យ |
| **សង្គម-វប្បធម៌** | **គោលដៅយុទ្ធសាស្ត្រទី៤ ៖**<br>សមាសភាគ៤.៨. ភាពក្រីក្រ ជនជាតិភាគតិច ភាពងាយរងគ្រោះ<br>៤.៨.១. ភាពក្រីក្រ<br>៤.៨.២.ពិការភាព<br>សមាសភាគ៤.៩. ការបញ្ជ្រាបយេនឌ័រ |
| **ហិរញ្ញប្បទាន** | **គោលដៅយុទ្ធសាស្ត្រទី៥ ៖**<br>សមាសភាគ៥.១ ហិរញ្ញប្បទាននៃចំណាយទុនដើម<br>៥.១.១. ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ និងផ្នែកទន់<br>៥.១.២. យន្តការហិរញ្ញប្បទានអនាម័យ<br>៥.១.៣. ការកសាងសមត្ថភាព<br>សមាសភាគ ៥.២. ហិរញ្ញប្បទានលើចំណាយចរន្ត |
| **ភាពក្រីក្រ** | **គោលដៅយុទ្ធសាស្ត្រទី២ ៖**<br>សមាសភាគ ២.១ ការបង្កើនលទ្ធភាពទទួលបានអនាម័យ<br>២.១.១ ការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា និងជម្រើសបង្គន់អនាម័យ<br>គោលដៅយុទ្ធសាស្ត្រទី៤ ៖<br>សមាសភាគ៤.៨. ភាពក្រីក្រ ជនជាតិភាគតិច ភាពងាយរងគ្រោះ<br>៤.៨.១. ភាពក្រីក្រ |

## ហិរញ្ញប្បទាន

ថ្មីៗនេះមានការរៀបចំអភិវឌ្ឍយុទ្ធសាស្ត្រហិរញ្ញប្បទានលើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅកម្ពុជា[2] ។ យុទ្ធសាស្ត្រនេះ បានប៉ាន់ស្មានពីការវិនិយោគហិរញ្ញវត្ថុ និងចំណាយប្រតិបត្តិការព្រមទាំង គម្លាតហិរញ្ញប្បទានសម្រាប់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ទាំងនៅទីក្រុង ទីប្រជុំជន និងជនបទ ។ ការសិក្សាដែលយុទ្ធសាស្ត្រហិរញ្ញប្បទានរបស់វិស័យនេះប្រើជាមូលដ្ឋាន គឺការវិភាគលើសេណារីយូ (scenarios) ចំនួនបួន ។ នៅក្នុងសេណារីយូ ទាំងនេះ គោលដៅអភិវឌ្ឍន៍[3]ពាក់ព័ន្ធនឹងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ គឺ ៖

- បង្កើនការទទួលបានសេវាផ្គត់ផ្គង់ទឹកដែលមានការកែលម្អនៅតំបន់ជនបទពី ៤០.៥% ក្នុងឆ្នាំ២០០៨ ទៅ ១០០% ក្នុងឆ្នាំ២០២៨
- បង្កើនការទទួលបានសេវាបង្គន់អនាម័យដែលមានការកែលម្អនៅតំបន់ជនបទពី ២៣.២% ក្នុងឆ្នាំ២០០៨ ទៅ ១០០% ក្នុងឆ្នាំ២០២៨

ដោយផ្អែកលើគោលដៅខាងលើ ការសិក្សានេះបានប៉ាន់ប្រមាណពីគម្លាតហិរញ្ញប្បទានដ៏ធំមួយដែលប្រែប្រួលតាមពេលវេលា សម្រាប់ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ។ ការប៉ាន់ប្រមាណទាំងនេះ គឺបានគិតបញ្ចូលនូវចំណាយទុនដើមនៃហេដ្ឋារចនាសម្ព័ន្ធថ្មី និងចំណាយលើការផ្លាស់ប្តូរហេដ្ឋារចនាសម្ព័ន្ធចាស់ៗ ព្រមទាំងចំណាយចរន្ត នៃប្រតិបត្តិការ និងការថែទាំ ។ ទាំងនេះមិនបានរាប់បញ្ចូលនូវការចំណាយលើផ្នែកទន់ រួមមានការអភិវឌ្ឍសមត្ថភាព និងការលើកកម្ពស់អនាម័យផ្ទាល់ខ្លួននិងប្រព័ន្ធទ្រទ្រង់ប្រតិបត្តិការ និងការថែទាំឡើយ ។ ការចំណាយនិងការផ្តល់ហិរញ្ញប្បទានដែលត្រូវបានប៉ាន់ប្រមាណ មាននៅក្នុងរូបភាពទី៣ សម្រាប់ការផ្គត់ផ្គង់ទឹកស្អាតជនបទ និងរូបភាពទី៤ សម្រាប់អនាម័យជនបទ ។

---

[2] យុទ្ធសាស្ត្រហិរញ្ញប្បទានលើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ កំពុងរងចាំការអនុម័តយល់ព្រមពីក្រសួងពាក់ព័ន្ធ

[3] តួលេខគ្របដណ្តប់ជាមូលដ្ឋានគិតជាភាគរយ គឺដកស្រង់ចេញពីទិន្នន័យជំរឿនឆ្នាំ២០០៨ ។

## រូបភាពទី៣ ៖ ការចំណាយ និងការផ្តល់ហិរញ្ញប្បទានផ្គត់ផ្គង់ទឹក ២០០៩-២០២៨




ប្រភព ៖ យុទ្ធសាស្ត្រជាតិហិរញ្ញប្បទានលើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ

## រូបភាពទី៤ ៖ ការចំណាយ និងការផ្តល់ហិរញ្ញប្បទានផ្នែកអនាម័យ ២០០៩-២០២៨




ប្រភព ៖ យុទ្ធសាស្ត្រជាតិហិរញ្ញប្បទានលើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ

## គោលនយោបាយ

មានគោលនយោបាយ និងផែនការមួយចំនួនទាក់ទងទៅនឹងយុទ្ធសាស្ត្រវិស័យផ្គត់ផ្គង់ទឹកស្អាត និង អនាម័យជនបទ ។ យុទ្ធសាស្ត្រនេះត្រូវអនុវត្តតាមគោលនយោបាយ និងផែនការទាំងនោះ និងរួមចំណែកក្នុងការសម្រេចឱ្យបាននូវទិសដៅដូចខាងក្រោម ៖

### យុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព - ដំណាក់កាលទី២[4]

ចំណុចពាក់ព័ន្ធ មានដូចជា ៖

- ការបន្តអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីធានាឱ្យមានការអនុវត្ត"ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ" ប្រកបដោយប្រសិទ្ធភាពតម្រូវឱ្យក្រសួងនីមួយៗ រៀបចំផែនការសកម្មភាពច្បាស់លាស់ ដើម្បីធ្វើប្រតិភូកម្មអំណាច និងមុខងារឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រៀបចំកម្មវិធីអនុវត្តជាតិរយៈពេល ១០ ឆ្នាំ ។

គោលដៅអាទិភាពដែលពាក់ព័ន្ធគ្នា ក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ មាន[5] ៖

- ធានាឲ្យមានការកាត់បន្ថយអត្រាភាពក្រីក្របានជាង១%ក្នុងមួយឆ្នាំ និងធានាឲ្យមានការកែលំអចំពោះសូចនាករសង្គមសំខាន់ៗ ជាពិសេសក្នុងវិស័យអប់រំ សុខាភិបាល និងសមធម៌យេនឌ័រ។
- ធានាឱ្យមានកំណើន ក្នុងការគ្របដណ្តប់ ប្រសិទ្ធភាព និងគុណភាពសេវាសាធារណៈ និងទទួលបានការទុកចិត្តពីសាធារណជន ។

ក្រសួងពាក់ព័ន្ធត្រូវធានាឱ្យមានការអនុវត្តដោយរលូន និងប្រកបដោយភាពស្របគ្នារវាង កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFMRP) និងកម្មវិធីកំណែទម្រង់សំខាន់ៗផ្សេងៗទៀតរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ ។

យុទ្ធសាស្ត្រនេះនឹងផ្ទេរមុខងារប្រតិបត្តិឱ្យទៅថ្នាក់ស្រុកជាជំហានៗ ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ហើយកែសម្រួលតួនាទីនៅថ្នាក់ជាតិ និងថ្នាក់ខេត្ត ។ ការផ្តោតសំខាន់របស់យុទ្ធសាស្ត្រនេះ គឺការបង្កើនការគ្របដណ្តប់ និងកែលម្អការផ្តល់សេវាកម្ម ដែលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រ ។

---

[4] ប្រសាសន៍លើកឡើងដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នៅកិច្ចប្រជុំគណៈរដ្ឋមន្ត្រីលើកទី១ នៃនីតិកាលទី៤ របស់រដ្ឋសភា នាថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០០៨ (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៨ខ)

[5] (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៨ខ)

## ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ២០០៩-២០១៣[6]

រជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ។ ដំណាក់កាលទី១ ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១២ មានលក្ខណៈសំខាន់សម្រាប់យុទ្ធសាស្ត្រនេះ ដោយផ្តោតលើការបង្កើត និងការរៀបចំស្ថាប័ន តាមរចនាសម្ព័ន្ធ និងក្របខ័ណ្ឌអភិបាលកិច្ចល្អ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។

អាទិភាពសម្រាប់ការអភិវឌ្ឍជនបទរួមមាន ការពង្រឹងសមត្ថភាពស្ថាប័ន ការអភិវឌ្ឍធនធានមនុស្ស និងការកែលម្អលទ្ធភាពទទួលបានទឹកបរិភោគប្រកបដោយសុវត្ថិភាព និងអនាម័យ ព្រមទាំងការអប់រំអំពីសុខភាព និងអនាម័យ ដែលទាំងអស់នេះមាននៅក្នុងយុទ្ធសាស្ត្រវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ។

## គោលនយោបាយជាតិ ស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ: ផ្នែកទី III - វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ[7]

គោលនយោបាយនេះគឺជាមគ្គុទេសក៍ដ៏សំខាន់ សម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ដែលបានកំណត់ជាគោលការណ៍សំខាន់ៗ រួមមាន ៖

- តួនាទីរបស់រដ្ឋាភិបាល ជាអ្នកសម្របសម្រួលការងាររបស់វិស័យនេះដោយផ្តល់លទ្ធភាពអង្គភាពផ្សេងៗទៀត ក្នុងការផ្តល់សេវាជាក់ស្តែង
- ផ្តល់អាទិភាពដល់ការផ្តល់សេវាសម្រាប់ប្រជាជនក្រីក្រ
- តួនាទីវិស័យឯកជនក្នុងការផ្តល់សេវា និងតួនាទីរដ្ឋាភិបាល ក្នុងការផ្តល់លទ្ធភាពឱ្យវិស័យឯកជនសម្រេចបានការងារនេះ រួមទាំងការលើកកម្ពស់ "តម្លាភាព និងការប្រកួតប្រជែងក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ"
- តួនាទីរបស់សហគមន៍ ក្នុងការគ្រប់គ្រងសំណង់ និងសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យរបស់ពួកគេ
- សហគមន៍ត្រូវជ្រើសរើសប្រភេទ និងកម្រិតនៃការផ្តល់សេវាដោយខ្លួនឯង ។

សម្រាប់ការរៀបចំស្ថាប័ន គោលនយោបាយនេះត្រូវបានជំនួសដោយយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការក្នុងទិដ្ឋភាពមួយចំនួន ដូចមានកំណត់នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ[8] ។ យុទ្ធសាស្ត្រនេះ លើកឡើងពីការផ្លាស់ប្តូរដែលត្រូវកើតមានឡើង ។

---

[6] (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៣)
[7] (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៣)
[8] (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៥)

## បទដ្ឋានគតិយុត្តិ

ច្បាប់ពាក់ព័ន្ធនឹងយុទ្ធសាស្រ្តនេះមានបង្ហាញនៅក្នុងតារាងទី៣។ប៉ុន្តែគ្មានច្បាប់ជាក់លាក់ណាមួយសម្រាប់ផ្នែកអនាម័យនោះទេ ។

### តារាងទី៣ ៖ ច្បាប់ពាក់ព័ន្ធនឹងយុទ្ធសាស្រ្តវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ

| ច្បាប់ | ភាពពាក់ព័ន្ធនឹងយុទ្ធសាស្រ្តនេះ |
|---|---|
| ច្បាប់ ស្តីពីទឹក | |
| ច្បាប់ ស្តីពីទឹក និងអនាម័យ នៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០០៤ (សេចក្តីព្រៀងច្បាប់) | ◆ មិនអនុវត្តចំពោះការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅតំបន់ជនបទនោះទេ លើកលែងការផ្គត់ផ្គង់ទឹកតាមបំពង់ទុយោដែលដំណើរការដោយប្រតិបត្តិករឯកជន ។ |
| អនុក្រឹត្យ ស្តីពីការគ្រប់គ្រងការបំពុលទឹក (គណៈរដ្ឋមន្ត្រី ឆ្នាំ១៩៩៩ខ) | ◆ គ្រួសារប្រជាពលរដ្ឋ មិនចាំបាច់សុំការអនុញ្ញាតនោះទ<br>◆ តែត្រូវឲ្យអាហារដ្ឋាន និងអាជីវកម្មខ្នាតតូចសុំការអនុញ្ញាត |
| អនុក្រឹត្យ ស្តីពីការគ្រប់គ្រងកាកសំណល់រឹង (គណៈរដ្ឋមន្ត្រី ឆ្នាំ១៩៩៩ក) | ◆ ពាក់ព័ន្ធតិចតួចជាមួយនឹងយុទ្ធសាស្រ្តវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ |
| ច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ(រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ ១៩៩៦) | ◆ តម្រូវឲ្យមានការវាយតម្លៃផលប៉ះពាល់បរិស្ថានសម្រាប់គម្រោងនានា |
| ច្បាប់ ស្តីពីការគ្រប់គ្រងធនធានទឹក នៃព្រះរាជាណាចក្រកម្ពុជា (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៧) | ◆ តម្រូវឲ្យមានការគ្រប់គ្រងរួមគ្នា និងការបែងចែកការទទួលខុសត្រូវ សម្រាប់អ្នកប្រើប្រាស់ផ្សេងៗគ្នា |
| អនុក្រឹត្យ ស្តីពីកំណត់ទិវាជាតិលើកកម្ពស់អនាម័យជនបទ (១៣ វិច្ឆិកា) | ◆ ជាផ្នែកមួយក្នុងការស្វែងរកការគាំទ្រលើផ្នែកអនាម័យ |
| ច្បាប់អង្គការ (Organizational Legislation) | |

| ច្បាប់ | ភាពពាក់ព័ន្ធនឹងយុទ្ធសាស្ត្រនេះ |
|---|---|
| ច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៨ ខ) | ◆ ផ្តល់ជាបរិបទទូទៅនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលយុទ្ធសាស្ត្រនេះ គួរអនុលោមតាម<br>◆ មុខងារជាក់លាក់សម្រាប់ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និង គណៈកម្មការបច្ចេកទេស<br>◆ បញ្ជាក់ខ្លះៗនូវទំនាក់ទំនងរវាងក្រុមប្រឹក្សា និងក្រសួងពាក់ព័ន្ធ<br>◆ ភាពពាក់ព័ន្ធនឹងអន្តរកាលនៃរចនាសម្ព័ន្ធបច្ចុប្បន្ន និងរចនាសម្ព័ន្ធនាពេលអនាគតប្រព័ន្ធតាមដានត្រួតពិនិត្យ គួររួមបញ្ចូលការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ<br>◆ យុទ្ធសាស្ត្រនេះត្រូវមានការ ពិនិត្យឡើងវិញដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)<br>◆ រាល់សំណើលើការទទួលខុសត្រូវផ្សេងៗ ចាំបាច់ត្រូវអនុលោមតាមច្បាប់អង្គការ |
| ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០១) | ◆ ក្រុមប្រឹក្សាឃុំសង្កាត់អាចប្រើបុគ្គលិកបច្ចេកទេសរបស់ខ្លួន<br>◆ ក្រុមប្រឹក្សាឃុំសង្កាត់មានសិទ្ធិអំណាចគ្រប់គ្រងសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងពាក់ព័ន្ធអាចធ្វើប្រតិភូកម្មមុខងារ និងការទទួលខុសត្រូវឲ្យទៅក្រុមប្រឹក្សាឃុំសង្កាត់<br>◆ មូលនិធិផ្តល់ដោយក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងពាក់ព័ន្ធ អាចឲ្យទៅក្រុមប្រឹក្សាឃុំសង្កាត់<br>◆ ជំនួយឥតសំណងពីម្ចាស់ជំនួយអាចផ្តល់ឲ្យទៅក្រុមប្រឹក្សាឃុំ សង្កាត់ |

| ច្បាប់ | ភាពពាក់ព័ន្ធនឹងយុទ្ធសាស្ត្រនេះ |
|---|---|
| ប្រកាសស្ដីពីការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ តួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មាធិការអភិវឌ្ឍន៍ជនបទ ខេត្ត ក្រុង និងគណៈកម្មាធិការប្រតិបត្តិ (គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ឆ្នាំ២០០៨) | ◆ ផ្ទេរតួនាទី និងការទទួលខុសត្រូវរបស់គណៈកម្មា-ធិការអភិវឌ្ឍន៍ជនបទខេត្ត ឲ្យទៅគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ<br>◆ ដាក់បញ្ចូលអង្គភាពគាំទ្របច្ចេកទេសនៅក្នុងរចនាសម្ព័ន្ធថ្មី |
| ច្បាប់សង្គមកិច្ច | |
| ច្បាប់ ស្ដីពីកិច្ចការពារ និងការលើកកម្ពស់សិទ្ធិជនពិការ (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៩) | ◆ ធានាឲ្យមានការចូលរួមពីជនពិការ ក្នុងការកំណត់ការផ្ដល់សេវា<br>◆ សំណង់ទឹកស្អាត និងអនាម័យដែលជនពិការគ្រប់ប្រភេទអាចប្រើបាន |
| ច្បាប់ស្ដីពីវិស័យឯកជន | |
| សេចក្ដីព្រៀងច្បាប់សម្បទាន (ECA, 2004a) | ◆ គ្របដណ្ដប់លើកិច្ចសន្យាសម្រាប់ការគ្រប់គ្រងសេវា<br>◆ លក្ខខណ្ឌតម្រូវសម្រាប់ការសម្របសម្រួល និងសេវារដ្ឋបាល តាមរយៈក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អាចមិនមានលក្ខណៈសមស្របសម្រាប់កិច្ចសន្យាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទនៅថ្នាក់ស្រុកនោះទេ |

## វិមជ្ឈការ និងវិសហមជ្ឈការ

រាជរដ្ឋាភិបាលបានប្ដេជ្ញាចិត្តចំពោះដំណើរនៃការកែទម្រង់អភិបាលកិច្ច ។ យោងតាមក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ការកែទម្រង់ តាមបែបប្រជាធិប្បតេយ្យថ្នាក់ក្រោមជាតិដែលជាគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ គឺមានគោលបំណងដើម្បីបង្កើតជាប្រព័ន្ធគ្រប់គ្រងរដ្ឋបាលឯកភាពនៅថ្នាក់រាជធានី ខេត្ត ស្រុក ខណ្ឌ និងឃុំ សង្កាត់[9]។ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ (ឆ្នាំ២០០១) និងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ឆ្នាំ២០០៨)[10]គឺជាសមាសភាគសំខាន់ៗនៃកំណែទម្រង់នេះ។ កាលពីខែឧសភា ឆ្នាំ២០១០ កិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានអនុម័តយល់ព្រមលើកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅ

[9] រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៥

[10] ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ និងព្រះរាជក្រមលេខ នស/រកម/០៥០៨/០១ តាមលំដាប់

ថ្នាក់ក្រោមជាតិ ដែលបានចែងថា "របៀបវារៈរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់រយៈពេល១០ឆ្នាំខាងមុខទៀតក្នុងដំណើរការកំណែទម្រង់អភិបាលកិច្ចឱ្យបានទូលំទូលាយ និងស៊ីជម្រៅ ដែលនឹងជះឥទ្ធិពលដល់ស្ថាប័នជាតិផ្សេងទៀតផងដែរ"[11]។

## យុទ្ធសាស្ត្រ និងផែនការពាក់ព័ន្ធផ្សេងៗ

យុទ្ធសាស្ត្រនានាដែលពាក់ព័ន្ធដោយផ្ទាល់នឹងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទមានដូចតទៅ ៖

- ការបំពុលទឹកក្រោមដីដោយសារធាតុអាសេនិកនៅកម្ពុជា ៖ បច្ចុប្បន្នកម្មផែនការសកម្មភាពយុទ្ធសាស្ត្រអាសេនិក៥ឆ្នាំ (២០១០-២០១៥)[12]
- យុទ្ធសាស្ត្រហិរញ្ញប្បទានវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅកម្ពុជា[13]

យុទ្ធសាស្ត្រ និងផែនការរបស់វិស័យនានាដែលពាក់ព័ន្ធ រួមមាន ៖

- យុទ្ធសាស្ត្រសម្រាប់កសិកម្ម និងទឹក ឆ្នាំ ២០០៦-២០១០[14]
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទឹក ឆ្នាំ ២០០៦-២០១០[15]
- ផែនការយុទ្ធសាស្ត្រសុខាភិបាល ឆ្នាំ២០០៨-២០១៥[16]
- ផែនការសកម្មភាពជាតិ សម្រាប់ជនពិការ រួមទាំងជនរស់រានពីមីនបង្កប់ក្នុងដី-សំណល់គ្រាប់មិនទាន់ផ្ទុះ ឆ្នាំ ២០០៩-២០១០[17]
- គោលនយោបាយសាលារៀនដែលល្អសម្រាប់កុមារ (២០០៧)[18]
- គោលនយោបាយជាតិ ស្តីពីការថែរក្សា និងការអភិវឌ្ឍនៅវ័យកុមារភាព (២០១០)[19]
- នារីរតនៈ III ៖ ផែនការយុទ្ធសាស្ត្ររយៈពេល ៥ឆ្នាំ ឆ្នាំ ២០០៩-២០១៣[20]
- យុទ្ធសាស្ត្រជាតិស្តីពីកិច្ចការពារសង្គមសម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ (សេចក្តីព្រាង)[21]

---

[11] រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០១០
[12] អនុគណៈកម្មការអន្តរក្រសួងសម្រាប់ត្រួតពិនិត្យសារធាតុអាសេនិក ឆ្នាំ២០១០
[13] (COWI, 2010)
[14] (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ & ក្រសួងធនធានទឹក និងឧតុនិយម ឆ្នាំ២០០៧ ៖ ក្រុមការងារបច្ចេកទេសកសិកម្ម និងទឹក ឆ្នាំ២០០៧)
[15] (ក្រសួងធនធានទឹក និងឧតុនិយម ឆ្នាំ២០០៥)
[16] (ក្រសួងសុខាភិបាល ឆ្នាំ២០០៨)
[17] (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឆ្នាំ២០០៩)
[18] (ក្រសួងអប់រំយុវជន និងកីឡា ឆ្នាំ២០០៧)
[19] (ក្រសួងអប់រំយុវជន និងកីឡា ឆ្នាំ២០១០)
[20] (ក្រសួងកិច្ចការនារី ឆ្នាំ២០០៩)
[21] (ក្រុមប្រឹក្សាកសិកម្ម និងអភិវឌ្ឍន៍ជនបទ ២០១០)

- ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ[22]
- ផែនការអភិវឌ្ឍន៍រយៈពេលបីឆ្នាំផែនការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ NP-SNDD (២០១១-២០១៣)
- ផែនការកសាងសមត្ថភាពគណៈកម្មការជាតិអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)សម្រាប់ឆ្នាំ២០១០[23]
- ផែនការយុទ្ធសាស្ត្រសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយឆ្នាំ២០០៨-២០១៣[24]
- កម្មវិធីជាតិនៃសកម្មភាពសម្របតាមការប្រែប្រួលអាកាសធាតុ[25]

## តួនាទី និងការទទួលខុសត្រូវ

តួនាទី និងការទទួលខុសត្រូវលើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ មានកំណត់នៅតាមក្រសួងពាក់ព័ន្ធនានា រួមមាន ៖

- ក្រសួងអភិវឌ្ឍន៍ជនបទ ទទួលខុសត្រូវលើវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ
- ក្រសួងធនធានទឹក និងឧតុនិយម ទទួលខុសត្រូវរួមលើការធ្វើផែនការ និងគ្រប់គ្រងធនធានទឹក
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ទទួលខុសត្រូវលើការផ្គត់ផ្គង់ទឹកតាមទីប្រជុំជនរាជធានី និងក្រុងលើបទបញ្ញត្តិនៃប្រព័ន្ធផ្គត់ផ្គង់ទឹកតាមទុយោដោយវិស័យឯកជន ការកំណត់បទដ្ឋានគុណភាពទឹកបរិភោគ គុណភាពទឹកផ្គត់ផ្គង់តាមទុយោ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ទទួលខុសត្រូវលើគុណភាពទឹកតាមទុយោដែលផ្គត់ផ្គង់តាមទីសាធារណៈ
- ក្រសួងផែនការទទួលខុសត្រូវលើការតាមដានត្រួតពិនិត្យការអនុវត្តគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា

រចនាសម្ព័ន្ធរបស់ក្រសួងអភិវឌ្ឍន៍ជនបទ មានបង្ហាញនៅក្នុងរូបភាពទី៥ ។ នាយកដ្ឋានសំខាន់ៗដែលទទួលខុសត្រូវនៅថ្នាក់ជាតិ រួមមាននាយកដ្ឋានផ្គត់ផ្គង់ទឹកជនបទ និងនាយកដ្ឋានថែទាំសុខភាពជនបទ ដែលនាយកដ្ឋានទាំងពីរនេះ ស្ថិតនៅក្រោមអគ្គនាយកដ្ឋានបច្ចេកទេស។ នៅថ្នាក់ក្រោមជាតិ មន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត មានការិយាល័យអភិវឌ្ឍន៍ជនបទស្រុក តែទោះបីយ៉ាងណាក៏ដោយ នៅមិនទាន់មានធនធានគ្រប់គ្រាន់ ដើម្បីដំណើរការការិយាល័យទាំងអស់នៅឡើយទេ មកទល់បច្ចុប្បន្ននេះ ។

[22] (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៥)
[23] (គណៈកម្មការជាតិនៃលេខាធិការដ្ឋានអភិវឌ្ឍន៍ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឆ្នាំ២០១០)
[24] (គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយជាតិ និងក្រសួងផែនការ ឆ្នាំ២០០៨)
[25] (ក្រសួងបរិស្ថាន ឆ្នាំ២០០៦)

## រូបភាពទី៩ ៖ រចនាសម្ព័ន្ធរបស់ក្រសួងអភិវឌ្ឍន៍ជនបទ[26]




[26] (ក្រសួងអភិវឌ្ឍន៍ជនបទ)

## ការសម្របសម្រួល

ក្រសួងអភិវឌ្ឍន៍ជនបទ ជាស្ថាប័នទទួលខុសត្រូវសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទនៅប្រទេសកម្ពុជា ដោយមានការទទួលខុសត្រូវជាក់លាក់លើការដឹកនាំ និងសម្របសម្រួល ។ មានយន្តការពីរសំខាន់ សម្រាប់ការសម្របសម្រួលវិស័យនេះ ។ ក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ដែលមានឯកឧត្តមរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទជាប្រធាន នាំឱ្យមានការរួមសហការគ្នា នៅថ្នាក់កំពូលរវាង "រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ និងធានាឱ្យបាននូវការសម្របសម្រួលមួយកាន់តែមានប្រសិទ្ធភាព និងឆ្លើយតបទៅលើបញ្ហាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ និងការលើកកម្ពស់អនាម័យផ្ទាល់ខ្លួន[27]" ហើយតួនាទីនេះរាប់បញ្ចូលទាំងការសម្របសម្រួលយុទ្ធសាស្ត្រនេះផងដែរ ។ ក្រុមការងារសម្របសម្រួលវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ដែលដឹកនាំដោយក្រសួងអភិវឌ្ឍន៍ជនបទ ជាអ្នករៀបចំឱ្យមានកិច្ចប្រជុំប្រចាំខែរវាងស្ថាប័ន និងដៃគូពាក់ព័ន្ធ ដើម្បីផ្លាស់ប្តូរព័ត៌មានឱ្យគ្នាទៅវិញទៅមក ។

## ការគ្រប់ដណ្តប់ និងចំណុចគោលដៅ

ផ្អែកតាមទិន្នន័យជំរឿនទូទៅនូវប្រជារាស្ត្រកម្ពុជាឆ្នាំ២០០៨ ប្រជាពលរដ្ឋជនបទទទួលបានការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យដែលមានការកែលម្អ រួមជាមួយនឹងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា និងចំណុចគោលដៅរបស់ទស្សនវិស័យនេះ មានបង្ហាញនៅក្នុងតារាងទី៤ ។

**តារាងទី៤ ៖ ការទទួលបានសេវាផ្គត់ផ្គង់ទឹក និងអនាម័យដែលមានការកែលម្អ**

| | ឆ្នាំ២០០៨ | គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ឆ្នាំ ២០១៥ | ទស្សនវិស័យ ឆ្នាំ ២០២៥ |
|---|---|---|---|
| សេវាផ្គត់ផ្គង់ទឹក ដែលមានការកែលម្អ | ៤០.៥% | ៥០% | ១០០% |
| បង្គន់អនាម័យ ដែលមានការកែលម្អ | ២៣,២% | ៣០% | ១០០% |

[27] (ក្រុមការងារបច្ចេកទេសខាងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ឆ្នាំ២០០៧)

តារាងទី៥[28] បង្ហាញពីចំនួនប្រជាជន និងចំនួនគ្រួសារនៃការគ្របដណ្តប់បច្ចុប្បន្ន និងចំណុចគោលដៅនៃការគ្របដណ្តប់ ជាមួយនឹងកំណើនដែលត្រូវការ ដើម្បីសម្រេចគោលដៅនោះ ។

**តារាងទី៥ ៖ គោលដៅ និងតម្រូវការនៃកំណើន**

| | **ឆ្នាំ២០០៨** | **គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ឆ្នាំ២០១៥** | **ទស្សនវិស័យ ឆ្នាំ២០២៥** |
|---|---|---|---|
| ចំនួនប្រជាពលរដ្ឋនៅតាមជនបទ (យោងតាមជំរឿនទូទៅនូវប្រជារាស្ត្រកម្ពុជាឆ្នាំ២០០៨) | ១០.៧៨១.៦៥៥ | ១២.០០២.០០០ | ១៣.៩៨៣.០០០ |
| ចំនួនគ្រួសារ នៅតាមជនបទ | ២.៣៤៣.៨៣៨ | ២.៤០០.៣០០ | ២.៧៩៧.០០០ |
| អត្រាកំណើនចំនួនប្រជាជន | ១.៥៤% | | |
| **សេវាផ្គត់ផ្គង់ទឹកស្អាត** | | | |
| ចំនួនប្រជាជន ដែលទទួលបានសេវាទឹកស្អាត ៤០.៥% (២០០៨) | ៤.៣៦៧.៥០០ | | |
| ចំនួនប្រជាជន ដែលមិនបានទទួលសេវាទឹកស្អាត (២០០៨) | ៦.៤១៦.៥០០ | | |
| **គោលដៅគ្របដណ្តប់របស់គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា** | | | |
| ចំនួនប្រជាជនដែលទទួលបានសេវាទឹកស្អាត ៥០% | | ៦.០០១.០០០ | |
| ចំនួនប្រជាជន ដែលមិនទទួលបានសេវាទឹកស្អាត | | ៦.១៥១.០០០ | |
| ចំនួនប្រជាជនដែលនឹងបង្កើនឡើងដើម្បីទទួលបានសេវាទឹកស្អាតឲ្យសម្រេចបានតាមគោលដៅ ២០១៥ | | ១.៦៣៣.០០០ | |
| **គោលដៅគ្របដណ្តប់របស់ទស្សនវិស័យផ្គត់ផ្គង់ទឹកស្អាត** | | | |

[28] (វិទ្យាស្ថានជាតិស្ថិតិ ឆ្នាំ២០០៩)

| | | | |
|---|---|---|---|
| ចំនួនប្រជាជន ដែលនឹងទទួលបានសេវាទឹកស្អាត ១០០% | | | ១៤.៩៨៣.០០០ |
| ចំនួនប្រជាជនដែលនឹងបង្កើនឡើងពីគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ដើម្បីសម្រេចបានគោលដៅ ១០០% | | | ៧.៩៨៣.០០០ |
| **បង្គន់អនាម័យ** | | | |
| ចំនួនគ្រួសារមានបង្គន់អនាម័យប្រើប្រាស់២៣,២% (២០០៨) | ៥០០.៤០០ | | |
| ចំនួនគ្រួសារមិនទាន់មានបង្គន់អនាម័យប្រើប្រាស់ (២០០៨) | ២.០៥៧.០០០ | | |
| **ចំណុចគោលដៅនៃការគ្របដណ្តប់តាមគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា** | | | |
| ចំនួនគ្រួសារ មានបង្គន់អនាម័យប្រើប្រាស់ ៣០% | | ៧២០.០០០ | |
| ចំនួនគ្រួសារ មិនទាន់មានបង្គន់អនាម័យប្រើប្រាស់ | | ១.៦៨០.០០០ | |
| ចំនួនប្រជាជន ដែលនឹងបង្កើនឡើងដើម្បីទទួលបានបង្គន់អនាម័យប្រើប្រាស់សម្រេចបានតាមគោលដៅ ២០១៥ | | ២២០.០០០ | |
| **ចំណុចគោលដៅគ្របដណ្តប់តាមរបស់ទស្សនវិស័យអនាម័យ** | | | |
| ចំនួនគ្រួសារ មានបង្គន់អនាម័យប្រើប្រាស់ ១០០% | | | ២.៧៩៧.០០០ |
| ចំនួនប្រជាជនដែលនឹងបង្កើនឡើងពីគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ដើម្បីសម្រេចបានគោលដៅ ១០០% | | | ២.០៧៧.០០០ |

## ភាពក្រីក្រ និងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ

សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យដែលបានកែលម្អ មានការពាក់ព័ន្ធផ្ទាល់ទៅនឹងចង្កោមអាទិភាពរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្រ ដូចបានចែងក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ជាពិសេស យុទ្ធសាស្ត្រទាំងអស់របស់វិស័យដែលពាក់ព័ន្ធនេះ បន្តការយកចិត្តទុកដាក់ចំពោះផលប៉ះពាល់ជាវិជ្ជមានលើភាពក្រីក្រ ដើម្បីសម្រេចបានគោលបំណងនៃការកាត់បន្ថយភាពក្រីក្រ ។ ការវិនិយោគទុន និងការយកចិត្តទុកដាក់លើចំណុចគោលដៅ គួរតែត្រូវបានផ្តោតទៅរកប្រជាពលរដ្ឋ និងតំបន់ដែលមិនទាន់មានសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ជាពិសេសផ្តោតទៅរកតំបន់ដែលមានអត្រាភាពក្រីក្រខ្ពស់[29]។

ទំនាក់ទំនងរវាងភាពក្រីក្រ និងការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ មានបង្ហាញនៅក្នុងរូបភាពទី៦ ។

[29] (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៦)

### រូបភាពទី៥ ៖ ទំនាក់ទំនងរវាងភាពក្រីក្រ និងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ[30]

| | | | |
|---|---|---|---|
| **កង្វះទឹកស្អាត បង្គន់អនាម័យ និងអនាម័យផ្ទាល់ខ្លួន** | ⇨ | ទិដ្ឋភាពនៃភាពក្រីក្រ | ផលប៉ះពាល់ជាគន្លឹះ |
| | | សុខភាព | ◆ ជំងឺផ្សេងៗដែលពាក់ព័ន្ធនឹងទឹកស្អាត និងអនាម័យ<br>◆ ក្រិនដោយសារកង្វះអាហារូបត្ថម្ភ ដែលបណ្តាលមកពីជំងឺរាករូស<br>◆ អាយុកាលជាមធ្យម ត្រូវបានកាត់បន្ថយ |
| | | ការអប់រំ | ◆ វត្តមានការសិក្សាក្នុងថ្នាក់របស់កុមារ (ជាពិសេសក្មេងស្រីត្រូវបានកាត់បន្ថយ ដោយសារតែសុខភាពទន់ខ្សោយ កង្វះអនាម័យទឹកស្អាត ឬភារកិច្ចត្រូវស្វែងរកទឹកយកមកប្រើប្រាស់ |
| | | យេនឌ័រនិងការចូលរួមក្នុងសង្គម | ◆ ស្ត្រីទទួលបន្ទុកធ្ងន់ហួសហេតុពេកធ្វើឱ្យពួកគេមានឱកាសតិចតួចសម្រាប់ប្រកបការងារដែលទទួលបានកម្រៃ<br>◆ ជនពិការ ប្រឈមនឹងភាពលំបាក |
| | | ប្រាក់ចំណូល និងចំណាយលើការប្រើប្រាស់ | ◆ ថវិកាដែលចំណាយលើការប្រើប្រាស់ទឹកមានកម្រិតខ្ពស់<br>◆ សក្តានុពលរកប្រាក់ចំណូល ត្រូវបានកាត់បន្ថយដោយសារសុខភាពទន់ខ្សោយពេលវេលាចំណាយលើការរកទឹក ឬខ្វះឱកាសធ្វើអាជីវកម្មដែលត្រូវប្រើទឹកជាសំខាន់<br>◆ ប្រឈមនឹងការចំណាយលើការប្រើប្រាស់ខ្ពស់ ដោយសារតែកត្តារដូវកាល និងកត្តាផ្សេងៗទៀត |

ក្រៅពីគោលដៅរបស់គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជាសម្រាប់ការផ្គត់ផ្គង់ទឹក និងអនាម័យដែលមានការកែលំអ ក៏នៅមានការចូលរួមចំណែកដោយផ្ទាល់ ទៅលើគោលដៅផ្សេងៗទៀតនៃគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជាផងដែរ ដូចដែលបានបង្ហាញក្នុងប្រអប់ទី១ ។

[30] ដកស្រង់ចេញពី (Bosch, Hommann, Rubio, Sadoff, & Travers, 2002)

### ប្រអប់ទី១ ៖ សារសំខាន់នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍បរិស្ថាន សម្រាប់គោលដៅផ្សេងទៀតនៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍[31]

| គោលដៅ | ការផ្សារភ្ជាប់ទៅនឹងបរិស្ថាន |
|---|---|
| ១. លុបបំបាត់ភាពក្រីក្រ និងភាពអត់ឃ្លានខ្លាំង | ជីវភាពរស់នៅ និងសន្តិសុខស្បៀងរបស់ប្រជាពលរដ្ឋក្រីក្រជារឿយៗ ពឹងផ្អែកទៅលើសេវាកម្ម និងផលិតផលនៃប្រព័ន្ធអេកូឡូស៊ី។ ប្រជាពលរដ្ឋក្រីក្រ មិនមានសិទ្ធិគ្រប់គ្រាន់ចំពោះធនធានបរិស្ថាន និងកង្វះលទ្ធភាពទីផ្សារ ខ្វះការសម្រេចចិត្ត និងព័ត៌មានបរិស្ថាននៅមានកម្រិតសម្រាប់ការយល់ដឹងរបស់ពួកគេដើម្បីការពារបរិស្ថាន និងធ្វើឲ្យប្រសើរឡើងនូវជីវភាព និងសុខុមាលភាពរបស់ពួកគេ ។ |
| ២. សម្រេចបានការសិក្សាអប់រំកម្រិតបឋមជាកល | ការស្វែងរកទឹកយកមកប្រើប្រាស់ និងការរកអុស បានកាត់បន្ថយពេលវេលារបស់ពួកគេទៅសាលារៀន ។ បន្ថែមពីនេះ កង្វះសេវាទឹកស្អាត និងអនាម័យនៅតាមតំបន់ជនបទជាឧបសគ្គមួយដែលគ្រូមានសមត្ថភាព មិនចង់ផ្លាស់ទៅបង្រៀននៅតាមភូមិក្រីក្រដាច់ស្រយាលទាំងនោះ ។ |
| ៣. លើកកម្ពស់សមធម៌យេនឌ័រ និងផ្តល់អំណាចដល់ស្ត្រី | ស្ត្រី និងក្មេងស្រី ទទួលបន្ទុកយ៉ាងធ្ងន់ធ្ងរក្នុងការស្វែងរកទឹកយកមកប្រើប្រាស់ និងរកអុសដុត ដែលសកម្មភាពនេះបានកាត់បន្ថយពេលវេលា និងឱកាសរបស់ពួកគេសម្រាប់ការសិក្សាអប់រំ អក្ខរភាព និងសកម្មភាពរកប្រាក់ចំណូលផ្សេងៗទៀត ។ ជាទូទៅ ស្ត្រីមានសិទ្ធិមិនស្មើគ្នា និងមានលទ្ធភាពគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិផ្សេងៗទៀតមិនច្បាស់លាស់ ដែលធ្វើឲ្យពួកគេខ្វះឱកាស និងសមត្ថភាពក្នុងការទទួលបានផលផ្សេងៗ |
| ៤. កាត់បន្ថយអត្រាមរណៈភាពរបស់កុមារ | ជំងឺ (ដូចជាជំងឺរាក) ដោយសារទឹកមិនស្អាត និងកង្វះអនាម័យព្រមទាំងការរលាកផ្លូវដង្ហើមដែលទាក់ទិននឹងការបំពុលនានាគឺជាពពួកជំងឺឈានមុខគេក្នុងការសម្លាប់កុមារក្រោមអាយុ ៥ ឆ្នាំ ។ កង្វះអុសសម្រាប់ដាំទឹកបរិភោគ បានរួមចំណែកបង្កឱ្យមានជំងឺឆ្លងតាមទឹក ដែលជាប្រភេទជំងឺដែលយើងអាចទប់ស្កាត់បាន ។ |

[31] (កម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ ឆ្នាំ២០០៣)

| | |
|---|---|
| ៥. ការលើកកម្ពស់សុខភាពមាតា | ការដងទឹក រែកទឹក និងទូលអុសធ្ងន់ៗ បានប៉ះពាល់ដល់សុខភាពស្ត្រី និង អាចធ្វើឱ្យពួកគេមានសុខភាពមិនល្អ និងបង្កផលវិបាកកាន់តែធ្ងន់នៅក្នុងអំឡុងពេលមានផ្ទៃពោះ ។ អនាម័យ មិនសមស្រប ធ្វើឱ្យអន្តរាយដល់ការថែទាំសុខភាព ជាពិសេសនៅតាមតំបន់ជនបទ ។ |
| ៦. ការប្រយុទ្ធនឹងជំងឺសំខាន់ៗ (Major diseases) | ២០%នៃជំងឺដែលកើតមាននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ បណ្តាលមកពីកត្តាហានិភ័យបរិស្ថាន (ដូចជាជំងឺគ្រុនចាញ់ និងប៉ារ៉ាសិត) ។ វិធានការទប់ស្កាត់ដើម្បីកាត់បន្ថយជំងឺសំខាន់ៗទាំងនេះ មានសារសំខាន់ដូចគ្នាទៅនឹងការព្យាបាលដែរតែមានការចំណាយថវិកាអស់តិចជាងការបាល។ |

# ៧. សេចក្តីសង្ខេបគោលដៅយុទ្ធសាស្ត្រ និងសមាសភាគ

| សមាសភាគបន្ទាប់បន្សំ | លទ្ធផល | សកម្មភាព | ការទទួលខុសត្រូវ |
|---|---|---|---|
| **គោលដៅយុទ្ធសាស្ត្រទី ១ ៖ ការទទួលបានសេវាកម្មផ្គត់ផ្គង់ទឹកដែលមានការកែលម្អ ប្រកបដោយនិរន្តរភាព** | | | |
| **សមាសភាគ ១.១៖ ការទទួលបានសេវាកម្មផ្គត់ផ្គង់ទឹក** | | | |
| ១.១.១. ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធថ្មី | សហគមន៍ និងស្ថាប័ននានាតាមជនបទ ទទួលបានសេវាផ្គត់ផ្គង់ទឹកតាម រយៈការផ្តល់ហេដ្ឋារចនាសម្ព័ន្ធថ្មី | ◆ រៀបចំបញ្ជីសារពើភ័ណ្ឌនៃសេវាផ្គត់ផ្គង់ទឹក និងភាពខ្វះ ចន្លោះផ្សេងៗនៅថ្នាក់ស្រុក ហើយចងក្រងព័ត៌មានទាំងនេះនៅ ថ្នាក់ខេត្ត និងថ្នាក់ជាតិ ។<br>◆ គ្រប់គ្រងការប្រើប្រាស់ប្រភពទឹកតាមផ្ទះឲ្យបានត្រឹមត្រូវ ដោយយោងទៅតាមគោលការណ៍ គ្រប់គ្រង ធនធានទឹកចម្រុះ ។<br>◆ កំណត់ការគាំទ្រដែលផ្តល់ដោយដោយរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ រួមទាំងអង្គការមិនមែនរដ្ឋាភិបាល។<br>◆ ជំរុញឱ្យមានដំណើរការដាក់ពាក្យស្នើសុំ ហេដ្ឋារចនាសម្ព័ន្ធថ្មីសម្រាប់សេវាផ្គត់ផ្គង់ទឹក។<br>◆ ការរៀបចំសហគមន៍សម្រាប់គ្រប់គ្រងការសាងសង់ ប្រតិបត្តិការ និងថែទាំសេវាកម្មផ្គត់ផ្គង់ទឹក។ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធថ្មី<br>◆ ការត្រួតពិនិត្យគុណភាពសំណង់ថ្មី ការផ្តល់មូលនិធិលើថ្លៃទុនដើម ( Capital Cost ) នៃហេដ្ឋារចនាសម្ព័ន្ធថ្មី | ◆ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត/ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងធនធានទឹក និងឧតុនិយម<br>◆ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងការិយាល័យអភិវឌ្ឍន៍ជនបទស្រុក<br>◆ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងការិយាល័យអភិវឌ្ឍន៍ជនបទស្រុក<br>◆ ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក អង្គការមិនមែនរដ្ឋាភិបាល<br>◆ វិស័យឯកជន ដែលទទួលភារកិច្ចពីការិយាល័យអភិវឌ្ឍន៍ជនបទស្រុក<br>◆ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងការិយាល័យអភិវឌ្ឍន៍ជនបទស្រុក<br>ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងភាពជាដៃគូជាមួយនឹងក្រសួងអភិវឌ្ឍន៍ជនបទ និងដៃគូអភិវឌ្ឍន៍ ព្រមទាំងសហគមន៍ |

| | | | |
|---|---|---|---|
| ១.១.៣ បច្ចេកវិទ្យាផ្គត់ផ្គង់ទឹក | | | |
| ១.១.៤ ការអភិវឌ្ឍបច្ចេកវិទ្យា និងសេវាកម្មសមស្រប | ជម្រើសបច្ចេកវិទ្យា ដែលមានតម្លៃសមស្រប សម្រាប់ការ ផ្គត់ផ្គង់ទឹកនៅតំបន់រាំងស្ងួត តំបន់ទទួលរងផលប៉ះពាល់ដោយសារធាតុអាសេនិក និងសម្រាប់សេចក្ដីត្រូវការសង្គមផ្សេងៗ ដែលអាចរកបាន | ◆ ធ្វើការសិក្សាស្រាវជ្រាវ អភិវឌ្ឍ និងសាកល្បងលើបច្ចេកវិទ្យាផ្គត់ផ្គង់ទឹកនៅតំបន់រាំងស្ងួត និងតំបន់ទទួលរងផលប៉ះពាល់ដោយសារធាតុអាសេនិក ស្របទៅតាមនីតិវិធីស្រាវជ្រាវ និងអភិវឌ្ឍនៅក្នុងសមាសភាគទី៤.៦ ។ ការសិក្សាស្រាវជ្រាវនេះ នឹងរួមបញ្ចូលទាំងការត្រួតពិនិត្យឡើងវិញ នូវភាពសមស្របនៃបច្ចេកវិទ្យាសម្រាប់ស្ត្រីដែលជាអ្នកប្រើប្រាស់ និងបច្ចេកវិទ្យានានា ដែលកំពុងប្រើប្រាស់តាមបណ្ដាប្រទេសនានា ។<br>◆ ធ្វើការសិក្សាស្រាវជ្រាវ អភិវឌ្ឍ និងសាកល្បង បច្ចេកទេសផ្គត់ផ្គង់ទឹក សម្រាប់បម្រើសេចក្ដីត្រូវការពិសេសរបស់សង្គម រួមមានអ្នកប្រើប្រាស់ជាជនពិការ និងស្ត្រី -កុមារ ស្របទៅតាមនីតិវិធីស្រាវជ្រាវនិងអភិវឌ្ឍនៅក្នុងសមាសភាគទី៤.៦។<br>◆ អនុវត្តការសិក្សាស្រាវជ្រាវ អភិវឌ្ឍន៍ និងពិសោធន៍ សាកល្បង។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ សាកលវិទ្យាល័យ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អង្គការមិនមែនរដ្ឋាភិបាល និង/ឬ ស្ថាប័នឯកជន |

| | | | |
|---|---|---|---|
| ១.១.៥ ការចែករំលែកហានិភ័យក្នុងការផ្តល់សេវាកម្ម | វិស័យឯកជនដែលនឹងត្រូវដំណើរការផ្តល់សេវាកម្មនៅតំបន់ដែលមានការលំបាក និងតំបន់;ដាច់ស្រយាល | ◆ បង្កើតប្រព័ន្ធច្បាស់លាស់មួយសម្រាប់បន្ថែមតម្លៃនៃការធ្វើការនៅតំបន់ដាច់ស្រយាល និងសម្រាប់រួមចំណែកក្នុងការខូចខាត ដែលនឹងអាចកើតមានឡើង ដើម្បីជាការលើកទឹកចិត្តដល់វិស័យឯកជន ឱ្យធ្វើការនៅតំបន់ដាច់ស្រយាល។ ប្រព័ន្ធនេះនឹងជួយក្នុងការចែករំលែកហានិភ័យទាំងឡាយជាមួយភាគីពាក់ព័ន្ធផ្សេងៗ។ ការផ្តល់លើកទឹកចិត្តដល់អ្នកវិនិយោគឯកជនទាំងនេះ គឺជាការសមស្របសម្រាប់ទូទាត់ជាមួយនឹង ហានិភ័យទាំងឡាយដែលពួកគេជួបប្រទះ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ |

## សមាសភាគ ១.២៖ ការអនុវត្តតាមបទដ្ឋានគុណភាពទឹក

| | | | |
|---|---|---|---|
| ១.២.១.ផែនការសុវត្ថិភាពទឹក និងប្រព័ន្ធត្រួតពិនិត្យគុណភាពទឹក (**Water Supply Surveillance**) | ដំណើរការនីតិវិធីដើម្បីឲ្យការផ្គត់ផ្គង់ទឹកអនុលោមទៅតាមស្តង់ដាគុណភាពទឹក សម្រាប់ជនបទ | ◆ ទទួលយកនូវទស្សនៈផែនការសុវត្ថិភាពទឹកសម្រាប់ប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា និងរៀបចំគោលការណ៍ណែនាំ ស្តីពីផែនការសុវត្ថិភាពទឹកសម្រាប់ក្រុមប្រឹក្សាឃុំ-សង្កាត់ រួមមានផែនការសុវត្ថិភាពទឹកទូទៅ ផ្អែកតាមឯកសារណែនាំ ស្តីពីផែនការសុវត្ថិភាពទឹក ដែលរៀបចំដោយអង្គការសុខភាពពិភពលោក។<br>◆ បង្កើតប្រព័ន្ធត្រួតពិនិត្យគុណភាពទឹក (Water Supply Surveillance) សម្រាប់ខេត្ត ហើយការទទួលខុសត្រូវលើប្រតិបត្តិការត្រូវផ្ទេរទៅឱ្យក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់។<br>◆ ក្រុមប្រឹក្សា ឃុំសង្កាត់នីមួយៗនឹងបង្កើតផែនការសុវត្ថិភាពទឹកសម្រាប់តំបន់របស់ខ្លួន ដែលជាផ្នែកមួយ នៃប្រព័ន្ធតាមដានគុណភាពទឹក។<br>◆ បង្កើតនីតិវិធីមួយសម្រាប់ធ្វើសេចក្តីសម្រេចចិត្ត និងសកម្មភាពមួយចំនួន ដើម្បីឆ្លើយតបទៅនឹងប្រភពទឹក ដែលមិនសមស្របតាមបទដ្ឋានស្តង់ដារួមទាំងការត្រួតពិនិត្យប្រភពទឹកផ្សេងៗ ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត<br>◆ ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក<br>◆ ក្រុម ប្រឹក្សាឃុំ សង្កាត់<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ |

| | | | |
|---|---|---|---|
| ១.២.២ ការការពារទឹកពីប្រភពទឹក រហូតដល់ការប្រើប្រាស់តាមផ្ទះ | ប្រជាពលរដ្ឋអនុវត្តការប្រើប្រាស់ទឹកប្រកបដោយ សុវត្ថិភាព ទាំងការទុកដាក់ទឹក ការប្រើប្រាស់ទឹកតាមផ្ទះ និងការបរិភោគ | ◆ ផ្សព្វផ្សាយ និងត្រួតពិនិត្យវាយតម្លៃពីប្រសិទ្ធភាពនៃគោលការណ៍ណែនាំស្តីពីការលើកកម្ពស់អនាម័យផ្ទាល់ខ្លួន ( Hygiene Promotion Guideline, 2010 ) ហើយកែលំអគោលការណ៍ណែនាំនេះ ប្រសិនបើមានការចាំបាច់ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ |
| | ឧបករណ៍បន្សុទ្ធទឹកតាមផ្ទះ ដែលបានដាក់លក់នៅលើទីផ្សារ ឬដែលបានផ្តល់ឱ្យដោយស្ថាប័នអភិវឌ្ឍន៍នានា ត្រូវឆ្លើយតបទៅតាមបទដ្ឋានស្តង់ដា | ◆ បញ្ចប់នីតិវិធីសម្រាប់វាយតម្លៃបច្ចេកវិទ្យាបន្សុទ្ធទឹកតាមផ្ទះ ETV ( Environmental Technology ) ហើយនឹងអនុម័តច្បាប់សំខាន់ៗនានាសម្រាប់ការពិសោធន៍ ដ៏ចាំបាច់ស្របតាមនីតិវិធី ETV នេះ។<br>◆ កសាងសមត្ថភាពសម្រាប់ធ្វើតេស្តបច្ចេកវិទ្យាបន្សុទ្ធទឹកផ្សេងៗ ។<br>◆ ចេញលិខិតបញ្ជាក់ទៅលើផលិតផលដែលឆ្លើយតបតាមបទដ្ឋានស្តង់ដា។<br>◆ ផ្សព្វផ្សាយព័ត៌មានជាសាធារណៈអំពីលិខិតបញ្ជាក់ទៅលើផលិតផល ។ | ◆ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងពាណិជ្ជកម្ម និងក្រសួងអភិវឌ្ឍន៍ជនបទ |

| | | | |
|---|---|---|---|
| **សមាសភាគ ១.៣៖ ប្រតិបត្តិការ និងការថែទាំ** | | | |
| ១.៣.១ ការគ្រប់គ្រងដោយសហគមន៍លើការប្រតិបត្តិការ និងថែទាំ | | | |
| ១.៣.២ ប្រព័ន្ធទ្រទ្រង់ការថែទាំ | ក្រុមប្រើប្រាស់ទឹក និងអនាម័យ | ◆ បង្កើតប្រព័ន្ធទ្រទ្រង់ ការថែទាំ ដែលរួមមានការត្រួតពិនិត្យតាមដាននីវូទឹកក្រោមដី។<br>◆ បង្កើតប្រព័ន្ធទ្រទ្រង់ ការថែទាំនៅថ្នាក់ស្រុកនីមួយៗ និងរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់បុគ្គលិក ដែលបានចាត់តាំង។ | ◆ ក្រសួង អភិវឌ្ឍន៍ជនបទ<br>◆ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត |
| សមាសភាគ ១.៤៖ ទីផ្សារសម្រាប់ផលិតផលទឹកស្អាត និងអនាម័យ | | | |
| ១.៤.១ ខ្សែសង្វាក់ផ្គត់ផ្គង់ | ប្រជាពលរដ្ឋ និងសហគមន៍អាចទិញផលិតផលទឹក និងអនាម័យ នៅទីផ្សារក្នុងតំបន់របស់ពួកគេ តាមរយៈខ្សែ សង្វាក់នៃការផ្គត់ផ្គង់ | ◆ រៀបចំគម្រោងដើម្បីបង្កើតគោលគំនិត និងការអនុវត្ត ខ្សែសង្វាក់ផ្គត់ផ្គង់អណ្តូងស្នប់ និងផលិតផលផ្គត់ផ្គង់ទឹកស្អាត និងបង្គន់អនាម័យ និងអនាម័យខ្លួនប្រាណផ្សេងៗទៀត ដោយផ្អែកលើការណែនាំផ្សេងៗដែលបោះពុម្ពផ្សាយដោយកម្មវិធីទឹកស្អាត និងអនាម័យរបស់ធនាគារពិភពលោក ក៏ដូចជាគោលការណ៍ណែនាំមួយចំនួនទៀត | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ គាំទ្រដោយដៃគូអភិវឌ្ឍ |
| គោលដៅយុទ្ធសាស្ត្រទី ២៖ ការទទួលបានអនាម័យដែលមានការកែលម្អ | | | |

**សមាសភាគ ២.១៖ ការបង្កើនលទ្ធភាពទទួលបានអនាម័យ**

| | | | |
|---|---|---|---|
| | ប្រជាពលរដ្ឋតាមគ្រួសារទិញសម្ភារសាងសង់ និងប្រើប្រាស់បង្គន់អនាម័យ | ◆ កំណត់បង្កើតប្រព័ន្ធផ្សព្វផ្សាយ និងវាយតម្លៃវិធីសាស្ត្រ នានា ដូចជា សហគមន៍ដឹកនាំអនុវត្តន៍អនាម័យ ដើម្បីផ្លាស់ប្តូរទម្លាប់អនាម័យផ្ទាល់ខ្លួន។<br>◆ អនុវត្តវិធីសាស្ត្រនានាដើម្បីជំរុញឱ្យសហគមន៍ និងគ្រួសារនីមួយៗផ្លាស់ប្តូរទម្លាប់ក្នុងការឈានទៅរកការប្រើប្រាស់បង្គន់អនាម័យ<br>◆ លើកស្ទួយផលិតផលផ្នែកអនាម័យ នៅតាមទីផ្សារ នៅតាមមូលដ្ឋាន តាមរយៈដំណើរការទីផ្សារសង្គម ។<br>◆ បង្កើតឱ្យមានផលិតផល និងសេវាកម្មអនាម័យនៅ តាមស្រុក ឃុំ និងសហគមន៍ តាមរយៈការកសាង សមត្ថភាពជាងសំណង់ និងទីផ្សារក្នុងមូលដ្ឋាន។<br>◆ ទិញសម្ភារសាងសង់បង្គន់។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ តាមរយៈមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងការិយាល័យអភិវឌ្ឍន៍ជនបទស្រុក<br>◆ ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក តាមរយៈអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន<br>◆ វិស័យឯកជន<br>◆ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័ននានាដែលបណ្តុះបណ្តាលកិច្ចការ អាជីវកម្ម និងបច្ចេកទេស<br>◆ គ្រួសារ |

| | | | |
|---|---|---|---|
| ២.១.១ ជម្រើសប្រភេទបង្គន់អនាម័យផ្សេងៗ និងការអភិវឌ្ឍបច្ចេកវិទ្យា | ជម្រើសប្រភេទបង្គន់អនាម័យ ដែលមានតម្លៃសមស្រប អាចឲ្យគ្រួសារ ក្រីក្របំផុតទិញបាន | ◆ ធ្វើការសិក្សាស្រាវជ្រាវដើម្បីកំណត់នូវជម្រើសបង្គន់អនាម័យដែលមានតម្លៃថោក ( ទាំងនៅក្នុងប្រទេសកម្ពុជា និងប្រទេសផ្សេងៗទៀត ) ហើយបង្កើត និងផ្សព្វផ្សាយប្លង់គំរូបង្គន់ ដែលសមស្របសម្រាប់ប្រើប្រាស់នៅសហគមន៍។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ |
| | ជម្រើសប្រភេទបង្គន់អនាម័យ ដែលមានតម្លៃសមស្របសម្រាប់គ្រួសាររស់នៅក្នុងតំបន់លិចទឹក ( Flood-prone areas ) និងនៅតាមភូមិបណ្តែតទឹក ( Floating villages ) | ◆ ធ្វើការសិក្សាស្រាវជ្រាវដើម្បីកំណត់ប្រភេទបង្គន់ ( ទាំងនៅក្នុងប្រទេសកម្ពុជា និងប្រទេសផ្សេងៗទៀត ) ហើយបង្កើត និងធ្វើតេស្តសាកល្បង លើប្រភេទបង្គន់ដែលសមស្របសម្រាប់ភូមិលិចទឹក និងភូមិបណ្តែតទឹក ស្របទៅតាមនីតិវិធីស្រាវជ្រាវ និងអភិវឌ្ឍន៍ ក្នុងសមាសភាគ ៤.៦។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ |

| សមាសភាគ២.២ ៖ ប្រតិបត្តិការ និងការថែទាំ | | | |
|---|---|---|---|
| | អ្នកផ្តល់សេវាកម្ម ដែលមាននៅមូលដ្ឋាន អាចអនុវត្តការគ្រប់គ្រង សំណល់អាងស្តុកលាមក និងស្តារយកកាកសំណល់ចេញពីបង្គន់ប្រកបដោយ សុវត្ថិភាព ស្រប តាមនីតិវិធី ប្រតិបត្តិការ | ◆ បង្កើតនីតិវិធីសម្រាប់ការគ្រប់គ្រងកាកសំណល់នៃអាងស្តុកលាមក និងស្តារយកកាកសំណល់ចេញ។<br>◆ បង្កើតប្រព័ន្ធសម្រាប់បន្សុទ្ធ ការទុកដាក់កាកសំណល់ ឬការប្រើប្រាស់ឡើងវិញ នូវកាកសំណល់នៃអាងស្តុក លាមកពីបង្គន់។<br>◆ បង្កើតសេវាស្តារសម្អាតអាងស្តុកលាមក និងរណ្តៅបង្គន់ រួមជាមួយនឹង ការបណ្តុះបណ្តាលពីការទុកដាក់កាកសំណល់បង្គន់ប្រកបដោយសុវត្ថិភាព។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ វិស័យឯកជន ក្រោមការឧបត្ថម្ភពីមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក |

| សមាសភាគ ២.៣ ៖ អនាម័យនៅតាមសាលារៀន គ្រឹះស្ថានសុខាភិបាល និងស្ថាប័នដទៃទៀតនៅតាមទីជនបទ | | | |
|---|---|---|---|
| ២.៣.១ អនាម័យនៅតាមសាលារៀន និងការអប់រំអនាម័យផ្ទាល់ខ្លួន | សាលារៀនមានបង្គន់អនាម័យ ដែលមានការកែលំអហើយសិស្សានុសិស្ស យល់ដឹង ពីការអនុវត្តអនាម័យផ្ទាល់ ខ្លួនប្រកបដោយសុវត្ថិភាព | ◆ បង្កើតនូវបទដ្ឋានថ្នាក់ជាតិ ដែលមានការកំណត់ពីចំនួនសិស្ស និងបុគ្គលិកសម្រាប់បង្គន់នីមួយៗ និងមានការបែងចែកបន្ទប់បង្គន់សម្រាប់ក្មេងប្រុស ក្មេងស្រី បុគ្គលិក និងកុមារពិការ។<br><br>◆ រៀបចំ និងថែទាំបញ្ជីសារពើភ័ណ្ឌសំណង់ផ្គត់ផ្គង់ទឹក និងសំណង់បង្គន់អនាម័យ ដែលមានស្រាប់ក្នុងសាលា រួមបញ្ចូលទាំងស្ថានភាពធ្វើឱ្យដំណើរការបង្គន់អនាម័យ និងទឹកនៅគ្រប់សាលាទាំងអស់។<br>◆ សាងសង់បង្គន់អនាម័យសមស្របនៅតាមសាលា រៀនទាំងអស់ក្នុងតំបន់ជនបទ ដោយប្រើ វិធីសាស្ត្រឆ្លើយតបទៅតាមតម្រូវការ។<br>◆ បង្កើត និងផ្តល់នូវការអប់រំមូលដ្ឋានពីបំនិនជីវិត ដែលជាផ្នែកមួយនៃកម្មវិធីសិក្សាស្នូលស្របគ្នាជាមួយនឹងការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ។ | ◆ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងអភិវឌ្ឍន៍ជនបទ<br><br>◆ ក្រសួងអប់រំ យុវជន និងកីឡា រួមជាមួយ នឹងសាលារៀន<br><br>◆ ក្រសួងអប់រំ យុវជន និងកីឡា រួមជាមួយ សាលារៀន<br><br>◆ ក្រសួងអប់រំ យុវជន និងកីឡា រួមជាមួយ សាលារៀន |

| | | | |
|---|---|---|---|
| ២.៣.២ អនាម័យនៅតាមគ្រឹះស្ថានសុខាភិបាល និង | គ្រឹះស្ថានសុខាភិបាល និងស្ថាប័នដទៃទៀត នៅតាមទីជនបទ មានបង្គន់អនាម័យ ដែលមានការកែលំអ | ◆ បង្កើតបទដ្ឋានថ្នាក់ជាតិ ដែលមានកំណត់ពីចំនួនអ្នក ជំងឺសម្រាកក្នុងមណ្ឌលសុខភាព និងអ្នកជំងឺដែលមកពិគ្រោះជំងឺ សម្រាប់បង្គន់អនាម័យនីមួយៗ ដោយមានការបែងចែកបន្ទប់បង្គន់សម្រាប់បុរស ស្ត្រី និងជនពិការ។<br>◆ រៀបចំ និងថែរក្សាបញ្ជីសារពើភ័ណ្ឌ នៃសំណង់ផ្គត់ផ្គង់ទឹក និងបង្គន់អនាម័យដែលមានស្រាប់ ដោយរាប់បញ្ចូលទាំងស្ថានភាពដំណើរការរបស់វា នៅតាមគ្រឹះស្ថានសុខាភិបាល និងស្ថាប័នដទៃទៀត នៅទីជនបទ។<br>◆ សាងសង់បង្គន់អនាម័យនៅគ្រប់គ្រឹះស្ថានសុខាភិបាល និងស្ថាប័នដទៃទៀតនៅទីជនបទ ដោយប្រើវិធីសាស្ត្រឆ្លើយតបតាមតម្រូវការ | ◆ ក្រសួងសុខាភិបាល<br>◆ ក្រសួងសុខាភិបាលរួមជាមួយនឹងការិយា- ល័យសុខាភិបាលស្រុកប្រតិបត្តិ ឬអាជ្ញាធរពាក់ព័ន្ធ<br>◆ ក្រសួងសុខាភិបាល រួមជាមួយនឹងការិយាល័យសុខាភិបាលស្រុក ឬស្ថាប័នពាក់ព័ន្ធ |
| ២.៣.៣ អនាម័យបរិស្ថាន ទាំងកាកសំណល់រាវ និងរឹង | ផែនការ សម្រាប់អនុវត្តជាយុទ្ធសាស្ត្រ សម្រាប់ អនាម័យបរិស្ថាន ដោយផ្អែកលើតម្រូវការជាក់ស្តែង | ◆ ធ្វើការសិក្សាស្រាវជ្រាវពីប្រព័ន្ធបង្ហូរកាកសំណល់រាវ ដើម្បីវាយតម្លៃទំហំនៃបញ្ហា និងសំណើដំណោះស្រាយជាយុទ្ធសាស្ត្រ។<br>◆ ធ្វើការសិក្សាស្រាវជ្រាវពីកាកសំណល់រឹង ដើម្បីវាយតម្លៃទំហំនៃបញ្ហា និងសំណើដំណោះស្រាយជាយុទ្ធសាស្ត្រ។<br>◆ អភិវឌ្ឍ និងអនុវត្តផែនការដើម្បីដោះស្រាយការបង្ហូរ កាកសំណល់រាវ និងការទុកដាក់សំណល់រឹង។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត |

| គោលដៅយុទ្ធសាស្ត្រទី៣៖ ការផ្លាស់ប្តូរឥរិយាបថផ្នែកអនាម័យផ្ទាល់ខ្លួន | | | |
|---|---|---|---|
| **សមាសភាគ ៣.១ ៖ ការលើកកម្ពស់អនាម័យផ្ទាល់ខ្លួន** | | | |
| | ប្រជាពលរដ្ឋបានយល់ដឹង និងអនុវត្ត អនាម័យផ្ទាល់ខ្លួនប្រកបដោយសុវត្ថិភាព ពាក់ព័ន្ធនឹងការប្រើប្រាស់ទឹកស្អាត និងបង្គន់អនាម័យ | ◆ អនុម័ត និងផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីការលើកកម្ពស់អនាម័យផ្ទាល់ខ្លួនតាមដាន ត្រួតពិនិត្យការអនុវត្ត និងវាយតម្លៃប្រសិទ្ធភាពនៃការផ្លាស់ប្តូរទម្លាប់ក្នុងការប្រតិបត្តិអនាម័យល្អ។<br>◆ ពិនិត្យមើលឡើងវិញ និងកែសម្រួលគោលការណ៍ណែនាំ ស្តីពីការលើកកម្ពស់អនាម័យផ្ទាល់ខ្លួន បន្ទាប់ពីការវាយ តម្លៃប្រសិទ្ធភាពនៃការអនុត្តគោលការណ៍ណែនាំនេះ។ធ្វើការអង្កេតទិន្នន័យមូលដ្ឋាន និងតាមដានការអនុវត្តអនាម័យ ហើយរាយការណ៍លទ្ធផលទៅឱ្យ ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ។<br>◆ ធ្វើយុទ្ធនាការផ្សព្វផ្សាយពីការផ្លាស់ប្តូរឥរិយាបថអនាម័យផ្ទាល់ខ្លួន នៅតាមសហគមន៍ និងតាមផ្ទះ។<br>◆ ធ្វើការអប់រំបណ្តុះបណ្តាលជាទៀងទាត់ និងវគ្គបំប៉នស្តីពីការផ្លាស់ប្តូរឥរិយាបថអនាម័យផ្ទាល់ខ្លួន | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសុខាភិបាល<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសុខាភិបាល<br>◆ ស្ថាប័នលើកកម្ពស់ការផ្លាស់ប្តូរទម្លាប់ អនាម័យ<br>◆ ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក តាមរយៈគណៈកម្មការទទួលបន្ទុកស្ត្រី និងកុមារឃុំ និងស្ថាប័នលើកកម្ពស់ការផ្លាស់ប្តូរទម្លាប់អនាម័យ<br>◆ គណៈកម្មការ ទទួលបន្ទុកស្ត្រី និងកុមារឃុំ រួមជាមួយនឹង មន្ត្រីលើកកម្ពស់អនាម័យ នៃការិយាល័យអភិវឌ្ឍន៍ជនបទស្រុក |

| | | | |
|---|---|---|---|
| គោលដៅយុទ្ធសាស្ត្រទី៤ ៖ ការអភិវឌ្ឍ និងការប្រតិបត្តិលើមធ្យោបាយនានា ដើម្បីសម្រេចឱ្យបានសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទប្រកបដោយនិរន្តរភាព | | | |
| **សមាសភាគ៤.១ ៖ ការគ្រប់គ្រងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ** | | | |
| | វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ជនបទ ត្រូវបានរៀបចំឲ្យបានសមស្រប និងដំណើរការប្រកប ដោយប្រសិទ្ធភាព ដើម្បីឱ្យដំណើរ ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងទស្សនវិស័យរបស់គោលនយោបាយជាតិ ស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ | ◆ សម្របសម្រួល និងគ្រប់គ្រងសកម្មភាពនានានៃការផ្លាស់ប្តូរស្ថាប័ន ក្នុងយុទ្ធសាស្ត្រនេះ រួមជាមួយនឹងផែនការសកម្មភាព ០៥ ឆ្នាំ។<br>◆ តាមដានត្រួតពិនិត្យការរីកចម្រើនសកម្មភាព និងសមិទ្ធផលរបស់យុទ្ធសាស្ត្រ ស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹក ស្អាត និងអនាម័យជនបទ |
| **៤.១.១ ការរៀបចំអង្គភាពស្ថាប័ន និងការកែសម្រួលរចនាសម្ព័ន្ធ ក្រោមប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ** | ការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ និងការលើកកម្ពស់អនាម័យផ្ទាល់ខ្លួន ត្រូវបានសម្របសម្រួល គ្រប់គ្រង និងតាមដានយ៉ាងមានប្រសិទ្ធភាពនៅថ្នាក់ស្រុក | ◆ ពង្រឹងការិយាល័យអភិវឌ្ឍន៍ជនបទស្រុកតាមស្រុកនីមួយៗ ដោយមានការគាំទ្រពីមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្ត។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ រួមជាមួយមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត |

| | | | |
|---|---|---|---|
| **៤.១.២.តួនាទី និងការទទួលខុសត្រូវក្រោមប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ** | តួនាទីរបស់ស្ថាប័នក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទត្រូវបានកំណត់ច្បាស់លាស់ | ដាក់ឱ្យប្រើប្រាស់សេចក្តីប្រកាស ដែលកំណត់ពីតួនាទីរបស់ស្ថាប័នពាក់ព័ន្ធក្នុងវិស័យនេះ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ |
| **៤.១.៣. អភិបាលកិច្ច និងគណនេយ្យភាព** | មានយន្តការគណនេយ្យភាពប្រកបដោយប្រសិទ្ធភាពសម្រាប់ការអនុវត្តនៅថ្នាក់មូលដ្ឋាន | ◆ បង្កើតនីតិវិធីដើម្បីធ្វើឱ្យអាជ្ញាធរមូលដ្ឋាន មានគណនេយ្យភាពចំពោះសហគមន៍ ក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត អនាម័យ និងអនាម័យផ្ទាល់ខ្លួន រួមទាំងការប្រើប្រាស់យន្តការសហគមន៍ ដើម្បីតាមដាន និងត្រួតពិនិត្យនៃការផ្តល់សេវាកម្ម។<br>◆ បង្កើតគោលការណ៍ណែនាំ សម្រាប់រដ្ឋបាលមូលដ្ឋាន (អ្នកផ្តល់សេវា និងស្ថាប័នគាំទ្រ) ពីរបៀបក្នុងការធានាឲ្យបាននូវគណនេយ្យភាព ចំពោះអ្នកខាងលើ និងអ្នកខាងក្រោម។<br>◆ បង្កើតឲ្យមានប្រព័ន្ធមួយសម្រាប់ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ដើម្បីស្វែងរកព័ត៌មាន ទទួលព័ត៌មាន និងមតិត្រឡប់ (ឧទាហរណ៍ ការត្អូញត្អែរ) ដែលទទួលបានពីសហគមន៍ គ្រួសារ និងក្រុមប្រឹក្សាឃុំ រួមទាំងប្រព័ន្ធតាមដានប្រៀបធៀបការអនុវត្តរវាងថ្នាក់ស្រុក និងសហគមន៍នីមួយៗ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ |

| | | | |
|---|---|---|---|
| **៤.១.៤. គោលការណ៍ណែនាំ និងនីតិវិធី** | ការផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធភាពជាមួយនិងបទដ្ឋានស្តង់ដាផ្សេងៗ ដើម្បីឲ្យមានគណនេយ្យភាព | ◆ ពិនិត្យឡើងវិញគោលការណ៍ណែនាំ និងនីតិវិធីផ្សេងៗ ដែលមានស្រាប់ ហើយកែសម្រួល បើចាំបាច់។<br>◆ បង្កើតគោលការណ៍ណែនាំ និងនីតិវិធីថ្មីៗ តាមតម្រូវការក្នុងផ្នែកផ្សេងៗនៃយុទ្ធសាស្ត្រនេះ ។<br>◆ ចងក្រងឯកសារគោលការណ៍ណែនាំ និងផ្សព្វផ្សាយទៅឲ្យស្ថាប័នថ្នាក់ជាតិ អាជ្ញាធរមូលដ្ឋាន អ្នកផ្តល់សេវាកម្ម ក្រុមប្រឹក្សាស្រុក និងឃុំ ព្រមទាំងសហគមន៍ អ្នកប្រើប្រាស់ ។<br>◆ តាមដានត្រួតពិនិត្យការប្រើប្រាស់ និងប្រសិទ្ធភាព នៃគោលការណ៍ណែនាំ និងការកែសម្រួល ប្រសិនបើចាំបាច់។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយនឹងដៃគូ វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយនឹងដៃគូ វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត រាយការណ៍ទៅ ក្រសួងអភិវឌ្ឍន៍ជនបទ |

| សមាសភាគ៤.២ ៖ ការអភិវឌ្ឍធនធានមនុស្ស និងសមត្ថភាព | | | |
|---|---|---|---|
| **៤.២.១. ថ្នាក់ជាតិ** និងរដ្ឋបាលថ្នាក់ក្រោមជាតិ | សមត្ថភាពសម្រាប់សម្របសម្រួល និងធ្វើឱ្យមាននិរន្តរភាពនៃការផ្តល់សេវាកម្មនៅថ្នាក់ក្រោមជាតិ ដែលគាំទ្រដោយថ្នាក់ជាតិ | ◆ ពង្រឹងសមត្ថភាពមន្ត្រីការិយាល័យអភិវឌ្ឍន៍ជនបទស្រុក។<br>◆ រៀបចំផែនការលម្អិតសម្រាប់អភិវឌ្ឍន៍សមត្ថភាពដើម្បីកំណត់៖<br>បទពិសោធន៍ និងជំនាញ សម្រាប់កិច្ចការចាំបាច់ នៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ។<br>សមត្ថភាព និងចំនួនបុគ្គលិកដែលមានស្រាប់។<br>ការបណ្តុះបណ្តាលបន្ថែមដល់បុគ្គលិក ដែលត្រូវបំពេញតួនាទី។<br>ថវិកាសម្រាប់ការអនុវត្តផែនការ។<br>◆ សម្របសម្រួលការធ្វើផែនការអភិវឌ្ឍសមត្ថភាពជាមួយនឹងវិស័យដទៃៗទៀត និងដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីធានាថា ការអភិវឌ្ឍសមត្ថភាពទាំងអស់នោះ អាចធ្វើទៅបាន ។<br>◆ អនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពដែលបានបង្កើតរួច។<br>◆ បង្កើតវគ្គបណ្តុះបណ្តាលរយៈពេលខ្លី សម្រាប់មន្ត្រីថ្នាក់ក្រោមជាតិ និងបុគ្គលិកពីស្ថាប័នពាក់ព័ន្ធនានា។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br><br><br><br><br><br><br><br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br><br><br><br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ និងស្ថាប័នផ្តល់វគ្គបណ្តុះបណ្តាល<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ |

| សមាសភាគ ៤.៣ ៖ ការអភិវឌ្ឍវិស័យឯកជន | | | |
|---|---|---|---|
| **៤.៣.១.** ការបង្កើតបរិយាកាសប្រកួតប្រជែង | កិច្ចសន្យាផ្ដល់សេវាកម្ម□សម្រាប់សហគ្រាសធុនតូច និងមធ្យម ដែលពាក់ព័ន្ធនឹងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនា ម័យជនបទ ត្រូវបានធ្វើឡើងដោយក្នុង បរិយាកាសប្រកួតប្រជែងប្រកបដោយការទទួលខុសត្រូវខ្ពស់ | ◆ បង្កើតនីតិវិធីបន្ថែមចំនួនបី ដើម្បីធានាឲ្យមានការគោរពកិច្ចសន្យា និងនីតិវិធីលទ្ធកម្ម ៖<br>- ធ្វើឲ្យក្រុមប្រើប្រាស់ទឹក និងអនាម័យមានតួនាទីក្នុងកិច្ចសន្យា ដូច្នេះ កិច្ចសន្យានេះគឺធ្វើឡើងរវាងអាជ្ញាធរមានសមត្ថកិច្ច រួមគ្នាជាមួយនឹងក្រុមប្រើប្រាស់ទឹក និងអនាម័យជាភាគីម្ខាងជាមួយនឹងភាគីម្ខាងទៀត ដែលជាក្រុមហ៊ុនឯកជន ។<br>- យោងទៅតាមដំណើរការដេញថ្លៃ ត្រូវផ្សព្វផ្សាយទៅឲ្យសហគមន៍អ្នកប្រើប្រាស់ អំពីការដេញថ្លៃរើសយកអ្នកម៉ៅការដែលមានតម្លៃទាបជាងគេបំផុត ចំនួនបីនាក់រួមទាំងការប៉ាន់ស្មានតម្លៃ ដោយអាជ្ញាធរមានសមត្ថកិច្ច (រួមទាំងរបៀបនៃការប៉ាន់ស្មានដែលផ្ដោតលើគោលការណ៍ថ្លៃពលកម្ម គ្រឿងចក្រ និងសម្ភារៈ)។<br>- ពេលកិច្ចសន្យានៃការសាងសង់ត្រូវបានបញ្ចប់ ត្រូវធ្វើការផ្សព្វផ្សាយព័ត៌មានផ្លូវការជាសាធារណៈ អំពីគណនីរបស់គម្រោងដល់សហគមន៍ ដោយភ្ជាប់ជាមួយនឹងពត័មានលម្អិតពីថវិកាក្នុងគម្រោង ដែលបានចំណាយក្នុងការអនុវត្តផែនការអភិវឌ្ឍសមត្ថភាព។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ |

| | | | |
|---|---|---|---|
| | | ◆ រៀបចំ និងចងក្រងផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពីការទទួលខុសត្រូវ គណនេយ្យភាព ការព្យាករណ៍ និងតម្លាភាព សម្រាប់វិស័យឯកជន។<br>◆ ផ្សព្វផ្សាយគោលការណ៍ណែនាំនេះ ទៅការិយាល័យរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ដែលពាក់ព័ន្ធនឹងវិស័យនេះ និង ក្រុមប្រឹក្សាឃុំ-សង្កាត់ ។<br>◆ ផ្សព្វផ្សាយគោលការណ៍ណែនាំខាងលើ ទៅសហគ្រាសធុនតូច និងមធ្យមទាំងអស់ ដែលមានចំណាប់អារម្មណ៍ក្នុងការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ការិយាល័យ អភិវឌ្ឍន៍ជនបទស្រុក |
| | វិស័យឯកជន មានការជឿជាក់ក្នុងការវិនិយោគលើប្រតិបត្តិការ ផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទរយៈពេលវែង | ◆ កិច្ចសន្យាសម្រាប់អ្នកផ្តល់សេវាកម្ម រួមមានការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ដែលមានរយៈពេលយ៉ាងហោចណាស់ ១០ ឆ្នាំ ដើម្បីឲ្យអ្នកម៉ៅការអាចពង្រីកទុនវិនិយោគ ហើយអាចទទួលបានចំណូលពីការវិនិយោគនោះមកវិញ។ កិច្ចសន្យានេះ រួមមានបទប្បញ្ញត្តិផ្លូវច្បាប់ សម្រាប់ការបញ្ចប់កិច្ចសន្យាមុនពេលកំណត់ ក្នុងករណីដែលការផ្តល់សេវាកម្មមិនបានល្អ ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ |

| | | | |
|---|---|---|---|
| **៤.៣..២** លទ្ធភាពទទួលបានទុនសម្រាប់ការវិនិយោគ និងប្រាក់កម្ចី | មានការផ្តល់ប្រាក់កម្ចីទ្រទ្រង់ទ្រាយតូច ដល់អាជីវកម្មធុនតូច និងមធ្យមនៅជនបទ សម្រាប់ការផ្តល់សេវាកម្ម និងផលិតផល នៃការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ | ◆ កំណត់រក និងរក្សាឲ្យមានធនធានជាមូលធន សម្រាប់ការវិនិយោគ តាមរយៈស្ថាប័នមីក្រូហិរញ្ញវត្ថុ។ | ◆ ស្ថាប័នមីក្រូហិរញ្ញវត្ថុ |
| **៤.៣.៣.** ការអភិវឌ្ឍជំនាញអាជីវកម្ម និងបច្ចេកទេស | អាជីវកម្មធុនតូច និងមធ្យម ដែលបម្រើសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ មានសមត្ថភាពជាមូលដ្ឋានលើការគ្រប់គ្រងអាជីវកម្ម និងការគ្រប់គ្រងហិរញ្ញវត្ថុ | ◆ កំណត់រកស្ថាប័នបណ្តុះបណ្តាលសមស្រប និងបង្កើតកម្មវិធីបណ្តុះបណ្តាល។<br>◆ ផ្តល់វគ្គបណ្តុះបណ្តាលដល់សហគ្រាសខ្នាតតូច និងមធ្យម នៅថ្នាក់មូលដ្ឋាន។<br>◆ ផ្តល់ការណែនាំលើការតាមដាន ត្រួតពិនិត្យ និងគាំទ្រដល់អាជីវកម្មខ្នាតតូច។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័ន និងសាកលវិទ្យាល័យ ដែលផ្តល់វគ្គបណ្តុះ បណ្តាលអាជីវកម្ម<br>◆ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័ន និងសាកលវិទ្យាល័យដែលផ្តល់វគ្គបណ្តុះ បណ្តាលអាជីវកម្ម |

| | | | |
|---|---|---|---|
| **សមាសភាគ៤.៤ ៖ ការធ្វើផែនការ និង ប្រព័ន្ធគ្រប់គ្រងព័ត៌មាន** | | | |
| | ប្រព័ន្ធគ្រប់គ្រងព័ត៌មានរួមមួយត្រូវបានប្រើប្រាស់ សម្រាប់ធ្វើផែនការ និងគ្រប់គ្រងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ប្រកបដោយប្រសិទ្ធភាព | ◆ ធ្វើកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងព័ត៌មានបច្ចុប្បន្ន ជាមួយនឹងទិន្នន័យផ្សេងៗសម្រាប់បង្កើតឲ្យមានប្រព័ន្ធគ្រប់គ្រងព័ត៌មានរួមមួយ ។<br>◆ ធ្វើឲ្យប្រព័ន្ធគ្រប់គ្រងព័ត៌មានអាចប្រើបានដោយអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងវិស័យនេះ និងដាក់វាទៅក្នុងគេហទំព័រ និងតាមរយៈមធ្យោបាយផ្សេងៗសម្រាប់ប្រាស្រ័យទាក់ទងដល់អ្នកពាក់ព័ន្ធ ដែលគ្មានលទ្ធភាពប្រើប្រាស់អ៊ីនធឺណែត។<br>◆ ធានាថា ទិន្នន័យទាំងអស់អំពីហេដ្ឋារចនាសម្ព័ន្ធ ស្ថាប័ន និងកត្តាសង្គម ត្រូវបានប្រមូល ហើយចែកចេញជាផ្នែកស្ត្រី បុរស កុមារ ជនពិការ និងជនជាតិភាគតិច ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងការិយាល័យអភិវឌ្ឍន៍ជនបទស្រុក |
| **សមាសភាគ៤.៥ ៖ ការវាយតម្លៃ និងការរៀនសូត្រ** | | | |
| | ប្រព័ន្ធចែករំលែក ចំណេះដឹង និងបទពិសោធន៍ដ៏មានប្រសិទ្ធភាពពីបុគ្គលនីមួយៗ និងក្រុមនានា ដែលធ្វើការលើទិដ្ឋភាពផ្សេងៗគ្នា សម្រាប់ភាគីពាក់ព័ន្ធ នៃវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ | ◆ បង្កើតប្រព័ន្ធចែករំលែកលទ្ធផលនៃការវាយតម្លៃ ក្រោមការគ្រប់គ្រងរបស់ក្រុមការងារសម្របសម្រួលវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។<br>◆ ធ្វើការវាយតម្លៃ និងផ្សព្វផ្សាយនូវលទ្ធផលឲ្យបានទូលំទូលាយក្នុងវិស័យផ្គត់ផ្គង់ទឹក និងអនាម័យ និងការសិក្សាលើទិដ្ឋភាពជាក់លាក់ និងវិធីសាស្ត្រមួយចំនួនក្នុងវិស័យនេះ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ |

| | | | |
|---|---|---|---|
| **សមាសភាគ៤.៦ ៖ ការស្រាវជ្រាវ ការអភិវឌ្ឍ និងការច្នៃប្រឌិត** | | | |
| | នីតិវិធីដ៏ល្អិតល្អន់មួយ ត្រូវបានអនុវត្ត សម្រាប់ការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍ និងការច្នៃប្រឌិត ខាងបច្ចេកវិទ្យាថ្មី ហើយ និងវិធីសាស្ត្រផ្នែកទន់ | ◆ បង្កើតនីតិវិធីជាលក្ខណៈប្រព័ន្ធ សម្រាប់អនុវត្តការធ្វើពិសោធន៍ ការអនុម័ត និងផ្សព្វផ្សាយអំពីវិធីសាស្ត្រ និងលទ្ធផលអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗ។<br>◆ បង្កើតគណៈកម្មាធិការសម្រាប់ណែនាំ និងអនុម័តក្នុងការងារនេះ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ |
| **សមាសភាគ៤.៧ ៖ ទំនាក់ទំនង** | | | |
| | ទំនាក់ទំនងប្រកបដោយប្រសិទ្ធភាពទាំងក្នុង និងក្រៅវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ | ◆ បង្កើត និងអនុវត្តយុទ្ធសាស្ត្រទំនាក់ទំនង ដើម្បីដោះស្រាយបញ្ហាផ្សេងៗ រួមមាន៖<br>- លើកកម្ពស់មុខមាត់របស់វិស័យនេះនៅក្នុងឆាកនយោបាយ តាមរយៈការផ្សព្វផ្សាយពីឥទ្ធិពលរបស់វិស័យនេះ ទៅលើទិដ្ឋភាពនយោបាយជាអាទិភាពនានា ដូចជាការអភិវឌ្ឍសុខភាព និងសេដ្ឋកិច្ច។<br>- ធ្វើឲ្យវិស័យនេះមានការទាក់ទាញចំពោះសារព័ត៌មាន។<br>- ផ្សព្វផ្សាយយុទ្ធសាស្ត្ររបស់វិស័យនេះ ទាំងនៅក្នុង និងក្រៅវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ជនបទ។<br>- បង្កើតយន្តការទំនាក់ទំនងអន្តរក្រសួង។<br>- កំណត់ទិន្នន័យសំខាន់ៗ - និងព័ត៌មានដែលចាំបាច់។<br>- បង្កើតបណ្តាញ និងយន្តការទំនាក់ទំនងផ្ទៃក្នុង។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ និងដៃគូអភិវឌ្ឍន៍ |

| សមាសភាគ៤.៨ ៖ ភាពក្រីក្រ ជនជាតិភាគតិច ភាពងាយរងគ្រោះ | | | |
|---|---|---|---|
| **៤.៨.១. ភាពក្រីក្រ** | គ្រួសារក្រីក្របំផុត និងគ្រួសារងាយរងគ្រោះបំផុត ត្រូវបានផ្តល់អាទិភាពសម្រាប់ការទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ | ◆ ផ្តល់អាទិភាពដល់តំបន់ក្រីក្របំផុត និងតំបន់ដែលពុំធ្លាប់មានការគាំទ្រ ដើម្បីផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។<br>◆ កំណត់រកស្រុក និងឃុំក្រីក្របំផុតនៅក្នុងខេត្ត និងគ្រួសារក្រីក្របំផុតនៅក្នុងភូមិ ដោយយោងតាមបញ្ជីកំណត់គ្រួសារក្រីក្រ ដែលត្រូវបានបង្កើតឡើង និងរក្សាដោយមន្ទីរផែនការខេត្ត។ | ◆ ស្ថាប័នអភិវឌ្ឍន៍សេវាកម្ម<br>◆ ស្ថាប័នអភិវឌ្ឍន៍សេវាកម្ម |
| **៤.៨.២. ពិការភាព** | សេចក្តីត្រូវការនិងក្តីបារម្ភរបស់ជនពិការ ត្រូវបានដោះស្រាយជាអាទិភាព ក្នុងការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ និងលើកកម្ពស់ការផ្លាស់ប្តូរឥរិយាបថអនាម័យផ្ទាល់ខ្លួន | ◆ ការបង្កើត និងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ត្រូវគោរពតាមច្បាប់ស្តីពីកិច្ចគាំពារ និងការលើកកម្ពស់សិទ្ធជនពិការ (ឆ្នាំ២០០៩)។<br>◆ គម្រោង និងកម្មវិធីទឹកស្អាត និងអនាម័យជនបទ ទាំងអស់នឹងត្រូវពិចារណាលើសេចក្តីត្រូវការរបស់ជនពិការ នៅគ្រប់ដំណាក់កាលនៃការរៀបចំ និងអនុវត្តគម្រោង និងកម្មវិធី។<br>◆ អង្គការជនពិការ នឹងត្រូវបានបញ្ចូល ឬធ្វើជាតំណាងនៅក្នុងដំណើរការពិគ្រោះយោបល់គណៈកម្មការ ឬក្រុមប្រឹក្សាផ្តល់យោបល់ ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រុមប្រឹក្សាសកម្មភាពជនពិការ ដៃគូអភិវឌ្ឍន៍ និងអ្នកផ្តល់សេវាទាំងអស់<br>◆ អ្នកផ្តល់សេវាទាំងអស់<br>◆ ក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ ក្រសួងអភិវឌ្ឍន៍ជនបទ គណៈកម្មាធិការ និងក្រុមប្រឹក្សាផ្សេងៗទៀត |

## សមាសភាគ ៤.៩ ៖ ការបញ្ជ្រាបយេនឌ័រ

| | | | |
|---|---|---|---|
| | យេនឌ័រ ត្រូវបានបញ្ជ្រាបទៅក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ | ◆ ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពបញ្ជ្រាបយេនឌ័រ។<br>◆ ពិនិត្យឡើងវិញរាល់គោលការណ៍ណែនាំ និងនីតិវិធីដែលមានស្រាប់ និងត្រូវបង្កើតនៅពេលខាងមុខរបស់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ដើម្បីធានាថាគោលការណ៍ណែនាំ និងនីតិវិធីទាំងនេះបានបញ្ជាក់និងណែនាំអំពីបញ្ហាយេនឌ័របានគ្រប់គ្រាន់។<br>◆ បង្កើតវគ្គតំរង់ទិសអំពីយេនឌ័រ សម្រាប់មន្ត្រីរដ្ឋាភិបាល ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងអ្នកផ្តល់សេវាកម្ម ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។<br>◆ រៀបចំវគ្គតំរង់ទិសអំពីយេនឌ័រ សម្រាប់ភាគីពាក់ព័ន្ធទាំងឡាយ។ | ◆ ក្រុមការងារបញ្ជ្រាបយេនឌ័រ នៃក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយក្រសួងកិច្ចការនារី<br>◆ ក្រុមការងារបញ្ជ្រាបយេនឌ័រ នៃក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយក្រសួងកិច្ចការនារី<br>◆ ក្រុមការងារបញ្ជ្រាបយេនឌ័រ នៃក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយអង្គការផ្តល់ការ បណ្តុះបណ្តាល<br>◆ អង្គការផ្តល់ការបណ្តុះបណ្តាល |

| សមាសភាគ ៤.១០ ៖ បរិស្ថាន | | | |
|---|---|---|---|
| | ផលប៉ះពាល់បរិស្ថានបណ្តាលមកពីសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ត្រូវបានយល់ដឹងនៅគ្រប់លំដាប់ថ្នាក់ទាំងអស់ ហើយផលប៉ះពាល់ទាំងនេះ នឹងត្រូវបានកាត់បន្ថយនៅក្នុងដំណើរការអភិវឌ្ឍ និងផ្តល់សេវាកម្ម | ◆ ធ្វើការសិក្សាពីកម្រិតយល់ដឹង និងទំនាក់ទំនងរវាងសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ និងផលប៉ះពាល់បរិស្ថាន រួមទាំងការគ្រប់គ្រងធនធានទឹកចំរុះ និងផលប៉ះពាល់ដល់សុខភាព។<br>◆ កសាងគោលការណ៍ណែនាំ និងនីតិវិធី ដើម្បីដោះស្រាយផលប៉ះពាល់បរិស្ថាន រួមទាំងច្បាប់ដែលពាក់ព័ន្ធក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ |

| សមាសភាគ ៤.១១ ៖ ការគ្រប់គ្រង និងកាត់បន្ថយហានិភ័យ គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ | | | |
|---|---|---|---|
| | សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទត្រូវបានអភិវឌ្ឍ ដោយកាត់បន្ថយផលប៉ះពាល់ គ្រោះមហន្តរាយ និងហានិភ័យនៃការប្រែប្រួលអាកាសធាតុ | ◆ សម្របសម្រួលជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នូវវិធានការត្រៀមបង្ការ និងគ្រប់គ្រងគ្រោះមហន្តរាយ។<br>◆ កែសម្រួលលក្ខណៈបច្ចេកទេស សម្រាប់សំណង់ផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្នុងតំបន់ងាយរងគ្រោះដោយទឹកជំនន់។<br>◆ រៀបចំផែនទីចង្អុលបង្ហាញពីតំបន់ងាយរងគ្រោះដោយទឹកជំនន់ រាំងស្ងួត និងបង្កើតវិធានការកាត់បន្ថយផលប៉ះពាល់។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |

| គោលដៅយុទ្ធសាស្ត្រទី៥ ៖ ហិរញ្ញប្បទានសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ | | | |
|---|---|---|---|
| **សមាសភាគ៥.១ ៖ ហិរញ្ញប្បទាននៃចំណាយទុនដើម** | | | |
| **៥.១.១.** ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ និងផ្នែកទន់ | ធ្វើឲ្យមានមូលនិធិហិរញ្ញវត្ថុចាំបាច់ សម្រាប់ផ្តល់ហេដ្ឋារចនាសម្ព័ន្ធថ្មី និងការជួសជុលហេដ្ឋារចនាសម្ព័ន្ធ ដែលមានស្រាប់ នៃសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ | ◆ រៀបចំផែនការវិនិយោគវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។<br>តស៊ូមតិឲ្យមានការបង្កើននូវមូលនិធិគាំទ្រពីរាជរដ្ឋា<br>- ភិបាល ដោយបង្ហាញពីផលចំណេញសេដ្ឋកិច្ច និងសង្គមកិច្ច ដែលបានមកពីការវិនិយោគលើសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។<br>◆ ពិនិត្យឡើងវិញលើសមាមាត្រនៃការចូលរួមបដិភាគពីសហគមន៍ក្នុងខេត្ត និងស្រុកនីមួយៗ ៖<br>- បង្កើតនីតិវិធី និងលក្ខណៈវិនិច្ឆ័យ សម្រាប់កំណត់អត្រាចូលរួមបដិភាគរបស់សហគមន៍។<br>- កំណត់អត្រាចូលរួមបដិភាគនៅតាមមូលដ្ឋាន ដោយអនុលោមតាមនីតិវិធីដែលបានបង្កើតឡើង។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទជាមួយនឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍<br>ក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយនឹងក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ<br><br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរមូលដ្ឋាន |

| | | | |
|---|---|---|---|
| **៥.១.២.** យន្តការផ្តល់ហិរញ្ញប្បទានផ្នែកអនាម័យ | ការផ្តល់ហិរញ្ញប្បទានផ្នែកអនាម័យ នឹងអនុវត្តយន្តការដែលមានការសាកល្បងត្រឹមត្រូវហើយបង្ហាញថាមានប្រសិទ្ធភាពខ្ពស់ក្នុងការទទួលបានសេវា អនាម័យប្រកបដោយនិរន្តរភាព ដើម្បីការពារសុខភាព និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន | ◆ បង្កើតក្រុមការងារដើម្បីដឹកនាំ និងណែនាំការបង្កើតជម្រើសយន្តការនានាសម្រាប់ការធ្វើហិរញ្ញប្បទានផ្នែកអនាម័យ ដោយប្រើនីតិវិធីក្នុងសមាសភាគទី៦ ៖ ការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍ និងការច្នៃប្រឌិត។<br>◆ បង្កើតឲ្យមានការសាកល្បងដកពិសោធន៍យន្តការផ្តល់ហិរញ្ញប្បទាន។<br>◆ តាមដានត្រួតពិនិត្យប្រសិទ្ធភាពនៃយន្តការនោះ ដោយពិនិត្យទៅលើការដែលបានរាប់បញ្ចូល ឬមិនបានរាប់បញ្ចូលក្រុមគោលដៅដែលត្រូវទទួលបានហិរញ្ញប្បទាននិងការទទួលយកឥរិយាបថអនុវត្តអនាម័យល្អ។<br>◆ ធ្វើការវាយតម្លៃប្រៀបធៀបយន្តការផ្តល់ហិរញ្ញប្បទានទាំងឡាយបន្ទាប់ពីដាក់ឲ្យអនុវត្តមួយរយៈកន្លងមក។<br>◆ បង្កើតឲ្យមានគោលការណ៍ណែនាំ ស្តីពីយន្តការប្រកបដោយប្រសិទ្ធភាពសមស្របសម្រាប់ក្រុមគោលដៅ ផ្សេងៗ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍<br>◆ ដៃគូអភិវឌ្ឍន៍ អាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយនឹងក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងដៃគូអភិវឌ្ឍន៍ |

| | | | |
|---|---|---|---|
| **៥.១.៣.** ការអភិវឌ្ឍសមត្ថភាព | មានមូលនិធិ សម្រាប់អភិវឌ្ឍសមត្ថភាព ស្ថាប័ន និងវិស័យឯកជន នៅលើការគ្រប់គ្រង និងផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ព្រមទាំងការលើកកម្ពស់អនាម័យផ្ទាល់ខ្លួន | ◆ ប៉ាន់ស្មានថវិកាចំណាយលើផែនការអភិវឌ្ឍន៍សមត្ថភាព<br>◆ ប៉ាន់ស្មានថវិកាចំណាយលើការអភិវឌ្ឍវិស័យឯកជន។<br>◆ តស៊ូមតិឲ្យមានការបង្កើននូវមូលនិធិគាំទ្រពីរដ្ឋាភិបាល ដោយបង្ហាញពីផលចំណេញសេដ្ឋកិច្ច និងសង្គមកិច្ច ដែលបានមកពីការវិនិយោគលើសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។<br>◆ ស្វែងរកដៃគូអភិវឌ្ឍន៍ ដើម្បីចូលរួម និងផ្តល់មូលនិធិ គាំទ្រផែនការអភិវឌ្ឍន៍សមត្ថភាព និងអភិវឌ្ឍន៍វិស័យឯកជន។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ<br><br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |

## សមាសភាគ ៥.២ ៖ ហិរញ្ញប្បទានលើចំណាយចរន្ត

| | | | |
|---|---|---|---|
| | មានថវិកាចំណាយចរន្ត សម្រាប់និរន្តរ-ភាពនៃសេវាផ្គត់ផ្គង់ទឹកស្អាត និងអនា-ម័យជនបទ | ◆ ចំណាយសម្រាប់ប្រតិបត្តិការលើសេវាផ្គត់ផ្គង់ទឹកស្អាត រួមទាំងការទូទាត់ថ្លៃចំណាយលើបុគ្គលិក ឬអ្នកម៉ៅការ ចំណាយលើការជួសជុល និងការថែទាំ ព្រមទាំងគ្រឿងបន្លាស់ និងការចូលរួមបដិភាគដល់ប្រព័ន្ធទ្រទ្រង់ការថែទាំ ។<br>◆ បង្កើត និងគ្រប់គ្រងមូលនិធិថែទាំ តាមរយៈការចូលរួមបដិភាគជាប្រចាំពីគ្រួសារអ្នកប្រើប្រាស់។<br>◆ ក្រុមគ្រួសារនីមួយៗនឹងបង់ថ្លៃចំណាយលើការប្រើប្រាស់ និងថែទាំបង្គន់អនាម័យរបស់ពួកគេផ្ទាល់ រួមមានការគ្រប់គ្រងកាកសំណល់លាមក និងការស្តារយកកាកសំណល់ទាំងនោះចេញ ។<br>◆ រៀបចំថវិកា និងបែងចែក ព្រមទាំងផ្តល់មូលនិធិសម្រាប់ចំណាយចរន្តលើការសម្របសម្រួល និងត្រួត - ពិនិត្យការផ្តល់សេវាកម្ម ដោយអនុលោមតាមវដ្តនៃការគ្រប់គ្រងហិរញ្ញវត្ថុនាពេលបច្ចុប្បន្ន និងអនាគត។ | ◆ អ្នកប្រើប្រាស់តាមផ្ទះ តាមរយៈក្រុមប្រើប្រាស់ទឹក និងអនាម័យ<br>◆ ក្រុមប្រើប្រាស់ទឹក និងអនាម័យ<br>◆ អ្នកប្រើប្រាស់តាមផ្ទះ<br>◆ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រព័ន្ធហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ |

# ៨. សមាសភាគយុទ្ធសាស្ត្រ

សមាសភាគជាច្រើន នៅក្នុងគោលដៅយុទ្ធសាស្ត្រទី១ ទី២ និងទី៣ តម្រូវឲ្យមានគោលការណ៍ណែនាំ និងនីតិវិធីសម្រាប់អនុវត្ត ។ គោលដៅយុទ្ធសាស្ត្រទី៤ បានចែងពីសមាសភាគមួយសម្រាប់ការរៀបចំគោលការណ៍ណែនាំ និងនីតិវិធីសម្រាប់អនុវត្តទាំងនោះ ។

## គោលដៅយុទ្ធសាស្ត្រទី ១ ៖ ការទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត ដែលមានការកែលំអប្រកបដោយនិរន្តរភាព

ដំណាក់កាលចម្បង សម្រាប់ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត មានបីគឺ ៖

- **ការអភិវឌ្ឍ និងការរៀបចំផែនការ** រួមបញ្ចូលទាំងការបង្កើតតម្រូវការតាមរយៈការផ្សព្វផ្សាយសំណើពីសហគមន៍ចំពោះការផ្តល់មូលនិធិ ការរៀបចំគម្រោងស្នើសុំការវាយតម្លៃ និងការចាត់អាទិភាព ព្រមទាំងការបញ្ជូនសំណើសុំមូលនិធិ។
- **ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ** រួមបញ្ចូលទាំងការរៀបចំ និងចលនាសហគមន៍ ការពន្យល់ពីជម្រើសបច្ចេកទេសនានា ដែលអាចទទួលយកបានការសម្រេចចិត្តលើជម្រើសបច្ចេកទេសដែលពេញចិត្ត ការព្រមព្រៀង ការបង្កើតក្រុមប្រើប្រាស់ទឹក និងអនាម័យការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងនិងថែទាំដោយសហគមន៍ ការចែកចាយ និងលក់ផលិតផលទឹកស្អាត និងអនាម័យព្រមទាំងការកសាងហេដ្ឋារចនាសម្ព័ន្ធ
- **ប្រតិបត្តិការ** រួមបញ្ចូលទាំងការត្រួតពិនិត្យមើលការគ្រប់គ្រងលើសេវាកម្ម ពីសំណាក់ក្រុមប្រើប្រាស់ទឹក និងអនាម័យ ការថែទាំ និងជួសជុលដោយមានកិច្ចគាំទ្រពីរដ្ឋបាលមូលដ្ឋានលើផ្នែកតាមដាននិងត្រួតពិនិត្យ និងការបណ្តុះបណ្តាលរយៈពេលខ្លី ដើម្បីបង្កើនជំនាញ និងចំណេះដឹងថ្មីៗ ។

### សមាសភាគ ១.១ ៖ ការទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត

#### ១.១.១ ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធថ្មី

ការគ្របដណ្តប់ដែលមានស្រាប់ និងកម្រិតនៃការផ្តល់ហេដ្ឋារចនាសម្ព័ន្ធថ្មីបានបង្ហាញឲ្យឃើញថាប្រទេសកម្ពុជា ស្ថិតនៅលើគន្លងផ្លូវឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាឆ្នាំ២០១៥ ។ ទោះបីជាយ៉ាងនេះក្តី ចាប់ពីឆ្នាំ២០១៥ទៅនឹងទាមទារឲ្យមានការពន្លឿនកម្រិតនៃការផ្តល់ហេដ្ឋារចនាសម្ព័ន្ធថ្មី ដើម្បីសម្រេចឲ្យបានតាមទស្សនវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ពោលគឺប្រជាជនរស់នៅជនបទទាំងអស់នឹងទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាតដែលមានការកែលម្អ ។

ដោយផ្អែកលើគោលការណ៍នៃវិធីសាស្ត្រឆ្លើយតបទៅនឹងតម្រូវការ និងការគ្រប់គ្រងដោយសហគមន៍ ការពន្លឿននេះពាក់ព័ន្ធទៅនឹងការបង្កើត និងរៀបចំផែនការសម្រាប់ហេដ្ឋារចនាសម្ព័ន្ធថ្មីដោយរួមបញ្ចូលទាំងការធ្វើបញ្ជីសារពើភ័ណ្ឌនៃសេវាដែលមានស្រាប់ ការបង្កើតតម្រូវការ ការរៀបចំសហគមន៍សម្រាប់ការគ្រប់គ្រង និងការផ្តល់ហេដ្ឋារចនាសម្ព័ន្ធដោយវិស័យឯកជន ។

ការគ្រប់គ្រងធនធានទឹកចម្រុះ គឺជាដំណើរការតាមប្រព័ន្ធមួយ សម្រាប់អភិវឌ្ឍប្រកបដោយនិរន្តរភាព លើការបែងចែក និងតាមដានត្រួតពិនិត្យការប្រើប្រាស់ធនធានទឹកក្នុងបរិបទបម្រើប្រយោជន៍សង្គម សេដ្ឋកិច្ច និងបរិស្ថាន[32] ។ ការគ្រប់គ្រងធានទឹក រាប់បញ្ចូលទាំងការបែងចែកធនធានទឹកសម្រាប់ការប្រើប្រាស់លើវិស័យផ្សេងៗ គឺជាការទទួលខុសត្រូវរបស់ក្រសួងធនធានទឹក និងឧតុនិយម ។

| **លទ្ធផល** | **សហគមន៍ និងស្ថាប័ននានាតាមជនបទ ទទួលបានសេវាផ្គត់ផ្គង់ទឹកតាម រយៈការផ្តល់ហេដ្ឋារចនាសម្ព័ន្ធថ្មី** | **ការទទួលខុសត្រូវ** |
|---|---|---|
| សកម្មភាព | ◆ រៀបចំបញ្ជីសារពើភ័ណ្ឌនៃសេវាផ្គត់ផ្គង់ទឹក និងភាពខ្វះ ចន្លោះផ្សេងៗនៅថ្នាក់ស្រុក ហើយចងក្រងព័ត៌មានទាំងនេះនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ ។ | ◆ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត/ ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ក្រសួងអភិវឌ្ឍន៍ជនបទ |
| | ◆ គ្រប់គ្រងការប្រើប្រាស់ប្រភពទឹកតាមផ្ទះឲ្យបានត្រឹមត្រូវដោយយោងទៅតាមគោលការណ៍គ្រប់គ្រងធនធានទឹកចម្រុះ ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ និង ក្រសួងធនធានទឹក និង ឧតុនិយម |
| | ◆ កំណត់ការគាំទ្រដែលផ្តល់ដោយដោយរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ រួមទាំងអង្គការមិនមែនរដ្ឋាភិបាល។ | ◆ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និង ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក |
| | ◆ ជំរុញឱ្យមានដំណើរការដាក់ពាក្យស្នើសុំហេដ្ឋារចនាសម្ព័ន្ធថ្មីសម្រាប់សេវាផ្គត់ផ្គង់ទឹក។ | ◆ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និង ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក |
| | ◆ ការរៀបចំសហគមន៍សម្រាប់គ្រប់គ្រងការសាងសង់ ប្រតិបត្តិការ និងថែទាំសេវាកម្មផ្គត់ផ្គង់ទឹក។ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធថ្មី | ◆ ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជនដែលទទួលភារកិច្ចពីការិយាល័យអភិវឌ្ឍន៍ជនបទស្រុក |
| | ◆ ការត្រួតពិនិត្យគុណភាពសំណង់ថ្មី | ◆ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និង ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក |
| | ◆ ការផ្តល់មូលនិធិលើថ្លៃទុនដើម ( Capital Cost )នៃហេដ្ឋារចនាសម្ព័ន្ធថ្មី | ◆ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងភាពជាដៃ គូជាមួយនឹងក្រសួងអភិវឌ្ឍន៍ជនបទ និងដៃគូអភិវឌ្ឍន៍ ព្រមទាំងសហគមន៍ |

32 (Cap-Net, Global Water Partnership, & UNDP, 2005)

### ១.១.២ ការស្តារឡើងវិញ ហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់

ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកជាច្រើន ដែលបានកសាងកាលពីពេលកន្លងទៅ បានបាក់បែកខូចខាតដោយសារមូលហេតុផ្សេងៗជាច្រើន ហើយឥឡូវពុំអាចប្រើប្រាស់បានទៀតទេ។ ដូចនេះ ចាំបាច់ត្រូវស្វែងយល់ពីទំហំ និងមូលហេតុផ្សេងៗនៃការបាក់បែកខូចខាតទាំងនេះ មុនពេលធ្វើការស្តារឡើងវិញនូវស្នប់អណ្តូងទឹក និងហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកផ្សេងៗទៀត ។

| លទ្ធផល | សហគមន៍ និងស្ថាប័ននានាតាមជនបទ ទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត តាមរយៈការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ ដែលអាចធ្វើទៅបាន | ការទទួលខុសត្រូវ |
|---|---|---|
| សកម្មភាព | ◆ ធ្វើការសិក្សាស្រាវជ្រាវ ដើម្បីកំណត់ទំហំ និងមូលហេតុនៃការខូចខាតកន្លងមក និងដើម្បីកំណត់ពីតម្លៃដើម្បីប្រៀបធៀបសម្រាប់ការជួសជុល ឬ ការសាងសង់ថ្មី។<br>◆ បង្កើតនីតិវិធី និងគោលការណ៍ណែនាំស្តីអំពីការស្តារឡើងវិញ នូវហេដ្ឋារចនាសម្ព័ន្ធដែលសំដៅទៅលើមូលហេតុ នៃការខូចខាតពីមុន។<br>◆ ជំរុញឱ្យមានដំណើរការដាក់ពាក្យស្នើសុំសម្រាប់ការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹក។<br>◆ ការរៀបចំសហគមន៍ដើម្បីគ្រប់គ្រងការសាងសង់ប្រតិបត្តិការ និងការថែទាំសេវាផ្គត់ផ្គង់ទឹក។<br>◆ ការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់<br>◆ ការត្រួតពិនិត្យគុណភាពនៃការស្តារឡើងវិញ<br>◆ ការផ្តល់មូលនិធិលើថ្លៃទុនដើម សម្រាប់ការស្តារឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និង ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ការិយាល័យអភិវឌ្ឍន៍ជនបទស្រុកអង្គការមិនមែនរដ្ឋាភិបាល<br>◆ វិស័យឯកជន ដែលទទួលភារកិច្ចពីការិយាល័យអភិវឌ្ឍន៍ជនបទស្រុក<br>◆ វិស័យឯកជន តាមរយៈការិយាល័យអភិវឌ្ឍន៍ជនបទស្រុក<br>◆ ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក<br>◆ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងភាពជាដៃគូជាមួយនឹងក្រសួងអភិវឌ្ឍន៍ ជនបទ និង ដៃគូអភិវឌ្ឍន៍ និងសហគមន៍ |

### ១.១.៣ បច្ចេកវិទ្យាផ្គត់ផ្គង់ទឹក

### ជម្រើសសម្រាប់ការផ្គត់ផ្គង់ទឹក

ជម្រើសបច្ចេកវិទ្យាផ្សេងៗសម្រាប់ផ្គត់ផ្គង់ទឹកស្អាត ត្រូវបានចាត់ថ្នាក់ជាពីរប្រភេទ គឺប្រភេទដែលមានការកែលម្អ និងប្រភេទដែលមិនមានការកែលម្អ (តារាងទី៦)[33] ។ ជម្រើសទាំងនេះគឺផ្អែកទៅលើនិយមន័យ ដែលកំណត់ដោយកម្មវិធីតាមដានរួមគ្នា (JMP) របស់មូលនិធិអង្គការសហប្រជាជាតិសម្រាប់កុមារ (UNICEF) និងអង្គការសុខភាពពិភពលោក (WHO) ។ ស្ថាប័ន ឬអង្គការណាមួយដែលផ្ដល់ហិរញ្ញប្បទានសម្រាប់គម្រោងផ្គត់ផ្គង់ទឹកថ្មីនឹងត្រូវធ្វើឱ្យស្របទៅតាមជម្រើសដែលមានការកែលម្អ ។ ចំណាត់ថ្នាក់នេះ នឹងត្រូវប្រើប្រាស់សម្រាប់រាល់ការធ្វើអង្កេតទាំងអស់ដែលចង់ពិនិត្យមើលលើការទទួលបានការផ្គត់ផ្គង់ទឹក និងអនាម័យដែលមានការកែលម្អ ។

**តារាងទី៦៖ ជម្រើសការផ្គត់ផ្គង់ទឹក ដែលមានការកែលម្អ និងមិនមានការកែលម្អ**

| ប្រភពទឹកដែលមានការកែលំអ | កំណត់សម្គាល់ |
|---|---|
| ១. ទឹកភ្ជាប់ទៅតាមផ្ទះ | ការផ្គត់ផ្គង់ទឹកតាមទុយោ៖ បើទឹកត្រូវយកចេញពីប្រភពទឹកលើដី ទឹកនោះត្រូវតែបន្សុទ្ធឱ្យស្របទៅតាមបទដ្ឋានគុណភាពទឹកសម្រាប់បរិភោគ |
| ២.ទឹកដែលតទៅបំពង់សម្រាប់ប្រើនៅទីសាធារណៈ | |
| ៣. អណ្តូងស្នប់ ឬ ខួង | |
| ៤. អណ្ដូងជីកដែលមានការការពារ | អណ្ដូងជីកដែលមានការការពារ ត្រូវមាន ៖<br>-លូទ្រនាប់ការពារអណ្តូង (lining)<br>-ខ្នោះអណ្ដូង (លូលយចេញខ្ពស់ផុតពីដី)<br>-ខឿនអណ្ដូង (platform)<br>-គម្រប (cover) |
| ៥. ការស្តុកទឹកភ្លៀងដែលមានការកែលម្អ និងការការពារត្រឹមត្រូវ | អាងស្តុកទឹកភ្លៀងត្រូវបានចាត់ទុកថា មានការកែលម្អ និងការការពារត្រូវមាន ៖<br>-បិទជិតទាំងស្រុង<br>-មានក្បាលរ៉ូប៊ីនេសម្រាប់បើកទឹក<br>-ស្តុកទឹកបានយ៉ាងហោចណាស់ ៣.០០០ លីត្រ |
| ៦. ស្រះទឹកដែលមានភ្ជាប់ជាមួយអាងចម្រោះទឹកស្អាត | TBD |
| ប្រភពទឹកដែលមិនមានការកែលម្អ | |

[33] (ក្រសួងអភិវឌ្ឍន៍ជនបទ និងដៃគូអភិវឌ្ឍន៍ ឆ្នាំ២០០៨)

| | |
|---|---|
| ៧. អណ្តូងជីកដែលមិនមានការការពារ | |
| ៨. ស្រះ ស្ទឹង ឬ អូរ | |
| ៩. ការស្តុកទឹកភ្លៀងដែលមិនមានការកែលម្អ និងការការពារត្រឹមត្រូវ | |
| ១០. ទឹកផ្តល់ដោយអ្នកដើរលក់ | ទាំងនេះ គឺជាជម្រើសដែលមិនមានការកែលំអពីព្រោះតែតម្លៃនិងការពិបាកក្នុងការទទួលបានទឹកនោះយកមកប្រើប្រាស់ |
| ១១. ទឹកច្រកដប | |
| ១២. ការផ្តល់ទឹកតាមរថយន្តដឹកទឹក | |

### ជម្រើសបច្ចេកវិទ្យាផ្គត់ផ្គង់ទឹក

ស្ថាប័នណាក៏ដោយដែលផ្តល់ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកថ្មី ត្រូវផ្តល់ឱ្យសហគមន៍នូវជម្រើសដែលមានការកែលំអស្របតាមលក្ខណៈបច្ចេកទេសសង្គមសេដ្ឋកិច្ចក្នុងបរិបទមូលដ្ឋាន។កត្តាសង្គមត្រូវពិចារណាទៅលើភាពងាយស្រួលក្នុងការប្រើប្រាស់ទឹកស្អាតសម្រាប់ស្ត្រី កុមារ និងសេចក្តីត្រូវការផ្សេងៗរបស់ជនពិការ ។ សហគមន៍នឹងជ្រើសរើសបច្ចេកវិទ្យា ដែលពួកគេពេញចិត្ត ផ្អែកលើការយល់ដឹងគ្រប់គ្រាន់ អំពីជម្រើសដែលអាចប្រើប្រាស់បាន ក្នុងស្ថានភាពទីតាំងភូមិសាស្ត្រជាក់ស្តែង ។ ស្ថាប័នដែលផ្តល់ហេដ្ឋារចនាសម្ព័ន្ធទៅឲ្យសហគមន៍នឹងកំណត់ជម្រើសដែលអាចប្រើប្រាស់បានហើយពន្យល់ពីជម្រើសទាំងនេះទៅដល់សហគមន៍ដោយរៀបរាប់អំពីគុណសម្បត្តិនិងគុណវិបត្តិនៃជម្រើសនីមួយៗ ។ ព័ត៌មាននេះ ត្រូវរួមបញ្ចូលថ្លៃសាងសង់ និងជួសជុល ព្រមទាំងថ្លៃប្រតិបត្តិការពេញមួយឆ្នាំ ដែលផ្តោតលើថ្លៃគ្រឿងបន្លាស់ដែលត្រូវផ្លាស់ប្តូរនៅពេលដែលបច្ចេកវិទ្យានៃជម្រើសនោះលែងដំណើរការតទៅទៀត ។

## ១.១.៤ ការអភិវឌ្ឍបច្ចេកវិទ្យា និងសេវាកម្មសមស្រប

បច្ចេកវិទ្យាដែលសមស្រប និងមានតម្លៃសមរម្យសម្រាប់ការផ្គត់ផ្គង់ទឹក នៅតំបន់រាំងស្ងួតគឺពុំទាន់មានទូលំទូលាយនៅឡើយទេក្នុងប្រទេសកម្ពុជា ។ នៅតំបន់ដែលរងផលប៉ះពាល់ដោយសារធាតុអាសេនិក ត្រូវមានជម្រើសទឹកផ្សេងៗក្រៅពីប្រភពទឹកក្រោមដី ។ ការតម្រូវបច្ចេកវិទ្យាឱ្យសមស្របទៅនឹងតម្រូវការសង្គម ដូចជា យេនឌ័រ និងពិការភាព ក៏មានភាពចាំបាច់ផងដែរ ។

| លទ្ធផល | ជម្រើសបច្ចេកវិទ្យាដែលមានតម្លៃសមស្រប សម្រាប់ការផ្គត់ផ្គង់ទឹកនៅតំបន់រាំងស្ងួត តំបន់ទទួលរងផលប៉ះពាល់ដោយសារធាតុអាសេនិក និងសម្រាប់សេចក្តីត្រូវការសង្គមផ្សេងៗ ដែលអាចរកបាន | ការទទួលខុសត្រូវ |
|---|---|---|
| សកម្មភាព | ◆ ធ្វើការសិក្សាស្រាវជ្រាវ អភិវឌ្ឍ និងដកពិសោធន៍លើបច្ចេកវិទ្យាផ្គត់ផ្គង់ទឹកស្អាត នៅតំបន់រាំងស្ងួត និងតំបន់ទទួលរងផលប៉ះពាល់ដោយសារធាតុអាសេនិក ស្របទៅតាមនីតិវិធីស្រាវជ្រាវ និងអភិវឌ្ឍន៍ នៅក្នុងសមាសភាគទី៤.៦ ។ ការសិក្សាស្រាវជ្រាវនេះនឹងរួមបញ្ចូលការពិនិត្យមើលឡើងវិញពីភាពសមស្របនៃបច្ចេកវិទ្យាសម្រាប់អ្នកប្រើប្រាស់ជាស្ត្រី កុមារ ជនពិការ និងបច្ចេកវិទ្យានានា ដែលបានប្រើដោយប្រទេសផ្សេងៗ ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ |
| | ◆ ធ្វើការសិក្សាស្រាវជ្រាវ អភិវឌ្ឍ និងដកពិសោធន៍លើបច្ចេកវិទ្យាផ្គត់ផ្គង់ទឹក សម្រាប់សេចក្តីត្រូវការនានារបស់សង្គម ដោយរួមបញ្ចូលទាំងអ្នកប្រើប្រាស់ជាជនពិការ និងស្ត្រី ស្របទៅតាមនីតិវិធីស្រាវជ្រាវនិងអភិវឌ្ឍន៍ នៅក្នុងសមាសភាគទី៤.៦ ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ |
| | ◆ អនុវត្តការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍ និងដកពិសោធន៍ | ◆ ផ្នែកបច្ចេកទេសរបស់សាកលវិទ្យាល័យ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ អង្គការមិនមែនរដ្ឋាភិបាល និង ឬ ស្ថាប័នឯកជន |

### ១.១.៥. ការចែករំលែកហានិភ័យក្នុងការផ្តល់សេវាកម្ម

ការផ្តល់សេវាបច្ចេកទេស នៅតំបន់ដាច់ស្រយាល និងតំបន់ដែលពិបាក គឺមានតម្លៃថ្លៃជាងតំបន់ដែលមានភាពងាយស្រួល និងថ្លៃជាងតំបន់ដែលបច្ចេកវិទ្យាមានរួចហើយ ។ ថ្លៃបន្ថែមនេះ គឺដោយសារហេតុផលពីរយ៉ាង ៖ទី១-ការចំណាយបន្ថែមលើការដឹកជញ្ជូនសម្ភារៈ ការលើកទឹកចិត្តបុគ្គលិក និងភស្តុភារផ្សេងៗ និងទី២-ហានិភ័យនៃការធ្វើការនៅតំបន់ ដែលមិនអាចដឹងច្បាស់ពីស្ថានភាពទឹកក្រោមដីនិងគុណភាពទឹក។ការចំណាយខ្ពស់នៃបញ្ហានេះត្រូវតែមានការទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ច និងដៃគូអភិវឌ្ឍន៍ ។

| លទ្ធផល | វិស័យឯកជនដែលនឹងត្រូវដំណើរការផ្តល់សេវាកម្មនៅតំបន់ដែលមានការលំបាក និងតំបន់ដាច់ស្រយាល | ការទទួលខុសត្រូវ |
|---|---|---|
| សកម្មភាព | ◆ បង្កើតប្រព័ន្ធច្បាស់លាស់មួយ សម្រាប់បន្ថែមតម្លៃនៃការធ្វើការនៅតំបន់ដាច់ស្រយាល និងសម្រាប់រួមចំណែកក្នុងការខូចខាត ដែលនឹងអាចកើតមានឡើង ដើម្បីជាការលើកទឹកចិត្តដល់វិស័យឯកជនឱ្យធ្វើការនៅតំបន់ដាច់ស្រយាល។ ប្រព័ន្ធនេះនឹងជួយក្នុងការចែករំលែកហានិភ័យទាំងឡាយជាមួយភាគីពាក់ព័ន្ធផ្សេងៗ។ ការផ្តល់លើកទឹកចិត្តដល់អ្នកវិនិយោគឯកជនទាំងនេះ គឺជាការសមស្របសម្រាប់ទូទាត់ជាមួយនឹង ហានិភ័យទាំងឡាយដែលពួកគេជួបប្រទះ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ |

### សមាសភាគ ១.២ ៖ ការអនុវត្តបទដ្ឋានគុណភាពទឹក

ការផ្គត់ផ្គង់ទឹកតាមសហគមន៍ជនបទ ត្រូវអនុលោមទៅតាមបទដ្ឋានគុណភាពទឹកសម្រាប់បរិភោគ[34] ។ បទដ្ឋាននេះ បានបង្កើតប៉ារ៉ាម៉ែត្រអាទិភាពជាច្រើន សម្រាប់ការផ្គត់ផ្គង់ទឹកខ្នាតតូចនៅតាមជនបទ[35] រួមជាមួយនឹងភាពញឹកញាប់នៃការយកសំណាកទឹក សម្រាប់ធ្វើការវិភាគរកមេរោគ ដូចបានបង្ហាញក្នុងតារាងទី៧ ។

[34] (ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឆ្នាំ២០០៤)
[35] (ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឆ្នាំ២០០៤)

### តារាងទី៧៖ ប៉ារ៉ាម៉ែត្រគុណភាពទឹកសំខាន់ៗ សម្រាប់ការផ្គត់ផ្គង់ទឹកខ្នាតតូច

| ប៉ារ៉ាម៉ែត្រ | កម្រិតអតិបរិមា |
|---|---|
| សន្ទស្សន៍អាស៊ីត និងបាស (pH ) | ៦,៥ -៨,៥ |
| ភាពល្អក់ | ៥ NTU (ខ្នាតវាស់កំហាប់សម្រាប់គុណភាពទឹក ) |
| សារធាតុអាសេនិក | 0,0៥ មីលីក្រាមក្នុងមួយលីត្រ |
| សារធាតុដែក | 0,៣ មីលីក្រាមក្នុងមួយលីត្រ |
| នីត្រាត ដូចជា NO3- | ៥0 មីលីក្រាមក្នុងមួយលីត្រ |
| នីត្រាត ដូចជា NO2- | ៣ មីលីក្រាមក្នុងមួយលីត្រ |
| សារធាតុមិនរលាយទាំងស្រុងក្នុងទឹក (TDS) | ៨00 មីលីក្រាមក្នុងមួយលីត្រ |
| កម្រិតមេរោគ ទម្រង់កូលី ឬអ៊ីកូលី ដែលធន់ នឹងកំដៅ | 0 ក្នុង ១00  មីលីលីត្រ |
| ភាពញឹកញាប់ក្នុងការកយសំណាកទឹក សម្រាប់ការវិភាគមីក្រុប ចំពោះប្រជាជនតិចជាង ៥.000 នាក់ | សំណាកគំរូ ១ រៀងរាល់ខែ |
| ភាពញឹកញាប់ក្នុងការកយសំណាកទឹកសម្រាប់វិភាគធាតុផ្សំអសរីរាង្គ | មួយដង ក្នុងមួយឆ្នាំ |

### ១.២.១. ផែនការសុវត្ថិភាពទឹក និងប្រព័ន្ធត្រួតពិនិត្យគុណភាពទឹក

បទដ្ឋានគុណភាពទឹកសម្រាប់បរិភោគ បានចែងថា៖ ក្រុមអ្នកត្រួតពិនិត្យគុណភាពទឹកមកពីស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវអនុវត្តបទដ្ឋានទាំងនេះ ជាមួយនឹងការទទួលខុសត្រូវច្បាស់លាស់ ។ មន្ទីរអភិវឌ្ឍន៍ជនបទខេត្តត្រូវទទួលខុសត្រូវបង្កើតប្រព័ន្ធត្រួតពិនិត្យគុណភាពទឹក ហើយការទទួលខុសត្រូវនៅកម្រិតសហគមន៍ ត្រូវផ្ទេរទៅឱ្យក្រុមប្រឹក្សាស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ ។ ការទទួលខុសត្រូវ និងការផ្ទេរភារកិច្ច មាននៅក្នុងឧបសម្ព័ន្ធទី១ ។ ប្រព័ន្ធត្រួតពិនិត្យនេះអាចត្រូវបានបញ្ចូលគ្នា ជាមួយនឹងប្រព័ន្ធទ្រទ្រង់ការថែទាំនៅថ្នាក់ស្រុក ។

ម្យ៉ាងវិញទៀត បទដ្ឋានគុណភាពទឹកសម្រាប់បរិភោគ ក៏តម្រូវឱ្យមានការអង្កេតស្ថានភាពអនាម័យ (Sanitary survey) នៅតាមប្រភពទឹកស្របទៅតាមគោលការណ៍ណែនាំ[36] របស់អង្គការសុខភាពពិភពលោក ផងដែរ ។ អង្គការសុខភាពពិភពលោក ដែលរៀបចំបទដ្ឋានទាំងនេះ បានបង្កើតគោលគំនិតជាច្រើននៃផែនការសុវត្ថិភាពទឹក[37] ។ ក្រុមប្រឹក្សាឃុំ សង្កាត់នឹងអនុវត្តបទដ្ឋានទាំងនេះជាដំណើរការតាមបែបចូលរួម ដើម្បីជួយសហគមន៍ឱ្យយល់ដឹងពីសារៈសំខាន់នៃការការពារប្រភពទឹក និងការប្រើប្រាស់ទឹកដែលមានសុវត្ថិភាព ។

[36] (អង្គការសុខភាពពិភពលោក ឆ្នាំ២00៣)
[37] (អង្គការសុខភាពពិភពលោក ឆ្នាំ២00៥)

| លទ្ធផល | ដំណើរការនីតិវិធីដើម្បីឲ្យការផ្គត់ផ្គង់ទឹកអនុលោមទៅតាមស្តង់ដាគុណភាពទឹកសម្រាប់ជនបទ | ការទទួលខុសត្រូវ |
|---|---|---|
| សកម្មភាព | ◆ ទទួលយកនូវទស្សនៈផែនការសុវត្ថិភាពទឹកសម្រាប់ប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា និងរៀបចំគោលការណ៍ណែនាំ ស្តីពីផែនការសុវត្ថិភាពទឹកសម្រាប់ក្រុមប្រឹក្សាឃុំ-សង្កាត់ រួមមានផែនការសុវត្ថិភាពទឹកទូទៅ ផ្អែកតាមឯកសារណែនាំ ស្តីពីផែនការសុវត្ថិភាពទឹក ដែលរៀបចំដោយអង្គការសុខភាពពិភពលោក។<br>◆ បង្កើតប្រព័ន្ធត្រួតពិនិត្យគុណភាពសម្រាប់ខេត្ត ហើយការទទួលខុសត្រូវលើប្រតិបត្តិការត្រូវផ្ទេរទៅឱ្យក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ សង្កាត់។<br>◆ ក្រុមប្រឹក្សា ឃុំសង្កាត់នីមួយៗនឹងបង្កើតផែនការសុវត្ថិភាពទឹកសម្រាប់តំបន់របស់ខ្លួន ដែលជាផ្នែកមួយ នៃប្រព័ន្ធតាមដានគុណភាពទឹក។<br>◆ បង្កើតនីតិវិធីមួយសម្រាប់ធ្វើសេចក្តីសម្រេចចិត្ត និងសកម្មភាព មួយចំនួន ដើម្បីឆ្លើយតបទៅនឹងប្រភពទឹក ដែលមិនសមស្របតាមបទដ្ឋានស្តង់ដា រួមទាំងការត្រួតពិនិត្យប្រភពទឹកផ្សេងៗ ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត<br>◆ ការិយាល័យ<br>អភិវឌ្ឍន៍ជនបទស្រុក<br>ក្រុមប្រឹក្សាឃុំសង្កាត់<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ |

### ១.២.២ ការការពារទឹកពីប្រភពទឹក រហូតដល់ការប្រើប្រាស់តាមផ្ទះ

ក្រសួងអភិវឌ្ឍន៍ជនបទ និងដៃគូអភិវឌ្ឍ បានកំណត់ទម្លាប់អនាម័យផ្ទាល់ខ្លួនបីយ៉ាងដែលត្រូវលើកកម្ពស់។ ទម្លាប់មួយដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងទឹក គឺការបរិភោគទឹកមិនមានសុវត្ថិភាព ។

| លទ្ធផល | ប្រជាពលរដ្ឋអនុវត្តការប្រើប្រាស់ទឹកប្រកបដោយសុវត្ថិភាព ទាំងការទុកដាក់ទឹក ការប្រើប្រាស់ទឹកតាមផ្ទះ និងការបរិភោគ | ការទទួលខុសត្រូវ |
|---|---|---|
| សកម្មភាព | ◆ ផ្សព្វផ្សាយ និងត្រួតពិនិត្យវាយតម្លៃពីប្រសិទ្ធភាពនៃគោលការណ៍ណែនាំស្តីពីការលើកកម្ពស់អនាម័យផ្ទាល់ខ្លួន (Hygiene Promotion Guideline, 2010) ហើយកែលំអគោលការណ៍ណែនាំនេះ ប្រសិនបើមានការចាំបាច់ | ◆ ក្រសួងអភិវឌ្ឍន៍ ជនបទ |

ក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះ ធុងចម្រោះសេរ៉ាមិច បានត្រូវណែនាំឱ្យប្រើប្រាស់ នៅក្នុងប្រទេសកម្ពុជា ដែលនេះគឺជាផ្នែកមួយនៃខ្សែសង្វាក់ផ្គត់ផ្គង់ទឹកដែលមានសុវត្ថិភាពនៅចំណុចបរិភោគ ។ ដំណើរការបង្កើត និងពិសោធន៍ឱ្យបានល្អិតល្អន់ ដើម្បីធានាថា ធុងចម្រោះទាំងនេះនឹងផលិតទឹកដែលមានសុវត្ថិភាព ស្របតាមបទដ្ឋានគុណភាពទឹកសម្រាប់បរិភោគ នឹងដើរតួជាគំរូមួយសម្រាប់ការបង្កើតបច្ចេកវិទ្យាបន្សុទ្ធទឹកតាមផ្ទះទៀតផង ។ បច្ចុប្បន្ននេះ គម្រោងរៀបចំដើម្បីបង្កើតនីតិវិធីត្រួត- ពិនិត្យបច្ចេកវិទ្យាបរិស្ថាន (ETV) ដែលនឹងរួមបញ្ចូលសកម្មភាពមួយចំនួនដូចជា ការធ្វើពិសោធន៍ និងការតាមដានទៅលើបច្ចេកវិទ្យាចម្រោះទឹកតាមផ្ទះ និងសហគមន៍។ ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព និងសុវត្ថិភាពរបស់ផលិតផល និងសេវាកម្ម (ឆ្នាំ ២០០០) ដែលរៀបចំដោយក្រសួងពាណិជ្ជកម្ម គឺមានការពាក់ព័ន្ធទៅនឹងនីតិវិធីត្រួតពិនិត្យបច្ចេកវិទ្យាបរិស្ថាន (ETV)[38] នេះ។

| លទ្ធផល | ឧបករណ៍បន្សុទ្ធទឹកតាមផ្ទះ ដែលបានដាក់លក់នៅលើទីផ្សារ ឬដែលបានផ្តល់ឱ្យដោយស្ថាប័នអភិវឌ្ឍន៍នានា ត្រូវឆ្លើយតបទៅតាមបទដ្ឋាន | ការទទួលខុសត្រូវ |
|---|---|---|
| សកម្មភាព | ◆ បញ្ចប់នីតិវិធីសម្រាប់វាយតម្លៃបច្ចេកវិទ្យាបន្សុទ្ធទឹកតាមផ្ទះ ETV (Environmental Technology Verification) ហើយនឹងអនុម័តច្បាប់សំខាន់ៗនានាសម្រាប់ការពិសោធន៍ ដ៏ចាំបាច់ស្របតាមនីតិវិធី ETVនេះ។<br>◆ កសាងសមត្ថភាពសម្រាប់ធ្វើតេស្តបច្ចេកវិទ្យាបន្សុទ្ធទឹកផ្សេងៗ ។<br>◆ ចេញលិខិតបញ្ជាក់ទៅលើផលិតផលដែលឆ្លើយតបតាមបទដ្ឋាន។<br>◆ ផ្សព្វផ្សាយព័ត៌មានជាសាធារណៈអំពីលិខិតបញ្ជាក់ទៅលើផលិតផល ។ | ◆ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងពាណិជ្ជកម្ម និងក្រសួងអភិវឌ្ឍន៍ជនបទ |

[38] (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០០)

## សមាសភាគ ១.៣ ៖ ប្រតិបត្តិការ និងការថែទាំ

### ១.៣.១ ការគ្រប់គ្រងដោយសហគមន៍លើការប្រតិបត្តិការ និងការថែទាំ

សហគមន៍អ្នកប្រើប្រាស់មានការទទួលខុសត្រូវជាចម្បងលើប្រតិបត្តិការ និងថែទាំសេវាផ្គត់ផ្គង់ទឹកតាមសហគមន៍។ សហគមន៍នីមួយៗនឹងជ្រើសរើសក្រុមប្រើប្រាស់ទឹក និងអនាម័យ (WSUG) ដើម្បី គ្រប់គ្រងប្រតិបត្តិការលើសេវាផ្គត់ផ្គង់ទឹក។ ក្រុមប្រើប្រាស់ទឹក និងអនាម័យ ត្រូវតែជាតំណាងឱ្យសហគមន៍របស់ខ្លួន ក្នុងនោះរួមមានទាំងសមាជិកស្ត្រី និងតំណាងជនជាតិភាគតិច ជនពិការ និងក្រុមងាយរងគ្រោះដទៃទៀត ។ សហគមន៍ នឹងជ្រើសរើសក្រុមប្រើប្រាស់ទឹក និងអនាម័យ របស់ពួកគេសាជាថ្មី តាមពេលវេលាមួយទៀងទាត់ដែលបានកំណត់ ។

ក្រុមប្រើប្រាស់ទឹក និងអនាម័យ អាចប្រើវិធីសាស្ត្រខុសៗគ្នា ដើម្បីដំណើរការសេវាផ្គត់ ផ្គង់ទឹក ។ ជម្រើសផ្សេងៗរួមមាន ៖

- ជួលបុគ្គលិកដោយឲ្យបៀវត្សឱ្យអនុវត្តប្រតិបត្តិការ ថែទាំ និងជួសជុល ជាប្រចាំ
- ធ្វើកិច្ចសន្យាជាមួយអ្នកផ្តល់សេវាកម្មឯកជនខ្នាតតូច ឱ្យដំណើរការសេវាកម្ម
- ក្រុមប្រើប្រាស់ទឹក និងអនាម័យ ដែលនៅជិតគ្នា រួមសហការគ្នា ដើម្បីធ្វើ កិច្ចសន្យា ជាមួយអ្នកផ្តល់សេវាឯកជនខ្នាតធំ ឱ្យដំណើរការសេវាកម្ម ។

### ១.៣.២ ប្រព័ន្ធទ្រទ្រង់ការថែទាំ

តាមបទពិសោធន៍ជាសាកលបានបង្ហាញថា ការបណ្តុះបណ្តាលក្រុមប្រើប្រាស់ទឹក និងអនាម័យ និងផ្តល់ការគាំទ្ររយៈពេលមួយ ឬពីរឆ្នាំក្នុងពេលគម្រោងកំពុងអនុវត្ត ហើយដែលសំណង់ផ្គត់ផ្គង់ទឹកនៅថ្មីនៅឡើយមិនទាន់គ្រប់គ្រាន់ទេ សម្រាប់ធានាបាននូវនិរន្តរភាពរយៈពេលវែងសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងការគ្រប់គ្រងដោយក្រុមប្រើប្រាស់ទឹក និងអនាម័យ ។ ការគាំទ្រដល់ការគ្រប់គ្រងនៅថ្នាក់សហគមន៍ គឺជាករណីចាំបាច់ ប្រសិនបើយើងចង់ឲ្យប្រព័ន្ធផ្គត់ផ្គង់ទឹកមាននិរន្តរភាព ។ ការគាំទ្រនេះមិនមែនមានន័យថា ជាការទាញយកការទទួលខុសត្រូវពីសហគមន៍ក្នុងការគ្រប់គ្រងនោះទេ ប៉ុន្តែមានន័យថា ជាការផ្តល់ដំបូន្មានបច្ចេកទេស ការបណ្តុះបណ្តាល និងដំបូន្មានក្នុងការគ្រប់គ្រងដើម្បីឱ្យសហគមន៍អាចគ្រប់គ្រងសកម្មភាពនេះដោយខ្លួនឯងបាន ។ សំខាន់យើងត្រូវតាមដានថា តើសហគមន៍គ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹករបស់គេបានជោគជ័យដែរឬទេ? ហើយត្រូវធ្វើសកម្មភាពដើម្បីដោះស្រាយបញ្ហាប្រសិនជាមាន[39]។ ការគាំទ្រគួរបញ្ចូលផងដែរ នូវការតាមដាននីវ៉ូទឹកក្រោមដីនៅទីកន្លែងដែលទឹកក្រោមដីត្រូវបានយកមកប្រើ ។

ប្រព័ន្ធទ្រទ្រង់ការថែទាំនឹងត្រូវបង្កើតឡើង និងដំណើរការ ក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាស្រុកខណ្ឌនីមួយៗ តាមរយៈក្រុមប្រឹក្សាឃុំសង្កាត់ ។ មុខងារសំខាន់ៗនៃប្រព័ន្ធគាំទ្រស្ថាប័ននេះ មានចែងក្នុងឧបសម្ព័ន្ធទី៣ ។ ការចំណាយលើដំណើរការសេវាកម្មនេះ ត្រូវមានការរួមចំណែករវាងសហគមន៍អ្នកប្រើប្រាស់ និងរដ្ឋបាលមូលដ្ឋាន (តាមរយៈវិភាជន៍ថវិកាប្រចាំឆ្នាំពីថ្នាក់ជាតិ)។ ប្រព័ន្ធទ្រទ្រង់ការថែទាំ នឹងត្រូវបង្ហាញពីសារៈប្រយោជន៍របស់វា ទៅកាន់សហគមន៍អ្នកប្រើប្រាស់ ដើម្បីឲ្យពួកគេយល់ថាការចំណាយរបស់ពួកគេគឺបានផលត្រឡប់មកវិញ។

[39] ចេញពីសេចក្តីព្រៀងយុទ្ធសាស្ត្រវិស័យរយៈពេលដប់ឆ្នាំ ពីឆ្នាំ២០០១-២០១០ (ក្រសួងអភិវឌ្ឍន៍ជនបទ)

| **លទ្ធផល** | ក្រុមប្រើប្រាស់ទឹក និងអនាម័យ ក៏ដូចជាសហគមន៍ទទួលបានការណែនាំបច្ចេកទេស ការបណ្តុះបណ្តាល និងការបង្ហាញផ្ទាល់ ដើម្បីធានាឱ្យបាននូវនិរន្តរភាពរយៈពេលវែងសម្រាប់គ្រប់គ្រង សេវាផ្គត់ផ្គង់ទឹកដោយសហគមន៍ | **ការទទួលខុសត្រូវ** |
|---|---|---|
| សកម្មភាព | ◆ បង្កើតប្រព័ន្ធទ្រទ្រង់ ការថែទាំដែលរួមមានការត្រួតពិនិត្យតាមដាននីវ៉ូទឹកក្រោមដី។<br><br>◆ បង្កើតប្រព័ន្ធទ្រទ្រង់ ការថែទាំនៅថ្នាក់ស្រុកនីមួយៗ និងរៀបចំវគ្គបណ្តុះបណ្តាលសម្រាប់បុគ្គលិក ដែលបានចាត់តាំង។ | ◆ ក្រសួង អភិវឌ្ឍន៍ជនបទ<br><br>◆ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត |

### ការផ្តល់មូលនិធិលើប្រតិបត្តិការ និងថែទាំ

ឆន្ទៈនយោបាយ គឺជាកត្តាសំខាន់ ក្នុងការបង្កើតប្រព័ន្ធទ្រទ្រង់ប្រតិបត្តិការ និងថែទាំឱ្យបានជោគជ័យ ដូច្នេះហិរញ្ញវត្ថុ នឹងត្រូវបានគេយកចិត្តទុកដាក់ផ្តល់ឲ្យគ្រប់គ្រាន់ដើម្បីឲ្យប្រជាពលរដ្ឋទទួលបានសេវា ។ បរាជ័យ នៃហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកមួយចំនួន នាពេលកន្លងមកគួរជាក្តីបារម្ភដ៏ធំមួយ នៅថ្នាក់ជាតិ ។ ផ្ទុយទៅវិញ ការយកចិត្តទុកដាក់ខ្លាំងមានតែនៅលើការស្តារឡើងវិញ ឬការផ្លាស់ប្តូរ សំណង់ផ្គត់ផ្គង់ទឹក ជាជាងការដោះស្រាយបញ្ហាប្រឈមនានាដើម្បីធានាក្នុងការបន្តដំណើរការផ្គត់ផ្គង់ ទឹកឱ្យបានជោគជ័យ ។ ចាំបាច់ត្រូវមានការខិតខំប្រឹងប្រែងជាច្រើនទៀតដើម្បីបង្កើនការយល់ដឹងនៅកម្រិតនយោបាយលើការគ្រប់គ្រងបញ្ហាទាំងនេះ។ សូចនាករជោគជ័យក្នុងបញ្ហានេះ គឺការបែងចែកហិរញ្ញវត្ថុប្រចាំឆ្នាំឲ្យបានគ្រប់គ្រាន់នៅក្នុងថវិកាជាតិ សម្រាប់ចំណាយចរន្តលើប្រព័ន្ធគ្រប់គ្រង់ប្រតិបត្តិការ និងថែទាំ ដែលបានបង្កើតឡើង ។

**ព័ត៌មានទាំងនេះ មាននៅក្នុងគោលដៅយុទ្ធសាស្ត្រទី៥ សមាសភាគទី២ ស្តីពីការផ្តល់មូលនិធិចរន្ត។**

## សមាសភាគ ១.៤ ៖ ទីផ្សារសម្រាប់ផលិតផលទឹកស្អាត និងអនាម័យ

### ១.៤.១ ខ្សែសង្វាក់ផ្គត់ផ្គង់

ខ្សែសង្វាក់ផ្គត់ផ្គង់ គឺជាពាក្យប្រើសម្រាប់ដំណើរការទាក់ទងនឹងសកម្មភាពទាំងអស់ពាក់ព័ន្ធនឹងលំហូរ និងការផ្លាស់ប្តូរទំនិញ ចាប់តាំងពីដំណាក់កាលវត្ថុធាតុដើម រហូតទៅដល់ដំណាក់កាលអ្នកប្រើប្រាស់ចុងក្រោយ ព្រមទាំងលំហូរព័ត៌មានទាំងឡាយដែលពាក់ព័ន្ធ[40] ។

[40] ផ្នែកនេះ គឺផ្អែកទៅលើ (Oyo, 2002)

គោលដៅជាមូលដ្ឋាននៃខ្សែសង្វាក់ផ្គត់ផ្គង់ទាំងអស់ គឺដើម្បីផ្ដល់ជូននូវផលិតផលដ៏ល្អមួយជាមួយនឹងប្រាក់ចំណេញក្នុងកម្រិតសមរម្យ ។ ដើម្បីសម្រេចបាននូវគោលដៅនេះ ផលិតផលត្រូវតែឆ្លើយតបទៅនឹងការចង់បានរបស់អតិថិជន ដែលពាក់ព័ន្ធទៅនឹង ៖

- ភាពដែលអាចរកបាន
- តម្លៃសមរម្យអាចទទួលយកបាន
- គុណភាពល្អ
- ការផ្ដល់ជូនបានទាន់ពេលវេលា

ដើម្បីឱ្យខ្សែសង្វាក់ផ្គត់ផ្គង់បានដំណើរការទៅមានប្រសិទ្ធភាព ចាំបាច់ត្រូវមានតម្រូវការទំនិញនិងសេវាកម្មដែលខ្សែសង្វាក់ផ្គត់ផ្គង់នេះផ្ដល់ជូន ។ ដើម្បីបង្កើតឱ្យមានតម្រូវការផលិតផលកត្តាសំខាន់រួមមានតម្លៃសមរម្យ និងភាពងាយស្រួលខាងបច្ចេកវិទ្យារបស់ផលិតផលនោះ ។ ដើម្បីឱ្យវិស័យឯកជនចូលរួមក្នុងខ្សែសង្វាក់ផ្គត់ផ្គង់នេះ ចាំបាច់ត្រូវមានការលើកទឹកចិត្តឱ្យបានគ្រប់គ្រាន់ដូចជាមានតម្រូវការច្រើនល្មមផលិតផល ហើយមានផលចំណេញសមរម្យ និងមានលិខិតបទដ្ឋានគតិយុត្តលើការប្រកួតប្រជែង។ ជាចុងក្រោយ ដើម្បីបង្កើតនិងធ្វើឱ្យមាននិរន្តរភាពខ្សែសង្វាក់ផ្គត់ផ្គង់ត្រូវមានលំហូរព័ត៌មានត្រឹមត្រូវ រវាងភាគីពាក់ព័ន្ធ ការគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់ប្រកបដោយប្រសិទ្ធភាព និងបរិយាកាសសមស្រប ដែលមិនរឹតបន្តឹងដល់ការធ្វើពាណិជ្ជកម្ម ។

| **លទ្ធផល** | ប្រជាពលរដ្ឋ និងសហគមន៍អាចទិញ ផលិតផលទឹក និងអនាម័យ នៅទីផ្សារក្នុងតំបន់របស់ពួកគេ តាមរយៈខ្សែ សង្វាក់នៃការផ្គត់ផ្គង់ | **ការទទួលខុសត្រូវ** |
|---|---|---|
| សកម្មភាព | ◆ រៀបចំគម្រោងដើម្បីបង្កើតគោលគំនិត និង ការអនុវត្ត ខ្សែសង្វាក់ផ្គត់ផ្គង់អណ្ដូងស្នប់ និងផលិតផលផ្គត់ផ្គង់ទឹកស្អាត និងបង្គន់អនាម័យ និងអនាម័យខ្លួនប្រាណផ្សេងៗទៀត ដោយផ្អែកលើការណែនាំផ្សេងៗដែលបោះពុម្ពផ្សាយដោយកម្មវិធីទឹកស្អាត និងអនាម័យរបស់ធនាគារពិភពលោក ក៏ដូចជាគោលការណ៍ណែនាំមួយចំនួនទៀត | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ គាំទ្រដោយ ដៃគូអភិវឌ្ឍ |

ការណែនាំលើផ្នែកនេះមាននៅឧបសម្ព័ន្ធទី៣ ។

## គោលដៅយុទ្ធសាស្ត្រទី២ ៖ ការទទួលបានអនាម័យដែលមានការកែលម្អ

### សមាសភាគ ២.១ ៖ ការបង្កើនលទ្ធភាពទទួលបានអនាម័យ

បទពិសោធន៍ជាសាកលបានបង្ហាញថា វិធីសាស្ត្រ ដែលបានប្រើកន្លងទៅ ក្នុងការលើកកម្ពស់អនាម័យ ដោយផ្តោតលើការសាងសង់បង្គន់អនាម័យ មិនសូវទទួលបានលទ្ធផល ក្នុងការពង្រីកការគ្របដណ្តប់អនាម័យប្រកបដោយនិរន្តរភាពឡើយ ។ ការបង្កើតឲ្យមានតម្រូវការ សម្រាប់អនាម័យដោយផ្តោតលើការផ្លាស់ប្តូរទម្លាប់ជាមួយគ្នានឹងការធ្វើឲ្យមានសេវា និងផលិតផល គឺជាយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពជាង។ បទពិសោធន៍នៅក្នុងប្រទេសកម្ពុជា កាលពីប៉ុន្មានឆ្នាំមុនបង្ហាញថា៖ ថវិកាគម្រោងអាចរួមចំណែកបានត្រឹមតែ ២០% ប៉ុណ្ណោះក្នុងការបង្កើនការគ្របដណ្តប់បង្គន់អនាម័យ តែថវិកាជាង ៨០% ដែលវិនិយោគលើការសាងសង់អនាម័យនៅតាមគ្រួសារ ត្រូវទទួលបន្ទុកដោយគ្រួសារខ្លួនឯងផ្ទាល់ចំពោះការចំណាយទាំងនោះ[41]។ ដោយហេតុថាមូលនិធិសម្រាប់ឧបត្ថម្ភធនដល់គ្រួសារនៅតាមជនបទឱ្យមានបង្គន់មានចំនួនមិនគ្រប់គ្រាន់នោះប្រការសំខាន់ គឺត្រូវចំណាយមូលនិធិដែលមាននេះឱ្យមានប្រសិទ្ធភាព និងសក្តិសិទ្ធិ ។ លើសពីនេះទៅទៀត ការយល់ដឹងពីកត្តាលើកទឹកចិត្ត និងកត្តារាំងស្ទះ ដើម្បីឲ្យប្រជាពលរដ្ឋផ្លាស់ប្តូរទៅរកការអនុវត្តអនាម័យប្រកបដោយសុវត្ថិភាព ក៏នៅមិនទាន់គ្រប់គ្រាន់ផងដែរ ។

ហេតុនេះហើយវិធីសាស្ត្រដើម្បីឲ្យប្រជាពលរដ្ឋទទួលបានអនាម័យ នឹងផ្តោតទៅលើការបង្កើតតម្រូវការ ដើម្បីឱ្យប្រជាពលរដ្ឋ និងគ្រួសារនីមួយៗ មានតម្រូវការបង្គន់អនាម័យ និងអាចទទួលបានបង្គន់ទាំងនោះ ដោយការចំណាយខ្លួនឯងផ្ទាល់ ព្រមទាំងផ្តោតផងដែរទៅលើសេវាកម្ម ដើម្បីថែទាំបង្គន់ទាំងនោះក្នុង រយៈពេលវែង ដូចជាការបូមកាកសំណល់ចេញពីបង្គន់ និងការស្តារភក់ចេញពីលូស្តុកលាមកជាដើម ។ វិធីសាស្ត្រមួយចំនួន បានបង្ហាញពីភាពជោគជ័យរួចមកហើយនៅប្រទេសកម្ពុជា ក៏ប៉ុន្តែចាំបាច់ត្រូវធ្វើការស្រាវជ្រាវបន្តទៀត ដើម្បីបង្ហាញពីប្រសិទ្ធភាពរបស់វិធីសាស្ត្រទាំងនេះក្នុងរយៈពេលវែង ។ កិច្ចខិតខំប្រឹងប្រែងលើការលើកកម្ពស់អនាម័យនឹងផ្តោតទៅលើ ៖

- **ការផ្លាស់ប្តូរទម្លាប់អនាម័យ** តាមរយៈវិធីសាស្ត្រដូចជា សហគមន៍ដឹកនាំអនុវត្តអនាម័យ (Commu-nity-Ley Total Sanitation)។ ចាំបាច់ត្រូវទទួលស្គាល់ថា ការសម្រេចបានអនាម័យដែលមានការកែលំអ ទាល់តែឆ្លងកាត់តាមដំណាក់កាលជាច្រើនរួមមានដំណាក់កាលទី១ គឺត្រូវឱ្យប្រជាពលរដ្ឋពិចារណាចំពោះទម្លាប់របស់ពួកគាត់ និងឱ្យពួកគាត់បង្កើតនូវតម្រូវការចង់បានបង្គន់អនាម័យ ។ ដំណាក់កាលទី២ គឺត្រូវធានាឱ្យប្រជាជនដែលមិនទាន់មានលទ្ធភាពទិញសម្ភារៈសាងសង់បង្គន់ ត្រូវប្រើប្រាស់បង្គន់សាមញ្ញសិន (Basic level of toilet) ហើយដំណាក់កាលទី៣ គឺត្រូវធានាឱ្យ ប្រជាពលរដ្ឋមានបង្គន់អនាម័យដែលមានការកែលំអប្រើប្រាស់ ។
- **ទីផ្សារអនាម័យ (Sanitation Marketing)** ចំពោះប្រភេទបង្គន់ជាច្រើន ដែលមានតម្លៃសមរម្យប្រជាជនអាចទិញបាន ជាពិសេសសម្រាប់អ្នកក្រីក្រ ។
- **ការកសាងសមត្ថភាពដល់វិស័យឯកជន** និងការធានានូវបរិយាកាសដែលអាចឱ្យសហគ្រាសខ្នាតតូចផ្តល់សេវាកម្មអនាម័យបាននៅតាមតំបន់ជនបទ ។

[41] (កម្មវិធីទឹក និងអនាម័យ ឆ្នាំ២០០៨)

- **ការអភិវឌ្ឍយន្តការផ្នែកហិរញ្ញវត្ថុ** ដើម្បីធានាថា គ្រួសារក្រីក្រអាចមានលទ្ធភាពទិញបង្គន់ បានកំណត់នៅក្នុងផ្នែកទី៥.១.២ .
- **បន្តការសិក្សា** ដោយប្រើក្របខ័ណ្ឌដូចជា SaniFOAM[42] ដើម្បីស្វែងយល់ពីឥរិយាបថផ្នែកអនាម័យ និងបង្កើតនូវវិធីសាស្ត្រទទួលបានអនាម័យដ៏ប្រសិទ្ធភាព ។

| **លទ្ធផល** | ប្រជាពលរដ្ឋតាមគ្រួសារទិញសម្ភារសាងសង់ និងប្រើប្រាស់បង្គន់អនាម័យ | **ការទទួលខុសត្រូវ** |
|---|---|---|
| **សកម្មភាព** | ◆ កំណត់បង្កើតប្រព័ន្ធផ្សព្វផ្សាយ និងវាយតម្លៃវិធីសាស្ត្រ នានា ដូចជា សហគមន៍ដឹកនាំអនុវត្តន៍អនាម័យ ដើម្បីផ្លាស់ប្តូរទម្លាប់អនាម័យផ្ទាល់ខ្លួន។<br>◆ អនុវត្តវិធីសាស្ត្រនានាដើម្បីជំរុញឱ្យសហគមន៍ និងគ្រួសារនីមួយៗផ្លាស់ប្តូរទម្លាប់ក្នុងការឈានទៅរកការប្រើប្រាស់បង្គន់អនាម័យ<br>◆ លើកស្ទួយផលិតផលផ្នែកអនាម័យ នៅតាមទីផ្សារ នៅតាមមូលដ្ឋាន តាមរយៈដំណើរការទីផ្សារសង្គម ។<br>◆ បង្កើតឱ្យមានផលិតផល និងសេវាកម្មអនាម័យនៅ តាមស្រុក ឃុំ និងសហគមន៍ តាមរយៈការកសាង សមត្ថភាពជាងសំណង់ និងទីផ្សារក្នុងមូលដ្ឋាន។<br>◆ ទិញសម្ភារសាងសង់បង្គន់។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ តាមរយៈ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងការិយាល័យអភិវឌ្ឍន៍ជនបទស្រុក<br>◆ ការិយាល័យអភិវឌ្ឍន៍ជនបទស្រុកតាមរយៈ អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន<br>◆ វិស័យឯកជន<br>◆ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័ននានា ដែលបណ្តុះបណ្តាលកិច្ចការ អាជីវកម្ម និងបច្ចេកទេស<br>◆ គ្រួសារ |

[42] (Devine, 2009) ការណែនាំអំពី SaniFOAM: ក្របខ័ណ្ឌវិភាគទម្លាប់អនាម័យ ដើម្បីកសាងនូវកម្មវិធីអនាម័យដែលមានប្រសិទ្ធភាព បោះពុម្ពដោយ កម្មវិធីទឹក និងអនាម័យ

## បច្ចេកវិទ្យាអនាម័យ

និយមន័យបច្ចេកទេសអនាម័យ ត្រូវបានកំណត់ជាពីរប្រភេទ គឺប្រភេទមានការកែលម្អ និងប្រភេទមិនមានការកែលម្អ ដូចមានបង្ហាញនៅក្នុងតារាងទី៨[43]។ ការបែងចែកនេះផ្អែកលើការកំណត់និយមន័យ ក្នុងកម្មវិធីពិនិត្យរួមគ្នា (Joint Monitoring Programme) របស់មូលនិធិអង្គការសហប្រជាជាតិ សម្រាប់កុមារ (UNICEF) និងអង្គការសុខភាពពិភពលោក (WHO)។ ការបែងចែកនេះនឹង ត្រូវប្រើប្រាស់សម្រាប់រាល់ការធ្វើអង្កេតទាំងអស់ ដែលចង់ពិនិត្យមើល ពីការទទួលបានសេវាផ្គត់ផ្គង់ ទឹកស្អាត និងអនាម័យដែលមានការកែលម្អ។

### តារាងទី៨៖ ជម្រើសបង្គន់អនាម័យដែលមានការកែលម្អ និងមិនមានការកែលម្អ

| ជម្រើសបង្គន់អនាម័យដែលមានការកែលម្អ | ជម្រើសបង្គន់អនាម័យមិនមានការកែលម្អ |
|---|---|
| ១. បង្គន់ចាក់ទឹកភ្ជាប់ទៅនឹងប្រព័ន្ធលូបង្ហូរទឹក (**Flush or pour flush to sewerage**) | ៥.បង្គន់អនាម័យសាធារណៈ ឬ បង្គន់ប្រើប្រាស់រួមគ្នា (**Any type of Public or shared latrine**) |
| ២. បង្គន់ចាក់ទឹកភ្ជាប់ទៅនឹងអាងស្តុកលាមក ឬរណ្តៅបង្គន់ (**Flush or pour flush to septic tank or pit**) | ៦. បង្គន់ចាក់ទឹកដែលភ្ជាប់ទៅនឹងកន្លែងផ្សេងទៀត (**Flush or pour flush to elsewhere**) |
| ៣. បង្គន់ស្ងួតមានផែនត្រឹមត្រូវសម្រាប់ជាន់ជុះ (**Pit latrine with slab**) | ៧. បង្គន់ស្ងួតគ្មានផែនត្រឹមត្រូវសម្រាប់ជាន់ជុះ (**Open pit latrine without slab**) |
| ៤. បង្គន់អនាម័យដែលបានកែលម្អឲ្យមានខ្យល់ចេញចូលក្នុងរណ្តៅ (**Ventilated Improved Pit latrine**) | ៨. បង្គន់ជុះដាក់ទឹក (**Latrine overhanging water**) |
| | ៩. ប្រភេទបង្គន់ផ្សេងៗទៀត |
| | ១០. គ្មានបង្គន់ |

### ២.១.១ ជម្រើសប្រភេទបង្គន់អនាម័យផ្សេងៗ និងការអភិវឌ្ឍផ្នែកបច្ចេកវិទ្យា

បើទោះជាគោលបំណងរយៈពេលវែង គឺធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋទទួលបាននូវជម្រើសបង្គន់អនាម័យដែលមានការកែលម្អក៏ដោយ ក៏មានការទទួលស្គាល់ថា គោលបំណងនេះអាចសម្រេចទៅបាន លុះត្រាតែដើរតាមដំណាក់កាលសន្សឹមៗប៉ុណ្ណោះ។ គោលបំណងដំបូងគឺត្រូវធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋផ្លាស់ប្តូរឥរិយាបថដោយបន្ទោបង់ក្នុងបង្គន់អនាម័យទោះជាប្រភេទដែលមានការកែលម្អ ឬ ក៏ប្រភេទបង្គន់មិនមានការកែលម្អ (បង្គន់សាមញ្ញ) ក៏ដោយ វាប្រសើរជាងការបន្ទោរបង់ពាសវាល

[43] (ក្រសួងអភិវឌ្ឍន៍ជនបទ និងដៃគូអភិវឌ្ឍ ឆ្នាំ២០០៨)

៣សកាល ។ ចំណែងគោលបំណងរយៈពេលមធ្យមគឺថា នៅពេលដែលប្រជាជនចាប់ផ្តើមអនុវត្តគោលការណ៍អនាម័យហើយនោះយើងនឹងជំរុញពួកគាត់ឱ្យជ្រើសរើសការប្រើប្រាស់បង្គន់អនាម័យដែលមានការកែលម្អ ដោយអភិវឌ្ឍបង្គន់បន្តិចម្តងៗ។

ដើម្បីឱ្យប្រជាពលរដ្ឋក្រីក្របំផុត អនុវត្តបាននូវគោលការណ៍លើកកម្ពស់អនាម័យ យើងត្រូវការបន្ថែមនូវជំហានជាច្រើននៅដំណាក់កាលដំបូង ក្នុងគោលបំណងផ្តល់ឱ្យពួកគាត់នូវជម្រើសមានតម្លៃទាបជាច្រើនទៀត ដែលមានលក្ខណៈសមរម្យសម្រាប់ស្ត្រី កុមារ និងជនពិការ ។

| **លទ្ធផល** | ជម្រើសប្រភេទបង្គន់អនាម័យដែលមានតម្លៃសមស្រប អាចឲ្យគ្រួសារក្រីក្របំផុតទិញបាន | **ការទទួលខុសត្រូវ** |
|---|---|---|
| **សកម្មភាព** | ◆ ធ្វើការសិក្សាស្រាវជ្រាវ ដើម្បីកំណត់នូវជម្រើសបង្គន់អនាម័យដែលមានតម្លៃថោក (ទាំងនៅក្នុងប្រទេសកម្ពុជា និងប្រទេសផ្សេងៗទៀត) ហើយបង្កើត និងផ្សព្វផ្សាយប្លង់គំរូបង្គន់ ដែលសមស្របសម្រាប់ប្រើប្រាស់នៅសហគមន៍។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ |

នៅប្រទេសកម្ពុជា ប្រភេទបង្គន់អនាម័យដែលមានតម្លៃសមរម្យ នៅមិនទាន់មានគ្រប់គ្រាន់នៅឡើយទេ នៅតាមភូមិបណ្តែតទឹក និងតំបន់លិចទឹក ។

| លទ្ធផល | ជម្រើសប្រភេទបង្គន់អនាម័យ ដែលមាន តម្លៃសមស្របសម្រាប់គ្រួសាររស់នៅក្នុងតំបន់លិចទឹក (**Flood-prone areas**)និងនៅតាមភូមិបណ្តែតទឹក (**Floating villages**) | ការទទួលខុសត្រូវ |
|---|---|---|
| សកម្មភាព | ◆ ធ្វើការសិក្សាស្រាវជ្រាវ ដើម្បីកំណត់ប្រភេទបង្គន់ (ទាំងនៅក្នុងប្រទេសកម្ពុជា និងប្រទេសផ្សេងៗទៀត) ហើយបង្កើត និងធ្វើតេស្តសាកល្បង លើប្រភេទបង្គន់ ដែលសមស្របសម្រាប់ភូមិលិចទឹក និងភូមិបណ្តែតទឹក ស្របទៅតាមនីតិវិធីស្រាវជ្រាវ និងអភិវឌ្ឍន៍ ក្នុងសមាសភាគ ៤.៦។ | ក្រសួងអភិវឌ្ឍន៍ជនបទ |

## សមាសភាគ២.២. ៖ ប្រតិបត្តិការ និងការថែទាំ

គ្រួសារនីមួយៗ នឹងទទួលខុសត្រូវលើការថែទាំ ការពារការខូចខាត និងការកែប្រែបង្គន់ របស់ពួកគេឲ្យរឹតតែមានអនាម័យ ។

## សាលារៀន និងគ្រឹះស្ថានសុខាភិបាល

អ្នកគ្រប់គ្រងសាលារៀន ឬគ្រឹះស្ថានសុខាភិបាលនឹងទទួលខុសត្រូវចំពោះប្រតិបត្តិការ និង ការថែទាំបង្គន់អនាម័យ សម្រាប់ផ្តល់ជូនដល់បុគ្គលិក សិស្ស និងអ្នកជម្ងឺ ។

## ការស្តារសម្អាតអាងស្តុកលាមក និងរណ្តៅបង្គន់

បង្គន់ស្ងួត និងបង្គន់ចាក់ទឹក តម្រូវឱ្យមានការបង្ហូរ ឬបូមកាកសំណល់ចេញ ព្រមទាំងស្តារភក់ចេញពីអាងស្តុកលាមក ។ ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក នឹងធ្វើការជាមួយវិស័យឯកជន ដើម្បីបង្កើតសេវាកម្មបូមកាកសំណល់លាមក ព្រមទាំងផ្តល់ការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងកាកសំណល់ ប្រកបដោយសុវត្ថិភាព ក្រោមការគាំទ្រពីសំណាក់មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ។

| **លទ្ធផល** | អ្នកផ្តល់សេវាកម្មដែលមាននៅមូលដ្ឋាន អាចអនុវត្តការគ្រប់គ្រងសំណល់អាងស្តុកលាមក និងស្តារយកកាកសំណល់ចេញពីបង្គន់ប្រកបដោយសុវត្ថិភាព ស្របតាមនីតិវិធីប្រតិបត្តិការ | **ការទទួលខុសត្រូវ** |
|---|---|---|
| **សកម្មភាព** | ◆ បង្កើតនីតិវិធីសម្រាប់ការគ្រប់គ្រងកាកសំណល់នៃអាងស្តុកលាមក និងស្តារយកកាកសំណល់ចេញ។<br>◆ បង្កើតប្រព័ន្ធសម្រាប់បន្សុទ្ធ ការទុកដាក់កាកសំណល់ ឬ ការប្រើប្រាស់ឡើងវិញនូវកាកសំណល់នៃអាងស្តុកលាមកពីបង្គន់។<br>◆ បង្កើតសេវាស្តារសម្អាតអាងស្តុកលាមក និងរណ្តៅបង្គន់រួមជាមួយនឹងការបណ្តុះបណ្តាលពីការទុកដាក់កាកសំណល់បង្គន់ប្រកបដោយសុវត្ថិភាព។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ វិស័យឯកជន ក្រោមការឧបត្ថម្ភពីមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក |

## សមាសភាគ ២.៣ ៖ អនាម័យនៅតាមសាលារៀន គ្រឹះស្ថានសុខាភិបាល និងស្ថាប័នដទៃទៀត នៅតាមជនបទ

### ២.៣.១ អនាម័យនៅតាមសាលារៀន និងការអប់រំអនាម័យផ្ទាល់ខ្លួន

នៅពេលដែលសាលារៀនខ្វះខាតការផ្គត់ផ្គង់ទឹកជាមូលដ្ឋានក៏ដូចជាបង្គន់អនាម័យ និងកន្លែងលាងដៃ សិស្សសាលាទាំងនោះនឹងមិនមានទម្លាប់អនុវត្តអនាម័យល្អទេ ដូច្នេះការកើតមាន ជំងឺលើកុមារ ដូចជាជំងឺរាក និងជំងឺព្រូនចំពោះសិស្សសាលានឹងមានកម្រិតខ្ពស់ ។ ជាលទ្ធផល បញ្ហានេះនឹង ប៉ះពាល់ដល់ការចូលរៀនរបស់កុមារ បន្ថយអត្រាចុះឈ្មោះចូលរៀន បង្កើនអវត្តមានរបស់សិស្ស និងធ្វើឱ្យគុណភាពសិក្សាក្នុងថ្នាក់ធ្លាក់ចុះ ព្រមទាំងធ្វើឱ្យកុមារឆាប់បោះបង់ចោលការសិក្សាទៀតផង ។ ជំងឺក៏បានធ្វើឱ្យសមត្ថភាពសិក្សាធ្លាក់ចុះផងដែរ ដែលត្រូវបានវាស់ស្ទង់បានតាមរយៈសកម្មភាពសិក្សា លទ្ធផលនៃការសិក្សា និងផលិតភាពនៃការសិក្សា ។ កង្វះកន្លែងអនាម័យសមរម្យអាចបង្អាក់កុមារមិន ឱ្យចូលរៀន ជាពិសេសក្មេងស្រីក្នុងអំឡុងពេលកំពុងមានរដូវ អាចមិនទៅសាលាដោយសារតែកង្វះភាព បិទបាំង ។

ដោយសារតែកុមារបានចំណាយពេលវេលាជាច្រើននៅក្នុងសាលា និងជុំវិញបរិវេណសាលា ដូច្នេះបរិស្ថានសាលាចាំបាច់ត្រូវតែប្រកបដោយសុខភាព សុវត្ថិភាព និងសន្តិសុខ ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការរៀនសូត្រ ឱ្យស្របទៅតាមគោលនយោបាយជាតិស្តីពីសាលាកុមារមេត្រី ( **Child Friendly School** )[44] ។ ការផ្តល់សំណង់បង្គន់អនាម័យ ដោយបែកចែកបន្ទប់បុរស និងស្ត្រីអាចជាវិធីមួយដើម្បីបង្កើនការចូលរៀនរបស់ក្មេងស្រី ។ ម្យ៉ាងទៀត សាលារៀនក៏បានផ្តល់ឱកាស ឲ្យកុមារដែលជាអ្នកស្ថិតក្រោមការថែទាំពីសាលា ជាមួយនឹង “ គំរូ ” ផ្នែកអនាម័យផងដែរ ។ ពីព្រោះតែស្ថានភាព បង្គន់គ្មានអនាម័យនៅតាមសាលារៀន បានធ្វើឱ្យកុមារយល់ខុសពីសារៈសំខាន់នៃអនាម័យ ហេតុនេះសាលារៀនត្រូវក្លាយទៅជាកន្លែងល្អបំផុត ដើម្បីបង្កើតឥរិយាបថអនាម័យផ្ទាល់ខ្លួនល្អ (ក៏ដូចជាឥរិយាបថដទៃទៀត) ព្រមទាំងផ្តល់នូវគំរូបរិស្ថានដ៏រឹងមាំ ។ កុមារដែលរៀនពីការអនុវត្តអនាម័យល្អនៅសាលា អាចក្លាយទៅជាអ្នកផ្សព្វផ្សាយផ្នែកសុខភាពដ៏សំខាន់នៅតាមផ្ទះ[45] ។

---

[44] ក្រសួងអប់រំយុវជន និងកីឡា ឆ្នាំ២០០៧

[45] (Mooijman, Berg, Jensen, & Bundy, 2005)

| លទ្ធផល | សាលារៀនមានបង្គន់អនាម័យដែលមានការកែលំអហើយសិស្សានុសិស្ស យល់ដឹង ពីការអនុវត្តអនាម័យផ្ទាល់ខ្លួនប្រកប ដោយសុវត្ថិភាព | ការទទួលខុសត្រូវ |
|---|---|---|
| សកម្មភាព | ◆ បង្កើតនូវបទដ្ឋានថ្នាក់ជាតិ ដែលមានការកំណត់ពីចំនួនសិស្ស និងបុគ្គលិកសម្រាប់បង្គន់នីមួយៗ និងមានការបែងចែកបន្ទប់បង្គន់សម្រាប់ក្មេងប្រុស ក្មេងស្រី បុគ្គលិក និងកុមារពិការ។<br>◆ រៀបចំ និងថែទាំបញ្ជីសារពើភ័ណ្ឌសំណង់ផ្គត់ផ្គង់ទឹក និងសំណង់បង្គន់អនាម័យ ដែលមានស្រាប់ក្នុងសាលា រួមបញ្ចូលទាំងស្ថានភាពធ្វើឱ្យដំណើរការបង្គន់អនាម័យ និងទឹកនៅគ្រប់សាលាទាំងអស់។<br>◆ សាងសង់បង្គន់អនាម័យសមស្របនៅតាមសាលារៀនទាំងអស់ក្នុងតំបន់ជនបទ ដោយប្រើ វិធីសាស្ត្រឆ្លើយតបទៅតាមតម្រូវការ។<br>◆ បង្កើត និងផ្តល់នូវការអប់រំមូលដ្ឋានពីបំនិនជីវិត ដែលជាផ្នែកមួយនៃកម្មវិធីសិក្សាស្នូល ស្របគ្នាជាមួយនឹងការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ។ | ◆ ក្រសួងអប់រំ យុវជន និង កីឡា និង ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអប់រំ យុវជន និង កីឡា រួមជាមួយនឹងសាលារៀន<br>◆ ក្រសួងអប់រំ យុវជន និងកីឡា រួមជាមួយ សាលារៀន<br>◆ ក្រសួងអប់រំ យុវជន និងកីឡា រួមជាមួយ សាលារៀន |

ក្រោមវិធីសាស្ត្រឆ្លើយតបទៅនឹងតម្រូវការ សាលារៀននឹងជ្រើសរើសជម្រើសនានាទាក់ទងនឹងកម្រិតនៃការចូលរួម សេវាកម្ម និងយន្តការនៃការផ្តល់សេវា ។វិធីសាស្ត្រប្រភេទនេះ អាចធ្វើឱ្យសាលារៀនធ្វើការសម្រេចចិត្តលើការវិនិយោគអនាម័យ និងការផ្គត់ផ្គង់ទឹក និងធ្វើឱ្យសាលានោះកំណត់ប្រភេទបច្ចេកវិទ្យា និងកម្រិតនៃសេវាកម្ម ដែលគេពេញចិត្ត ដោយផ្អែកលើឆន្ទៈក្នុងការចូលរួម ។ វិធីសាស្ត្រឆ្លើយតបទៅនឹងតម្រូវការ នឹងធានាថា បុគ្គលិកសាលារៀន កុមារ (ទាំងកុមារា កុមារី) គណៈកម្មាធិការទ្រទ្រង់សុខភាពសាលារៀន ដែលមានស្រាប់ព្រមទាំងភាគីពាក់ព័ន្ធសំខាន់ៗផ្សេងទៀតចូលរួម ក្នុងការរៀបចំផែនការអនុវត្ត ប្រើប្រាស់ និងថែទាំសេវាផ្គត់ផ្គង់ទឹកស្អាត បង្គន់អនាម័យ និងការប្រតិបត្តិអនាម័យផ្ទាល់ខ្លួន[46]។

[46] (Mooijman et al., 2005)

### ២.៣.២. អនាម័យនៅតាមគ្រឹះស្ថានសុខាភិបាលនិងស្ថាប័នដទៃទៀតនៅតាមជនបទ

| លទ្ធផល | គ្រឹះស្ថានសុខាភិបាល និងស្ថាប័នដទៃទៀត នៅតាមទីជនបទ មានបង្គន់អនាម័យ ដែលមានការថែលម្អ | ការទទួលខុសត្រូវ |
|---|---|---|
| សកម្មភាព | ◆ បង្កើតបទដ្ឋានថ្នាក់ជាតិ ដែលមានកំណត់ពីចំនួនអ្នកជំងឺសម្រាកក្នុងមណ្ឌលសុខភាព និងអ្នកជំងឺដែលមកពិគ្រោះជំងឺ សម្រាប់បង្គន់អនាម័យនីមួយៗ ដោយមានការបែងចែកបន្ទប់បង្គន់សម្រាប់បុរស ស្ត្រី និងជនពិការ។ | ◆ ក្រសួងសុខាភិបាល |
| | ◆ រៀបចំ និងថែរក្សាបញ្ជីសារពើភ័ណ្ឌនៃសំណង់ផ្គត់ផ្គង់ទឹក និងបង្គន់អនាម័យដែលមានស្រាប់ ដោយរាប់បញ្ចូលទាំងស្ថានភាពដំណើរការរបស់វា នៅតាមគ្រឹះស្ថានសុខាភិបាល និងស្ថាប័នដទៃទៀត នៅទីជនបទ។ | ◆ ក្រសួងសុខាភិបាល រួមជាមួយនឹង ការិយាល័យសុខាភិបាលស្រុក ឬអាជ្ញាធរ ពាក់ព័ន្ធ |
| | ◆ សាងសង់បង្គន់អនាម័យនៅគ្រប់គ្រឹះស្ថានសុខាភិបាល និងស្ថាប័នដទៃទៀត នៅទីជនបទ ដោយប្រើវិធីសាស្ត្រឆ្លើយតបតាមតម្រូវការ | ◆ ក្រសួងសុខាភិបាល រួមជាមួយនឹង ការិយាល័យ សុខាភិបាលស្រុក ឬ ស្ថាប័នពាក់ព័ន្ធ |

### ២.៣.៣ អនាម័យបរិស្ថាន ទាំងកាកសំណល់រឹងនិងរាវ

ការគ្រប់គ្រងកាកសំណល់រាវនៅមិនទាន់បានចាត់ទុកថាជាបញ្ហាសំខាន់នៅឡើយទេមកទល់បច្ចុប្បន្ននេះ សហគមន៍ជារឿយៗបានប្រើប្រាស់កាកសំណល់រាវដោយផ្ទាល់ដើម្បីដាំបន្លែបង្កា និងដំណាំផ្សេងៗជាលក្ខណៈខ្នាតតូច ។ ចាំបាច់ត្រូវមានការសិក្សាពីបញ្ហា ដើម្បីកំណត់វិសាលភាព និងទំហំនៃបញ្ហា ក៏ដូចជាដើម្បីកំណត់នូវសកម្មភាពដែលត្រូវធ្វើ ។

ស្រដៀងគ្នានេះដែរ ការចោលកាកសំណល់រឹង ក៏មិនទាន់បានលើកមកដោះស្រាយ នៅឡើយទេ តាមតំបន់ជនបទ ។ បញ្ហាគ្រប់គ្រងកាកសំណល់រឹង ទំនងកាន់តែរីកធំឡើងៗ ជាមួយនឹងការកើនឡើងនៃការប្រើប្រាស់កញ្ចប់ចង់ ដែលបានលក់នៅតាមតំបន់ជនបទ និងការកើនឡើងនូវការប្រើប្រាស់ថង់ប្លាស្ទិក ។ ជាថ្មីម្តងទៀតត្រូវមានការសិក្សាពីបញ្ហានេះ ដើម្បីកំណត់វិសាលភាព និងទំហំនៃបញ្ហា ក៏ដូចជាដើម្បីកំណត់នូវសកម្មភាពដែលត្រូវធ្វើ ។

| លទ្ធផល | ផែនការ សម្រាប់អនុវត្តជាយុទ្ធសាស្រ្ត សម្រាប់ អនាម័យបរិស្ថាន ដោយផ្អែកលើតម្រូវការជាក់ស្តែង | ការទទួលខុសត្រូវ |
|---|---|---|
| សកម្មភាព | ◆ ធ្វើការសិក្សាស្រាវជ្រាវពីប្រព័ន្ធបង្ហូរកាកសំណល់រាវ ដើម្បីវាយតម្លៃទំហំនៃបញ្ហា និងសំណើដំណោះស្រាយជាយុទ្ធសាស្ត្រ។<br>◆ ធ្វើការសិក្សាស្រាវជ្រាវពីកាកសំណល់រឹង ដើម្បីវាយតម្លៃទំហំនៃបញ្ហា និងសំណើដំណោះស្រាយជាយុទ្ធសាស្ត្រ។<br>◆ អភិវឌ្ឍ និងអនុវត្តផែនការដើម្បីដោះស្រាយការបង្ហូរ កាកសំណល់រាវ និងការទុកដាក់សំណល់រឹង។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ និងមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត |

## គោលដៅយុទ្ធសាស្រ្តទី ៣ ៖ ការផ្លាស់ប្តូរឥរិយាបថផ្នែកអនាម័យផ្ទាល់ខ្លួន

### សមាសភាគ ៣.១ ៖ ការលើកកម្ពស់អនាម័យផ្ទាល់ខ្លួន

ថ្មីៗនេះ ក្រសួងអភិវឌ្ឍន៍ជនបទ និងដៃគូអភិវឌ្ឍន៍នានា ដែលធ្វើការទាក់ទិននឹងការផ្លាស់ប្តូរឥរិយាបថផ្នែកអនាម័យផ្ទាល់ខ្លួន បានសម្រេចចិត្តផ្តោតលើឥរិយាបថប្រឈមនឹងគ្រោះថ្នាក់សំខាន់បីដែលត្រូវធ្វើការយកចិត្តទុកដាក់តាមរយៈការលើកកម្ពស់ផ្នែកអនាម័យ ៖

- ការបន្ទោបង់ពាសវាលពាសកាល
- ការមិនលាងសម្អាតដៃ
- ការបរិភោគទឹកគ្មានសុវត្ថិភាព

ក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មការទទួលបន្ទុកស្ត្រី និងកុមារឃុំ សង្កាត់ បានសង្កេតឃើញពីតម្រូវការនៃការអប់រំជាបន្តបន្ទាប់ពីការផ្លាស់ប្តូរឥរិយាបថផ្នែកអនាម័យផ្ទាល់ខ្លួន បន្ទាប់ពីសកម្មភាពផ្សព្វផ្សាយលើកដំបូង ។

ការវាយតម្លៃពីប្រសិទ្ធភាពនិងផលប៉ះពាល់នៃសកម្មភាពរបស់គម្រោងដែល ព្យាយាមលើកកម្ពស់ការផ្លាស់ប្តូរឥរិយាបថផ្នែកអនាម័យផ្ទាល់ខ្លួននេះនៅ មានការលំបាក ព្រោះថាមានការស្រាវជ្រាវមូលដ្ឋាន (**Baseline**) តិចតួចដែលអាចឲ្យយើងវាស់វែងពីការផ្លាស់ប្តូរ ឥរិយាបថទាំងនោះ។ ដោយហេតុថាការអង្កេតនៅមានកម្រិត ភាគច្រើនផ្អែកលើកម្រងសំណួរ ដោយគ្មានការធ្វើសង្កេតដោយផ្ទាល់ នោះឡើយ ។ ហេតុនេះហើយទើបលទ្ធផលដែលបានមក គឺគ្រាន់តែបង្ហាញពីការយល់ឃើញ និង ឥរិយាបថរបស់ប្រជាពលរដ្ឋ ប៉ុន្តែមិនប្រាកដថាជាការអនុវត្តជាក់ស្តែងរបស់ពួកគាត់នោះទេ ។

| លទ្ធផល | ប្រជាពលរដ្ឋបានយល់ដឹង និងអនុវត្ត អនាម័យផ្ទាល់ខ្លួនប្រកបដោយសុវត្ថិភាព ពាក់ព័ន្ធនឹងការប្រើប្រាស់ទឹកស្អាត និងបង្គន់អនាម័យ | ការទទួលខុសត្រូវ |
|---|---|---|
| សកម្មភាព | ◆ អនុម័ត និងផ្សព្វផ្សាយគោលការណ៍ណែនាំ ស្តីពីការលើកកម្ពស់អនាម័យផ្ទាល់ខ្លួន តាមដានត្រួតពិនិត្យការអនុវត្ត និងវាយតម្លៃប្រសិទ្ធភាពនៃការផ្លាស់ប្តូរទម្លាប់ក្នុងការប្រតិបត្តិអនាម័យល្អ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសុខាភិបាល |
| | ◆ ពិនិត្យមើលឡើងវិញ និងកែសម្រួលគោលការណ៍ណែនាំ ស្តីពីការលើកកម្ពស់អនាម័យផ្ទាល់ខ្លួន បន្ទាប់ពីការវាយ តម្លៃប្រសិទ្ធភាពនៃការអនុវត្តគោលការណ៍ណែនាំនេះ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសុខាភិបាល |
| | ◆ ធ្វើការអង្កេតទិន្នន័យមូលដ្ឋាន និងតាមដានការអនុវត្តអនាម័យ ហើយរាយការណ៍លទ្ធផលទៅឱ្យការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ។ | ◆ ស្ថាប័នលើកកម្ពស់ ការផ្លាស់ប្តូរទម្លាប់ អនាម័យ |
| | ◆ ធ្វើយុទ្ធនាការផ្សព្វផ្សាយពីការផ្លាស់ប្តូរឥរិយាបថអនាម័យខ្លួនប្រាណ នៅតាមសហគមន៍ និងតាមផ្ទះ។ | ◆ ការិយាល័យអភិវឌ្ឍន៍ជនបទស្រុកតាមរយៈគណៈកម្មការទទួលបន្ទុកស្ត្រី និងកុមារឃុំ និងស្ថាប័នលើកកម្ពស់ការផ្លាស់ប្តូរទម្លាប់អនាម័យ |
| | ◆ ធ្វើការអប់រំបណ្តុះបណ្តាលជាទៀងទាត់ និងវគ្គបំប៉នស្តីពីការផ្លាស់ប្តូរឥរិយាបថអនាម័យផ្ទាល់ខ្លួន | ◆ គណៈកម្មការ ទទួលបន្ទុកស្ត្រី និងកុមារឃុំ រួមជាមួយនឹងមន្ត្រីលើកកម្ពស់អនាម័យ នៃការិយាល័យអភិវឌ្ឍន៍ជនបទស្រុក |

## គោលដៅយុទ្ធសាស្ត្រទី៤ ៖ ការអភិវឌ្ឍនិងការប្រតិបត្តិលើមធ្យោបាយនានាដើម្បីសម្រេច ឱ្យបានសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទប្រកបដោយនិរន្តរភាព

### សមាសភាគ ៤.១ ៖ ការគ្រប់គ្រងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ

យុទ្ធសាស្ត្រតម្រូវឱ្យមានការផ្លាស់ប្តូរសំខាន់ៗ នៅក្នុងការរៀបចំស្ថាប័នសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យដែលរួមមានការធ្វើវិមជ្ឈការលើការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យ

ដល់ថ្នាក់ស្រុក តាមរយៈវិស័យឯកជន ក៏ដូចជាសកម្មភាពលើចំណុចជាក់លាក់មួយចំនួន ។ ក្រសួងអភិវឌ្ឍន៍ជនបទនឹងដឹកនាំ ការសម្របសម្រួលជាមួយស្ថាប័ន ដែលពាក់ព័ន្ធដូចជាក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងគណៈកម្មការសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NCDD) ។

| **លទ្ធផល** | វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ត្រូវបានរៀបចំឲ្យបានសមស្រប និងដំណើរការប្រកបដោយប្រសិទ្ធភាព ដើម្បីឱ្យដំណើរការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងទស្សនវិស័យរបស់គោលនយោបាយជាតិស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ | **ការទទួលខុសត្រូវ** |
|---|---|---|
| **សកម្មភាព** | ◆ សម្របសម្រួល និងគ្រប់គ្រងសកម្មភាពនានានៃការផ្លាស់ប្តូរស្ថាប័ន ក្នុងយុទ្ធសាស្រ្តនេះ រួមជាមួយនឹងផែនការសកម្មភាព ០៥ឆ្នាំ។<br>◆ តាមដានត្រួតពិនិត្យការរីកចម្រើនសកម្មភាព និងសមិទ្ធផលរបស់យុទ្ធសាស្រ្ត ស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និង អនាម័យជនបទ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ |

## ៤.១.១ ការរៀបចំអង្គភាពស្ថាប័ន និងការកែសម្រួលរចនាសម្ព័ន្ធក្រោមប្រព័ន្ធវិមជ្ឈការ និង វិសហមជ្ឈការ

ទស្សនវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានលើកឡើងនៅក្នុងក្របខ័ណ្ឌយុទ្ធសាស្រ្តសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺដើម្បី ៖

បង្កើតប្រព័ន្ធគ្រប់គ្រងថ្នាក់រាជធានី ខេត្ត-ក្រុង ស្រុក-ខណ្ឌ និងឃុំ-សង្កាត់ ដោយផ្អែក លើគោលការណ៍ “ **ការចូលរួមតាមបែបប្រជាធិបតេយ្យ** ” ។ ប្រព័ន្ធនេះនឹងប្រតិបត្តិការដោយមានតម្លាភាព និងគណនេយ្យភាពដើម្បីលើកកម្ពស់ការអភិវឌ្ឍថ្នាក់មូលដ្ឋាននិងការផ្តល់សេវាសាធារណៈដើម្បីបំពេញឱ្យបាននូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងដែនដីរៀងៗខ្លួន ។[47]

[47] (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៥)

ទិសដៅគោលនយោបាយនេះ ត្រូវបានបញ្ជាក់តាមការអនុម័តច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (“ច្បាប់អង្គការ organic law”)[48] ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (ផយអជ) ក៏ទទួលស្គាល់ពីសេចក្តីត្រូវការលើកកំណែទម្រង់ចាំបាច់ នៅក្នុងរដ្ឋបាលសាធារណៈ និងកំណែទម្រង់តាមវិស័យដើម្បីធ្វើឲ្យប្រសើរឡើង ឆ្ពោះទៅរកការសម្រេចបានទស្សនវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាល[49] ។

សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យតាមផ្ទះ គឺជាសេវាមូលដ្ឋានដ៏សំខាន់សម្រាប់សហគមន៍ និងគ្រួសារ ។ ហេតុនេះ ការរៀបចំឱ្យមានការផ្តល់សេវា ត្រូវបង្កើត និងគ្រប់គ្រងនៅថ្នាក់មូលដ្ឋាន ។

**ក្រុមប្រឹក្សាឃុំសង្កាត់** មិនអាចមានលទ្ធភាពជ្រើសរើសបុគ្គលិកបច្ចេកទេសជំនាញ សម្រាប់ការងារផ្គត់ផ្គង់ទឹកស្អាត និងអនាម័យបាននោះទេ ។ បច្ចុប្បន្ន អ្នកដែលមានចំណេះដឹងបទពិសោធន៍ និងសម្បទាសម្រាប់ការងារក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ នៅមានកម្រិតនៅឡើយ។ នាពេលអនាគត យុវជនវ័យក្មេងដែលនឹងចូលរួមក្នុងទីផ្សារការងារ ហើយមានចំណាប់អារម្មណ៍ធ្វើការនៅ ក្នុងវិស័យនេះក៏ទំនងនៅតែមានកម្រិតដដែល ។

ដោយធនធានមនុស្ស និងហិរញ្ញវត្ថុនៅមានកម្រិត ហេតុនេះហើយកម្រិតថ្នាក់ សមរម្យបំផុតសម្រាប់ការគ្រប់គ្រងការផ្តល់សេវានៅក្រោមគោលនយោបាយ និងច្បាប់វិមជ្ឈការ និងវិសហមជ្ឈការ គឺកម្រិតថ្នាក់ស្រុក ខណ្ឌ ដោយមានក្រុមប្រឹក្សាស្រុក ខណ្ឌ ជាអង្គភាពទទួលខុសត្រូវនៅមូលដ្ឋាន ដែលគាំទ្រដោយរដ្ឋបាលមួយ (រួមទាំងការិយាល័យបច្ចេកទេស) ដែលមានមន្ត្រីរាជការជាអ្នកបម្រើការងារក្នុងរដ្ឋបាលនោះ ។ ស្រុកនីមួយៗនឹងទទួលបានធនធានសមត្ថភាព និងហិរញ្ញវត្ថុ ដើម្បីបម្រើឱ្យក្រុមប្រឹក្សាឃុំ នៅក្នុងតំបន់ភូមិសាស្ត្ររបស់ខ្លួន ។ នៅដំណាក់កាលដំបូង ក្រសួងអភិវឌ្ឍន៍ជនបទនឹងពង្រឹងការិយាល័យអភិវឌ្ឍន៍ជនបទស្រុក។ នៅដំណាក់កាលក្រោយមកទៀត នៅពេលដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ មុខងារ និងតួនាទី របស់ការិយាល័យអភិវឌ្ឍន៍ជនបទស្រុកនឹងត្រូវពិនិត្យឡើងវិញ ដើម្បីឲ្យស្របទៅតាមបែបប្រជាធិបតេយ្យ សម្រាប់សេវាមូលដ្ឋាន។

| **លទ្ធផល** | ការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និង អនាម័យជនបទ និងការលើកកម្ពស់ អនាម័យផ្ទាល់ខ្លួន ត្រូវបានសម្របសម្រួល គ្រប់គ្រង និងតាមដានយ៉ាងមានប្រសិទ្ធភាពនៅថ្នាក់ស្រុក | **ការទទួលខុសត្រូវ** |
|---|---|---|
| **សកម្មភាព** | ◆ ពង្រឹងការិយាល័យអភិវឌ្ឍន៍ជនបទស្រុកតាមស្រុកនីមួយៗ ដោយមានការគាំទ្រពីមន្ទីរអភិវឌ្ឍន៍ជនបទ ខេត្ត។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ រួមជាមួយមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត |

48 (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៨ក)

49 កថាខណ្ឌ៣.០១ និង ៣.០៧ នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៦-២០១០

នាពេលបច្ចុប្បន្ន ថ្នាក់ស្រុកនៅមិនទាន់មានសមត្ថភាពនៅឡើយទេ ប៉ុន្តែនៅរយៈពេល០៥ឆ្នាំខាងមុខ ថ្នាក់ស្រុកនឹងអាចបង្កើតប្រព័ន្ធគាំទ ដែលចាំបាច់ដើម្បីផ្តល់លទ្ធភាពឱ្យសហគមន៍អាចទទួលបានសេវា និងរក្សាសេវានោះឱ្យមាននិរន្តរភាព។ ផ្នែកនេះកំណត់នូវស្ថានភាពដែលនៅចុងក្រោយ ដែលចាំបាច់ត្រូវធ្វើឡើងជាដំណាក់កាល ដើម្បីសម្រេចការងារនេះ ដូចមានកំណត់នៅក្នុងផែនការអនុវត្តន៍ដែលមានភ្ជាប់មកជាមួយ ។

### ៤.១.២ តួនាទី និងការទទួលខុសត្រូវក្រោមប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការ

តួនាទី និងការទទួលខុសត្រូវ ត្រូវបានកំណត់នៅក្នុងគោលនយោបាយជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ (ផ្នែក III - ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ)[50] ។ នៅថ្នាក់ក្រោមជាតិ ចំណុចទាំងនេះត្រូវបានជំនួសដោយចំណុចមួយចំនួន ហើយនឹងត្រូវកែសម្រួលឱ្យស្របទៅតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ[51] និងច្បាប់ដែលពាក់ព័ន្ធ[52] ។ ការផ្លាស់ប្តូរនៅថ្នាក់ជាតិ គឺថាក្រសួងអភិវឌ្ឍន៍ជនបទ ប្តូរពីការគ្រប់គ្រងគម្រោង និងកម្មវិធីទៅជាការគ្រប់គ្រងវិស័យដោយអនុលោមតាមគោលនយោបាយជាតិវិញ ។ តួនាទីទាំងឡាយត្រូវបានសង្ខេបនៅក្នុងតារាងទី៩ និងមានបង្ហាញជាដ្យាក្រាមនៅក្នុងឧបសម្ព័ន្ធទី៤ ។ តួនាទីលម្អិត មានបង្ហាញនៅក្នុងតារាងពីរ ក្នុងឧបសម្ព័ន្ធទី៥ ដែលតារាងមួយបង្ហាញអំពីការផ្តល់សេវា និងតារាងមួយទៀតបង្ហាញអំពីបរិយាកាសសមស្រប ។

---

[50] (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៣)

[51] ក្របខ័ណ្ឌជាយុទ្ធសាស្ត្រសម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (ឆ្នាំ២០០៥)

[52] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧

### តារាងទី៩ ៖ តួនាទី របស់អង្គភាពនីមួយៗ

| អង្គភាព ឬ ក្រុម | តួនាទី |
|---|---|
| ក្រសួងអភិវឌ្ឍន៍ជនបទ | ◆ ធានាឱ្យមានហិរញ្ញប្បទានសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ<br>◆ បង្កើត ផ្សព្វផ្សាយ និងអនុវត្តគោលនយោបាយ បទបញ្ញត្តិ និងយុទ្ធសាស្ត្រ ផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ<br>◆ រៀបចំផែនការសម្រាប់ដាក់អនុវត្តគោលនយោបាយ<br>◆ សម្របសម្រួល ជំនួយពីខាងក្នុង និងពីខាងក្រៅ ព្រមទាំងកិច្ចអន្តរាគមន៍លើវិស័យនេះ<br>◆ អភិវឌ្ឍ និងលើកកម្ពស់ជំនួយបច្ចេកទេស ក្នុងវិស័យធនធានមនុស្ស<br>◆ បង្កើតកម្មវិធីអភិវឌ្ឍន៍ ស្រាវជ្រាវ និងអប់រំសហគមន៍<br>◆ កសាង និងពង្រឹងយន្តការ ឬប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃសមត្ថភាព បំពេញការងាររបស់វិស័យនេះ ដើម្បីធានាវឌ្ឍនភាពឆ្ពោះទៅរកទស្សនវិស័យរបស់វិស័យនេះ តាមចំណុចគោលដៅ<br>◆ ការស្វែងរកការគាំទ្រ<br>◆ ដឹកនាំ និងសម្របសម្រួលការដល់ផ្តល់សេវាកម្មទឹកស្អាត និងអនាម័យ |
| មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត | ◆ ប្រមូលទិន្នន័យ និងព័ត៌មានចាំបាច់សម្រាប់ធ្វើផែនការ<br>◆ រៀបចំផែនការអភិវឌ្ឍន៍ខេត្ត និងថវិកាដែលពាក់ព័ន្ធ<br>◆ សម្របសម្រួល តាមដានត្រួតពិនិត្យ និងវាយតម្លៃគ្រប់កម្មវិធី និងគម្រោងអភិវឌ្ឍន៍ជនបទ<br>◆ ផ្តល់ការគាំទ្រ ដល់សហប្រតិបត្តិការ និងការសម្របសម្រួលអន្តរនាយកដ្ឋាន នៅក្នុងវិស័យសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទថ្នាក់ខេត្ត<br>◆ ផ្តល់ការគាំទ្រ ដល់ការអភិវឌ្ឍវិស័យឯកជន ជាពិសេសការអភិវឌ្ឍវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ<br>◆ ការស្វែងរកការគាំទ្រ |

| | |
|---|---|
| ការិយាល័យ អភិវឌ្ឍន៍ ជនបទស្រុក | ◆ ការអភិវឌ្ឍសមត្ថភាពរបស់ក្រុមប្រើប្រាស់ទឹក និងអនាម័យ គាំទ្រក្រុមប្រើប្រាស់ទឹក និងអនាម័យ (ណែនាំលើការគ្រប់គ្រង ហិរញ្ញវត្ថុ និងការថែទាំ ការដោះស្រាយជម្លោះ)<br>◆ ការឃ្លាំមើល និងត្រួតពិនិត្យគុណភាពទឹក<br>◆ ការប្រមូលទិន្នន័យ សម្រាប់ប្រព័ន្ធគ្រប់គ្រងព័ត៌មាន<br>◆ ការប្រឹក្សាបច្ចេកទេស សម្រាប់ការស្ថាបនា និងការគ្រប់គ្រងគុណភាព របស់ ហេដ្ឋារចនាសម្ព័ន្ធថ្មី<br>◆ ការគ្រប់គ្រងលើគុណភាពនៃការផ្តល់ហេដ្ឋារចនាសម្ព័ន្ធថ្មី<br>◆ ការលើកកម្ពស់អនាម័យផ្ទាល់ខ្លួន |
| វិស័យឯកជន | ◆ ផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និង អនាម័យជនបទ |
| អង្គការមិនមែន រដ្ឋាភិបាល[53] | ◆ ចូលរួមសម្រួលការផ្តល់សេវាកម្ម[54]<br>◆ ចូលរួមអប់រំសហគមន៍ ការលើកកម្ពស់ការយល់ដឹង ការលើកកម្ពស់ និងការធ្វើទីផ្សារអនាម័យ<br>◆ ចូលរួមកសាងភាពជាដៃគូ និងការលើកកម្ពស់បណ្តាញការងារ<br>◆ ចូលរួមកសាងសមត្ថភាព<br>◆ ចូលរួមស្រាវជ្រាវ និងការច្នៃប្រឌិត<br>◆ ចូលរួមក្នុងការសន្ទនាគោលនយោបាយ |

| **លទ្ធផល** | តួនាទីរបស់ស្ថាប័នក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ត្រូវបានកំណត់ច្បាស់លាស់ | **ការទទួលខុសត្រូវ** |
|---|---|---|
| **សកម្មភាព** | ◆ ដាក់ឱ្យប្រើប្រាស់សេចក្តីប្រកាស ដែលកំណត់ពីតួនាទីរបស់ស្ថាប័នពាក់ព័ន្ធក្នុងវិស័យនេះ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ |

## ៤.១.៣ អភិបាលកិច្ច និងគណនេយ្យភាព

គោលការណ៍មួយនៃគោលការណ៍កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺគណនេយ្យភាពវិស័យសាធារណៈ ដែលពង្រឹងគណនេយ្យភាពនៅគ្រប់ជាន់ថ្នាក់ ហើយដែលផ្តល់លទ្ធភាពឲ្យប្រជាពលរដ្ឋ ពិនិត្យលើកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុនៃរដ្ឋបាលទាំងនោះ ។ លើសពីនេះទៅទៀត ស្ថាប័ន និងបុគ្គល ទាំងអស់នៅក្នុងវិស័យនេះ មានគណនេយ្យភាពយ៉ាងច្រើនចំពោះសកម្មភាពរបស់ខ្លួន ជាលក្ខណៈសង្គមកិច្ច ហិរញ្ញវត្ថុ បច្ចេកទេស និងបរិស្ថាន ។

[53] ដកស្រង់ចេញពី (Carrard, Pedi, Willetts, & Powell, 2009)

[54] អង្គការមិនមែនរដ្ឋាភិបាល គួរជៀសវាងនិន្នាការបង្កើតរចនាសម្ព័ន្ធផ្តល់សេវាស្របគ្នា ដែលអាចបង្វែង ជាជាងបន្ថែម និងពង្រឹងការច្នៃប្រឌិតដែលមានស្រាប់ និងស្ថាប័ននានាក្នុងប្រទេស (Carrard et al., 2009) ។ ឧទាហរណ៍ ការផ្តល់សេវាផ្ទាល់ ដែលកាត់ការងារវិស័យឯកជន ។

| **លទ្ធផល** | មានយន្តការគណនេយ្យភាពប្រកប ដោយប្រសិទ្ធភាព សម្រាប់ការអនុវត្តនៅថ្នាក់មូលដ្ឋាន | **ការទទួលខុសត្រូវ** |
|---|---|---|
| **សកម្មភាព** | ◆ បង្កើតនីតិវិធីដើម្បីធ្វើឱ្យអាជ្ញាធរមូលដ្ឋាន មានគណនេយ្យភាពចំពោះសហគមន៍ ក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត អនាម័យ និងអនាម័យផ្ទាល់ខ្លួន រួមទាំងការប្រើប្រាស់យន្តការសហគមន៍ ដើម្បីតាមដាន និងត្រួតពិនិត្យនៃការផ្តល់សេវាកម្ម។<br>◆ បង្កើតគោលការណ៍ណែនាំ សម្រាប់រដ្ឋបាលមូលដ្ឋាន (អ្នកផ្តល់សេវា និងស្ថាប័នគាំទ្រ) ពីរបៀបក្នុងការធានាឲ្យបាននូវគណនេយ្យភាព ចំពោះអ្នកខាងលើ និងអ្នកខាងក្រោម។<br>◆ បង្កើតឲ្យមានប្រព័ន្ធមួយសម្រាប់ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ដើម្បីស្វែងរកព័ត៌មាន ទទួលព័ត៌មាន និងមតិត្រឡប់ (ឧទាហរណ៍ ការត្អូញត្អែរ) ដែលទទួលបានពីសហគមន៍ គ្រួសារ និងក្រុមប្រឹក្សាឃុំ រួមទាំងប្រព័ន្ធតាមដានប្រៀបធៀបការអនុវត្តរវាងថ្នាក់ស្រុក និងសហគមន៍នីមួយៗ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ |

## ៤.១.៤ គោលការណ៍ណែនាំ និងនីតិវិធី

គោលការណ៍ណែនាំ និងនីតិវិធី គឺជាការចាំបាច់ដើម្បីឲ្យវិធីសាស្ត្រ និងនីតិវិធី ក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ព្រមទាំងការលើកកម្ពស់អនាម័យមានបទដ្ឋានរួមមួយ ។ គោលការណ៍ណែនាំគួរកំណត់បទដ្ឋានជាមូលដ្ឋានដែលនឹងធ្វើឲ្យប្រសើរឡើងចំពោះការផ្តល់សេវា បើមានការអនុវត្តតាមគោលការណ៍នេះបានត្រឹមត្រូវ ។ គោលការណ៍ណែនាំនោះ ក៏នឹងកំណត់បទដ្ឋានសម្រាប់គណនេយ្យភាពប្រសើរឡើងផងដែរ ដែលសហគមន៍នឹងដឹងពីគោលការណ៍ណែនាំនោះអំពីអ្វី ដែលពួកគេគួររំពឹងទុកពីអ្នកផ្តល់សេវា ។

គោលការណ៍ណែនាំ នឹងត្រូវរៀបចំឡើង និងបង្កើតជាសៀវភៅណែនាំ ស្តីពីសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទលម្អិត ដោយមានការណែនាំជាក់លាក់លើ ៖

- ការរៀបចំផែនការ
- ទំនាក់ទំនង
- ការរៀបចំ និងការកៀរគរសហគមន៍
- ការធ្វើសេចក្តីសម្រេច លើការជ្រើសរើសបច្ចេកវិទ្យា ដោយសហគមន៍

- ការស្តារហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត
- ការរៀបចំផែនការសុវត្ថិភាពទឹក ដោយប្រើទម្រង់ទូទៅ (generic format)
- ឆ្លើយតបទៅនឹងការផ្គត់ផ្គង់ទឹក ដែលមិនគោរពតាមបទដ្ឋានគុណភាពទឹក
- សហគមន៍ដឹកនាំអនុវត្តន៍អនាម័យទាំងស្រុង
- ទីផ្សារអនាម័យ
- ការលើកកម្ពស់អនាម័យ
- គោលការណ៍ នៃការទទួលខុសត្រូវ គណនេយ្យភាព ភាពប្រាកដប្រជា និងតម្លាភាព សម្រាប់វិស័យឯកជន
- ការបញ្ជ្រាបយេនឌ័រ
- ផលប៉ះពាល់បរិស្ថាន និងនីតិវិធីផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ
- ប្រព័ន្ធគ្រប់គ្រងព័ត៌មាន
- គណនេយ្យភាព (សង្គមកិច្ច ហិរញ្ញវត្ថុ បច្ចេកទេស និងបរិស្ថាន) សម្រាប់រដ្ឋបាលមូលដ្ឋាន អ្នកផ្តល់សេវា និងអង្គភាពគាំទ្រ

| **លទ្ធផល** | ការផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធភាពជាមួយ និងបទដ្ឋានផ្សេងៗដើម្បីឲ្យមានគណនេយ្យភាព | **ការទទួលខុសត្រូវ** |
|---|---|---|
| **សកម្មភាព** | ◆ ពិនិត្យឡើងវិញគោលការណ៍ណែនាំ និងនីតិវិធីផ្សេងៗដែលមានស្រាប់ ហើយកែសម្រួល បើចាំបាច់។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយនឹងដៃគូ វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ |
| | ◆ បង្កើតគោលការណ៍ណែនាំ និងនីតិវិធីថ្មីៗ តាមតម្រូវការ ក្នុងផ្នែកផ្សេងៗនៃយុទ្ធសាស្ត្រនេះ ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយនឹងដៃគូ វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ |
| | ◆ ចងក្រងឯកសារគោលការណ៍ណែនាំ និងផ្សព្វផ្សាយទៅឲ្យស្ថាប័នថ្នាក់ជាតិ អាជ្ញាធរមូលដ្ឋាន អ្នកផ្តល់សេវាកម្ម ក្រុមប្រឹក្សាស្រុក និងឃុំ ព្រមទាំងសហគមន៍អ្នកប្រើប្រាស់ ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ |
| | ◆ តាមដានត្រួតពិនិត្យការប្រើប្រាស់ និងប្រសិទ្ធភាព នៃគោលការណ៍ណែនាំ និងការកែសម្រួល ប្រសិនបើចាំបាច់។ | ◆ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត រាយការណ៍ទៅ ក្រសួងអភិវឌ្ឍន៍ជនបទ |

## សមាភាគ ៤.២ ការអភិវឌ្ឍធនធានមនុស្ស និងសមត្ថភាព

### ៤.២.១. ថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ

នាពេលបច្ចុប្បន្ន ថ្នាក់ស្រុកមិនទាន់មានសមត្ថភាពនៅឡើយទេ ប៉ុន្តែនឹងអាចបង្កើតប្រព័ន្ធគាំទ្រដែលចាំបាច់ នៅក្នុងការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ក្នុងរយៈពេល៥ឆ្នាំ ដើម្បីផ្តល់លទ្ធភាពឲ្យសហគមន៍អាចទទួលបានសេវា និងអាចធ្វើឲ្យសេវាមាននិរន្តរភាព ។ អាស្រ័យតាមទំហំស្រុក ត្រូវមាន មន្ត្រី ២ ឬ៣នាក់ សម្រាប់មុខងារគាំទ្រប្រតិបត្តិការ និងការថែទាំ បូកនឹងចំនួនបុគ្គលិកប្រហាក់ប្រហែលគ្នានេះសម្រាប់ការងារលើកកម្ពស់អនាម័យ[55]។ ក្នុងរយៈពេលខ្លីរហូតដល់រយៈពេលមធ្យម ស្រុកនីមួយៗ ក៏នឹងត្រូវការមន្ត្រីបច្ចេកទេសយ៉ាងហោចណាស់ម្នាក់ ដើម្បីផ្តល់ប្រឹក្សាបច្ចេកទេស ដល់ក្រុមប្រឹក្សាឃុំ និងក្រុមប្រើប្រាស់ទឹក និងអនាម័យ សម្រាប់ការគ្រប់គ្រងការសាងសង់ និងគុណភាព នៃហេដ្ឋារចនាសម្ព័ន្ធថ្មី ។ ការិយាល័យអភិវឌ្ឍន៍ជនបទស្រុកនីមួយៗ នឹងមានយ៉ាងហោចណាស់ស្ត្រីម្នាក់ ក្នុងក្រុមការងារ ។

បុគ្គលិកបម្រើការងារនៅក្នុងការិយាល័យអភិវឌ្ឍន៍ជនបទស្រុក ត្រូវតែមានសមត្ថភាពជាមូលដ្ឋាន ដើម្បីអនុវត្តការងារ ដែលបានដាក់ឱ្យ ឬត្រូវតែមានសម្បទា ដើម្បីសិក្សា និងទាញយកសមត្ថភាពទាំងនេះ ។

ការអភិវឌ្ឍសមត្ថភាពចម្បងៗរបស់ក្រុមប្រឹក្សាឃុំ និងប្រព័ន្ធគាំទ្ររដ្ឋបាលនិងបច្ចេកទេសនៃរដ្ឋបាលថ្នាក់ក្រោមជាតិ កំពុងត្រូវបានរៀបចំជាផែនការ និងអនុវត្តដែលជាផ្នែកមួយនៃដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ។ ចាំបាច់ត្រូវមានការសម្របសម្រួលល្អរវាងវិស័យនានា និងដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីធានាថា ការអភិវឌ្ឍសមត្ថភាពរួមមួយអាចធ្វើទៅបាន។

[55] ទោះបីជាតាមទ្រឹស្តី ការងារនេះមិនអាចរួមបញ្ចូលជាមួយបុគ្គលិកក្រសួងសុខាភិបាល នៅថ្នាក់ស្រុក តម្រូវការ លើតួនាទីធ្វើឲ្យការងារនេះត្រូវធ្វើពេញម៉ោង ។ ការងារនេះមិនគួររួមបញ្ចូលជាមួយការទទួលខុសត្រូវផ្សេងទៀតនោះទេ ។

| លទ្ធផល | សមត្ថភាពសម្រាប់សម្របសម្រួល និងធ្វើឱ្យមាននិរន្តរភាពនៃការផ្ដល់សេវាកម្ម នៅថ្នាក់ក្រោមជាតិ ដែលគាំទ្រដោយថ្នាក់ជាតិ | ការទទួលខុសត្រូវ |
|---|---|---|
| សកម្មភាព | ◆ ពង្រឹងសមត្ថភាពមន្ត្រីការិយាល័យអភិវឌ្ឍន៍ជនបទស្រុក។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ និង មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត |
| | ◆ រៀបចំផែនការលម្អិតសម្រាប់អភិវឌ្ឍន៍សមត្ថភាព ដើម្បីកំណត់៖<br>- បទពិសោធន៍ និងជំនាញ សម្រាប់កិច្ចការចាំបាច់នៅថ្នាក់ខេត្ត និងថ្នាក់ស្រុក ។<br>- សមត្ថភាព និងចំនួនបុគ្គលិកដែលមានស្រាប់។<br>- ការបណ្ដុះបណ្ដាលបន្ថែមដល់បុគ្គលិក ដែលត្រូវ បំពេញតួនាទី។<br>- ថវិកាសម្រាប់ការអនុវត្តផែនការ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ |
| | ◆ សម្របសម្រួលការធ្វើផែនការអភិវឌ្ឍសមត្ថភាព ជាមួយនឹងវិស័យដទៃៗទៀត និងដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីធានាថា ការអភិវឌ្ឍសមត្ថភាពទាំងអស់នោះ អាចធ្វើទៅបាន ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ |
| | ◆ អនុវត្តផែនការអភិវឌ្ឍន៍សមត្ថភាពដែលបានបង្កើតរួច។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ និងស្ថាប័នផ្ដល់វគ្គបណ្ដុះបណ្ដាល |
| | ◆ បង្កើតវគ្គបណ្ដុះបណ្ដាលរយៈពេលខ្លី សម្រាប់មន្ត្រី ថ្នាក់ក្រោមជាតិ និងបុគ្គលិកពីស្ថាប័នពាក់ព័ន្ធនានា។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ |

## សមាសភាគ ៤.៣ ការអភិវឌ្ឍវិស័យឯកជន

គោលនយោបាយជាតិបានចែងអំពី ‹ការបង្កើតបរិយាកាសប្រកួតប្រជែង ដែលលើកទឹកចិត្តឲ្យវិស័យឯកជនផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទប្រកបដោយប្រសិទ្ធភាពតម្លៃដែលឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍ ជាពិសេសតំបន់ដែលពុំមានសេវា› ។[56] ផ្អែកលើចំណុចនេះ យុទ្ធសាស្ត្រនោះ សំអាងទៅលើវិស័យឯកជន ដែលមានតួនាទីដ៏សំខាន់ ក្នុងការផ្តល់សេវាកម្ម ដល់សហគមន៍ជនបទ និងក្រុមគ្រួសារនីមួយៗ។ សេវាកម្មទាំងនេះ មានតាំងពីការផ្តល់ហេដ្ឋារចនាសម្ព័ន្ធរយៈពេលខ្លីដល់រយៈពេលវែង ព្រមទាំងការធ្វើប្រតិបត្តិការនៃការផ្គត់ផ្គង់ទឹក និងសេវាកម្មគាំទ្រជារៀងរហូត ។ ពាក្យ ‹វិស័យឯកជន› គ្របដណ្តប់លើអង្គភាព និងឯកត្តជនជាច្រើនប្រភេទ ។ ទាំងនេះរួមមានសិប្បករ និងជាងកំបោរ ជាងម៉ាស៊ីនតាមភូមិ និងឃុំ ទីផ្សារ ឬហាងនៅមូលដ្ឋាន ផលិតករនៅមូលដ្ឋាន ក្រុមហ៊ុនខួងអណ្តូង អ្នកផ្តល់ប្រឹក្សា (ឯកត្តជន និងក្រុមហ៊ុន) និងក្រុមហ៊ុនឯកទេស ។

មានផ្នែកចំនួនបី ដែលគាំទ្រដល់ការអភិវឌ្ឍវិស័យឯកជន ៖

- ការបង្កើតបរិយាកាសប្រកួតប្រជែង រួមមានតម្លាភាព និងការប្រកួតប្រជែង ដោយមានទំនាក់ទំនងកិច្ចសន្យារវាងក្រុមប្រើប្រាស់ទឹក និងអនាម័យ អ្នកផ្តល់សេវាកម្ម និង អាជ្ញាធរមូលដ្ឋាន
- ការទទួលបានការវិនិយោគលើទុនដើម និងប្រាក់កម្ចី
- ការអភិវឌ្ឍ ជំនាញបច្ចេកទេស និង អាជីវកម្ម

### ៤.៣.១. ការបង្កើតបរិយាកាសប្រកួតប្រជែង

មានកត្តាមួយចំនួន ពាក់ព័ន្ធនឹងការបង្កើតបរិយាកាសសមស្រប សម្រាប់សហគ្រាសធុនតូចនិងមធ្យម ដែលកត្តាទាំងនោះភាគច្រើនស្ថិតនៅក្រៅទំហំការងារវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ និងយុទ្ធសាស្ត្រនេះ ។ កត្តានានាមានបង្ហាញនៅក្នុងប្រអប់ទី២ ។

[56] (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៣) ជំពូក ៥ ៖ ការចូលរួមពីវិស័យឯកជន

## ប្រអប់ទី២ ៖ លក្ខណៈវិនិច្ឆ័យសម្រាប់វាស់វែងបរិយាកាសអាជីវកម្មនៅថ្នាក់ខេត្តក្នុងប្រទេសកម្ពុជា

| | |
|---|---|
| ចំណាយសុំចូលរួម | ពេលវេលា ដែលក្រុមហ៊ុនប្រើ ដើម្បីចុះបញ្ជី និងទទួលបានអាជ្ញាប័ណ្ណចាំបាច់ទាំងអស់ ដើម្បីចាប់ផ្តើមអាជីវកម្ម ចំនួនអាជ្ញាប័ណ្ណដែលត្រូវការ និងចំណាយផ្លូវការទាំងអស់ក្នុងការទទួលបានអាជ្ញាប័ណ្ណ-ការអនុញ្ញាត ។ |
| សិទ្ធិគ្រប់គ្រងទ្រព្យសម្បត្តិ | សិទ្ធិផ្លូវការ ចំពោះបរិវេណអាជីវកម្មនិងសន្តិសុខនៃសិទ្ធិកាន់កាប់នៅពេលទទួលបានដី និងមានប័ណ្ណកម្មសិទ្ធិត្រឹមត្រូវ |
| តម្លាភាព | វាស់វែងថាតើក្រុមហ៊ុនមានលទ្ធភាពទទួលបានព័ត៌មាន ដែលពួកគេត្រូវការអំពីបទបញ្ញត្តិ និងនីតិវិធីរបស់រាជរដ្ឋាភិបាល ព្រមទាំងឯកសារផ្លូវច្បាប់ដែល ចាំបាច់សម្រាប់ ប្រតិបត្តិការធុរកិច្ច ថាតើព័ត៌មានអំពីបទបញ្ញត្តិ និងឯកសារផ្លូវច្បាប់ មានផ្តល់ជូនអ្នកគ្រប់គ្នាដែលស្នើសុំ និងថាតើគោលនយោបាយ និងច្បាប់ថ្មីៗត្រូវបានប្រាស្រ័យទាក់ទងទៅក្រុមហ៊ុន និង ត្រូវបានអនុវត្តតាមការកំណត់ដែរឬយ៉ាងណា ។ |
| ពេលវេលា ចំណាយចំពោះការគោរពតាមបញ្ញត្តិ | វាស់វែងពេលវេលា ដែលក្រុមហ៊ុនប្រើ ចំពោះការគោរពតាមបទបញ្ញត្តិ របស់រាជរដ្ឋាភិបាល ពេលវេលាដែលពួកគេរង់ចាំដើម្បីបញ្ចប់នីតិវិធី ព្រមទាំងភាព ញឹកញាប់ដែលក្រុមហ៊ុនត្រូវបានចុះធ្វើអធិការកិច្ច ដោយទីភ្នាក់ងារ រដ្ឋបាលនៅមូលដ្ឋាន |
| ចំណាយក្រៅផ្លូវការ - សំណូក | វាស់វែង ភាពញឹកញាប់ ដែលក្រុមហ៊ុនបង់ថ្លៃក្រៅផ្លូវការ ដូចជាសំណូក និងប្រាក់ទឹកតែ (kickbacks) ដើម្បីទទួលកិច្ចសន្យាពីរដ្ឋាភិបាល កម្រិតដែល ការបង់ប្រាក់ក្រៅផ្លូវការនេះបង្កជាឧបសគ្គដល់ ប្រតិបត្តិការអាជីវកម្ម និង ថាតើការបង់ប្រាក់ក្រៅផ្លូវការមាន លក្ខណៈអាចទស្សន៍ទាយបាន និង សម្រេចបានលទ្ធផលដែលរំពឹងទុក ឬ យ៉ាងណា ។ |

| | |
|---|---|
| ការចូលរួម | វាស់វែងថាតើក្រុមហ៊ុនត្រូវបានពិគ្រោះយោបល់អំពីគោលនយោបាយខេត្ត ដែលបានស្នើឡើង និងថាតើសមាគមន៍អាជីវកម្ម ឬក្រុមដែលទទួលបានផលប្រយោជន៍ផ្សេងទៀតតស៊ូមតិតាងនាមឲ្យម្ចាស់អាជីវកម្មឬយ៉ាងណា ។ |
| ការបង្ការបទល្មើស | វាស់វែងចំណាយដែលក្រុមហ៊ុនបានបង់ ដែលបង្កពីការលួច ព្រមទាំងចំណាយបង្ការបទឧក្រិដ្ឋ ដែលបង់ឲ្យសេវាសន្តិសុខ និងបង់ប្រាក់ ថ្លៃការពារ ។ |
| រដ្ឋបាលពន្ធដារ | វាស់វែងនីតិវិធីរដ្ឋបាលទាំងពីរ ទាក់ទងនឹងការបង់ពន្ធ និងចំណាយពន្ធក្នុងខេត្ត ។ |
| ការត្រៀមលក្ខណៈ ជាមុនរបស់អ្នកដឹកនាំនៅថ្នាក់ខេត្ត | វាស់វែងភាពច្នៃប្រឌិត និងឆន្ទៈរបស់អាជ្ញាធរខេត្តក្នុងការបកស្រាយគោលនយោបាយ និងបទបញ្ញត្តិជាតិ ដើម្បីបំពេញបំណងរបស់ក្រុមហ៊ុន ឯកជន និង កសាងគំនិតផ្តួចផ្តើមរបស់ខេត្តខ្លួនដើម្បីលើកកម្ពស់ការ អភិវឌ្ឍវិស័យឯកជន ។ |
| ការដោះស្រាយជម្លោះ | វាស់វែងការពេញចិត្តរបស់ក្រុមហ៊ុន ចំពោះលទ្ធផលនៃវិធីសាស្ត្រផ្លូវការ និងក្រៅផ្លូវការក្នុងការដោះស្រាយជម្លោះក្នុងខេត្តរបស់ពួកគេ ។ |

**ប្រភព ៖ (សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ & មូលនិធិអាស៊ី ឆ្នាំ២០០៩)**

សកម្មភាពមួយចំនួនដែលទាក់ទងជាក់លាក់ទៅនឹងការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យអាចត្រូវយកមកអនុវត្ត ដើម្បីកែលម្អលក្ខខណ្ឌសហគ្រាសធុនតូច និងមធ្យមក្នុងការផ្តល់សេវាលើវិស័យនេះ ។ វិធានលទ្ធកម្មរបស់រាជរដ្ឋាភិបាលកម្ពុជា រួមទាំង មូលនិធិឃុំ-សង្កាត់ មូលនិធិវិនិយោគខេត្ត មានគ្រប់គ្រាន់ សម្រាប់ដាក់ដេញថ្លៃសេវា និងគម្រោង ។អ្វីដែលជាសេចក្តីត្រូវការនោះ គឺធ្វើយ៉ាងណាធានាឲ្យមានការ គោរពច្បាប់ ដោយលុបបំបាត់ការរួមគំនិត និងការអនុវត្តមិនត្រឹមត្រូវក្នុងដំណើរការដាក់ដេញថ្លៃ និង ក្នុងពេលអនុវត្តកិច្ចសន្យា ។

| | | |
|---|---|---|
| **លទ្ធផល** | កិច្ចសន្យាផ្តល់សេវាកម្មសម្រាប់ សហគ្រាសធុនតូច និងមធ្យម ដែលពាក់ព័ន្ធនឹងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ត្រូវបានធ្វើឡើងដោយក្នុង បរិយាកាសប្រកួតប្រជែងប្រកបដោយការទទួលខុសត្រូវខ្ពស់ | **ការទទួលខុសត្រូវ** |
| **សកម្មភាព** | ◆ បង្កើតនីតិវិធីបន្ថែមចំនួនបី ដើម្បីធានាឲ្យមានការគោរពកិច្ចសន្យា និងនីតិវិធីលទ្ធកម្ម ៖<br>- ធ្វើឲ្យក្រុមប្រើប្រាស់ទឹក និងអនាម័យមានតួនាទីក្នុងកិច្ចសន្យា ដូច្នេះ កិច្ចសន្យានេះគឺធ្វើឡើងរវាងអាជ្ញាធរមានសមត្ថកិច្ច រួមគ្នាជាមួយនឹងក្រុមប្រើប្រាស់ទឹក និងអនាម័យ ជាភាគីម្ខាងជាមួយនឹងភាគីម្ខាងទៀត ដែលជាក្រុមហ៊ុនឯកជន ។<br>- យោងទៅតាមដំណើរការដេញថ្លៃ ត្រូវផ្សព្វផ្សាយទៅឲ្យសហគមន៍អ្នកប្រើប្រាស់ អំពីការដេញថ្លៃរើសយកអ្នកម៉ៅការដែលមានតម្លៃទាបជាងគេបំផុត ចំនួនបីនាក់រួមទាំងការប៉ាន់ស្មានតម្លៃ ដោយអាជ្ញាធរមានសមត្ថកិច្ច (រួមទាំងរបៀបនៃការប៉ាន់ស្មានដែលផ្តោតលើគោលការណ៍ថ្លៃពលកម្ម គ្រឿងចក្រ និងសម្ភារ)។<br>- ពេលកិច្ចសន្យានៃការសាងសង់ត្រូវបានបញ្ចប់ ត្រូវធ្វើការផ្សព្វផ្សាយព័ត៌មានផ្លូវការជាសាធារណៈ អំពីគណនីរបស់គម្រោងដល់សហគមន៍ ដោយភ្ជាប់ជាមួយនឹងពត៌មានលម្អិតពីថវិកាក្នុងគម្រោង ដែលបានចំណាយក្នុងការអនុវត្តផែនការអភិវឌ្ឍសមត្ថភាព។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ |

| | | |
|---|---|---|
| | ◆ រៀបចំ និងចងក្រងផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពីការទទួលខុសត្រូវ គណនេយ្យភាព ការព្យាករណ៍ និងតម្លាភាព សម្រាប់វិស័យឯកជន។<br>◆ ផ្សព្វផ្សាយគោលការណ៍ណែនាំនេះ ទៅការិយាល័យរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ដែលពាក់ព័ន្ធនឹងវិស័យនេះ និងក្រុមប្រឹក្សាឃុំ-សង្កាត់ ។<br>◆ ផ្សព្វផ្សាយគោលការណ៍ណែនាំខាងលើ ទៅសហគ្រាសធុនតូច និងមធ្យមទាំងអស់ ដែលមានចំណាប់អារម្មណ៍ក្នុងការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ការិយាល័យអភិវឌ្ឍន៍ជនបទស្រុក |

| | | |
|---|---|---|
| **លទ្ធផល** | វិស័យឯកជនមានការជឿជាក់ក្នុងការវិនិយោគលើប្រតិបត្តិការ ផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទរយៈពេលវែង | **ការទទួលខុសត្រូវ** |
| **សកម្មភាព** | ◆ កិច្ចសន្យាសម្រាប់អ្នកផ្តល់សេវាកម្ម រួមមានការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ដែលមានរយៈពេលយ៉ាងហោចណាស់ ១០ឆ្នាំ ដើម្បីឲ្យអ្នកម៉ៅការអាចពង្រីកទុនវិនិយោគ ហើយអាចទទួលបានចំណូលពីការវិនិយោគនោះមកវិញ។ កិច្ចសន្យានេះ រួមមានបទប្បញ្ញត្តិផ្លូវច្បាប់ សម្រាប់ការបញ្ចប់កិច្ចសន្យាមុនពេលកំណត់ ក្នុងករណីដែលការផ្តល់សេវាកម្មមិនបានល្អ ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ |

## ៤.៣.២ លទ្ធភាពទទួលបានទុនសម្រាប់ការវិនិយោគ និងប្រាក់កម្ចី

មានការប៉ាន់ស្មានថា តម្រូវការសរុបលើឥណទាន ពីសំណាក់សហគ្រិនអាជីវកម្មខ្នាតតូចបំផុត និងខ្នាតតូច អាចមានចំនួន ១០០ ដល់ ១២៥លានដុល្លារអាមេរិក ។ មានត្រឹមតែ ៤៥ ភាគរយ ទៅ ៥៥ ភាគរយ នៃទឹកប្រាក់នេះប៉ុណ្ណោះ ត្រូវបានផ្តល់ដោយអ្នកផ្តល់សេវាហិរញ្ញវត្ថុដែលមានស្រាប់។ វិស័យហិរញ្ញវត្ថុនៅមិនទាន់មានការអភិវឌ្ឍនៅឡើយទេ ដោយខ្វះធនាគារអភិវឌ្ឍន៍ជនបទ និង បណ្តាញហិរញ្ញវត្ថុជនបទមានលក្ខណៈទន់ខ្សោយ ។មានធនាគារពាណិជ្ជ និងធនាគារឯកទេសចំនួន ១៧ប៉ុណ្ណោះដែលប្រតិបត្តិការនៅភ្នំពេញ និងទីរួមខេត្តសំខាន់ៗ។ ការអភិវឌ្ឍសកម្មភាពផ្តល់កម្ចី ពាណិជ្ជកម្ម មានការលំបាកនៅក្នុងតំបន់ជនបទ ដោយការចំណាយប្រតិបត្តិការខ្ពស់ ខ្វះសមត្ថភាព ក្នុងការផ្ទៀងផ្ទាត់ និងអនុវត្តសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ និងសកម្មភាពសេដ្ឋកិច្ចមានកម្រិតទាប ។ លទ្ធផលនោះ គឺថាប្រជាជនភាគច្រើននៅជនបទ ស្ទើរតែមិនអាចទទួលបានទម្រង់ផ្លូវការនៃសេវាហិរញ្ញវត្ថុទៀតផង[57]។

ស្ថាប័នមីក្រូហិរញ្ញវត្ថុមួយចំនួន ស្ថិតក្នុងដំណើរការកសាងបណ្តាញនៅជនបទ ដែលនឹងជាបណ្តាញសម្រាប់ផ្តល់កម្ចីខ្នាតតូច ដល់ក្រុមគ្រួសារនីមួយៗ និងអាជីវកម្មឯកជនតូចៗ ។ ឧបសគ្គចម្បងចំពោះការងារនេះ គឺមូលធនសម្រាប់កម្ចីក្នុងអត្រាការប្រាក់ទាប ដែលអាចឲ្យប្រជាពលរដ្ឋជនបទក្រីក្រទទួលយកបាន ។

| | | |
|---|---|---|
| **លទ្ធផល** | មានការផ្តល់ប្រាក់កម្ចីទ្រង់ទ្រាយតូច ដល់អាជីវកម្មធុនតូច និងមធ្យម នៅជនបទ សម្រាប់ការផ្តល់សេវាកម្ម និងផលិតផល នៃការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ | **ការទទួលខុសត្រូវ** |
| **សកម្មភាព** | ◆ កំណត់រក និងរក្សាឲ្យមានធនធាន ជាមូលធនសម្រាប់ការវិនិយោគ តាមរយៈស្ថាប័នមីក្រូហិរញ្ញវត្ថុ។ | ◆ ស្ថាប័នមីក្រូហិរញ្ញវត្ថុ |

## ៤.៣.៣. ការអភិវឌ្ឍជំនាញអាជីវកម្ម និងបច្ចេកទេស

សេចក្តីត្រូវការលើជំនាញអាជីវកម្មមូលដ្ឋាន ក្នុងការគ្រប់គ្រង និងហិរញ្ញវត្ថុ មានលើកឡើងជាញឹកញាប់ ថាជាការលំបាកក្នុងការជំរុញឲ្យអាជីវកម្មខ្នាតតូចមានការអភិវឌ្ឍ ។

57 (អង្គរមីក្រូហិរញ្ញវត្ថុកម្ពុជា ឆ្នាំ ២០០៩AMK, 2009)

| **លទ្ធផល** | អាជីវកម្មធុនតូច និងមធ្យម ដែលបម្រើសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ជនបទមានសមត្ថភាពជាមូលដ្ឋានលើការគ្រប់គ្រង អាជីវកម្ម និងការគ្រប់គ្រងហិរញ្ញវត្ថុ | **ការទទួលខុសត្រូវ** |
|---|---|---|
| សកម្មភាព | ◆ កំណត់រកស្ថាប័នបណ្តុះបណ្តាលសមស្រប និងបង្កើតកម្មវិធីបណ្តុះបណ្តាល។<br>◆ ផ្តល់វគ្គបណ្តុះបណ្តាលដល់សហគ្រាសខ្នាតតូច និងមធ្យម នៅថ្នាក់មូលដ្ឋាន។<br>◆ ផ្តល់ការណែនាំលើការតាមដាន ត្រួតពិនិត្យ និង គាំទ្រដល់អាជីវកម្មខ្នាតតូច។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័ន និងសាកលវិទ្យាល័យ ដែលផ្តល់វគ្គបណ្តុះបណ្តាលអាជីវកម្ម<br>◆ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័ន និងសាកលវិទ្យាល័យដែលផ្តល់វគ្គបណ្តុះបណ្តាលអាជីវកម្ម |

## សមាសភាគ ៤.៤ ការធ្វើផែនការ និងប្រព័ន្ធគ្រប់គ្រងព័ត៌មាន

ការធ្វើផែនការសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ចាំបាច់ត្រូវផ្អែកលើ ព័ត៌មានត្រឹមត្រូវ និងអាចទុកចិត្តបាន ។

| | | |
|---|---|---|
| **លទ្ធផល** | ប្រព័ន្ធគ្រប់គ្រងព័ត៌មានរួមមួយត្រូវបានប្រើប្រាស់សម្រាប់ធ្វើផែនការ និងគ្រប់គ្រងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ប្រកបដោយប្រសិទ្ធភាព | **ការទទួលខុសត្រូវ** |
| **សកម្មភាព** | ◆ ធ្វើកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងព័ត៌មានបច្ចុប្បន្នជាមួយនឹងទិន្នន័យផ្សេងៗសម្រាប់បង្កើតឲ្យមានប្រព័ន្ធគ្រប់គ្រងព័ត៌មានរួមមួយ ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ |
| | ◆ ធ្វើឲ្យប្រព័ន្ធគ្រប់គ្រងព័ត៌មានអាចប្រើបានដោយអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងវិស័យនេះ និងដាក់វាទៅក្នុងគេហទំព័រ និងតាមរយៈមធ្យោបាយផ្សេងៗសម្រាប់ប្រាស្រ័យទាក់ទងដល់អ្នកពាក់ព័ន្ធ ដែលគ្មានលទ្ធភាពប្រើប្រាស់អ៊ីនធឺណែត។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ |
| | ◆ ធានាថា ទិន្នន័យទាំងអស់អំពីហេដ្ឋារចនាសម្ព័ន្ធ ស្ថាប័ន និងកត្តាសង្គម ត្រូវបានប្រមូល ហើយចែកចេញជាផ្នែកស្ត្រី បុរស កុមារ ជនពិការ និងជនជាតិភាគតិច ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងការិយាល័យអភិវឌ្ឍន៍ជនបទស្រុក |

ក្របខ័ណ្ឌសម្រាប់ប្រព័ន្ធគ្រប់គ្រងព័ត៌មាន មានផ្តល់ជូនក្នុងឧបសម្ព័ន្ធទី៣ ។

## សមាសភាគ ៤.៥ ការវាយតម្លៃ និងការរៀនសូត្រ

ជាការសំខាន់ អ្នកពាក់ព័ន្ធនឹងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ត្រូវរៀនសូត្រអំពីបទពិសោធន៍នៃការប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នា ពីគ្នាទៅវិញទៅមក ។ ទោះបីជាស្ថាប័ននីមួយៗធ្វើការវាយតម្លៃលើការងាររបស់ពួកគេក៏ដោយ ក៏មិនមានប្រព័ន្ធសម្រាប់ចែករំលែកបទពិសោធន៍ពីការវាយតម្លៃនោះនៅឡើយទេ ។ ហើយក៏មិនមានប្រព័ន្ធសម្រាប់ធ្វើការវាយតម្លៃ និងសិក្សាអំពីវិធីសាស្ត្រផ្សេងៗ សម្រាប់វិស័យនោះដែរ[58] ។ ប្រធានបទបែបនេះ នឹងរួមមានការសិក្សាអំពីមុខងាររបស់ក្រុមប្រើប្រាស់ទឹក និងអនាម័យ (កត្តាដែលជំរុញ ឬ រារាំងភាពជោគជ័យ បញ្ហាយេនឌ័រ) និងអំពីមូលហេតុដែលបុរស ឬស្ត្រីត្រឡប់ ឬមិនត្រឡប់មករកការបន្ទោបង់ពាសវាលពាសកាលវិញ ។

[58] លើលែងការវាយតម្លៃថ្មីៗ របស់សហគមន៍ដឹកនាំអនុវត្តន៍អនាម័យ។

| | | |
|---|---|---|
| **លទ្ធផល** | ប្រព័ន្ធចែករំលែក ចំណេះដឹង និងបទពិសោធន៍ ដ៏មានប្រសិទ្ធភាពពីបុគ្គលនីមួយៗ និងក្រុមនានា ដែលធ្វើការលើទិដ្ឋភាពផ្សេងៗគ្នា សម្រាប់ភាគីពាក់ព័ន្ធ នៃវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ | **ការទទួលខុសត្រូវ** |
| **សកម្មភាព** | ◆ បង្កើតប្រព័ន្ធចែករំលែកលទ្ធផលនៃការវាយតម្លៃ ក្រោមការគ្រប់គ្រងរបស់ក្រុមការងារសម្របសម្រួលវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។<br>◆ ធ្វើការវាយតម្លៃ និងផ្សព្វផ្សាយនូវលទ្ធផលឲ្យបានទូលំទូលាយក្នុងវិស័យផ្គត់ផ្គង់ទឹក និងអនាម័យ និងការសិក្សាលើទិដ្ឋភាពជាក់លាក់ និងវិធីសាស្ត្រមួយចំនួនក្នុងវិស័យនេះ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ |

## សមាសភាគ៤.៦. ការស្រាវជ្រាវ ការអភិវឌ្ឍ និងការច្នៃប្រឌិត

ជម្រើសបច្ចេកទេសមួយចំនួន នៃសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ត្រូវបានបង្កើតឡើងបានយ៉ាងល្អនៅកម្ពុជា ។ ប៉ុន្តែ នៅមានបញ្ហាប្រឈមក្នុងការអភិវឌ្ឍ និងប្រើប្រាស់ បច្ចេកវិទ្យាសមស្រប នៅតំបន់ជួបការលំបាក មានដូចជាការផ្គត់ផ្គង់ទឹកនៅក្នុងតំបន់ងាយរងគ្រោះរាំងស្ងួតដោយ គ្មានទឹកក្រោមដី និងបង្គន់ក្នុងតំបន់ងាយរងគ្រោះដោយទឹកជំនន់តាមរដូវ ។ ដូចគ្នានេះដែរ មានវិធី សាស្ត្រជាច្រើនបានបង្កើតឡើង ដើម្បីផ្តល់សេវាផ្គត់ផ្គង់ទឹក ក៏ដូចជាវិធីសាស្ត្រ ដែលទើបតែណែនាំ ឲ្យអនុវត្តថ្មីៗ សម្រាប់អនាម័យ ដូចជា សហគមន៍ដឹកនាំអនុវត្តន៍អនាម័យ និងការធ្វើទីផ្សារសង្គម ។

ទោះជាយ៉ាងនេះក្តីសេចក្តីត្រូវការផ្នែកការបច្ចេកទេស និងវិធីសាស្ត្របន្ថែមទៀតក៏នៅតែមាន ។ ទាំងនេះអាចជា ការសម្របតាមវិធីសាស្ត្រដែលធ្លាប់បានប្រើក្នុងប្រទេសផ្សេងៗទៀត ឬការអភិវឌ្ឍគំនិតថ្មីៗ ដើម្បីបំពេញតាមសេចក្តីត្រូវការនៅក្នុងប្រទេសកម្ពុជា ។ មិនថាប្រើវិធីសាស្ត្រមួយណាក៏ដោយ ការសំខាន់ គឺត្រូវអនុវត្តនៅតំបន់ជនបទ ដោយប្រុងប្រយ័ត្ន តាមរយៈអនុវត្តន៍សាកល្បង ធ្វើតេស្ត និងផ្ទៀងផ្ទាត់ត្រឹមត្រូវមុននឹងដាក់ឲ្យអនុវត្តក្នុងលក្ខណៈទូទៅ ។ ក្នុងដំណើរការនេះ សំខាន់ត្រូវចងចាំថា គឺប្រជាពលរដ្ឋ និងសហគមន៍ក្រីក្រ និងស្ត្រីជាពិសេស ក្នុងនាមជាអ្នកគ្រប់គ្រងលើការប្រើប្រាស់ទឹក និងអនាម័យតាមផ្ទះ ត្រូវបានស្នើឲ្យទទួលយកហានិភ័យទៅក្នុងជីវភាពរស់នៅ និងសុខភាពរបស់ពួកគេ ក្នុងការសាកល្បងវិធីសាស្ត្រថ្មីៗ ។

| **លទ្ធផល** | នីតិវិធីដ៏ល្អិតល្អន់មួយ ត្រូវបានអនុវត្ត សម្រាប់ការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍ និងការច្នៃប្រឌិតខាងបច្ចេកវិទ្យាថ្មី ហើយនិងវិធីសាស្ត្រផ្នែកទន់ | **ការទទួលខុសត្រូវ** |
|---|---|---|
| សកម្មភាព | ◆ បង្កើតនីតិវិធីជាលក្ខណៈប្រព័ន្ធ សម្រាប់អនុវត្តការធ្វើពិសោធន៍ ការអនុម័ត និងផ្សព្វផ្សាយអំពីវិធីសាស្ត្រ និងលទ្ធផលអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗ។<br>◆ បង្កើតគណៈកម្មាធិការសម្រាប់ណែនាំ និងអនុម័តក្នុងការងារនេះ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ |

គណៈកម្មការ និងនីតិវិធីមានពណ៌នាលម្អិត នៅក្នុងឧបសម្ព័ន្ធទី៣ ។ គណៈកម្មការនេះនឹងទទួលខុសត្រូវផងដែរលើការវាយតម្លៃ និងការសិក្សា ។

## សមាសភាគ៤.៧. ទំនាក់ទំនង

ការផ្តល់អាទិភាពទាប ដោយរាជរដ្ឋាភិបាលដល់វិស័យនេះនាពេលបច្ចុប្បន្នព្រមទាំងកង្វះការយល់ដឹង អំពីបញ្ហាទឹកស្អាត និងអនាម័យជនបទ និងបញ្ហាឥរិយាបថក្នុងការអនុវត្តអនាម័យក្នុងចំណោមអ្នកនៅក្រៅវិស័យនេះ គឺជាក្តីបារម្ភដ៏ធ្ងន់ធ្ងរ ។ ទំនាក់ទំនងព័ត៌មាន លើសេចក្តីត្រូវការ និងអាទិភាពរបស់វិស័យនេះ បញ្ហា និងបច្ចេកវិទ្យានានាក្នុងវិស័យនេះ គឺនៅមានលក្ខណៈទន់ខ្សោយនៅតាមលំដាប់ថ្នាក់ ពោលគឺទាំងថ្នាក់ជាតិ ទាំងថ្នាក់ខេត្ត ទាំងថ្នាក់ស្រុក និងទាំងថ្នាក់សហគមន៍រវាងក្រសួងនិងមន្ត្រីដែលជាអ្នកធ្វើសេចក្តីសម្រេចចិត្ត ព្រមទាំងរវាងដៃគូអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាល ។

| លទ្ធផល | ទំនាក់ទំនងប្រកបដោយ ប្រសិទ្ធភាពទាំងក្នុង និងក្រៅវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ | ការទទួលខុសត្រូវ |
|---|---|---|
| សកម្មភាព | ◆ បង្កើត និងអនុវត្តយុទ្ធសាស្ត្រទំនាក់ទំនង ដើម្បីដោះស្រាយបញ្ហាផ្សេងៗ រួមមាន៖<br>- លើកកម្ពស់មុខមាត់របស់វិស័យនេះនៅក្នុងឆាកនយោបាយ តាមរយៈការផ្សព្វផ្សាយពីឥទ្ធិពលរបស់វិស័យនេះ ទៅលើទិដ្ឋភាពនយោបាយជាអាទិភាពនានា ដូចជាការអភិវឌ្ឍសុខភាព និងសេដ្ឋកិច្ច។<br>- ធ្វើឲ្យវិស័យនេះមានការទាក់ទាញចំពោះសារព័ត៌មាន។<br>- ផ្សព្វផ្សាយយុទ្ធសាស្ត្ររបស់វិស័យនេះ ទាំងនៅក្នុង និង ក្រៅវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។<br>- បង្កើតយន្តការទំនាក់ទំនងអន្តរក្រសួង។<br>- កំណត់ទិន្នន័យសំខាន់ៗ និងព័ត៌មានដែលចាំបាច់។<br>- បង្កើតបណ្តាញ និងយន្តការទំនាក់ទំនងផ្ទៃក្នុង។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ និងដៃគូអភិវឌ្ឍន៍ |

## សមាសភាគ ៤.៨ ភាពក្រីក្រ ជនជាតិភាគតិច ភាពងាយរងគ្រោះ

ទាក់ទងទៅនឹងភាពក្រីក្រជនជាតភាគតិចនិងភាពងាយរងគ្រោះយុទ្ធសាស្ត្រជាតិគាំពារសង្គម សម្រាប់ជនក្រីក្រ និងជនងាយរងគ្រោះ បានកំណត់ក្រុមងាយរងគ្រោះពិសេស រួមមានកុមារកំព្រា មនុស្សចាស់ជរា ស្ត្រីមេម៉ាយរស់នៅជាមួយកូន ជនពិការ និងប្រជាពលរដ្ឋ មានផ្ទុកមេរោគអេដស៍ និង/ឬ ជំងឺរបេង[59]។

### ៤.៨.១. ភាពក្រីក្រ

ការកាត់បន្ថយភាពក្រីក្រ គឺជាអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាល ។ ការសម្រេចបានវឌ្ឍនភាពក្នុងការកាត់បន្ថយភាពក្រីក្រ ដែលជាបញ្ហាពហុវិស័យ អាស្រ័យលើគោលនយោបាយគាំទ្រពលរដ្ឋក្រីក្រជារួម និងកិច្ចខិតខំប្រឹងប្រែងនៅក្នុងវិស័យទាំងអស់ ។ អាស្រ័យហេតុនេះ យុទ្ធសាស្ត្រតាមវិស័យទាំងអស់ គួររក្សាការផ្តោតលើឥទ្ធិពលជាវិជ្ជមានទៅលើភាពក្រីក្រ ។ ជាពិសេស ការវិនិយោគជាគោលដៅ គួរតម្រង់ទិសទៅរកប្រជាពលរដ្ឋ និងតំបន់ដែលខ្វះខាតសេវា ជាពិសេសកន្លែងដែលមានអត្រាប្រេវ៉ាឡង់ភាពក្រីក្រខ្ពស់ ។[60]

សៀវភៅណែនាំការអនុវត្ត ស្តីពីនីតិវិធីសម្រាប់កំណអត្តសញ្ញាណគ្រួសារក្រីក្រ[61]ផ្តល់នូវដំណើរការ និង សូចនាករ សម្រាប់កំណត់រកគ្រួសារក្រីក្រ ហើយបង្កើតជាបញ្ជីគ្រួសារក្រីក្រក្នុងភូមិនីមួយៗ ។

---

[59] (ក្រុមប្រឹក្សាកសិកម្ម និងអភិវឌ្ឍន៍ជនបទ ឆ្នាំ២០១០)
[60] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០០៥-២០១០ (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៦)
[61] (ក្រសួងផែនការ ឆ្នាំ២០០៨)

ជំហានទី៦ នៃដំណើរការនេះបានបញ្ជាក់ថាទិន្នន័យគ្រួសារក្រីក្រ ត្រូវចងក្រង និងរក្សាដោយមន្ទីរផែនការខេត្ត ដើម្បីឲ្យអង្គការប្រើប្រាស់ និងផ្តល់សេវាដល់គ្រួសារក្រីក្រ ។[62]

| **លទ្ធផល** | គ្រួសារក្រីក្របំផុត និងគ្រួសាររងាយរងគ្រោះបំផុត ត្រូវបានផ្តល់អាទិភាពសម្រាប់ការទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ | **ការទទួលខុសត្រូវ** |
| --- | --- | --- |
| **សកម្មភាព** | ◆ ផ្តល់អាទិភាពដល់តំបន់ក្រីក្របំផុត និងតំបន់ដែលពុំធ្លាប់មានការគាំទ្រ ដើម្បីផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។<br>◆ កំណត់រកស្រុក និងឃុំក្រីក្របំផុតនៅក្នុងខេត្ត និងគ្រួសារក្រីក្របំផុតនៅក្នុងភូមិ ដោយយោងតាមបញ្ជីកំណត់គ្រួសារក្រីក្រ ដែលត្រូវបានបង្កើតឡើង និងរក្សាដោយមន្ទីរផែនការខេត្ត។ | ◆ ស្ថាប័នអភិវឌ្ឍន៍សេវាកម្ម<br>◆ ស្ថាប័នអភិវឌ្ឍន៍សេវាកម្ម |

### ជនជាតិភាគតិច

ការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ និងការលើកកម្ពស់សុខភាព នឹងគោរពតាមគោលនយោបាយជាតិស្តីពីការអភិវឌ្ឍជនជាតិភាគតិច (ឆ្នាំ២០០៩) ។ ជាពិសេស រាល់សេចក្តីត្រូវការផ្នែកវប្បធម៌ ឬ ការប្រតិបត្តិពិសេស នឹងត្រូវយកមកធ្វើការពិចារណា នៅពេលបង្កើតសេវា ។

## ៤.៨.២. ពិការភាព

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំផែនការសកម្មភាពជាតិសម្រាប់ជនពិការ រួមទាំងអ្នករស់រានមានជីវិតពីគ្រាប់មីន គ្រាប់សំណល់មិនទាន់ផ្ទុះ (ឆ្នាំ២០០៩-២០១១)។

ការដោះស្រាយបញ្ហាពិការភាព នឹងរួមបញ្ចូលនូវដំណើរការវាយតម្លៃផលប៉ះពាល់ទៅលើជនពិការ នៃគម្រោងសកម្មភាពទាំងឡាយរួមទាំងច្បាប់ គោលនយោបាយ ឬកម្មវិធី ក្នុងគ្រប់តំបន់ នៅគ្រប់លំដាប់ថ្នាក់ ដោយទទួលយកនូវក្តីបារម្ភ និងបទពិសោធន៍របស់ជនពិការបញ្ចូលក្នុងការបង្កើតការអនុវត្ត ការតាមដានត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយ និងកម្មវិធីក្នុងគ្រប់ទិដ្ឋភាពនយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច នោះភាពស្មើគ្នាចំពោះឱកាសសម្រាប់ជនពិការ នឹងអាចសម្រេចបានដោយជោគជ័យ ។

[62] នេះជាផ្នែកនៃគម្រោងដែលទូទៅហៅថា គម្រោងអត្តសញ្ញាណកម្មគ្រួសារក្រីក្រ

សំខាន់ត្រូវចងចាំជានិច្ចថាមានសណ្ឋានជាច្រើននៃជនពិការ ។ ជនពិការជាក្រុម មិនត្រឹមតែមាន ភាពចុះអន់ខ្សោយផ្នែករាងកាយផ្សេងៗគ្នា ដែលត្រូវការការយកចិត្តទុកដាក់ខុសគ្នាប៉ុណ្ណោះទេ ថែមទាំងបង្ហាញពីភាពខុសគ្នារវាងសេចក្ដីត្រូវការពិសេសសម្រាប់បុរសនិងស្ត្រីកុមារនិងមនុស្សចាស់ ប្រជាពលរដ្ឋមកពីទីក្រុង ឬជនបទ ឬមានសាវតារប្បធម៌ សាសនា ឬប្រពៃណីខុសៗគ្នា ។

| **លទ្ធផល** | សេចក្ដីត្រូវការនិងក្ដីបារម្ភ របស់ជនពិការ ត្រូវបានដោះស្រាយជាអាទិភាព ក្នុងការផ្ដល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និង អនាម័យជនបទ និងលើកកម្ពស់ការផ្លាស់ប្ដូរឥរិយាបថអនាម័យផ្ទាល់ខ្លួន | **ការទទួលខុសត្រូវ** |
|---|---|---|
| **សកម្មភាព** | ◆ ការបង្កើត និងការផ្ដល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ត្រូវគោរពតាមច្បាប់ស្ដីពីកិច្ចគាំពារ និងការលើកកម្ពស់សិទ្ធជនពិការ (ឆ្នាំ២០០៩)។<br>◆ គម្រោង និងកម្មវិធីទឹកស្អាត និងអនាម័យជនបទទាំងអស់នឹងត្រូវពិចារណាលើសេចក្ដីត្រូវការរបស់ជនពិការ នៅគ្រប់ដំណាក់កាលនៃការរៀបចំ និងអនុវត្តគម្រោង និងកម្មវិធី។<br>◆ អង្គការជនពិការ នឹងត្រូវបានបញ្ចូល ឬធ្វើជាតំណាងនៅក្នុងដំណើរការពិគ្រោះយោបល់គណៈកម្មការ ឬ ក្រុមប្រឹក្សាផ្ដល់យោបល់ ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទក្រុមប្រឹក្សាសកម្មភាពជនពិការ ដៃគូអភិវឌ្ឍន៍ និងអ្នក ផ្ដល់សេវាទាំងអស់<br>◆ អ្នកផ្ដល់សេវាទាំងអស់<br>◆ ក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ ក្រសួងអភិវឌ្ឍន៍ជនបទ គណៈកម្មាធិការ និងក្រុមប្រឹក្សាផ្សេងៗទៀត |

ជាការសំខាន់ណាស់ដែលការយកចិត្តទុកដាក់ ត្រូវធ្វើទៅលើជនពិការគ្រប់ប្រភេទទាំងអស់ ។ ជាទូទៅគេសង្កេតឃើញអង្គការជនពិការ ភាគច្រើនតំណាងឲ្យក្រុមជនមានពិការភាពជាក់លាក់ផ្នែកណាមួយ (ខ្វាក់ភ្នែក រងរបួសដោយសារសង្គ្រាម ជាដើម) ខណៈដែលក្រុមដែលមានពិការភាពផ្សេងទៀត មិនត្រូវបានរួមបញ្ចូល ។ បើអាចធ្វើទៅបាន អ្នកតំណាងស្ត្រីពិការ គួរចូលរួមផងដែរ ដើម្បីរួមបញ្ចូលការបញ្ជ្រាបយេនឌ័រ ។

## សមាសភាគ ៤.៩ ការបញ្ជ្រាបយេនឌ័រ

ការបញ្ជ្រាបទិដ្ឋភាពយេនឌ័រ ទៅគ្រប់ប្រភេទនៃសកម្មភាព (ដែលហៅថា ការបញ្ជ្រាបយេនឌ័រ) គឺជាយុទ្ធសាស្ត្រដែលទទួលស្គាល់ជាសាកលសម្រាប់ការលើកកម្ពស់សមភាពយេនឌ័រ។ការបញ្ជ្រាបនេះ មិនមែនជាចំណុចចុងក្រោយនោះទេ ប៉ុន្តែវាជាមធ្យោបាយទៅរកគោលដៅសមភាពយេនឌ័រ ។

ការបញ្ជ្រាបនេះ ពាក់ព័ន្ធនឹងការធានាថា ទិដ្ឋភាពយេនឌ័រ និងការយកចិត្តទុកដាក់លើ គោលដៅសមភាពយេនឌ័រ គឺជាស្នូលនៃសកម្មភាពទាំងអស់ ដូចជាការកសាងគោលនយោបាយ ការស្រាវជ្រាវ ការតស៊ូមតិ ការសន្ទនា ការធ្វើច្បាប់ ការបែងចែកធនធាន ព្រមទាំងការធ្វើផែនការ ការអនុវត្ត និងការតាមដានត្រួតពិនិត្យកម្មវិធី និងគម្រោង ។ ការកសាងឲ្យមានការយល់ដឹងគ្រប់គ្រាន់ក្នុងការងារបញ្ជ្រាបយេនឌ័រ តម្រូវឲ្យមានភាពច្បាស់លាស់ចំពោះទស្សនាទាន យេនឌ័រ និងសមភាព[63] ។

ក្រសួងកិច្ចការនារី បានផ្សព្វផ្សាយផែនការនារីរតនៈ III ដែលជាផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ (២០០៩ ២០១៣) សម្រាប់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រីនៅកម្ពុជា ដែលរួមចំណែកដល់ការបញ្ជ្រាបយេនឌ័រ ។ មានការលើកបញ្ជាក់ថា ‹ទោះបីជាមានវឌ្ឍនភាពល្អក្នុងការបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ កម្មវិធី និងយន្តការនានា ដើម្បីគាំទ្រការបញ្ជ្រាបយេនឌ័រនៅ ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិក៏ដោយ ក៏សមត្ថភាពសម្រាប់ធ្វើការវិភាគយេនឌ័រ និងការតស៊ូមតិដោយផ្អែកលើភស្តុតាង នៅតែមានភាពទន់ខ្សោយនៅឡើយ ។ ការធ្វើសុខដុមនីយកម្មផែនការបញ្ជ្រាបយេនឌ័រ ជាមួយនឹងយុទ្ធសាស្ត្ររបស់វិស័យនានា និងយន្តការតាមដានត្រួតពិនិត្យ និងការប្រមូលធនធានឲ្យបានគ្រប់គ្រាន់ សម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព នៅតែជាបញ្ហាប្រឈម›[64]។ ផែនការនេះរួមមានផងដែរកម្មវិធីបញ្ជ្រាបយេនឌ័រ ដែលកំណត់លទ្ធផល ឬ ចំណុចគោលដៅ សម្រាប់ការបញ្ជ្រាបយេនឌ័រ នៅថ្នាក់វិស័យ និងការបញ្ជ្រាបយេនឌ័រក្នុងកម្មវិធីកំណែទម្រង់របស់រាជរដ្ឋាភិបាល ។ ចំណុចពាក់ព័ន្ធនានាក្រោមការងារនេះ មានដូចតទៅ ៖

- ការកាត់បន្ថយភាពក្រីក្រដែលឆ្លើយតបទៅនឹងយេនឌ័រ និងគោលនយោបាយ និងសេវាកម្មអភិវឌ្ឍន៍ជនបទ
- សេវាសុខាភិបាល ទឹកស្អាត និងអនាម័យត្រូវបានលើកកម្ពស់ ជាពិសេស ផ្តោតលើស្ត្រី និងកុមារ
- កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គឺមានលក្ខណៈឆ្លើយតបទៅនឹងយេនឌ័រ ។

នៅក្នុងក្រសួងអភិវឌ្ឍន៍ជនបទ មានក្រុមធ្វើសកម្មភាពបញ្ជ្រាបយេនឌ័រ ហើយក្រសួងអភិវឌ្ឍន៍ជនបទ គឺជាក្រសួងមួយក្នុងចំណោមក្រសួងដំបូង ដែលបានបង្កើតផែនការសកម្មភាពបញ្ជ្រាបយេនឌ័រឆ្នាំ២០០៦-២០១០ ។ ប៉ុន្តែ ទាំងខ្លឹមសារ និងការអនុវត្តផែនការ នៅទន់ខ្សោយនៅឡើយ ។[65]

---

[63] (OSAGI, 2001)

[64] (ក្រសួងកិច្ចការនារី ឆ្នាំ២០០៩)

[65] (Pennells, 2009)

| លទ្ធផល | យេនឌ័រ ត្រូវបានបញ្ជ្រាបទៅក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ | ការទទួលខុសត្រូវ |
|---|---|---|
| សកម្មភាព | ◆ ពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពផែនការសកម្មភាព បញ្ជ្រាបយេនឌ័រ។<br>◆ ពិនិត្យឡើងវិញរាល់គោលការណ៍ណែនាំ និងនីតិវិធីដែលមានស្រាប់ និងត្រូវបង្កើតនៅពេលខាងមុខរបស់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទដើម្បីធានាថាគោលការណ៍ណែនាំ និងនីតិវិធីទាំងនេះ បានបញ្ជាក់និងណែនាំអំពីបញ្ហាយេនឌ័របានគ្រប់គ្រាន់។<br>◆ បង្កើតវគ្គតំរង់ទិសអំពីយេនឌ័រ សម្រាប់មន្ត្រីរដ្ឋាភិបាល ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងអ្នកផ្តល់សេវាកម្មក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។<br>◆ រៀបចំវគ្គតំរង់ទិសអំពីយេនឌ័រ សម្រាប់ភាគីពាក់ព័ន្ធទាំងឡាយ | ◆ ក្រុមការងារបញ្ជ្រាបយេនឌ័រនៃក្រសួងអភិវឌ្ឍន៍ជនបទជាមួយក្រសួងកិច្ចការនារី<br>◆ ក្រុមការងារបញ្ជ្រាបយេនឌ័រនៃក្រសួងអភិវឌ្ឍន៍ជនបទជាមួយក្រសួងកិច្ចការនារី<br>◆ ក្រុមការងារបញ្ជ្រាបយេនឌ័រនៃក្រសួងអភិវឌ្ឍន៍ជនបទជាមួយអង្គការផ្តល់ការបណ្តុះបណ្តាល<br>◆ អង្គការផ្តល់ការបណ្តុះបណ្តាល |

ទិដ្ឋភាពផ្សេងៗទៀតនៃការបញ្ជ្រាបយេនឌ័រ មានរួមបញ្ចូលក្នុងសមាសភាគពាក់ព័ន្ធនៃ យុទ្ធសាស្រ្តនេះ ។

## សមាសភាគ ៤.១០ បរិស្ថាន

ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ មានផ្សារភ្ជាប់យ៉ាងជិតស្និតទៅនឹងបរិស្ថាន ។ ការផ្គត់ផ្គង់ទឹកអាស្រ័យលើការទទួលបានទឹកមានគុណភាពល្អពីបរិស្ថាន ហើយអនាម័យមិនល្អអាចនឹងធ្វើឲ្យមានការបំពុលប្រភពទឹក និងបង្កើនបន្ទុកជំងឺទៅក្នុងបរិស្ថានថែមទៀត ។ ការយល់ដឹងអំពីបញ្ហានេះ និងអំពីការគ្រប់គ្រងធនធានទឹកចម្រុះ នៅថ្នាក់សហគមន៍ និងថ្នាក់ក្រោមជាតិនៅមានកម្រិតនៅឡើយ ។

ក្រសួងបរិស្ថានបានអនុម័តច្បាប់ ដែលរួមមានច្បាប់ការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងប្រកាសជាច្រើន ប៉ុន្តែការអនុវត្តច្បាប់ទាំងនេះនៅក្នុងការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ត្រូវការការណែនាំច្បាស់លាស់ជាងនេះទៀត ។

| | | |
|---|---|---|
| **លទ្ធផល** | ផលប៉ះពាល់បរិស្ថានបណ្តាលមកពីសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ត្រូវបានយល់ដឹងនៅគ្រប់លំដាប់ថ្នាក់ទាំងអស់ ហើយផលប៉ះពាល់ទាំងនេះនឹងត្រូវបានកាត់បន្ថយនៅក្នុងដំណើរការអភិវឌ្ឍ និងផ្តល់សេវាកម្ម | **ការទទួលខុសត្រូវ** |
| **សកម្មភាព** | ◆ ធ្វើការសិក្សាពីកម្រិតយល់ដឹង និងទំនាក់ទំនងរវាងសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ និងផលប៉ះពាល់បរិស្ថាន រួមទាំងការគ្រប់គ្រងធនធានទឹកចំរុះ និងផលប៉ះពាល់ដល់សុខភាព។<br>◆ កសាងគោលការណ៍ណែនាំ និងនីតិវិធី ដើម្បីដោះស្រាយផលប៉ះពាល់បរិស្ថាន រួមទាំងច្បាប់ដែលពាក់ព័ន្ធ ក្នុងការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ |

## សមាសភាគ៤.១១. ការគ្រប់គ្រង និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

ហានិភ័យគ្រោះមហន្តរាយធំៗ ដែលប៉ះពាល់លើការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ គឺគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ។ ហានិភ័យទាំងនេះ ទំនងនឹងកើនឡើង ជាមួយនឹងការប្រែប្រួលអាកាសធាតុ រួមជាមួយនិងហានិភ័យបន្ថែមនៃការកើនឡើងកម្ពស់ទឹកសមុទ្រ ដែលជះឥទ្ធិពលទៅលើតំបន់ឆ្នេរផងនោះ គឺអាចបង្កឲ្យមានការជ្រាបចូលជាតិអំបិល ដែលប៉ះពាល់ដល់ទឹកក្រោមដី ។

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយដែលមាននាយករដ្ឋមន្ត្រីជាប្រធាន ត្រូវបាន □ ចាត់តាំងឲ្យដឹកនាំការគ្រប់គ្រងគ្រោះមហន្តរាយ រួមទាំងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ការត្រៀមលក្ខណៈចំពោះគ្រោះមហន្តរាយ និងការសម្របសម្រួលការអនុវត្ត ក្នុងករណីមានគ្រោះមហន្តរាយ ។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយបានផ្សព្វផ្សាយ ផែនការយុទ្ធសាស្ត្រសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ឆ្នាំ២០០៨-២០១៣ ។

| | | |
|---|---|---|
| **លទ្ធផល** | ◆ សេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទត្រូវបានអភិវឌ្ឍ ដោយកាត់បន្ថយផលប៉ះពាល់ គ្រោះមហន្តរាយ និងហានិភ័យនៃការប្រែប្រួលអាកាសធាតុ | **ការទទួលខុសត្រូវ** |
| **សកម្មភាព** | សម្របសម្រួលជាមួយគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ នូវវិធានការត្រៀមបង្ការ និងគ្រប់គ្រងគ្រោះមហន្តរាយ។<br>◆ កែសម្រួលលក្ខណៈបច្ចេកទេសសម្រាប់សំណង់ផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ក្នុងតំបន់ងាយរងគ្រោះដោយទឹកជំនន់។<br>◆ រៀបចំផែនទីចង្អុលបង្ហាញពីតំបន់ងាយរងគ្រោះដោយទឹកជំនន់ រាំងស្ងួត និងបង្កើតវិធានការកាត់បន្ថយផលប៉ះពាល់។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ |

## គោលដៅយុទ្ធសាស្ត្រទី៥ ៖ ហិរញ្ញប្បទានសម្រាប់វិស័យ

### សមាសភាគ៥.១. ហិរញ្ញប្បទាននៃចំណាយទុនដើម

ប្រភពហិរញ្ញប្បទាន រួមមាន ៖

- រដ្ឋាភិបាល តាមបណ្តាក្រសួងផ្សេងៗ និងតាមរយៈមូលនិធិឃុំ-សង្កាត់
- វិភាគទានពីអ្នកប្រើប្រាស់ ( ជាសាច់ប្រាក់ សម្ភារពលកម្ម [66]និងតាមរយៈការសងទៅ ហិរញ្ញប្បទានវិស័យឯកជន )
- កម្ចី[67] និងជំនួយឥតសំណង ពីដៃគូអភិវឌ្ឍន៍ ( ពហុភាគី ទ្វេភាគី និងអង្គការមិនមែនរដ្ឋាភិបាល ) យុទ្ធសាស្រ្តហិរញ្ញប្បទានវិស័យ ស្នើឡើងនូវមធ្យោបាយចំនួនបី សម្រាប់កាត់បន្ថយចំណុចខ្វះខាតផ្នែកហិរញ្ញប្បទាន ដែលក្នុងនោះមធ្យោបាយពីរពាក់ព័ន្ធនឹងវិស័យជនបទ[68] ៖
- ការកើនឡើងខ្ពស់ ក្នុងការគាំទ្រដោយថវិកាសាធារណៈ ក្នុងអំឡុងពេលនេះដល់ឆ្នាំ២០១៥ -បន្ទាប់មកអាច ថយចុះក្នុងអំឡុងពេលក្រោយឆ្នាំ២០២០
- ការកើនឡើងតិចតួចក្នុងហិរញ្ញប្បទានឯកជន ដែលផ្តល់ដោយគ្រួសារផ្ទាល់

[66] នៅក្នុងគោលនយោបាយជាតិ សហគមន៍ត្រូវ បង់វិភាគទានសំរាប់ការអនុវត្ត និងការសាងសង់សំណង់ទឹកស្អាត និងអនាម័យ ក្នុងនោះមានថវិការ កំលាំង ពលកម្ម សម្ភារៈ និងវិភាគទានជាទំរង់ផ្សេងៗទៀត ។
[67] កម្ចីក៏អាចចាត់ជាហិរញ្ញប្បទានរដ្ឋាភិបាល ព្រោះថាហិរញ្ញប្បទាននេះត្រូវសងមកវិញនាពេលអនាគត ដោយចំណូលរបស់រដ្ឋ ។
[68] វិធីទីបី( ការដំឡើងថ្លៃទៅលើអ្នកប្រើប្រាស់ ) គឺពាក់ព័ន្ធតែជាមួយវិស័យទីក្រុងប៉ុណ្ណោះ ។

យុទ្ធសាស្ត្រហិរញ្ញប្បទានវិស័យ សន្មតថាជំនួយអភិវឌ្ឍន៍ផ្លូវការនឹងនៅមានក្នុងកម្រិតថេរ (គិតជាដុល្លារអាមេរិក) ក្នុងអំឡុងពេលអនុវត្តន៍យុទ្ធសាស្ត្រទាំងមូល និងបានសន្មតថាជំនួយនេះនឹងមិនអាចកើនឡើងទេ។ ក៏មានការរំពឹងដែរថា ម្ចាស់ជំនួយធំៗ ដូចជា ធនាគារអភិវឌ្ឍន៍អាស៊ី នឹងកាត់បន្ថយជំនួយឥតសំណង ហើយបង្កើនបរិមាណប្រាក់កម្ចី (បើរាជរដ្ឋាភិបាលកម្ពុជាមានបំណងទទួលបានកម្ចីទាំងនោះ)។[69]

សហគមន៍នឹងត្រូវចូលរួមបដិភាគចំពោះចំណាយមូលធនលើហេដ្ឋារចនាសម្ព័ន្ធ ។ សមាមាត្រនៃការចូលរួមបដិភាគនេះ ត្រូវអនុវត្តក្នុងសណ្ឋានដូចគ្នា ដោយអង្គការគាំទ្រផ្សេងៗគ្នា ប៉ុន្តែអាចត្រូវមានភាពខុសៗគ្នាតាមតំបន់ផ្សេងៗនៅ្ទងប្រទេស  អាស្រ័យតាមលក្ខខណ្ឌសេដ្ឋកិច្ចនៅមូលដ្ឋាន។ នីតិវិធីនឹងត្រូវកសាងឡើង សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីកំណត់ការចុលរួមវិភាគទានជាភាគរយតាមខេត្ត ឬស្រុក ។

### ៥.១.១. ហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ និងផ្នែកទន់ (Software)

| **លទ្ធផល** | ធ្វើឲ្យមានមូលនិធិហិរញ្ញវត្ថុចាំបាច់ សម្រាប់ផ្តល់ហេដ្ឋារចនាសម្ព័ន្ធថ្មី និងការជួសជុលហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ នៃសេវាផ្គត់ផ្គង់ទឹកស្អាត និង អនាម័យជនបទ | **ការទទួលខុសត្រូវ** |
|---|---|---|
| **សកម្មភាព** | ◆ រៀបចំផែនការវិនិយោគវិស័យផ្គត់ផ្គង់ទឹកស្អាត និង អនាម័យជនបទ។<br>◆ តស៊ូមតិឲ្យមានការបង្កើននូវមូលនិធិគាំទ្រពីរាជរដ្ឋាភិបាល ដោយបង្ហាញពីផលចំណេញសេដ្ឋកិច្ច និងសង្គមកិច្ច ដែលបានមកពីការវិនិយោគលើសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។<br>◆ ពិនិត្យឡើងវិញលើសមាមាត្រនៃការចូលរួមបដិភាគ ពីសហគមន៍ក្នុងខេត្ត និងស្រុកនីមួយៗ ៖<br>- បង្កើតនីតិវិធី និងលក្ខណៈវិនិច្ឆ័យ សម្រាប់កំណត់អត្រាចូលរួមបដិភាគរបស់សហគមន៍។<br>- កំណត់អត្រាចូលរួមបដិភាគនៅតាមមូលដ្ឋាន ដោយអនុលោមតាមនីតិវិធីដែលបានបង្កើតឡើង។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទជាមួយ នឹងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយនឹងក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ<br><br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរមូលដ្ឋាន |

[69] (COWI, 2010)

## ៥.១.២. យន្តការផ្តល់ហិរញ្ញប្បទានផ្នែកអនាម័យ

បទពិសោធន៍នៅកម្ពុជា និងប្រទេសផ្សេងៗទៀតបានបង្ហាញថា ការឧបត្ថម្ភធនផ្ទាល់សម្រាប់ហេដ្ឋារចនាសម្ព័ន្ធអនាម័យ មិនមានប្រសិទ្ធភាពក្នុងការលើកកម្ពស់ការសាងសង់បង្គន់ ហើយនិងការផ្លាស់ប្តូរឥរិយាបថអនាម័យដែលធានានូវការប្រើប្រាស់បង្គន់អនាម័យនោះទេ។មានបញ្ហាមួយចំនួនពាក់ព័ន្ធនឹងការប្រើប្រាស់វិធីសាស្រ្តនោះដែលបញ្ហាទាំងនោះ រួមមានតម្លៃដ៏ខ្ពស់នៃការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ ការធ្វើឲ្យអន់ថយផ្សារសម្រាប់អនាម័យ ការរារាំងការលើកកំពស់ប្រភពហិរញ្ញប្បទានផ្សេងៗទៀត (ជាពិសេស ហិរញ្ញប្បទានគ្រួសារ និងពាណិជ្ជកម្ម) ភាពជាម្ចាស់ និងការប្រើប្រាស់បង្គន់ព្រមទាំងការទទួលបាន ឱកាសដោយគ្រួសារធូរធារនៅក្នុងពេលដែលមានការផ្តល់ការគាំទ្រសម្រាប់គ្រួសារក្រីក្រ ។ ការឧបត្ថម្ភធនលើសំណង់បង្គន់ គួរធ្វើឡើងដោយប្រុងប្រយ័ត្ន និងជាជម្រើសចុងក្រោយប៉ុណ្ណោះ។ ថវិកាសាធារណៈសម្រាប់អនាម័យគួរតែត្រូវបានប្រើបាស្រ់សម្រាប់ជំរុញឲ្យមានតម្រូវការ និងបង្កើតឲ្យមានបរិយាកាសសមស្រប (រួមទាំងលទ្ធភាពនៃការរកទិញបានផលិតផលបង្គន់អនាម័យដែលមានតម្លៃសមស្រប) ដើម្បីឲ្យគ្រួសារនីមួយៗចំណាយថវិកាផ្ទាល់ របស់គេដើម្បីសង់បង្គន់។ ការឧបត្ថម្ភធនផ្ទាល់សម្រាប់ការសាងសង់បង្គន់អនាម័យ ការឧបត្ថម្ភធនអាចត្រូវបានអនុវត្តចំពោះគ្រួសារក្រីក្រឲ្យមានបង្គន់ប្រើប្រាស់ ដើម្បីសម្រេចឲ្យបាននូវចក្ខុវិស័យ។ ការឧបត្ថម្ភធនសម្រាប់គ្រួសារក្រីក្រដើម្បីទទួលបានបង្គន់អនាម័យ អាចធ្វើទៅបានតាមយន្តការផ្សេងៗ ដែលមានបង្ហាញនៅក្នុងទំព័រក្រោយៗ។

អ្វីដែលត្រូវការនោះ គឺហិរញ្ញប្បទាន ដែលផ្តោតលើការផ្តល់ឲ្យនូវលទ្ធផលដែលអាចវាស់វែង និងអាចសម្រេចបាន ក្នុងការសម្រេចបានលទ្ធផលដែលប្រាថ្នាចង់បាន ។ ការឧបត្ថម្ភធនដោយផ្អែកលើលទ្ធផល គឺជាមធ្យោបាយមួយ ក្នុងការផ្តល់ហិរញ្ញប្បទានសាធារណៈដល់ផ្នែកអនាម័យដែលមានប្រសិទ្ធភាព ហើយដែលផលប៉ះពាល់ លើលទ្ធភាពទទួលបានសេវា និងប្រសិទ្ធភាពផ្នែកបរិស្ថានអាច វាសវែងបាន។ វាជាវិធីសាស្រ្តមួយដែលការវិនិយោគអាចរួមបញ្ចូលជាមួយគុណភាពនៃការអនុវត្តដែល កំពុងត្រូវបានគេលើកទឹកចិត្ត។ បញ្ហាប្រឈមសំខាន់ក្នុងវិស័យអនាម័យ (សេវាផ្សេងៗទៀត ដែលមិនមែនជាការផ្តល់ហេដ្ឋារចនាសម្ព័ន្ធសុទ្ធសាធ ប៉ុន្តែតម្រូវឲ្យមានការផ្លាស់ប្តូរឥរិយាបថ និងការអនុវត្ត ដែលបានចាក់ឫសយ៉ាងជ្រៅទៅក្នុងផ្នត់គំនិត) គឺថាលទ្ធផលដែលសម្រេចបានមានការលំបាកក្នុងការវាស់វែង និងកាន់តែលំបាកទៅទៀតក្នុងការកំណត់ថាលទ្ធផលនេះបានមកពីវិធីសាស្រ្តណាមួយ។[70] យន្តការផ្តល់ជំនួយដោយផ្អែកតាមលទ្ធផល (**OBA**) ដែលមានសក្តានុពលសម្រាប់ប្រភេទសេវាអនាម័យផ្សេងៗមានបង្ហាញក្នុងតារាងទី១០។

[70] (Trémolet & Evans, forthcoming)

## តារាងទី១០ ៖ យន្តការផ្តល់ជំនួយដោយផ្អែកតាមលទ្ធផល សម្រាប់ប្រភេទសេវាអនាម័យផ្សេងៗ

| ប្រភេទសេវា | ខ្ទង់ចំណាយផ្តល់ឲ្យខ្លះ ផ្អែកលើលទ្ធផលជាក់ស្តែង | | លទ្ធផលជាសូចនាករ (សម្រាប់តាមដាន ត្រួតពិនិត្យ និង ការទូទាត់) |
|---|---|---|---|
| | ចំណាយថ្លៃដើម | ចំណាយប្រតិបត្តិការ | |
| **ផ្អែកទន់** | | | |
| ទីផ្សារអនាម័យ | | ប្រាក់ខែបុគ្គលិក ចំណាយដឹកជញ្ជូន ការអភិវឌ្ឍសម្ភារៈ | ◆ ចំនួនទស្សនៈកិច្ច និង ការប្រជុំជំរុញ លើកទឹកចិត្ត<br>◆ ចំនួនប្រជាពលរដ្ឋ សម្រេចចិត្ត វិនិយោគលើការ សង់បង្គន់ ក្រោយពី មានទស្សនកិច្ច |
| ចលនាសង្គម ដោយមានការជំរុញ លើកទឹកចិត្ត | | | ◆ ភូមិ-សហគមន៍បញ្ឈប់ការ បន្ទោបង់ពាសវាល ពាសកាល |
| ការលើកកម្ពស់ អនាម័យផ្ទាល់ខ្លួន | | | ◆ ចំនួនប្រជាពលរដ្ឋប្រកាន់ យកការអនុវត្ត អនាម័យ ផ្ទាល់ខ្លួន |
| មីក្រូហិរញ្ញវត្ថុ សម្រាប់គ្រួសារ | | ឧបត្ថម្ភធនអត្រាការប្រាក់ និងចំណាយ កសាងផលិតផល ហិរញ្ញវត្ថុថ្មី | ទំហំប្រាក់កម្ចី ដែលបាន ផ្តល់ឲ្យ (ដោយសារការ ឧបត្ថម្ភធនត្រូវបង្កប់ នៅក្នុងអត្រាការប្រាក់ ការចេញប្រាក់ ធ្វើឡើង ប្រសិនបើប្រាក់កម្ចី ត្រូវបាន ផ្តល់ឲ្យ) |

| ផ្នែករឹង | | | |
|---|---|---|---|
| ការសង់បង្គន់នៅនឹងកន្លែង (បង្គន់ដែលប្រើរណ្តៅលូ ឬអាងស្តុកលាមក) | ចំណាយសាងសង់ | | ◆ ភូមិ-សហគមន៍ បានក្លាយទៅជាភូមិដែលមានការបញ្ឈប់ការបន្ទោបង់លាមក ពាសវាលពាសកាល ◆ ចំនួនបង្គន់សាងសង់សម្រាប់ គ្រួសារដែលមានលក្ខណៈគ្រប់គ្រាន់អាចទទួលបាន ◆ ចំនួនផែន និងចានបង្គន់ត្រូវបានលក់ឲ្យ គ្រួសារដែល មានលក្ខណៈវិនិច្ឆ័យ គ្រប់គ្រាន់ |
| ស្តារសម្អាតកាកសំណល់បង្គន់ ឬអាងស្តុកលាមក | ចំណាយនៃការចាប់ផ្តើម ឧបករណ៍ និងការស្តារឡើងវិញជាដំបូង | ចំណាយប្រតិបត្តិការ ឧបករណ៍ ប្រេង ប្រាក់ខែ ចំណាយសម្រាប់ការទុកដាក់លាមក | ◆ ចំនួនបង្គន់ដែលស្តារសម្អាតរួចសម្រាប់ គ្រួសារដែលមានលក្ខណៈវិនិច្ឆ័យ គ្រប់គ្រាន់ ◆ ទំហំកាកសំណល់ដែលបានយកចេញ |
| ដឹកជញ្ជូនសំណល់បង្គន់ និងទឹកលូ ទៅកន្លែងដែលមានការអនុញ្ញាតទុកដាក់សំណល់ | ចំណាយនៃការចាប់ផ្តើមការ វិនិយោគ | ប្រាក់ខែ ប្រេង ចំណាយសម្រាប់ចាក់កាកសំណល់ចោល | ◆ ចំនួនបង្គន់ដែលស្តារសម្អាតរួចសម្រាប់គ្រួសារដែលមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ ◆ ទំហំសំណល់ដែលត្រូវដឹកជញ្ជូនទៅកន្លែងទុកដាក់សំណល់ដែលមានការអនុញ្ញាត |

ដកស្រង់ចេញពី **(Trémolet & Evans, forthcoming)**

ក្នុងពេលបច្ចុប្បន្ន នៅប្រទេសកម្ពុជា បទពិសោធន៍អំពីទម្រង់នៃការផ្តល់ឧបត្ថម្ភធនប្រកបដោយភាពច្នៃប្រឌិតនៅមានកម្រិតនៅឡើយ ។ ក្រសួងអភិវឌ្ឍន៍ជនបទ នឹងបង្កើតក្រុមការងារដើម្បីណែនាំលើការកសាងយន្តការផ្សេងៗ សម្រាប់ធ្វើហិរញ្ញប្បទានផ្នែកអនាម័យ ។ ក្រុមនេះនឹង

រួមមានអ្នកតំណាងពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ។

វិធីសាស្ត្រផ្សេងៗគ្នា នឹងត្រូវបង្កើតឡើងសម្រាប់ក្រុមនីមួយៗដែលមិនបានទទួលសេវា និងសម្រាប់ ការផ្តល់ការលើកកម្ពស់អនាម័យដំបូង និងហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងប្រតិបត្តិការ និងការថែទាំរយៈពេលវែង ។ ក្រុមគោលដៅសម្រាប់វិធីសាស្ត្រនីមួយៗ គួរត្រូវកំណត់ឲ្យបាន ច្បាស់លាស់ ហើយភាពខ្វះចន្លោះត្រូវតែលើកឡើងដើម្បីឲ្យមានការអនុម័តវិធីសាស្ត្រតបន្តមទៀតដលែមានលក្ខណៈបំពេញគ្នា ។[71]

វិធីសាស្ត្រសម្រាប់ការឧបត្ថម្ភធនផ្នែកទន់ និងផ្នែករឹងនឹងត្រូវគិតពីកត្តាមួយចំនួន ដូចមានលើកឡើងក្នុងឧបសម្ព័ន្ធទី៣ ។

[71] (Robinson, 2010)

| លទ្ធផល | ការផ្តល់ហិរញ្ញប្បទានផ្នែកអនាម័យ នឹងអនុវត្តយន្តការដែលមានការសាកល្បងត្រឹមត្រូវហើយបង្ហាញថាមានប្រសិទ្ធភាពខ្ពស់ក្នុងការទទួលបានសេវា អនាម័យប្រកបដោយនិរន្តរភាព ដើម្បីការពារសុខភាព និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន | ការទទួលខុសត្រូវ |
|---|---|---|
| សកម្មភាព | ◆ បង្កើតក្រុមការងារដើម្បីដឹកនាំ និងណែនាំការបង្កើតជម្រើសយន្តការនានាសម្រាប់ការធ្វើហិរញ្ញប្បទាន ផ្នែកអនាម័យ ដោយប្រើនីតិវិធីក្នុងសមាសភាគទី៦ ៖ ការសិក្សាស្រាវជ្រាវ ការអភិវឌ្ឍ និងការច្នៃប្រឌិត។<br>បង្កើតឲ្យមានការសាកល្បងដកពិសោធន៍យន្តការផ្តល់ហិរញ្ញប្បទាន។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍<br><br>◆ ដៃគូអភិវឌ្ឍន៍ អាជ្ញាធរមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល |
| | ◆ តាមដានត្រួតពិនិត្យប្រសិទ្ធភាពនៃយន្តការនោះដោយពិនិត្យទៅលើការដែលបានរាប់បញ្ចូល ឬមិនបានរាប់បញ្ចូលក្រុមគោលដៅដែលត្រូវទទួលបានហិរញ្ញប្បទាននិងការទទួលយកឥរិយាបថអនុវត្តអនាម័យល្អ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br><br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ |
| | ◆ ធ្វើការវាយតម្លៃប្រៀបធៀបយន្តការផ្តល់ហិរញ្ញប្បទានទាំងឡាយបន្ទាប់ពីដាក់ឲ្យអនុវត្តមួយរយៈកន្លងមក។<br>◆ បង្កើតឲ្យមានគោលការណ៍ណែនាំស្តីពីយន្តការប្រកបដោយប្រសិទ្ធភាពសមស្របសម្រាប់ក្រុមគោលដៅផ្សេងៗ។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយនឹងក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងដៃគូអភិវឌ្ឍន៍ |

### ៥.១.៣. ការអភិវឌ្ឍសមត្ថភាព

ចំណាយសម្រាប់ការអភិវឌ្ឍសមត្ថភាព ក្នុងសមាសភាគ៤.២ និងសម្រាប់ការអភិវឌ្ឍវិស័យឯកជន ក្នុងសមាសភាគ៤.៣ មិនបានរួមបញ្ចូលក្នុងយុទ្ធសាស្ត្រហិរញ្ញប្បទានវិស័យនោះទេ ។ការប៉ាន់ ស្មានការចំណាយត្រូវធ្វើឡើងនៅក្នុងផែនការអភិវឌ្ឍន៍សមត្ថភាព ។

| **លទ្ធផល** | មានមូលនិធិ សម្រាប់អភិវឌ្ឍសមត្ថភាព ស្ថាប័ន និងវិស័យឯកជន នៅលើការគ្រប់គ្រង និងផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ជនបទ ព្រមទាំងការលើកកម្ពស់អនាម័យផ្ទាល់ខ្លួន | **ការទទួលខុសត្រូវ** |
|---|---|---|
| សកម្មភាព | ◆ ប៉ាន់ស្មានថវិកាចំណាយលើផែនការ អភិវឌ្ឍន៍សមត្ថភាព<br>◆ ប៉ាន់ស្មានថវិកាចំណាយលើការ អភិវឌ្ឍវិស័យឯកជន។<br>◆ តស៊ូមតិឲ្យមានការបង្កើននូវមូលនិធិគាំទ្រពីរ ដ្ឋាភិបាល ដោយបង្ហាញពីផលចំណេញសេដ្ឋកិច្ច និងសង្គមកិច្ច ដែលបានមកពីការវិនិយោគលើសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ។<br>◆ ស្វែងរកដៃគូអភិវឌ្ឍន៍ ដើម្បីចូលរួម និងផ្តល់មូលនិធិ គាំទ្រផែនការអភិវឌ្ឍន៍សមត្ថភាព និងអភិវឌ្ឍន៍វិស័យឯកជន។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ<br>◆ ក្រុមការងារបច្ចេកទេសវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ<br>◆ ក្រសួងអភិវឌ្ឍន៍ជនបទ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |

## សមាសភាគ៥.២. ហិរញ្ញប្បទានលើចំណាយចរន្ត

អនុលោមតាមគោលនយោបាយជាតិ ស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ សហគមន៍នឹងរ៉ាប់រងការចំណាយប្រតិបត្តិការទាំងស្រុងសម្រាប់ សេវាផ្គត់ផ្គង់ទឹកស្អាតរួមទាំងការទូទាត់ ដល់ បុគ្គលិក ឬអ្នកម៉ៅការ ចំណាយលើការជួសជុល និងការថែទាំ និងការផ្លាស់ប្តូរគ្រឿងបន្លាស់ (ដូច មានលើកឡើងក្នុងសមាសភាគ១.៣) ។ ក្រុមប្រើប្រាស់ទឹក និងអនាម័យ គួរបង្កើត និងរក្សាមូលនិធិថែទាំដើម្បីការងារនេះ ដោយមានវិភាគទានជាប្រចាំពីគ្រួសារអ្នកប្រើប្រាស់ ។ ក្រុមប្រើប្រាស់ទឹក និងអនាម័យ នឹងបញ្ចេញព័ត៌មានពេញលេញ និងជាប្រចាំអំពីគណនី ជូនដល់សហគមន៍ដែលប្រើប្រាស់ទឹក។ គ្រួសារទាំងអស់នឹងរ៉ាប់រងថ្លៃចំណាយលើប្រតិបត្តិការ និងការថែទាំបង្គន់របស់ពួកគេផ្ទាល់ រួមមានការគ្រប់គ្រងកាកសំណល់លាមកក្នុងលូស្តុក និងការស្តារសម្អាតនៅពេលចាំបាច់ ។

ការចំណាយលើដំណើរការប្រព័ន្ធទ្រទ្រង់ការថែទាំ នឹងជួយចេញដោយសហគមន៍អ្នកប្រើប្រាស់ (ពីមូលនិធិថែទាំរបស់ខ្លួន) និងរដ្ឋបាលនៅមូលដ្ឋាន (តាមរយៈការបែងចែកថវិកាវិភាជន៍ប្រចាំឆ្នាំពី រដ្ឋាភិបាលថ្នាក់ជាតិ) ។

ចំណាយចរន្តនៃការសម្របសម្រួល និងការពិនិត្យមើលលើការផ្តល់សេវា នឹងត្រូវរ៉ាប់រងដោយរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ចេញពីការបែងចែកវិភាជន៍ថវិកាប្រចាំឆ្នាំ ។

ចំណាយនៃការបន្តផ្តល់ការលើកកម្ពស់អនាម័យ និងការអប់រំ (ផ្នែកនៃសមាសភាគ៣.១) នឹងត្រូវទូទាត់ចេញពីខ្ទង់ចំណាយផ្នែកសង្គមនៃមូលនិធិឃុំ-សង្កាត់ ។

បច្ចុប្បន្ននេះ ប្រព័ន្ធហិរញ្ញវត្ថុរបស់រដ្ឋាភិបាល កំពុងតែធ្វើកំណែទម្រង់។ កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**PFMRP**) ដែលបានចាប់ផ្តើមនៅឆ្នាំ២០០៤ ហើយបច្ចុប្បន្ននេះស្ថិតក្នុងដំណាក់កាលទីពីរ ជាយានក្នុងការសម្រេចឲ្យបានការងារកំណែទម្រង់នេះ។ ចរិតលក្ខណនៃប្រព័ន្ធមានដែលនឹងកើតឡើងនេះរួមមាន[72]

- ការបែងចែកមុខងារច្បាស់លាស់តាមផ្លូវច្បាប់ និងអំណាចសារពើពន្ធ សម្រាប់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ប៉ុន្តែស្ថិតនៅក្នុងប្រព័ន្ធថវិកាតែមួយដូចគ្នា ដែលគ្របដណ្តប់គ្រប់ការិយាល័យមុខងារ កម្មវិធី និងគម្រោងទាំងអស់របស់រដ្ឋាភិបាល។
- ក្របខ័ណ្ឌវិភាគស្របគ្នា នៅគ្រប់វិស័យទាំងអស់ ដោយការចាយវាយ ឬរៀបចំថវិកាត្រូវធ្វើឡើងទៅតាមខ្ទង់រដ្ឋបាល សេដ្ឋកិច្ច និងមុខងារ ឬកម្មវិធីដែលកំណត់បង្ហាញពីការចំណាយពាក់ព័ន្ធនឹងភាពក្រីក្រ និងដែលគាំទ្រទិសដៅទូទៅនៃការគ្រប់គ្រងចំណាយសាធារណៈឆ្ពោះទៅរកការសម្រេចលទ្ធផលគោលនយោបាយ ។

ក្របខ័ណ្ឌផ្លូវច្បាប់នៃប្រព័ន្ធហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ ក៏កំពុងត្រូវបានកសាងផងដែរ រួមមានការរៀបចំ ‹ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ› ។ ទាំងនេះនឹងកំណត់យន្តការសម្រាប់កំណត់ថវិកាវិភាជន៍បែងចែក និងការផ្តល់ថវិកាចរន្ត សម្រាប់ប្រព័ន្ធរដ្ឋបាលថ្នាក់ខេត្ត និងថ្នាក់ស្រុក រួមទាំងបណ្តាមន្ទីរ និងការិយាល័យនៅថ្នាក់ទាំងនោះ ។

[72] (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២០១០)

| លទ្ធផល | មានថវិកាចំណាយចរន្ត សម្រាប់និរន្តរ-ភាពនៃសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ | ការទទួលខុសត្រូវ |
|---|---|---|
| សកម្មភាព | ◆ ចំណាយសម្រាប់ប្រតិបត្តិការលើសេវាផ្គត់ផ្គង់ទឹកស្អាត រួមទាំងការទូទាត់ថ្លៃចំណាយលើបុគ្គលិក ឬអ្នកម៉ៅការ ចំណាយលើការជួសជុល និងការថែទាំ ព្រមទាំងគ្រឿងបន្លាស់ និងការចូលរួមបដិភាគដល់ប្រព័ន្ធទ្រទ្រង់ការថែទាំ ។<br>◆ បង្កើត និងគ្រប់គ្រងមូលនិធិថែទាំ តាមរយៈការចូលរួមបដិភាគជាប្រចាំពីគ្រួសារអ្នកប្រើប្រាស់។<br>◆ ក្រុមគ្រួសារនីមួយៗនឹងបង់ថ្លៃចំណាយលើការប្រើប្រាស់ និងថែទាំបង្គន់អនាម័យរបស់ពួកគេផ្ទាល់ រួមមានការគ្រប់គ្រងកាកសំណល់លាមក និងការស្តារយកកាកសំណល់ទាំងនោះចេញ ។<br>◆ រៀបចំថវិកា និងបែងចែក ព្រមទាំងផ្តល់មូលនិធិសម្រាប់ចំណាយចរន្តលើការសម្របសម្រួល និងត្រួតពិនិត្យការផ្តល់សេវាកម្ម ដោយអនុលោមតាមវដ្តនៃការគ្រប់គ្រងហិរញ្ញវត្ថុនាពេលបច្ចុប្បន្ន និងអនាគត។ | ◆ អ្នកប្រើប្រាស់តាមផ្ទះ តាមរយៈក្រុមប្រើប្រាស់ទឹក និងអនាម័យ<br>◆ ក្រុមប្រើប្រាស់ទឹក និងអនាម័យ<br>◆ អ្នកប្រើប្រាស់តាមផ្ទះ<br>◆ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រព័ន្ធហិរញ្ញវត្ថុថ្នាក់ក្រោមជាតិ |

## ៩. តារាងពេលវេលា

យុទ្ធសាស្ត្រនេះគ្របដណ្តប់អំឡុងពេលពីឆ្នាំ ២០១១ - ២០២៥ ដែលជាកាលបរិច្ឆេទកំណត់ក្នុងគោលនយោបាយជាតិស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ដើម្បីសម្រេចឲ្យបានទស្សនវិស័យ របស់វិស័យនេះ ក្នុងការផ្តល់លទ្ធភាពទទួលបានសេវាដល់ប្រជាពលរដ្ឋនៅតាមជនបទទាំងអស់ ។ ឆ្នាំ ២០១៥ ជាកាលបរិច្ឆេទកំណត់ក្នុងការសម្រេចឲ្យបានគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា។

## ៩.១. អន្តរកាល

ក្នុងអំឡុងពេលពីឆ្នាំ២០១១-២០១៥ នឹងមានអន្តរកាលមួយ ។ ក្នុងអំឡុងពេលនោះ ការផ្លាស់ប្តូរធំៗ ក្នុងការរៀបចំស្ថាប័ន និងការកសាងសមត្ថភាព នឹងត្រូវបានធ្វើឡើង ។ គោលបំណង គឺធ្វើឲ្យមានការផ្លាស់ប្តូរឲ្យបានទាន់ពេលវេលា ដើម្បីឆ្លើយតបទៅនឹងកំណើនដ៏ធំធេង នៃការផ្តល់សេវាដែលត្រូវការរវាងឆ្នាំ២០១៥-២០២៥ ។

ការកសាងសមត្ថភាពចាំបាច់ត្រូវសម្របសម្រួលជាមួយការផ្លាស់ប្តូរក្នុងការរៀបចំស្ថាប័ន

រួមទាំងការកសាងសមត្ថភាព សម្រាប់ដំណើរការផ្សេងៗ ដូចជាផែនការកសាងសមត្ថភាព របស់គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឆ្នាំ ២០១០ ។

សកម្មភាពសម្រាប់ការផ្លាស់ប្តូរ ព្រមទាំងពេលវេលា និងលំដាប់លេខរៀង នឹងត្រូវកំណត់នៅក្នុងផែនការអនុវត្តន៍រយៈពេលប្រាំឆ្នាំ។

## ៩.២. ការពិនិត្យឡើងវិញ

ក្រសួងអភិវឌ្ឍន៍ជនបទ នឹងពិនិត្យឡើងវិញតាមកាលកំណត់ទៀងទាត់ លើការវិវឌ្ឍនៃការអនុវត្តយុទ្ធសាស្ត្រនេះ ។ ប្រសិនបើមានការចាំបាច់ ក្រសួងនឹងធ្វើការកែតម្រូវ ដោយយកចិត្តទុកដាក់ទៅលើការផ្លាស់ប្តូរ នៃតម្រូវការ និងកាលៈទេសៈ ជាពិសេសទៅលើការឆ្លើយតបទៅនឹងដំណើរការវិវឌ្ឍន៍ នៃវិមជ្ឈការ និងវិសហមជ្ឈការ។ ការពិនិត្យឡើងវិញលើកទី១ នឹងត្រូវអនុវត្តក្នុងឆមាសទី១ នៃឆ្នាំ ២០១៣ ដែលជាពាក់កណ្តាលផ្លូវនៃរយៈពេលអន្តរកាល ។

## ឧបសម្ព័ន្ធទី១ ៖ និយមន័យ

| | |
|---|---|
| ការទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាត ( **Access to water supply services** ) | លទ្ធភាពទទួលបានប្រភពទឹកកែលំអមួយ ដែលស្ថិតនៅចំងាយ ១៥០ម៉ែត្រ ពីលំនៅដ្ឋានអ្នកប្រើប្រាស់ ។ ប្រភពទឹក "កែលម្អ" គឺជាប្រភពទឹក ដែលអាចផ្តល់នូវទឹក "សុវត្ថិភាព" ដូចជាការតបណ្តាញទឹកនៅតាមផ្ទះ និងទឹកបានមកពីអណ្តូងខួងជាដើម ។ |
| ការទទួលបានអនាម័យសមស្រប ( **Access to adequate sanitation** ) | គឺជា លទ្ធភាពទទួលបានអនាម័យកែលម្អត្រឹមត្រូវមួយ នៅតាមលំនៅដ្ឋាន។ |
| វិធីសាស្ត្រ ( **Approaches** ) | មធ្យោបាយក្នុងការអនុវត្តកម្មវិធី ឬ គម្រោង ( តួនាទី និងវិធាន ) ។ |
| កម្រិតជាមូលដ្ឋាននៃសេវាផ្គត់ផ្គង់ទឹក និងអនាម័យ ( **Basic level of water supply and sanitation service** ) | បរិមាណទឹកជាមូលដ្ឋានសម្រាប់មនុស្សម្នាក់ ក្នុងមួយថ្ងៃគឺ ២០លីត្រ ដែលអាចរកបានពីប្រភពទឹកកែលំអនៅចម្ងាយ ១៥០ម៉ែត្រ ពីលំនៅដ្ឋានអ្នកប្រើប្រាស់ ។ |
| សហគមន៍ ( **Community** ) | ក្រុមមនុស្សជាក់លាក់ដែលស្ថិតនៅក្នុងការអនុវត្តសកម្មភាពរបស់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ។ |

[73] ( ក្រសួងអភិវឌ្ឍន៍ជនបទ និងដៃគូ ឆ្នាំ២០០៨ ) ព័ត៌មានបច្ចុប្បន្ននេះ មិនទាន់គ្រប់គ្រាន់ដើម្បីបង្កើតទំនាក់ទំនងរវាងការទទួលបានទឹក ប្រកបដោយសុវត្ថិភាព និងការទទួលបានប្រភពទឹកស្អាតនៅឡើយទេ ។ ពាក្យពីរខាងលើអាចនឹងច្រឡំគ្នា ឬត្រូវបានប្រើជំនួសឱ្យគ្នាទៅ វិញទៅមក

| | |
|---|---|
| ការចូលរួមថវិកាដោយសហគមន៍ ( **Community cost-sharing** ) | ការចំណាយដោយសមាជិកនៃសហគមន៍អ្នកប្រើប្រាស់សេវាកម្ម ទៅលើមូលនិធិថ្លៃទុនដើម ថ្លៃចំណាយចរន្ត ថ្លៃប្រតិបត្តិការ និងថែទាំ ឬក៏អាចជាថ្លៃអ្វីផ្សេងៗទៀតពាក់ព័ន្ធនឹងសេវាកម្ម ដែលត្រូវបានផ្តល់ឱ្យ ។ |
| វិមជ្ឈការ ( **Decentralisation** ) | រាជរដ្ឋាភិបាលកម្ពុជា ផ្តល់ឱ្យក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ នូវភាពជាម្ចាស់ លើមុខងាររដ្ឋាភិបាល អំណាច និងធនធានផ្សេងៗ ដើម្បីឆ្លើយតបទៅនឹងតម្រូវការនានាតាមមូលដ្ឋាន ។ ក្រុមប្រឹក្សា ត្រូវតែទទួលខុសត្រូវចំពោះប្រជាពលរដ្ឋតាមមូលដ្ឋាន ។ |
| វិសហមជ្ឈការ **(Deconcentration)** | រាជរដ្ឋាភិបាល ក្រសួង ឬស្ថាប័នផ្សេងៗទៀត ធ្វើប្រតិភូកម្មមុខងារ និងធនធានផ្សេងៗ ទៅឱ្យអង្គភាពថ្នាក់ក្រោមរបស់ខ្លួន ឬទៅឱ្យថ្នាក់ក្រុមប្រឹក្សាដទៃទៀតដើម្បីបំពេញការងារក្នុងនាមរាជរដ្ឋាភិបាល ក្រសួង ឬក៏ជាស្ថាប័ន។ អង្គភាពថ្នាក់ក្រោម ឬក្រុមប្រឹក្សាត្រូវតែមានគណនេយ្យភាពចំពោះ រាជរដ្ឋាភិបាល ក្រសួង ឬស្ថាប័ន ស្របតាមតម្រូវការផ្សេងៗ នៃប្រតិភូកម្មនោះ។ |
| ភាពឆ្លើយតបទៅនឹងតម្រូវការ ( **Demand responsiveness** ) | សកម្មភាព ឬវិធីសាស្ត្រផ្សេងៗ ដែលធានាឱ្យអ្នកប្រើប្រាស់ទទួលបាន ទំនិញ ឬសេវាកម្ម ដែលពួកគេចង់បាន និងស្ម័គ្រចិត្តចំណាយទៅលើទំនិញ ឬសេវាកម្មនោះ ។ |
| ដៃគូអភិវឌ្ឍន៍ ( **Development partners** ) | ម្ចាស់ជំនួយ ធនាគារអភិវឌ្ឍន៍ ឬអង្គការអភិវឌ្ឍន៍ពហុភាគីនានា ។ |
| ពិការភាព ( **Disability** ) | មនុស្សពិការ គឺជាពលរដ្ឋណាមួយ ដែលបាត់បង់សរីរៈ ឬសមត្ថភាព ឬមានជម្ងឺផ្លូវចិត្ត ដែលបណ្តាលឱ្យមានការលំបាកក្នុងជីវិតប្រចាំថ្ងៃ ឬ សកម្មភាពក្នុងសង្គមរបស់គាត់ ហើយបណ្តាលឱ្យមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងពីមនុស្សធម្មតា ឬ ជាមនុស្សដែលមានលិខិតបញ្ជាក់ពីពិការភាព ដែលចេញដោយក្រសួងសុខាភិបាល ។ |
| ទឹកសម្រាប់បរិភោគ ( **Drinking Water** ) | ទឹកដែលមានគុណភាពស្របតាមបទដ្ឋានស្តង់ដាគុណភាពទឹកស្អាត ហើយមានសុវត្ថិភាពក្នុងការទទួលទាន។ |

| | |
|---|---|
| ការប្រើប្រាស់សេវាប្រកបដោយប្រសិទ្ធភាព (**Effective use of services**) | ការប្រើប្រាស់ និងការគ្រប់គ្រងសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យតាមរបៀបដែលយើងរំពឹងទុកថានឹងអាចទទួលបានជាអតិបរមានូវអត្ថប្រយោជន៍ផ្នែកសុខភាព សេដ្ឋកិច្ច និងផលិតភាព។ |
| ការផ្តល់សិទ្ធិអំណាច (**Empower-ment**) | កិច្ចប្រឹងប្រែង ដែលធ្វើឡើងដោយបុគ្គល ឬក្រុមនៃបុគ្គលណាមួយ ដើម្បីកសាង និងពង្រឹង ភាពម្ចាស់ការ និងទំនុកចិត្តរបស់សហគមន៍  តាមរយៈការជំរុញឱ្យមានការថ្លៃប្រឌិត និងសក្តានុពលច្នៃប្រឌិតផ្ទាល់ខ្លួនរបស់សហគមន៍ ។ |
| បរិយាកាសសមស្រប (**Enabling Environment**) | គោលនយោបាយផ្សេងៗ ជំនួយហិរញ្ញវត្ថុនានា អង្គភាពផ្លូវការ និងអង្គការ សហគមន៍ និងភាពជាដៃគូដែលរួមគ្នាគាំទ្រ និងលើកស្ទួយដល់ការផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធភាព និង ប្រសិទ្ធផល។ |
| សមធម៌ (**Equity**) | បរិក្ខា ឬសំណង់ផ្គត់ផ្គង់ទឹក និងអនាម័យ ដែលសមាជិកក្នុងសហគមន៍ទាំងអស់អាចប្រើប្រាស់បានដោយមិនមានការបែងចែកភេទ ឬ លក្ខខណ្ឌសង្គមឡើយ។ |
| អនាម័យបរិស្ថាន (**Environmental sanitation**) | ការគ្រប់គ្រងកត្តាទាំងឡាយនៅក្នុងបរិស្ថានរូបវ័ន្តដែលអាចមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាព និងសុខុមាលភាពប្រជាជន ។ អនាម័យបរិស្ថាននេះជាធម្មតារួមបញ្ចូលទាំងការបង្ហូរ កាកសំណល់តាមលូ ការគ្រប់គ្រងកាកសំណល់រឹង និងការត្រួតពិនិត្យសត្វល្អិតបង្កជំងឺ បន្ថែមពីលើសកម្មភាពផ្សេងៗ ដែលស្ថិតនៅក្រោមរូបភាពអនាម័យ ។ |
| ការវាយតម្លៃ (**Evaluation**) | ការត្រួតពិនិត្យ ការប្រមូល និងការវិភាគព័ត៌មានអំពីការអភិវឌ្ឍគម្រោងកន្លងមក ដើម្បីធ្វើការ សម្រេចចិត្តលើការបន្តគម្រោង និង/ឬ កែលម្អការអនុវត្តគម្រោងដែលមានភាពស្រដៀងគ្នា និងវិស័យទាំងមូលតែម្តង ។ |
| យេនឌ័រ (**Gender**) | តួនាទី ឥរិយាបថ សកម្មភាព និងលក្ខណៈសម្បត្តិទាំងឡាយដែលមានក្នុងសង្គម និងត្រូវបានសង្គមចាត់ទុកថា សមស្របសម្រាប់បុរស និងស្ត្រី ។ |
| ផ្នែករឹង (**Hardware**) | ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជា អណ្តូងទឹក អណ្តូងស្អប់ និងបង្គន់ជាដើម ។ |

| | |
|---|---|
| អនាម័យផ្ទាល់ខ្លួន<br>( **Hygiene** ) | ឥរិយាបថទាំងឡាយដែលទាក់ទងទៅនឹងការទុក និងការប្រើប្រាស់ទឹកនៅក្នុងផ្ទះ ព្រមទាំងការអនុវត្តអនាម័យផ្សេងៗ ។ អនាម័យផ្ទាល់ខ្លួនល្អ គឺជាការអនុវត្តមួយដែលធ្វើឱ្យខ្លួនយើង ការរស់នៅរបស់យើង និងទីកន្លែងដែលយើងធ្វើការស្អាតជានិច្ច ដើម្បីការពារមិនឱ្យឆ្លងជំងឺ និងរោគាផ្សេងៗ ។ |
| បរិស្ថានប្រកបដោយអនាម័យ<br>( **Hygienic environment** ) | បរិស្ថានដែលស្អាត ហើយមិនអាចបង្កឱ្យមានជំងឺពាក់ព័ន្ធនឹងទឹក និងលាមក ។ |
| អនាម័យដែលមានការកែលម្អ<br>( **Improved sanitation** ) | បង្គន់ចាក់ទឹក ដែលត្រូវបានភ្ជាប់ទៅនឹងប្រព័ន្ធលូបង្ហូរទឹកស្អុយ ឬភ្ជាប់ទៅនឹងអាងស្តុកលាមក ឬរណ្តៅមានគម្របបង្គន់ស្ងួតដែលមានផែន ឬបង្គន់អនាម័យ ដែលមានទុយោខ្យល់ចេញចូលក្នុងរណ្តៅ ។ |
| ការផ្គត់ផ្គង់ទឹកដែលមានការកែលម្អ<br>( **Improved water supply** ) | ទឹកបានពីប្រភពដែលទំនងជាផ្តល់នូវទឹក “សុវត្ថិភាព” ដូចជា ទឹកតបណ្តាញតាមផ្ទះ និងទឹកដែលបានមកពីការខួងអណ្តូងជា ដើម[73]។ ជម្រើសបច្ចេកទេសមួយចំនួនមាននៅក្នុងតារាងទី៦ ផ្នែកទី៨។ |
| ការថែទាំ<br>( **Maintenance** ) | សកម្មភាពផ្សេងៗដែលតម្រូវឱ្យមាន ដើម្បីទ្រទ្រង់បន្តការផ្គត់ផ្គង់ទឹកឱ្យមានដំណើរការសមស្រប ។ ការថែទាំ អាចត្រូវបានចែកចេញជា៖<br>ការថែទាំតាមបែបការពារ ពោលគឺការត្រួតពិនិត្យទៀងទាត់ និងការផ្តល់សេវាកម្មដើម្បីការពារសម្ភារ និងកាត់បន្ថយការខូចខាតឱ្យនៅកម្រិតអប្បបរមា។<br>ការថែទាំតាមបែបជួសជុលពោលគឺការជួសជុលបន្តិចបន្តួច និងការផ្លាស់ប្តូរគ្រឿងបន្លាស់បាក់បែក និង រេចរិលមួយចំនួន ដើម្បីឱ្យបរិក្ខាប្រើប្រាស់ទាំងនោះ អាចដំណើរការបានឡើងវិញ។<br>ការថែទាំពេលជួបវិបត្តិ ការឆ្លើយតបផ្សេងៗដែលមិនបានរៀបចំទុកជាមុនទៅនឹងការខូចខាតបន្ទាន់ និងការត្អូញត្អែររបស់អ្នកប្រើប្រាស់ ដើម្បីស្តារឡើងវិញនូវការផ្គត់ផ្គង់ដែលមិនមានដំណើរការ។ |

| | |
|---|---|
| ប្រព័ន្ធគ្រប់គ្រងព័ត៌មាន (ការតាមដាន) (**Management information systems (Monitoring)**) | ការពិនិត្យ ការប្រមូល និងការវិភាគព័ត៌មាន ដើម្បីឱ្យការអនុវត្ត និងលទ្ធផលដែលទទួលបានមានភាពកាន់តែប្រសើរឡើង ។ អ្វីដែលសំខាន់នោះ គឺការប្រៀបធៀបគ្នា រវាងស្ថានភាពជាក់ស្តែង និងស្ថានភាពដែលបានរំពឹងទុកជាមុន (បានរៀបចំទុកជាមុន) ហើយបន្ទាប់មក ធ្វើយ៉ាងណាឱ្យភាពជាក់ស្តែង និងការរំពឹងទុកស្ថិតនៅជាមួយគ្នា ។ |
| មីក្រូហិរញ្ញវត្ថុ (**Microfinance**) | ការផ្តល់សេវាកម្មផ្នែកហិរញ្ញវត្ថុដូចជា ប្រាក់កម្ចី និងប្រាក់បញ្ញើ ទៅឱ្យប្រជាពលរដ្ឋ ក្រីក្រ គ្រួសារមានចំណូលតិច និងសហគ្រាសធុនតូច។ |
| អង្គការមិនមែនរដ្ឋាភិបាល (**NGOs**) | អង្គការមិនមែនរដ្ឋាភិបាល ជាពិសេសក្រុមអង្គការមិនរកប្រាក់ចំណេញ ដែលក្នុងនោះ រួមមានដូចជា អង្គការអន្តរជាតិ និងអង្គការថ្នាក់ជាតិ ព្រមទាំងអង្គការក្នុងស្រុកទាំងអស់ ។ |
| ប្រតិបត្តិការ (**Operation**) | រាល់គ្រប់ដំណើរការ និងការដោះស្រាយទៅលើការផ្គត់ផ្គង់ទឹកប្រចាំថ្ងៃ ពាក់ព័ន្ធនឹងសកម្មភាពមួយ ចំនួនដូចជា៖ ប្រតិបត្តិការសំខាន់ៗនានា ដែលចាំបាច់ក្នុងការផ្តល់ទឹកសម្រាប់បរិភោគប្រកបដោយសុវត្ថិភាពទៅដល់អ្នកប្រើប្រាស់ ដូចជាការចាប់ផ្តើម និងការបញ្ឈប់ម៉ាស៊ីនបូមទឹក ការផ្គត់ផ្គង់ប្រេងឥន្ធនៈ និងការគ្រប់គ្រងសន្ទះស្នប់ ការប្រើប្រាស់បរិក្ខាឱ្យបានត្រឹមត្រូវពីសំណាក់អ្នកប្រើប្រាស់ ដើម្បីធានាឱ្យបាននូវការប្រើប្រាស់ មានរយៈពេលយូរអង្វែង ដូចជា ការប្រើប្រាស់ខ្សែពួរ និងធុងទឹកនៅឯអណ្តូង ការប្រើប្រាស់ស្នប់ និងការប្រើប្រាស់ក្បាលរ៉ូប៊ីនេនៅឯកន្លែងផ្គត់ផ្គង់ទឹកសាធារណៈ ។ |
| ភាពជាម្ចាស់លើប្រព័ន្ធឬសេវាកម្មផ្គត់ផ្គង់ទឹក (**Ownership of system or service**) | គ្រប់គ្រងទៅលើការធ្វើសេចក្តីសម្រេចចិត្ត និងការចាត់ចែងលើប្រព័ន្ធ ឬ សេវាកម្មផ្គត់ផ្គង់ទឹកដែលត្រូវបានផ្តល់ឱ្យ ។ |
| ចំណាយចរន្ត (**Recurrent cost**) | ការចំណាយចាំបាច់ជាប្រចាំ ដើម្បីធានាឱ្យបានថាប្រព័ន្ធ ឬ អ្វីមួយដែលបានដំឡើងរួច នឹងបន្តដំណើរការគួរជាទីពេញចិត្ត។ |

| | |
|---|---|
| តួនាទី (Roles) | ការទទួលខុសត្រូវចំបងរបស់អ្នកពាក់ព័ន្ធសំខាន់ៗក្នុងវិស័យនេះ ។ |
| វិធាន (Rules) | គោលការណ៍ណែនាំ គោលនយោបាយ និងច្បាប់ផ្សេងៗដែលប្រកបដោយតម្លាភាព សម្រាប់តម្រង់សកម្មភាពនានាឆ្ពោះទៅរកគោលដៅទាំងឡាយរបស់វិស័យទឹក និងអនាម័យ និងណែនាំអ្នកពាក់ព័ន្ធឱ្យអនុវត្តទៅតាមតួនាទីរបស់ពួកគេរៀងៗខ្លួននៅ ក្នុងវិស័យនេះ ។ |
| សហគមន៍ជនបទ (Rural communities) | ការតាំងភូមិលំនៅ ដែលមានទីតាំងស្ថិតនៅភូមិសាស្ត្រក្រៅតំបន់ទីក្រុង ។ |
| ប្រភពទឹកសម្រាប់បរិភោគដែលមានសុវត្ថិភាព (Safe drinking water source) | ប្រភពមួយដែលផ្តល់ទឹកទៀងទាត់ ប្រកបដោយ គុណភាពស្របតាមបទដ្ឋានគុណភាពទឹកសម្រាប់បរិភោគនៅកម្ពុជា ឬស្របតាមគុណភាព ដែលចែងបណ្តោះអាសន្នដទៃទៀត ។ |
| អនាម័យ (Sanitation) | ការគ្រប់គ្រង និងការទុកដាក់កាកសំណល់រាវ (ទឹកនោម) និងលាមករបស់មនុស្ស និងកាកសំណល់រាវដែលបានមកពីការប្រើប្រាស់តាមផ្ទះ។ |
| សំណល់ក្នុងអាងស្តុកលាមក (Septage) | កាកសំណល់លាមកទាំងឡាយក្នុងអាងស្តុកលាមក ក្នុងនោះមានភក់លាមកនៅបាតអាង ទឹក និងកាកលាមកដែលអណ្តែតខាងលើ។ |
| ទីផ្សារសង្គមផ្នែកអនាម័យ (Social marketing of sanitation) | ការប្រើប្រាស់វិធីសាស្ត្រទីផ្សារ ដើម្បីសម្រេចនូវតាមគោលដៅសង្គម ។ វិធីសាស្ត្រទីផ្សារ មានសកម្មភាពផ្សេងៗ ដើម្បីទទួលបានអតិថិជន និងបញ្ចុះបញ្ចូលពួកគេឱ្យទិញ និងប្រើប្រាស់ផលិតផល ឬសេវាកម្មណាមួយ ។ វិធីសាស្ត្រទីផ្សារមានសមាសភាគបួនយ៉ាងគឺ ផលិតផល តម្លៃ ទីតាំង និងការផ្សព្វផ្សាយ ដែលអាចនឹងត្រូវបានកែប្រែឱ្យស្របតាមវិធីសាស្ត្រទីផ្សារសង្គម ។ |

| | |
|---|---|
| ផ្នែកទន់ (Software) | សកម្មភាពដែលទាក់ទងនឹងការកែលម្អការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ដែលមិនរួមបញ្ចូលនូវការសាងសង់ និងប្រើប្រាស់ ហេដ្ឋារចនាសម្ព័ន្ធ ។ ពោលគឺថា ផ្នែកទន់សំដៅលើបរិយាកាសសមស្រប ព្រមទាំងប្រព័ន្ធ និងនីតិវិធីរបស់បរិយាកាសនោះ ការលើកកម្ពស់អនាម័យ និងអនាម័យផ្ទាល់ខ្លួន (រួមបញ្ចូលទាំងសហគមន៍ដឹកនាំអនុវត្តន៍អនាម័យ និងវិធីសាស្រ្តទីផ្សារសង្គម) ការបណ្តុះបណ្តាល ការជំរុញសកម្មភាព និងការកសាងសមត្ថភាពសហគមន៍។ |
| អ្នកពាក់ព័ន្ធ (Stakeholder) | ភាគីដែលមានចំណាប់អារម្មណ៍ដោយផ្ទាល់ទៅនឹងសកម្មភាព ឬកិច្ចអន្តរាគមន៍ច្បាស់លាស់ណាមួយនៅក្នុងវិស័យទឹក និងអនាម័យ។ |
| ឧបត្ថម្ភធន (Subsidy) | ទម្រង់នៃការផ្តល់ជំនួយហិរញ្ញវត្ថុ ដែលត្រូវបានផ្តល់ឱ្យបុគ្គល អាជីវកម្ម ឬក៏វិស័យ សេដ្ឋកិច្ចណាមួយ ដើម្បីសម្រេចបានគោលបំណងគោលនយោបាយជាក់លាក់ណាមួយ។ ឧទាហរណ៍ ឧបត្ថម្ភធន អាចត្រូវបានប្រើ ដើម្បីគាំទ្រដល់បណ្តាអាជីវកម្មទាំងឡាយណាដែលអាចនឹងបរាជ័យ បើគ្មានការឧបត្ថម្ភធននោះទេ ឬក៏ប្រើដើម្បីគាំទ្រសកម្មភាពនានា ដែលសកម្មភាពទាំងនោះអាចនឹងមិនកើតមានឡើង បើគ្មានការឧបត្ថម្ភធនទេនោះ។ |
| សេវាប្រកបដោយនិរន្តរភាព (Sustainable services) | សេវាផ្សេងៗដែលមានទាំងធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស សម្រាប់ប្រតិបត្តិការ ការថែទាំ និងការផ្លាស់ប្តូរគ្រឿងបន្លាស់ និងយកចិត្តទុកដាក់ទៅលើទិដ្ឋភាពបច្ចេកទេស សង្គម ស្ថាប័ន និងបរិស្ថាន ដើម្បីឱ្យសេវាទាំងនេះអាចបន្តផ្តល់នូវ សេវាកម្មជាមូលដ្ឋាន ដែលអាចទទួលយកបាន ។ |
| ទស្សនវិស័យ (Vision) | គោលដៅវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ រយៈពេល២៥ឆ្នាំ ដូចដែលបានចែងក្នុងគោលនយោបាយជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ (សូមមើលផ្នែកទី៥.១)។ |

| | |
|---|---|
| ក្រុមងាយរងគ្រោះ<br>( **Vulnerable groups** ) | ជាពាក្យទូទៅប្រើសម្រាប់ចាត់ប្រភេទក្រុមមនុស្សដែលក្នុងនោះមានអ្នកក្រីក្រ ជនពិការ និងប្រជាជនរងគ្រោះដោយសារ សង្គ្រាម និងជម្លោះ កុមារ និងយុវជន មនុស្សចាស់ ស្ត្រី និងជនជាតិភាគតិច ។ ប្រភេទមនុស្សខ្លះអាចចាត់ចូលក្នុងក្រុមច្រើនជាងមួយក្នុងចំណោមប្រភេទក្រុមមនុស្សខាងលើ ។ ភាពងាយរងគ្រោះ គឺជាប់ពាក់ព័ន្ធទៅនឹងភាពប្រឈមនឹងហានិភ័យ ( ការតក់ស្លុត និងកម្រិតនៃភាពក្រីក្រ ) និងសមត្ថភាពគ្រប់គ្រង ( ធនធាន និងលទ្ធភាពទទួលបានសំណាញ់សុវត្ថិភាព ) ។ |
| បរិស្ថានទឹក<br>( **Water environment** ) | ជាប្រព័ន្ធជលសាស្ត្រ ដែលនៅក្នុងនោះសហគមន៍មួយមានដំណើរការទៅបាន ។ បរិស្ថានទឹក អាចនឹងមានទំហំធំជាងសហគមន៍ ឧទាហរណ៍ដូចជា អាងទន្លេ ។ |
| ធនធានទឹក<br>( **Water resource** ) | ទឹកដែលអាចយកមកប្រើប្រាស់បាន ដូចជាបឹង ទន្លេ ឬស្រទាប់ទឹកក្រោមដី ។ វា ក៏អាចរាប់បញ្ចូលទាំងទឹកភ្លៀងផងដែរ ។ |
| ប្រភពទឹក<br>( **Water source** ) | កន្លែងដែលទឹក អាចត្រូវបានទាញយកមកប្រើ ដូចជាកន្លែងទឹកចេញតាមភ្នំ ឬអណ្តូង ។ ប្រភពទឹកនេះអាច ជាទន្លេ ឬក៏បឹងផងដែរ អាស្រ័យលើបរិបទ ។ |
| ការផ្គត់ផ្គង់ទឹក<br>( **Water supply** ) | ទឹកប្រើប្រាស់ក្នុងផ្ទះ ដូចជាទឹកសម្រាប់ផឹក លាងសម្អាត ងូត និងទឹកប្រើប្រាស់សម្រាប់សកម្មភាពសេដ្ឋកិច្ចតាមផ្ទះមួយចំនួនទៀត ។ |

# ឧបសម្ព័ន្ធទី២៖ សាខតានៃគោលការណ៍

## ១.១. និរន្តរភាព

និរន្តរភាពនៃសំណង់ផ្គត់ផ្គង់ទឹកស្អាត និងអនាម័យដែលមានការកែលម្អ និងឥរិយាបថផ្នែកអនាម័យផ្ទាល់ខ្លួនគួរតែជាគោលដៅគន្លឹះ នៃការផ្តល់សេវា ។ និយមន័យដ៏សាមញ្ញនៃពាក្យថានិរន្តរភាពគឺជាការបន្តដំណើរការគ្រប់ពេលវេលា ទាក់ទិននឹងសេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យព្រមទាំងការអនុវត្តអនាម័យ ។ នៅពេលដែលសំណង់ទាំងនោះបង្កើតឡើងភ្លាម ប្រព័ន្ធទាំងនេះគួរតែផ្តល់នូវសេវាកម្មជាអចិន្ត្រៃយ៍ដល់អ្នកប្រើប្រាស់ (និងអ្នកដែលប្រើប្រាស់ប្រព័ន្ធទាំងនេះនាពេលអនាគត) ។

រូបមន្តសម្រាប់និរន្តរភាពកម្មវិធីផ្គត់ផ្គង់ទឹកស្អាត អនាម័យ និងការទទួលយកនូវឥរិយាបថផ្នែកសុវត្ថិភាពអនាម័យមិនមែនមានតែមួយនោះទេ ។ អ្នកពាក់ព័ន្ធក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ គួរពិចារណាលើកត្តាអន្តរទំនាក់ទំនងមួយចំនួន និងបញ្ហាដែលរួមចំណែកធ្វើឲ្យនិរន្តរភាពកាន់តែប្រសើរឡើង ឬក៏កង្វះខាតនៃនិរន្តរភាពដូចជា៖

### ផលប៉ះពាល់ផ្នែកបរិស្ថាន

- ធនធានទឹក មិនគួរត្រូវបានប្រើប្រាស់ឲ្យហួសហេតុពេកនោះទេ។ ការយកទឹកមកប្រើប្រាស់មិនមែនត្រឹមតែអ្នកប្រើប្រាស់តាមផ្ទះនោះទេ គប្បីមិនគួរប្រើប្រាស់ឲ្យលើសពីលទ្ធភាពដែលធម្មជាតិអាចបង្កើតឡើងវិញបាន ។ ការប្រើប្រាស់ទឹកក្រោមដី សម្រាប់វិស័យកសិកម្ម អាចមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ធនធានទឹក ។
- ធនធានទឹកគួរតែត្រូវបានការពារ មិនឲ្យមានការបំពុល ជាពិសេសការបំពុលដែលបណ្តាលមកពីកង្វះអនាម័យ។

### បរិយាកាសសមស្រប

- ការផ្តល់នូវច្បាប់ បទបញ្ញាតិ ការអប់រំ ព័ត៌មាន និងការលើកទឹកចិត្តដទៃទៀត។
- មានស្ថាប័នរឹងមាំនៅថ្នាក់ណាមួយដែលសមស្រប ដូចជាភ្នាក់ងារទឹកស្អាត និងរចនាសម្ព័ន្ធសហគមន៍ដែលបង្កើតតាមផ្លូវច្បាប់ មានការទទួលខុសត្រូវច្បាស់លាស់ មានហិរញ្ញវត្ថុគាំទ្រគ្រប់គ្រាន់ មានការរៀបចំល្អ និងតំណាងឲ្យអ្នកប្រើប្រាស់ ទាំងអស់មានស្ត្រី និងគ្រួសារក្រីក្រ។
- មានឥរិយាបថគាំទ្រ ដូចជាការប្តេជ្ញាចិត្តរបស់ភ្នាក់ងារទឹកស្អាត និងសហគមន៍ ក្នុងការចែករំលែកនូវការទទួលខុសត្រូវ ការបង្កើតនូវភាពជាម្ចាស់កម្មសិទ្ធិច្បាស់លាស់ និងរួមចំណែកដល់ការគាំទ្រផ្នែក ហិរញ្ញវត្ថុដល់សេវាកម្មទាំងនេះ ។
- ឆន្ទៈនយោបាយនិងការប្តេជ្ញាចិត្ត ដូចជាអ្នកនយោបាយគួរធានាឲ្យបានថាគោលការណ៍នៃការគ្រប់គ្រងដោយផ្អែកលើសហគមន៍ ត្រូវបានលើកកម្ពស់និងលើកទឹកចិត្ត ។ មធ្យោបាយនៃការសម្រេចនូវប្រការនេះ រួមមានការប្តេជ្ញាចិត្តក្នុងការផ្តល់ធនធានគ្រប់គ្រាន់ដល់វិស័យនេះសម្រាប់គាំទ្រ និងបណ្តុះបណ្តាលសហគមន៍ អំពីប្រព័ន្ធគាំទ្រការប្រើប្រាស់ និងការថែទាំក៏ដូចជាការសាងសង់ថ្មីៗ ។

### ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច សង្គម និងសុខភាព

- ភាពមានស្រាប់នៃការឲ្យតម្លៃដល់គុណប្រយោជន៍នៃការផ្គត់ផ្គង់ទឹកមានសុវត្ថិភាព និងអនាម័យ។ ផលប្រយោជន៍ទាំងនេះរួមមាន ផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច និងសង្គម ក៏ដូចជាការលើកកម្ពស់សុខភាព ។ ការផ្សាភ្ជាប់ទៅនឹងវិធីសាស្ត្រភាពប្រកបដោយនិរន្តរភាពនៃការរស់នៅអាចគាំទ្រដល់ការឲ្យតម្លៃនេះ ។

### ជម្រើស នៃកម្រិតសេវាកម្មសមស្រប និងបច្ចេកវិទ្យាសមស្រប

- កម្រិតសេវាដែលមានតម្លៃសមរម្យ និងអាចគ្រប់គ្រងបាន ហើយដែលអាចធ្វើឲ្យប្រសើរឡើងនៅពេលក្រោយ នៅពេលដែលស្ថានភាពសង្គម-សេដ្ឋកិច្ច មានការរីកចម្រើន ។ ប្រព័ន្ធទាំងនេះមិនគួរមានទំហំធំពេក សម្រាប់ការគ្រប់គ្រងដោយអ្នកប្រើប្រាស់នោះទេ។
- បច្ចេកវិទ្យាដែលងាយស្រួល មានតម្លៃសមរម្យ និងអាចទទួលយកបាន ដូចជាភាពពេញចិត្តលើបច្ចេកវិទ្យា និងប្រព័ន្ធមានបទដ្ឋានត្រឹមត្រូវ ដែលងាយស្រួលប្រតិបត្តិការ និងថែទាំ ទំនៀមទំលាប់ប្រពៃណីអាចទទួលយកបាន និងងាយស្រួលប្រើប្រាស់សម្រាប់ភេទទាំងពីរ។

### ការផ្តល់នូវការប្រតិបត្តិ និងថែទាំប្រកបដោយប្រសិទ្ធភាព

- ជំនាញ និងភាពបិនប្រសប់ ពោលគឺការបណ្តុះបណ្តាលបុគ្គលិកភ្នាក់ងារ និងសមាជិកសហគមន៍នូវ ជំនាញចាំបាច់សម្រាប់ការប្រតិបត្តិ និងថែទាំ។
- ខ្សែសង្វាក់ផ្គត់ផ្គង់ដ៏មានប្រសិទ្ធភាពសម្រាប់គ្រឿងបន្លាស់ សម្ភារ និងបរិក្ខាដូចជាសម្ភារ ដែលសឹក ត្រូវតែអាចរកបានយ៉ាងងាយស្រួល ដើម្បីឲ្យសហគមន៍អាចរក្សាប្រព័ន្ធឲ្យដំណើរការ ។
- ប្រព័ន្ធគាំទ្រដ៏មានប្រសិទ្ធភាព ដើម្បីធានាថាសហគមន៍អាចអនុវត្តភារកិច្ចទទួលខុសត្រូវសម្រាប់ការគ្រប់គ្រងសេវាកម្មទាំងនេះបាន ។

### និរន្តរភាពផ្នែកហិរញ្ញវត្ថុ

- សមត្ថភាព និងឆន្ទៈក្នុងការចំណាយ រួមមានទាំងការចូលរួមថ្លៃទុនដើម នៃប្រព័ន្ធទាំងនេះ ។
- ការបង្កើតនូវប្រព័ន្ធប្រាក់កម្ចី និងមូលនិធិបង្វិល សម្រាប់ការប្រតិបត្តិ និងការថែទាំ ។
- ការកំណត់រក និងសម្រួលដល់ជម្រើសកាន់តែច្រើន សម្រាប់ការរកប្រាក់ចំណូលរបស់អ្នកប្រើប្រាស់។
- ជំនាញក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ជាពិសេសនៅក្នុងបរិបទដែលសហគមន៍កំពុងត្រូវបានគេប្រគល់អំណាចឲ្យមាននូវការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ។ លើកទឹកចិត្ត និងលើកកម្ពស់ការសន្សំប្រាក់ របស់សហគមន៍ និងគណនេយ្យភាព ។

### ប្រព័ន្ធគ្រប់គ្រងព័ត៌មាន

- ព័ត៌មានដែលអាចទុកចិត្តបាន មានសារសំខាន់ណាស់ ដើម្បីដឹងថា តើនិរន្តរភាពអាចទទួលជោគជ័យ និងបន្តទៅទៀតបានដែរឬទេ ហើយថាតើចាំបាច់ត្រូវធ្វើសកម្មភាពដើម្បីកែតម្រូវការបរាជ័យដែរឬទេ ។

## ១.២. ការគ្រប់គ្រងដោយសហគមន៍

គោលនយោបាយជាតិកំណត់នូវតួនាទី និងការទទួលខុសត្រូវមួយចំនួនសម្រាប់សហគមន៍ និងក្រុមប្រើប្រាស់ទឹក និងអនាម័យ ។ តួនាទីនិងការទទួលខុសត្រូវទាំងនេះនឹងត្រូវបានកំណត់ម្តងទៀតនៅក្នុងគោលការណ៍នៃការគ្រប់គ្រងសហគមន៍ ដែលជាវិធីសាស្ត្រដែលត្រូវអនុវត្តក្នុងការផ្តល់សេវា ។ គោលការណ៍នេះសង្កត់ធ្ងន់លើអំណាចក្នុងការសម្រេចចិត្តដោយខ្លួនឯងរបស់សហគមន៍ សម្រាប់ សមាសភាគជាច្រើនដែលសហគមន៍ទទួលខុសត្រូវ ។ ទិដ្ឋភាពសំខាន់ៗក្នុងការគ្រប់គ្រងសហគមន៍រួមមាន ៖[74]

- ការចូលរួម ៖ ចាំបាច់ត្រូវធានាថាសមាជិកសហគមន៍ទាំងអស់មានកាលានុវត្តភាពស្មើគ្នាក្នុងការចូលរួមរៀបចំផែនការ និងការសម្រេចចិត្តដែលទាក់ទងទៅនឹងប្រភេទ និងកម្រិតនៃសេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ដែលពួកគេទទួលបាន និងវិធីដែលសេវាកម្មទាំងនោះនឹងត្រូវទទួលបានហិរញ្ញវត្ថុ អនុវត្ត គ្រប់គ្រង និងត្រួតពិនិត្យ[75] ។ ចាំបាច់ត្រូវតែមាននូវការគាំទ្រពីសហគមន៍ដ៏ទូលំទូលាយសម្រាប់ការអនុវត្តនៃការគ្រប់គ្រងសហគមន៍ ។ ការចូលរួមរបស់សហគមន៍ត្រូវតែបន្តជារៀងរហូត ។
- ការទទួលខុសត្រូវ ៖ សហគមន៍ត្រូវមានភាពជាម្ចាស់ និងយកចិត្តទុកដាក់ចំពោះប្រព័ន្ធទាំងនេះ។ បើទោះបីជាគេចង់បាននូវភាពជាម្ចាស់កម្មសិទ្ធិស្របច្បាប់ផ្លូវការ នៃហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ក៏កម្មសិទ្ធិនេះអាចនឹងមិនអាចទៅរួចទេ នៅក្នុងក្របខ័ណ្ឌច្បាប់ដែលមានស្រាប់នាពេលបច្ចុប្បន្ន ។ អ្វីដែលមានភាពសំខាន់ដែរនោះ គឺការទទួលអារម្មណ៍ថាជាម្ចាស់កម្មសិទ្ធិពីសំណាក់សហគមន៍អ្នកប្រើប្រាស់ ។
- អំណាច៖ សហគមន៍មានសិទ្ធិអំណាចស្របច្បាប់ក្នុងការសម្រេចចិត្តលើប្រព័ន្ធទាំងនេះ ក្នុងនាមតំណាងឲ្យអ្នកប្រើប្រាស់ ។
- ការត្រួតពិនិត្យ ៖ សហគមន៍អាចអនុវត្ត និងកំណត់នូវលទ្ធផលនៃការសម្រេចចិត្តរបស់ខ្លួន ។ សហគមន៍ត្រូវតែត្រួតពិនិត្យដោយផ្ទាល់ ឬដោយប្រយោលទៅលើប្រតិបត្តិការ និងការគ្រប់គ្រងនៃប្រព័ន្ធផ្គត់ផ្គង់ទឹករបស់សហគមន៍។ ពាក្យថាត្រួតពិនិត្យ មានន័យថា សមត្ថភាពក្នុងការសម្រេចចិត្តជាយុទ្ធសាស្ត្រពីដំណើរការ ចាប់ចេញពីដំណាក់កាលរៀបចំដំបូងដល់ការប្រតិបត្តិ និងថែទាំរយៈពេលវែង ។
- គណនេយ្យភាព ៖ សហគមន៍ទទួលយកនូវផលវិបាក នៃការសម្រេចចិត្តរបស់ខ្លួន និងយល់ថាពួកគេជាអ្នកដែលត្រូវធ្វើសកម្មភាពទាំងឡាយ ។

ចាប់ចេញពីចំណុចទាំងនេះ ចាំបាច់តម្រូវឲ្យសហគមន៍ធ្វើការសម្រេចចិត្តក្នុងការជ្រើសរើសប្រភេទបច្ចេកវិទ្យា កម្រិតសេវា ការរៀបចំសង្គម បទបញ្ញត្តិ នៃការប្រើប្រាស់ និងយន្តការផ្នែកហិរញ្ញវត្ថុ ។ សហគមន៍ទទួលខុសត្រូវលើការថែទាំ និងជួសជុល ព្រមទាំងកិច្ចការហិរញ្ញវត្ថុ ។

[74] ពឹងផ្អែកដោយផ្អែកទៅលើ (Lockwood, 2004)
[75] យកចេញពីគោលការណ៍ណែនាំទី ៤ នៅក្នុងគោលនយោបាយជាតិផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ

## ១.៣ វិធីសាស្ត្រឆ្លើយតបទៅនឹងតម្រូវការ

វិធីសាស្ត្រឆ្លើយតបទៅនឹងតម្រូវការ គឺជាមូលដ្ឋានគ្រឹះសម្រាប់ការគ្រប់គ្រងសហគមន៍ ។ នៅក្នុងចំណុចនេះ សហគមន៍ផ្តួចផ្តើមនូវដំណើរការនៃការអភិវឌ្ឍសេវាកម្ម ដោយស្នើសុំការគាំទ្រពីអាជ្ញាធរពាក់ព័ន្ធ ឬក៏អ្នកផ្តល់សេវា ។ បន្ទាប់មកទៀត សហគមន៍ធ្វើការជ្រើសរើសដោយមានព័ត៌មានគ្រប់គ្រាន់ ស្តីពីជម្រើសសេវា ដោយផ្អែកលើឆន្ទៈក្នុងការចំណាយចំពោះសេវានោះ និងការទទួលយកការទទួលខុសត្រូវសម្រាប់ការប្រតិបត្តិ និងថែទាំជាបន្ត។ គោលការណ៍គន្លឹះរួមមាន[76]៖

- ការជ្រើសរើសដោយសហគមន៍ តាមរយៈការរៀបចំផែនការដែលមានការចូលរួម និងសហគមន៍ចូលរួមក្នុងការអនុវត្តដើម្បីធានានូវភាពជាម្ចាស់។
- ការទទួលខុសត្រូវយ៉ាងពេញលេញក្នុងការគ្រប់គ្រងសហគមន៍ សម្រាប់ការប្រតិបត្តិ និងថែទាំ ។
- ការចូលរួមចំណែករបស់សហគមន៍អ្នកប្រើប្រាស់ទៅលើការចំណាយទុនដើម និងការចំណាយទាំងស្រុងលើការប្រតិបត្តិ និងថែទាំ ដោយសហគមន៍អ្នកប្រើប្រាស់ ។
- ជំរុញឲ្យមានជម្រើសផ្តល់សេវាឲ្យបានកាន់តែច្រើន ។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការ អាជ្ញាធរឬអ្នកផ្តល់សេវាត្រូវផ្តល់ដល់អតិថិជនទាំងអស់នូវ ៖

- ព័ត៌មានស្តីពីបច្ចេកវិទ្យា និងសេវាកម្មដែលខ្លួនផ្តល់ឲ្យ ការចំណាយទុនដើម និងចំណាយចរន្តនិងវិធីសាស្ត្រថែទាំ។ល។
- ជម្រើស (ឲ្យបានច្រើនបំផុតដែលអាចទៅរួច) ស្តីពីសេវាកម្មនេះ ៖ ប្រភេទនៃបច្ចេកវិទ្យា ទីតាំងបញ្ជីអ្នកម៉ៅការ ការបង្កើតគណៈកម្មការគ្រប់គ្រងចំណុចប្រភពទឹក របៀបប្រមូលមូលនិធិជាដើម។
- កាលានុវត្តភាពក្នុងការសម្រេចចិត្តចំពោះជម្រើសទាំងអស់ ។
- កាលានុវត្តភាពក្នុងការមានឥទ្ធិពល ឬ ត្រួតពិនិត្យដំណើរការ នៃការបង្កើត និងគ្រប់គ្រងសេវា ៖ ការយល់ព្រមក្នុងការសាងសង់ និងការយល់ព្រមលើការទូទាត់ឲ្យអ្នកម៉ៅការ ជាដើម[77] ។

ការិយាល័យអភិវឌ្ឍន៍ជនបទស្រុកនឹងត្រូវផ្តល់ព័ត៌មានតាមរយៈក្រុមប្រឹក្សាឃុំស្តីពីកាលានុវត្តភាពសម្រាប់ការបង្កើតសេវា ដើម្បីជាមូលដ្ឋាន សម្រាប់វិធីសាស្ត្រឆ្លើយតបទៅនឹងតម្រូវការ ។

## ១.៤. ការចូលរួមក្នុងការចំណាយ

នៅក្នុងគោលនយោបាយជាតិ តម្រូវឲ្យសហគមន៍ត្រូវ “បរិច្ចាគក្នុងការអនុវត្តនិងការកសាងសំណង់ផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ដូចជាហិរញ្ញវត្ថុ កម្លាំងពលកម្ម សម្ភារ និងការបរិច្ចាគទម្រង់ដទៃៗទៀត”។

ការចូលរួមក្នុងការចំណាយ គឺដើម្បីធានាថាអ្នកទទួលផលប្រយោជន៍បានចំណាយសម្រាប់សេវាដែលខ្លួនទទួល និងដើម្បីបង្កើតនូវអារម្មណ៍នៃភាពជាម្ចាស់សម្រាប់ការថែទាំសំណង់ប្រកប

---

[76] កម្មវិធីទឹក និងអនាម័យនៅអាព្រិចខាងកើត

[77] យកលំនាំចេញពីកំណត់ហេតុគោលការណ៍ណែនាំជាយុទ្ធសាស្ត្រ គម្រោង PCB កម្ពុជា កម្មវិធីទឹក និងអនាម័យនៅអាស៊ីអាគ្នេយ៍ ឆ្នាំ២០០១

ដោយប្រសិទ្ធភាព ។ អ្នកប្រើប្រាស់សេវាផ្គត់ផ្គង់ទឹកគឺជាប្រភពស្ថិតស្ថេរ នៃការផ្តល់មូលនិធិសម្រាប់ការថែទាំទៀងទាត់សេវាផ្គត់ផ្គង់ទឹកស្អាត ។ អ្នកប្រើប្រាស់នឹងចំណាយចំពោះថ្លៃសេវាប្រសិនបើសេវានេះអាចទុកចិត្តបាន និងឆ្លើយតបទៅនឹងតម្រូវការរបស់ពួកគេ ។ ហេតុនេះហើយជាការចាំបាច់ណាស់ក្នុងការជំរុញសហគមន៍ចូលរួមក្នុងការកំណត់នូវចំណុចដូចជា ៖

- កម្រិត និងប្រភេទនៃសេវាដែលពួកគេចង់បាន ។
- សេវាកម្មនានាដែលពួកគេអាចមានលទ្ធភាពចំណាយបាន ។
- សេវាកម្មនានាដែលពួកគេអាចគ្រប់គ្រងក្នុងប្រតិបត្តិការ និងថែទាំ ។

បដិភាគរបស់សហគមន៍ សម្រាប់ការចំណាយទុនដើមនៃហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ទឹកស្អាត គួរតែត្រូវបានកំណត់ដោយអាជ្ញាធរមូលដ្ឋាន ស្របតាមស្ថានភាព សេដ្ឋកិច្ចក្នុងតំបន់ផ្ទាល់ ដោយយោងតាមស្មារតី នៃគោលការណ៍ណែនាំរបស់ក្រសួងអភិវឌ្ឍន៍ជនបទ ។ ការបរិច្ចាគអាចជាថវិកា ឬ មិនមែនថវិកាដែលជានិច្ចកាល អាចជាកម្លាំងពលកម្ម និងសម្ភារដែលមានក្នុងតំបន់ ។ ការចូលរួមនេះក៏បានរាប់បញ្ចូលផងដែរ នូវការចំណាយពេលវេលាដោយមិនគិតប្រាក់កម្រៃរបស់ក្រុមប្រើប្រាស់ទឹក និងអនាម័យ។ ការរៀបចំនីតិវិធី និងលក្ខណៈវិនិច្ឆ័យក្នុងការកំណត់សមាមាត្រនៃការចូលរួមរបស់សហគមន៍ គឺជាសកម្មភាពមួយដែលមានចែងនៅក្នុងយុទ្ធសាស្ត្រវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ ។ នៅកន្លែងណាដែលសហគមន៍អាចមានលទ្ធភាពចូលរួមចំណែកក្នុងការចំណាយបានទាំងស្រុងនោះគេគួរតែលើកទឹកចិត្ត និងជំរុញការចូលរួមបែបនេះ ។

សហគមន៍គួរចំណាយទាំងស្រុង ទៅលើចំណាយចរន្តសម្រាប់ការប្រតិបត្តិ និងថែទាំ ។ ការចំណាយដែលមិនមានជាថវិកា អាចជាផលិតផលកសិកម្ម ឬ ផលិតផលដទៃៗទៀត ដែលអាចបំលែងទៅជាទឹកប្រាក់សម្រាប់ការចំណាយចរន្តបាន ។ សហគមន៍គួរតែចូលរួមក្នុងចំណាយលើសេវាគាំទ្រការថែទាំដែលនឹងបង្កើតឡើងនៅក្នុងការិយាល័យអភិវឌ្ឍន៍ជនបទស្រុកនីមួយៗ ។ ចំនួននៃការចំណាយទាំងនេះនឹងត្រូវបានកំណត់ដោយនីតិវិធីដូចជាការចំណាយទុនដើមដែរ។

## ១.៥. ការផ្តល់ហិរញ្ញប្បទានផ្នែកអនាម័យ

ការសិក្សាមួយនៅក្នុងប្រទេសកម្ពុជាកាលពីឆ្នាំ២០០៧បានរកឃើញថា យន្តការឧបត្ថម្ភធនមិនបានដំណើរការល្អនោះទេ ។ នៅក្នុងអំឡុងពេលនោះ គម្រោងអនាម័យភាគច្រើនបានផ្តល់នូវការឧបត្ថម្ភធនជារូបវន្តជូនដល់គ្រួសារដោយមានចំនួនកំណត់នៅក្នុងភូមិគោលដៅរបស់ខ្លួន ។ ផ្ទុយពីគោលនយោបាយរបស់វិស័យដែលផ្តោតលើការកាត់បន្ថយភាពក្រីក្រ គេឃើញថាជារឿយៗ ការឧបត្ថម្ភធន ជារូបវន្តត្រូវធ្លាក់ទៅក្នុងដៃគ្រួសារដែលមិនមែនជាអ្នកក្រីក្រ ដែលគ្រួសារទាំងនោះមានលទ្ធភាពរួមចំណែកក្នុងការបង់ប្រាក់តាមតម្រូវការរបស់គម្រោង ឬ ក៏ជាគ្រួសារដែលមានឥទ្ធិពលទៅលើក្រុមអ្នកដែលចាត់ចែងថវិកា សម្រាប់ការផ្តល់បង្គន់របស់គម្រោង ។[78]

[78] (Robinson, 2007)

ការសិក្សាថ្មីមួយនៅក្នុងប្រទេសកម្ពុជាបានបង្ហាញថា ការផ្តល់ហិរញ្ញប្បទានសារធារណៈសម្រាប់ផ្នែកអនាម័យ មិនទាន់ទៅដល់ក្រុមប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រនៅឡើយទេ ។

នៅក្នុងគម្រោងមួយ ៩០ភាគរយ នៃការផ្តល់ហិរញ្ញប្បទានសារធារណៈបានធ្លាក់ទៅក្នុងដៃគ្រួសារដែលមិនមែនជាអ្នកក្រីក្រ ហើយគម្រោងទីផ្សារអនាម័យចំនួនពីរ តម្រូវឲ្យគ្រួសារនីមួយៗចំណាយយ៉ាងតិចចំនួន៣០ដុល្លារអាមេរិក ដើម្បីទទួលបាននូវបង្គន់មួយ ។ ទិន្នន័យបង្ហាញអំពីឆន្ទៈក្នុងការចំណាយ បញ្ជាក់ថាទឹកប្រាក់ចំនួន១០ដុល្លារអាមេរិកគឺជាចំនួនអតិបរិមាដែលគ្រួសារក្រីក្រភាគច្រើនមានឆន្ទៈក្នុងការចំណាយដើម្បីទទួលបានបង្គន់មួយ ។[79]

ភស្តុតាងពីប្រទេសកម្ពុជានេះ បានគាំទ្រដល់សេចក្តីសម្អាងដែលបានមកពីបទពិសោធន៍អន្តរជាតិទាក់ទងទៅនឹងការប្រើប្រាស់ការឧបត្ថម្ភធន។ សេចក្តីសម្អាងនេះទាក់ទងជាសំខាន់ទៅនឹងបញ្ហាដែលបណ្តាលមកពីការរៀបចំមិនបានល្អ ឬ ក៏កង្វះការគិតគូរពីរបៀបដែលការឧបត្ថម្ភធនត្រូវបាន អនុវត្ត ដោយរួមមាន ៖[80]

- បង្គន់ដែលបានតាមការឧបត្ថម្ភធនជាច្រើន មានតម្លៃខ្ពស់ទាំងដែលគ្មានភាពចាំបាច់សោះ ដោយសារតែការកំណត់បទដ្ឋានខ្ពស់ដែលធ្វើដោយកម្មវិធីនោះ ។
- ការឧបត្ថម្ភធនអាចធ្វើឲ្យខូចដល់ប្រភពមូលនិធិដទៃៗទៀត ដូចជាគ្រួសារខ្លួនឯងដែលចង់រង់ចាំដើម្បីទទួលបានបង្គន់ដោយមិនបាច់ចំណាយ ជាជាងចំណាយថវិកាសាងសង់បង្គន់ខ្លួនឯង
- ជាផលវិបាកនៃបញ្ហាទាំងពីរនេះ កម្មវិធីឧបត្ថម្ភធនជាច្រើនអាចនឹងមិនមានហិរញ្ញវត្ថុរឹងមាំ និងមិនមានថវិកាគ្រប់គ្រាន់ក្នុងការចំណាយសម្រាប់ការគ្របដណ្តប់ដែលតម្រូវឲ្យមាននោះ ទេ។
- ការឧបត្ថម្ភធនអាចរាំងនូវការច្នៃប្រឌិត (ការបង្កើតថ្មី) ដោយហេតុតែការគ្រប់គ្រង និងការកំណត់ប្រភេទបង្គន់ដែលអាចសាងសង់បាន ត្រូវធ្វើឡើងដោយអ្នកនៅថ្នាក់កណ្តាល។
- ការកំណត់ប្រជាជនគោលដៅមិនបានល្អបណ្តាលឲ្យការឧបត្ថម្ភធនធ្លាក់ទៅក្នុងដៃគ្រួសារ និងសហគមន៍អ្នកមាន ជាជាងទៅដល់ប្រជាជនក្រីក្រ។
- ការផ្តេកផ្តួលធ្វើឲ្យប្រជាជនរង់ចាំបង្គន់ដែលបានដោយការឧបត្ថម្ភធន ជាជាងសាងសង់វាដោយខ្លួនឯង។
- តម្រូវការមិនពិតប្រាកដ ពោលគឺ នៅពេលដែលគ្រួសារជាច្រើនទទួលបាននូវបង្គន់ឬសេវាកម្មដែលបានដោយការឧបត្ថម្ភធនពីព្រោះតែពួកគេអាចទទួលបានវា ខណៈដែលបង្គន់ ឬសេវាកម្មទាំងនេះមិនមែនជា តម្រូវការពិតប្រាកដ របស់ពួកគេ។

ជាការសំខាន់ណាស់ក្នុងការយល់ពីសមាសធាតុនៃអនាម័យដើម្បីកំណត់ទីកន្លែងនិងរបៀបក្នុងការផ្តល់ការឧបត្ថម្ភធន ។ ការចំណាយសរុបផ្នែកអនាម័យ រួមបញ្ចូលនូវការចំណាយផ្នែកទន់[81]ដូចជា ៖

- ការគាំទ្រ និងបង្កើតនូវបរិយាកាសសមស្រប។
- សកម្មភាពផ្លាស់ប្តូរឥរិយាបថផ្នែកអនាម័យ។

---

79 (Robinson, 2010)

80 សង្ខេបចេញពី (Evans et al., 2009)

81 យកលំនាំចេញពី (Evans et al., 2009)

- ការចំណាយលើការងារទីផ្សារអនាម័យ (ការវាយតម្លៃទីផ្សារ ការលើកកម្ពស់តម្រូវការ ការចំណាយលើសកម្មភាពសហគមន៍ដឹកនាំអនុវត្តន៍អនាម័យអន្តរាគមន៍ដើម្បីភ្ជាប់ដល់ការផ្គត់ផ្គង់នូវទំនិញនិងសេវាសមរម្យ (ឧទាហរណ៍ ការគាំទ្រដល់ការបណ្ដុះបណ្ដាល ឬ ហិរញ្ញវត្ថុដល់អ្នកផ្ដល់សេវាឯកជន) ជាដើម។

ហើយក៏រួមបញ្ចូលនូវការចំណាយផ្នែករឹងដូចជា ៖

- ការចំណាយលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាសាធារណៈ (ការចំណាយទុនដើម និងប្រតិបត្តិការ) ។ ជាឧទាហរណ៍ សាលារៀន និងបង្គន់សាធារណៈ ជាដើម។
- ការចំណាយលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាឯកជន (ការចំណាយទុនដើម និងប្រតិបត្តិការ) នៃបង្គន់អនាម័យតាមគ្រួសារ ។

សកម្មភាពទាំងអស់នេះត្រូវការមូលនិធិឧបត្ថម្ភ ជាថវិកាសាធារណៈ ដូចជាពីរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល ឬ ថវិកាឯកជន ដូចជាគ្រួសារផ្ទាល់ ការវិនិយោគផ្នែកឯកជនដោយរួមទាំងមីក្រូហិរញ្ញវត្ថុ។

ការវិនិយោគទៅលើអនាម័យសម្រាប់គ្រួសារមួយ គឺមិនត្រឹមតែផ្ដល់ផលប្រយោជន៍ត្រឹមតែគ្រួសារនោះប៉ុណ្ណោះទេ ថែមទាំងផ្ដល់ផលប្រយោជន៍ដល់សហគមន៍ទាំងមូលផងដែរ។ នេះគឺជាហេតុផលដ៏សំខាន់មួយសម្រាប់ការវិនិយោគសាធារណៈលើផ្នែកអនាម័យ ។ គ្រួសារខ្លះមិនបានឲ្យតម្លៃអំពីសារសំខាន់នៃអនាម័យចំពោះសហគមន៍នោះទេ។[82]

ការអភិវឌ្ឍផ្នែកអនាម័យនៅតាមគ្រួសារនៅជនបទនៃប្រទេសកម្ពុជា ច្បាស់ជាត្រូវការជាចាំបាច់នូវការឧបត្ថម្ភធន ។ ការឧបត្ថម្ភធននឹងផ្ដោតលើការចំណាយលើផ្នែកទន់ដែលមានរាយនៅក្នុងបញ្ជីសមាសភាគខាងលើ ហើយការឧបត្ថម្ភធនដើម្បីធានាឲ្យគ្រួសារដែលក្រីក្រជាងគេមានបង្គន់សមរម្យក៏អាចប្រើប្រាស់បានដែរ ដោយប្រើនូវយន្តការផ្សេងៗ ដែលបញ្ចៀសនូវបញ្ហាដែលលើកឡើងពីខាងលើ។

## ១.៦ សមាហរណកម្ម ឬ ការធ្វើដោយខ្សែកពីគ្នា នៃវិស័យផ្គត់ផ្គង់ទឹកស្អាត អនាម័យ និងការលើកកម្ពស់អនាម័យផ្ទាល់ខ្លួន

ប្រាកដហើយថាការផ្គត់ផ្គង់ទឹក អនាម័យ និងឥរិយាបថផ្នែកអនាម័យផ្ទាល់ខ្លួន មានទំនាក់ទំនងនឹងគ្នាទៅវិញទៅមក លើបញ្ហាសុខភាព និងជម្ងឺ ការចម្លងរោគទៅប្រភពទឹកតាមរយៈភាពគ្មានអនាម័យតម្រូវការទឹកសម្រាប់ផ្នែកអនាម័យ និងភស្តុតាងដែលថាការរួមបញ្ចូលនៃសមាសភាគទាំងបីនេះ មានផលប៉ះពាល់ខ្លាំងទៅលើសុខភាព បើធៀបទៅនឹងការលើកកម្ពស់តែសមាសភាគណាមួយ ។

មិនតែប៉ុណ្ណោះ ក៏មានភាពខុសគ្នាដ៏សំខាន់រវាងលក្ខណៈនៃសមាសភាគនីមួយៗ ។ ជាទូទៅវិស័យផ្គត់ផ្គង់ទឹកស្អាតគឺជាសេវាកម្មរបស់សហគមន៍ ក៏ប៉ុន្តែផលប្រយោជន៍ (ព្រមទាំងផលប៉ះពាល់ដែលកើតអំពីការផ្គត់ផ្គង់ទឹកមិនល្អ) គឺបានដល់បុគ្គលឬនៅតាមគ្រួសារនីមួយៗ។ផ្ទុយទៅវិញ បង្គន់អនាម័យគឺសម្រាប់គ្រួសារនីមួយៗ ហើយផ្ដល់ផលប្រយោជន៍ដល់គ្រួសារនីមួយៗរៀងខ្លួន ក៏ប៉ុន្តែ

[82] ( Trémolet & Evans, forthcoming)

ប្រសិនបើ  បង្គន់អនាម័យមិនមានសុវត្ថិភាព ឬមានការបន្ទោបង់ពាសវាលពាសកាល នោះនឹងមានផលប៉ះពាល់ឲ្យខូចដល់សុខភាពបរិស្ថាន សម្រាប់សហគមន៍ទាំងមូល ។ តម្រូវការផ្គត់ផ្គង់ទឹកដែលមានការកែលម្អ  គឺកើតឡើងដោយខ្លួនឯង  ប៉ុន្តែតម្រូវការផ្នែកអនាម័យ  និងការផ្លាស់ប្តូរឥរិយាបទអនាម័យផ្ទាល់ខ្លួន ទាមទារឲ្យមានការបង្កើតឡើង និងលើកកម្ពស់។

## ១.៧. ប្រតិបត្តិការ និងថែទាំ

ដូចដែលបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងគោលនយោបាយជាតិ សហគមន៍អ្នកប្រើប្រាស់ទទួលខុសត្រូវសម្រាប់ការប្រតិបត្តិ  និងថែទាំសេវាកម្មផ្គត់ផ្គង់ទឹកស្អាត  តាមរយៈក្រុមប្រើប្រាស់ទឹក  និងអនាម័យដែលជាតំណាងឲ្យសហគមន៍ ។ ប្រតិបត្តិការ និងថែទាំបង្គន់នៅតាមគ្រួសារ គឺជាការទទួលខុសត្រូវរបស់គ្រួសារនីមួយៗ ។ ប្រតិបត្តិការ និងថែទាំបង្គន់នៅតាមស្ថាប័នគឺជាការទទួលខុសត្រូវរបស់ស្ថាប័ននោះផ្ទាល់ ។

ឥឡូវនេះមានការទទួលស្គាល់កាន់តែច្រើនឡើងថា សហគមន៍ភាគច្រើននឹងមិនមានសមត្ថភាពក្នុងការគ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតរបស់ពួកគេនោះទេ  បើមិនមានជំនួយ  ពីខាងក្រៅ  ។ បើទោះបីជា  មានវិធីសាស្ត្រដែលមានការ  កែលម្អដោយផ្តោតទៅលើការបង្កើនសមត្ថភាពគ្រប់គ្រងក៏ដោយ  ក៏ហាក់ដូចជាមិនអាចទៅរួចដែរ  ក្នុងការសង្ឃឹមថាសហគមន៍ជនបទអាចទ្រទ្រង់ខ្លួនឯងបានទាំងស្រុងនោះ  ជាពិសេសនៅអំឡុងឆ្នាំដំបូង  បន្ទាប់ពីប្រព័ន្ធទាំងនេះត្រូវបានសាងសង់។ ការកើនឡើង  នៃការទទួលស្គាល់នូវភាពមានកម្រិតនៃការគ្រប់គ្រងសហគមន៍នេះ  គឺផ្អែកលើបទពិសោធន៍ក្នុងការចុះអនុវត្តជាក់ស្តែងជាច្រើន ពីសំណាក់អ្នកអនុវត្តការងារផ្ទាល់ និង ស្ថាប័នជាច្រើនជុំវិញពិភពលោក ។[83] ដូច្នោះហើយ ដើម្បីធានាឲ្យសហគមន៍បំពេញបាននូវការទទួលខុសត្រូវក្នុងការរៀបចំ និងគ្រប់គ្រងសេវាផ្គត់ផ្គង់ទឹកស្អាតនេះ រដ្ឋាភិបាល និងភ្នាក់ងារគាំទ្រដទៃៗទៀតនឹងផ្តល់ជូននូវប្រព័ន្ធគាំទ្រមួយ ។

## ១.៨. កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់កំណែទម្រង់វិមជ្ឈការ  និងវិសហមជ្ឈការ  (ឆ្នាំ២០០៥)  បានកំណត់នូវគោលការណ៍មូលដ្ឋានមួយចំនួនសម្រាប់ដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ ។ វិស័យផ្គត់ផ្គង់ទឹកស្អាត  និងអនាម័យជនបទ  ព្រមទាំងយុទ្ធសាស្ត្រនៃវិស័យនេះ  គួរតែអនុលោមតាមគោលការណ៍ទាំងនេះ ក្នុងការរៀបចំស្ថាប័នរបស់ខ្លួន ដើម្បីធានាការផ្តល់សេវាទាំងនេះដល់  សហគមន៍ជនបទ ។

ក្របខ័ណ្ឌយុទ្ធសាស្ត្រសម្រាប់ដំណើរការវិមជ្ឈការ និងវិសហមជ្ឈការ បានកំណត់នូវគោលដៅយុទ្ធសាស្ត្រចំនួនពីរសម្រាប់កំណែទម្រង់ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់រាជធានី/ខេត្ត/ក្រុង ស្រុក/ខណ្ឌ និងឃុំ/សង្កាត់ ដែលគោលដៅទាំងពីរនេះគឺ ៖

[83] (Rosensweig F., 2000; Lockwood H.. 2002; Schouten and Moriarty, 2003). In (Lockwood, 2004). See also IRC, June 2002, Background paper for "Beyond the Community", e-conference on scaling up community management of rural water supply, http://www.irc.nl/manage/debate/econf.html

- ពង្រឹង និងពង្រីកប្រជាធិបតេយ្យក្នុងតំបន់។
- ជំរុញការអភិវឌ្ឍក្នុងមូលដ្ឋាន និងកាត់បន្ថយភាពក្រីក្រ ។

ដោយមានកំណែទម្រង់ដែលផ្អែកលើគោលការណ៍សំខាន់ៗដូចខាងក្រោម ៖[84]

- តំណាងតាមបែបប្រជាធិបតេយ្យ ៖ កំណែទម្រង់នឹងពង្រឹងនូវតួនាទី នៃក្រុមប្រឹក្សានៅរដ្ឋបាល រាជធានី/ខេត្ត/ក្រុង ស្រុក/ខណ្ឌ និងឃុំ/សង្កាត់ ដែលត្រូវបង្កើតឡើងស្របតាមគោលការណ៍ប្រជាធិបតេយ្យ ដោយពង្រីកអំណាច កាតព្វកិច្ច ការទទួលខុសត្រូវ និងធនធានរបស់ពួកគេ ។
- ការចូលរួមរបស់ប្រជាពលរដ្ឋ ៖ កំណែទម្រង់នេះនឹងបញ្ចូលនូវប្រព័ន្ធ និងដំណើរការ ដើម្បីធានាថាប្រជាពលរដ្ឋ ពិសេសស្ត្រី ក្រុមជនងាយរងគ្រោះ និងក្រុមជនជាតិភាគតិច អាចចូលរួមក្នុងដំណើរការនៃការសម្រេចចិត្ត នៅនឹងកម្រិតថ្នាក់រាជធានី/ខេត្ត/ក្រុង ស្រុក/ខណ្ឌ និងឃុំ/សង្កាត់ ។
- គណនេយ្យភាពនៃវិស័យសាធារណៈ ៖ កំណែទម្រង់នេះ នឹងពង្រឹងគណនេយ្យភាពនៅរដ្ឋបាលគ្រប់ថ្នាក់ ព្រមទាំងសម្រួលការត្រួតពិនិត្យរបស់ប្រជាពលរដ្ឋទៅលើ កិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ នៃរដ្ឋបាលទាំងនោះ ។
- ប្រសិទ្ធភាព ៖ កំណែទម្រង់នឹងធ្វើឲ្យសេវាសាធារណៈចូលទៅកាន់តែក្បែរអ្នកប្រើប្រាស់សេវាតាមរយៈការអនុញ្ញាតឲ្យប្រជាពលរដ្ឋចូលរួមក្នុងការរៀបចំ និងត្រួតពិនិត្យសេវាសាធារណៈដើម្បីឲ្យ សេវាទាំងនេះឆ្លើយតបទៅនឹងតម្រូវការ និងអាទិភាពក្នុងតំបន់របស់ពួកគេ ។ កំណែទម្រង់នេះក៏នឹងធ្វើឲ្យប្រសើរឡើងនូវការងាររដ្ឋបាល និងការងារសម្របសម្រួល ថែមទាំងពង្រឹងសមត្ថភាពគ្រប់គ្រងរាជធានី/ខេត្ត/ក្រុងស្រុក/ខណ្ឌនិងឃុំ/សង្កាត់ដើម្បីលើកកម្ពស់គុណភាពសេវា និងពង្រីកការផ្តល់ជូនសេវាសាធារណៈ ។
- ការផ្តោតលើការកាត់បន្ថយភាពក្រីក្រ ៖ កំណែទម្រង់នឹងពង្រឹងសមត្ថភាពក្នុងមូលដ្ឋានក្នុងការប្រើប្រាស់ធនធានក្នុងគោលបំណងគាំទ្រដល់សកម្មភាពកាត់បន្ថយភាពក្រីក្រ ជាពិសេសសម្រាប់ក្រុមជនងាយរងគ្រោះ ក្រុមជនជាតិភាគតិច ព្រមទាំងស្ត្រីនិងកុមារ ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា ។

ការផ្គត់ផ្គង់ទឹកស្អាតនៅតាមផ្ទះគឺជាសេវាកម្មនៅនឹងមូលដ្ឋានសម្រាប់សហគមន៍ ។ ស្រដៀងគ្នានេះដែរ គេគួរតែលើកកម្ពស់និងសម្របសម្រួលនូវអនាម័យដែលផ្តល់ជូនផលប្រយោជន៍សម្រាប់សហគមន៍ទាំងមូល ដោយផ្អែកលើគ្រួសារនីមួយៗមានបង្គន់អនាម័យ និងប្រើប្រាស់ នៅនឹងកម្រិតមូលដ្ឋាន ។

ក្រុមប្រឹក្សាឃុំទាំងអស់ នឹងមិនអាចមានលទ្ធភាពចំណាយក្នុងការជួលបុគ្គលិកឯកទេសជំនាញសម្រាប់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យបានទេ ។ នាពេលបច្ចុប្បន្ន ចំនួនមនុស្សដែលមានចំណេះដឹង បទពិសោធន៍ និងសម្បទាគ្រប់គ្រាន់ សម្រាប់ធ្វើការក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទនៅមានកម្រិត ។ ហើយក្នុងពេលអនាគត ចំនួនយុវជនដែលចូលទៅក្នុងទីផ្សារការ

[84] ស្រង់ចេញពី (រាជរដ្ឋាភិបាលកម្ពុជា ឆ្នាំ២០០៥)

ងារ ហើយមានចំណាប់អារម្មណ៍ធ្វើការងារក្នុងវិស័យនេះ ក៏ទំនងជានឹងនៅតែមានកម្រិតផងដែរ ។ ដូច្នេះហើយយោងតាមធនធានមនុស្សនិងហិរញ្ញវត្ថុនៅមានកម្រិតនិងទៅតាមគោលការណ៍វិមជ្ឈការ និងវិសហមជ្ឈការ នោះកម្រិតថ្នាក់សមស្របក្នុងការធានាដល់ការផ្តល់ជូននូវសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ គឺនៅនឹងកម្រិតថ្នាក់ស្រុក ។

## ១.៩. គណនេយ្យភាព

គ្រប់ស្ថាប័នទាំងអស់មានការទទួលខុសត្រូវក្នុងការរក្សានូវគណនេយ្យភាព ។ អ្វីដែលគេចង់ដឹងនោះ គឺថាតើគណនេយ្យភាពលើផ្នែកអ្វី និងចំពោះអ្នកណា ? ចម្លើយសម្រាប់សំណួរនោះ គឺពិតប្រាកដណាស់ មិនមែនត្រឹមតែគណនេយ្យភាពលើផ្នែកហិរញ្ញវត្ថុប៉ុណ្ណោះនោះទេ ប៉ុន្តែក៏បញ្ចូលនូវគណនេយ្យភាពសម្រាប់ទិដ្ឋភាព និងផលប៉ះពាល់ផ្នែកសង្គម បច្ចេកវិទ្យា និងបរិស្ថាន នៃការផ្តល់សេវាផងដែរ ។ គណនេយ្យភាពគឺជាប្រធានបទសំខាន់មួយដោយឡែករបស់វា ហេតុនេះ យើងនឹងពិចារណាចំពោះតែទិដ្ឋភាពនៃការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យព្រមទាំងបច្ចេកវិទ្យានៃវិស័យនេះប៉ុណ្ណោះ ។ ដូច្នេះ ស្ថាប័ននានាមានគណនេយ្យភាពជាច្រើន ដោយគណនេយ្យភាពចំពោះអ្នកខាងក្រោមរួមមាន អ្នកទទួលផលម្ចាស់ឆ្នោត បុគ្គលិកថ្នាក់ក្រោម និងអ្នកគាំទ្រ និងគណនេយ្យភាពចំពោះអ្នកខាងលើរួមមានម្ចាស់ជំនួយ ឬ រដ្ឋាភិបាល។[85]

ជាការសំខាន់ត្រូវមានការញែកឲ្យដាច់រវាងគណនេយ្យភាពលើមុខងារដែលមានរយៈពេលខ្លី សម្រាប់ធនធាន ការប្រើប្រាស់ធនធាន ព្រមទាំងផលប៉ះពាល់រយៈពេលខ្លី ទៅនឹងគណនេយ្យភាពជាយុទ្ធសាស្ត្រ សម្រាប់ផលប៉ះពាល់ដែលសកម្មភាពរបស់ស្ថាប័នមួយមានទៅលើស្ថាប័នដទៃនិងបរិស្ថានផ្សេងទៀត។[86] តារាងទី១១ បង្ហាញពីរបៀបដែលគម្រោងនិងកម្មវិធីផ្គត់ផ្គង់ទឹកស្អាត និងអនាម័យរួមនឹងបច្ចេកវិទ្យារបស់ខ្លួនបន្សុំទៅនឹងផ្នែកទាំងពីរ ដោយមាននូវគណនេយ្យភាពចំពោះអ្នកខាងលើ និងអ្នកខាងក្រោម ។[87]

---

[85] យកលំនាំចេញពី Edwards M. and Hulme D., 1995, NGO Performance and Accountability: Introduction and Overview, in Non-Governmental Organisations - Performance and Accountability, ed. Edwards M. and Hulme D., Earthscan Publications Ltd., London.

[86] Avina J., 1993, The evolutionary life cycle of non-governmental development organisations, in Public Administration and Development, Vol.13, No.5 (December), quoted in Edwards and Hulme (1995).

[87] យកលំនាំចេញពី Ockelford, J., 1996. Technical and Management Issues. In: Smout I. (Editor), Water and NGOs: Proceedings of an ODA Workshop. Loughborough University, Loughborough, UK

## តារាងទី១១៖ គណនេយ្យភាពនៅក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យ

| គណនេយ្យភាព | មុខងារ (ធនធាន ការប្រើប្រាស់ធនធាន និងផលប៉ះពាល់ភ្លាមៗ) | យុទ្ធសាស្ត្រ (ផលប៉ះពាល់ទៅលើស្ថាប័ន និងបរិស្ថានផ្សេងទៀត) |
|---|---|---|
| ចំពោះអ្នកខាងលើ (អ្នកផ្តល់ជំនួយ រដ្ឋាភិបាលថ្នាក់លើ) | ◆ ប្រជាជនដែលត្រូវគ្របដណ្តប់<br>◆ ចំណាយក្នុងមនុស្សម្នាក់<br>◆ ហិរញ្ញវត្ថុនិងថវិកា<br>◆ បុគ្គលិក<br>◆ នីតិវិធី<br>◆ ការប្រើប្រាស់សម្ភារៈ និងឧបករណ៍ដែលផលិតក្នុង ប្រទេស<br>◆ ការទាញយកមកវិញពីការចំណាយ | ◆ ស្របទៅតាមគោលនយោបាយជាតិ<br>◆ ឥទ្ធិពលទៅលើគោលនយោបាយជាតិ<br>◆ សម្របសម្រួលសហប្រតិបត្តិការ<br>◆<br>រចនាសម្ព័ន្ធនិងយន្តការគាំទ្រ<br>◆ ឧបត្ថម្ភធន<br>◆ ការចូលរួមចំណាយ<br>◆ យេនឌ័រ<br>◆ ការកំណត់បទដ្ឋាន<br>◆ ការអភិវឌ្ឍបច្ចេកវិទ្យាថ្មីៗ<br>◆ ការត្រួតពិនិត្យនិងវាយតម្លៃ<br>◆ ភាពជាអាជីព |
| ចំពោះអ្នកខាងក្រោម (អ្នកទទួលផល ម្ចាស់ឆ្នោត បុគ្គលិក រដ្ឋាភិបាល ថ្នាក់ក្រោម) | ◆ ការវាយតម្លៃពីតម្រូវការ<br>◆ សហគមន៍ក្នុងការសម្រេចចិត្ត<br>◆ ជម្រើសបច្ចេកវិទ្យា<br>◆ ធនធានឬសម្ភារនៅនឹងមូលដ្ឋាន<br>◆ ការអនុវត្តដែលមានស្រាប់<br>◆ យេនឌ័រ<br>◆ តម្លៃសមរម្យអាចទទួលយកបានភាពដែលអាចចំណាយបាន<br>◆ ភាពសមស្របសម្រាប់ការប្រតិបត្តិនិងការថែទាំនៅថ្នាក់ភូមិ<br>◆ ភាពរកបាននៃគ្រឿងបន្លាស់<br>◆ ការបណ្តុះបណ្តាល | ◆ ផលប៉ះពាល់ផ្នែកបរិស្ថាន<br>◆ យេនឌ័រ<br>◆ សុខភាព<br>◆ ការត្រួតពិនិត្យនិងវាយតម្លៃ<br>◆ ភាពជាអាជីព |

នៅក្នុងប្រទេសកម្ពុជា ពាក្យថា “គណនេយ្យភាព” គឺសំដៅទៅនឹងកិច្ចការអនុវត្តផ្នែកគណនេយ្យ (ដូចជាការប្រើប្រាស់ប្រកបដោយតម្លាភាពនៃមូលនិធិសាធារណៈ) ដោយពាក្យទាំងពីរនេះសឹងតែមានន័យដូចគ្នានៅក្នុងភាសាខ្មែរ ។[88] ការអភិវឌ្ឍគណនេយ្យភាពនៅក្នុងអភិបាលកិច្ចនៃប្រទេសកម្ពុជាគួរតែពឹងផ្អែកលើចំណុចដូចខាងក្រោម ៖[89]

- គណនេយ្យភាព គឺជាគុណតម្លៃដែលមានលក្ខណៈបុគ្គល រដ្ឋបាល និងនយោបាយ ដែលគេឃើញមាននៅគ្រប់ប្រព័ន្ធរដ្ឋាភិបាលក្នុងទម្រង់ផ្លូវការ និងមិនផ្លូវការ និងក្នុងទម្រង់នយោបាយ និងរដ្ឋបាល ។

គណនេយ្យភាពមិនត្រឹមតែជាទំនាក់ទំនងរវាងតួអង្គពីរនោះទេ ប៉ុន្តែត្រូវទទួលខុសត្រូវទាំងយន្តការវិន័យ និងធនធានដើម្បីធានាឲ្យប្រព័ន្ធអភិបាលកិច្ចមួយដំណើរការប្រកបដោយការទទួលខុសត្រូវ ។

កម្ពុជាចាំបាច់គួរតែជាម្ចាស់ នៃប្រព័ន្ធអភិបាលកិច្ចដែលប្រកបដោយគណនេយ្យភាព និងឆ្លុះបញ្ចាំងពីគុណតម្លៃរបស់កម្ពុជា ។ ប្រព័ន្ធនេះចាំបាច់ត្រូវកំណត់គោលដៅក្នុងការកសាងទំនុកចិត្ត និងការពារប្រយោជន៍សាធារណៈ ជាពិសេសប្រយោជន៍របស់ជនក្រីក្រ ប្រកបដោយប្រសិទ្ធភាព និងប្រកបដោយការទទួលខុសត្រូវខ្ពស់ ។

គណនេយ្យភាពទាមទារឲ្យមានការគាំទ្រពីថ្នាក់ខ្ពស់ ការចូលរួមពី សាធារណជន និងការឆ្លើយតបផ្នែកនយោបាយ អព្យាក្រឹតភាពនិងការទទួលខុសត្រូវផ្នែករដ្ឋបាលព្រមទាំងភាពចម្រុះដ៏ត្រឹមត្រូវនៃការបែងចែកកាតព្វកិច្ច ។

ប្រព័ន្ធគណនេយ្យភាពដែលប្រសើរ នឹងត្រូវបង្កើតឡើងដើម្បីបែងចែកតួនាទី និងការទទួលខុសត្រូវជាក់លាក់ ធនធានគ្រប់គ្រាន់ និងមានលក្ខណៈប្រាកដប្រជា ការសម្របសម្រួលតាមរយៈខ្សែបណ្ដោយ និងទទឹង តម្លាភាព ការពង្រឹងច្បាប់ ព្រមទាំងការលើកទឹកចិត្តសម្រាប់ភាគីទាំងអស់ឲ្យធ្វើការងារ ។

## ១.១០. ការបញ្ច្រាបយេនឌ័រ

នៅក្នុងកម្មវិធីនារីរតនៈទី III ផែនការយុទ្ធសាស្ត្រប្រាំឆ្នាំចាប់ពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០១៣ ដើម្បីសមភាពយេនឌ័រនិងការផ្តល់អំណាចដល់ស្ត្រីក្នុងប្រទេសកម្ពុជាក្រសួងកិច្ចការនារីបានប្រកាសថាការធ្វើសុខដុមនីយកម្មផែនការបញ្ច្រាបយេនឌ័រ ជាមួយនឹងយុទ្ធសាស្ត្ររបស់វិស័យ នានាព្រមទាំងយន្តការនៃការតាមដានត្រួតពិនិត្យ និងកៀរគរធនធានគ្រប់គ្រាន់សម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាព នៅតែជាបញ្ហាប្រឈមនៅឡើយ ។

ក្រុមប្រឹក្សាសន្តិសុខសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិ កំណត់និយមន័យនៃពាក្យ “ការបញ្ច្រាបយេនឌ័រ” ថាជាដំណើរការ នៃការវាស់វែងនូវ “ភាពទទួលរងផលប៉ះពាល់របស់ស្ត្រី និងបុរស ពីសកម្មភាពទាំងឡាយដែលបានរៀបចំធ្វើដែលរួមមានការរៀបចំច្បាប់ គោលនយោបាយ ឬកម្មវិធីនៅគ្រប់ផ្នែកនិងគ្រប់កម្រិត ។ នេះជាយុទ្ធសាស្ត្រមួយសម្រាប់ការធ្វើឲ្យកង្វល់របស់ស្ត្រី

88 (Eng & Craig, 2009)
89 (Eng & Craig, 2009)

និងបុរសទៅជាទិដ្ឋភាពរួមមួយក្នុងការរៀបចំអនុវត្ត តាមដានត្រួតពិនិត្យ និងវាយតម្លៃ គោលនយោបាយ និងកម្មវិធីនៅគ្រប់ទិដ្ឋភាព តាំងពីនយោបាយ សេដ្ឋកិច្ច និងសង្គម ដើម្បីឲ្យស្ត្រីនិងបុរសទទួលបានផលប្រយោជន៍ស្មើគ្នា ហើយវិសមភាពរវាងស្ត្រី និងបុរសនឹងមិនមានទៀតទេ” ។[90]

ការបញ្ជ្រាបយេនឌ័រមានន័យថា ការទទួលស្គាល់នូវតួនាទី តម្រូវការ និងការរួមចំណែកខុសៗគ្នារបស់ស្ត្រី និងបុរស ៖[91]

- តើស្ត្រីនឹងទទួលបានផលប្រយោជន៍ដូចបុរសដែរឬទេ ?
- តើស្ត្រី និងបុរសបានទទួលការប្រឹក្សាស្តីពីការតំឡើង ជម្រើសបច្ចេកវិទ្យា ការរៀបចំស្ថាប័ន និងថាតើគំនិតរបស់ពួកគេត្រូវបានយកទៅពិចារណាក្នុងការរៀបចំគម្រោងដែរឬទេ ?
- តើការលើកកម្ពស់ផ្នែកអនាម័យផ្តោតផ្ទាល់ដល់ជនដែលជារឿយៗ ទទួលខុសត្រូវចំពោះការងារនេះ ពោលគឺស្ត្រីពេញវ័យ និងថាតើបណ្តាញទំនាក់ទំនងឆ្លើយតបមិនផ្លូវការ នៃស្ត្រី និងបុរសត្រូវបានប្រើប្រាស់ដើម្បីបង្កើតសារអប់រំសុខភាពដែរឬទេ ?
- តើតម្រូវការជាច្រើនទៅលើពេលវេលារបស់ស្ត្រី និងតម្លៃកាលានុវត្តភាពដែលស្ត្រីជួបប្រទះ ត្រូវបានទទួលស្គាល់ដែរឬទេនៅពេលរៀបចំផែនការ ដើម្បីរួមបញ្ចូលស្ត្រីទៅក្នុងការពិភាក្សានិងការចូលរួម ?
- តើការទទួលខុសត្រូវផ្សេងៗគ្នារវាងស្ត្រីនិងបុរសក្នុងការចាត់ចែងថវិកាគ្រួសារត្រូវបានគិតបញ្ចូលដែរឬទេនៅពេលប៉ាន់ស្មាននូវឆន្ទៈនិងលទ្ធភាពក្នុងការចំណាយ ?

## ១.១១. ការបញ្ជ្រាបពិការភាព

ការបញ្ជ្រាបពិការភាព រួមបញ្ចូលដំណើរការនៃការវាស់វែងនូវភាពទទួលរងផលប៉ះពាល់របស់ជនពិការក្នុងសកម្មភាពទាំងឡាយដែលរៀបចំឡើងរួមមានការរៀបចំច្បាប់ គោលនយោបាយ ឬ កម្មវិធីនៅគ្រប់ផ្នែកនិងគ្រប់កម្រិត ។ តាមរយៈការធ្វើឲ្យកង្វល់ និងបទពិសោធន៍របស់ជនពិការទៅជាទិដ្ឋភាពរួមមួយក្នុងការរៀបចំ អនុវត្ត តាមដានត្រួតពិនិត្យ និងវាយតម្លៃ គោលនយោបាយនិងកម្មវិធីនៅគ្រប់ទិដ្ឋភាពទាំងឡាយរួមមាននយោបាយ សេដ្ឋកិច្ច និងសង្គម នោះគោលដៅចុងក្រោយនៃសមភាពនៃកាលានុវត្តភាពសម្រាប់ជនពិការ នឹងអាចសម្រេចបាន ។[92]

មានប្រភេទនៃវិធីសាស្ត្រផ្សេងៗគ្នា សម្រាប់ធ្វើ នៅពេលដែលលើកឡើងមកដោះស្រាយនូវបញ្ហាពិការភាព ៖

- គម្រោងផ្តោតលើពិការភាពដែលផ្តល់នូវសេវាកម្មនានាដែលផ្តោតលើមនុស្សមានពិការភាព។
- ការបញ្ជ្រាបបញ្ហាពិការភាពទទួលខុសត្រូវក្នុងការពិចារណាលើតម្រូវការ និងសិទ្ធិនៃជនពិការនៅគ្រប់វិស័យទាំងអស់។
- វិធីសាស្ត្រតាមផ្លូវពីររួមគ្នា គឺជាការរួមបញ្ចូលគ្នានូវវិធីសាស្ត្រទាំងពីរខាងលើ នៃគម្រោងផ្តោតលើពិការភាព និងការបញ្ជ្រាបបញ្ហាពិការភាព។

---

[90] ក្រុមប្រឹក្សាសន្តិសុខសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិ ឆ្នាំ១៩៩៧ លើកឡើងនៅក្នុងកម្មវិធីទឹកស្អាត និងអនាម័យនៅអាស៊ីអាគ្នេយ៍ ឆ្នាំ២០០០

[91] WELL/DFID, 1998

[92] (កម្មវិធីទឹកស្អាត និងអនាម័យ ឆ្នាំ២០០០)

ផ្នែកដ៏សំខាន់មួយនៃវិធីសាស្ត្រនេះគឺការធ្វើឲ្យប្រាកដថាអង្គការជនពិការ (**DPO**) ត្រូវបានរួមបញ្ចូល ឬ តំណាងឲ្យ នៅក្នុងគ្រប់ដំណើរការនៃការប្រឹក្សា គណៈកម្មការ ឬ ក្រុមប្រឹក្សាភិបាល។ ការដែលសំខាន់ផងដែរនោះត្រូវរួមបញ្ចូលជនពិការគ្រប់ប្រភេទនៅក្នុងដំណើរការ ព្រោះថាអង្គការជនពិការនីមួយៗភាគច្រើនតំណាងឲ្យក្រុមមនុស្សដែលពិការភាពជាក់លាក់ណាមួយ (ឧទាហរណ៍ពិការភ្នែក ការរងរបួសដោយសារសង្គ្រាមជាដើម) នៅខណៈដែលក្រុមជនពិការដទៃទៀតមិនត្រូវបានរាប់បញ្ចូល។ បើអាចទៅរួច អ្នកតំណាងស្ត្រីពិការគួរតែចូលរួមដើម្បីឲ្យមានការបញ្ជ្រាបយេនឌ័រ ។

ជាការសំខាន់ត្រូវចងចាំក្នុងចិត្តនូវភាពចម្រុះគ្នានៃជនពិការ ។ ជនពិការដែលរួមគ្នាជាក្រុមមិនត្រឹមតែមាននូវពិការភាពផ្សេងៗគ្នាដែលតម្រូវឲ្យមានការយកចិត្តទុកដាក់ខុសៗគ្នាប៉ុណ្ណោះនោះទេ ក៏ប៉ុន្តែបានបង្ហាញនូវភាពខុសគ្នារវាងតម្រូវការពិសេសសម្រាប់បុរស និងស្ត្រី ក្មេង និងមនុស្សចាស់ មនុស្សរស់នៅតំបន់ប្រជុំជននិងតំបន់ជនបទ ឬ មានវប្បធម៌ សាសនា និងទំនៀមទម្លាប់ផ្សេងៗគ្នា ។ ដូច្នេះហើយ ជាការសំខាន់ក្នុងការមាននូវការសហប្រតិបត្តិការយ៉ាងជិតស្និទ្ធរវាងជនពិការ ឬ អង្គការជនពិការនីមួយៗ និងអ្នកបង្កើត និងអ្នកផ្តល់សេវាកម្ម ។

## ឧបសម្ព័ន្ធទី៣ ៖ គោលការណ៍ណែនាំដើម្បីទ្រទ្រង់សកម្មភាព

### យន្តការផ្តល់ហិរញ្ញប្បទានផ្នែកអនាម័យ

ការអភិវឌ្ឍវិធីសាស្ត្រដោយថ្នាក់ជាតិ នូវយន្តការផ្តល់មូលនិធិសម្រាប់ផ្នែកទន់ និងផ្នែករឹងនៃសេវាអនាម័យកក់រិតគ្រួសារ ចាំបាច់ត្រូវពិចារណានូវកត្តាមួយចំនួន ហើយដៃគូអភិវឌ្ឍន៍ទាំងអស់គួរតែពិចារណាចំពោះកត្តាទាំងអស់នោះ នៅពេលបង្កើត និងអនុវត្តការអន្តរាគមន៍នានាលើយន្តការផ្តល់ហិរញ្ញប្បទានអនាម័យ ។ កត្តាទាំងនេះ ត្រូវបានស្រង់ចេញពីឯកសារយោងមួយចំនួន[93] ។

### កត្តាទូទៅ

- ការឧបត្ថម្ភធនគួរតែសម្រេចឲ្យបានតាមលទ្ធផលនៃគោលនយោបាយដែលបានគ្រោងទុក ប្រការនេះមិនត្រឹមតែតម្រូវឲ្យមានការបង្កើតឧបត្ថម្ភធនដ៏ឈ្លាសវៃនោះទេ តែក៏តម្រូវឲ្យមានការកំណត់ឲ្យច្បាស់លាស់អំពីអ្វីខ្លះដែលជាគោលដៅគោលនយោបាយ ។ ត្រូវធ្វើការជ្រើសរើស និងថ្លឹងថ្លែងអំពីក្រុមអ្នកទទួលផលផ្សេងៗគ្នា គឺរវាងអ្នកមាន និងអ្នកក្រ អ្នកជនបទ និងអ្នកទីក្រុង ព្រមទាំងរវាងគោលដៅរយៈពេលខ្លី និងរយៈពេលវែង ។
- សូម្បីតែនៅតំបន់ជនបទ ការចំណាយគឺត្រូវរួមបញ្ចូលទាំងការចំណាយលើថ្លៃទុនដើម និងការចំណាយផ្នែកប្រតិបត្តិការ និងថែទាំក្នុងរយៈពេលវែង ឧទាហរណ៍ ការចំណាយលើការសាងសង់ និងការចំណាយប្រតិបត្តិការលើការស្តារសម្អាតកាកសំណល់លាមក និងការទុកដាក់កាកសំណល់ ។
- ដើម្បីកុំឲ្យខូចដល់ដំណើការរៀបចំចាត់ចែង សម្រាប់ការផ្តល់សេវាដែលកំពុងធ្វើការបានល្អនោះការរៀបចំការផ្តល់ហិរញ្ញប្បទានសាធារណៈផ្នែកអនាម័យ ត្រូវពិចារណាលើប្រភេទផ្សេងៗនៃអ្នកផ្តល់សេវា និងមិនត្រូវគិតថាការផ្តល់សេវាទាំងអស់ ត្រូវតែធ្វើដោយវិស័យសាធារណៈ

[93] រួមបញ្ចូល (Evans et al., 2009; Mehta, 2003; Robinson, 2010),

នោះឡើយ។

- ការត្រួតពិនិត្យ និងវាយតម្លៃដ៏សមស្រប គឺជាផ្នែកមួយដ៏សំខាន់នៃតម្លាភាព ហើយផ្នែកនេះចាំបាច់ត្រូវតែទទួលបានការផ្តល់ហិរញ្ញប្បទានពេញលេញ ដែលជាផ្នែកមួយនៃការឧបត្ថម្ភធន ។

**ផ្នែកទន់នៃអនាម័យ៖** ការគាំទ្រ និងបង្កើតនូវបរិយាកាសសមស្រប ដូចជាសកម្មភាពផ្លាស់ប្តូរឥរិយាបថអនាម័យ ការចំណាយលើការងារទីផ្សារអនាម័យ។

- សមាសធាតុផ្នែកទន់នេះ គួរតែត្រូវបានដំណើការក្នុងរបៀបដែលមិនធ្វើឲ្យមានការប៉ះពាល់ដល់តម្រូវការ ឬ មានឥទ្ធិពលមិនសមរម្យដល់ការផ្គត់ផ្គង់ទំនិញ និងសេវាកម្មអនាម័យ ។ សមាសធាតុទាំងនេះក៏មិនត្រូវឲ្យមានផលប៉ះពាល់ជាវិជ្ជមានដល់ឆន្ទៈគ្រួសារ ក្នុងការវិនិយោគធនធានរបស់ពួកគេផ្ទាល់ទៅលើផ្នែកអនាម័យ នោះដែរ ។

**ផ្នែករឹងនៃអនាម័យ៖** ចំណាយលើហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មឯកជន

- ជាក់ស្តែង ការឧបត្ថម្ភធនជាច្រើនករណី មិនបានផ្សាភ្ជាប់ទៅនឹងគោលបំណងច្បាស់លាស់ដើម្បីសម្រេចឲ្យបាននូវកម្រិតនៃអត្រាគ្របដណ្តប់ណាឡើយ ហើយជាញឹកញាប់វាបានផ្តល់លទ្ធផលមកវិញ នូវការឧបត្ថម្ភធនក្នុងកម្រិតដ៏ខ្ពស់ទៅដល់ប្រជាជនមួយចំនួនតូចហើយនឹងបរាជ័យក្នុងការសម្រេចបាននូវអត្រាគ្របដណ្តប់ខ្ពស់។ ការរៀបចំគម្រោងឧបត្ថម្ភធន ត្រូវធ្វើឡើងដោយយោងលើចំនួនប្រជាជនអ្នកទទួលផលទាំងអស់ ដើម្បីឲ្យការពង្រីកសេវាអាចសម្រេចបាននូវអត្រាគ្របដណ្តប់ខ្ពស់ក្នុងរយៈពេលកំណត់មួយ ។ ប្រសិទ្ធភាពនៃការគ្របដណ្តប់ និងពង្រីកសេវាកម្ម ក៏ផ្សាភ្ជាប់ទៅនឹងការកំណត់ប្រជាជនគោលដៅផងដែរ ព្រោះការកាត់បន្ថយការលេចធ្លាយឲ្យនៅកម្រិតអប្បបរមានឹងអាចកាត់បន្ថយការចំណាយលើការឧបត្ថម្ភធន និង អាចពង្រីកអត្រាគ្របដណ្តប់ ជាមួយនឹងកម្រិតធនធានដែលមាន ។
- ជាការចាំបាច់ ត្រូវវាយតម្លៃឲ្យបាននូវតម្រូវការពិតប្រាកដសម្រាប់ការឧបត្ថម្ភធន ។ ការពិចារណាសម្រាប់ការវាយតម្លៃនេះ រួមបញ្ចូលទាំងកម្រិតប្រាក់ចំណូលក្នុងចំណោមក្រុមគោលដៅ និងកម្រិតនៃភាពងាយរងគ្រោះ ដូចជា កុមារកំព្រា មនុស្សចាស់ជរា ស្ត្រីមេម៉ាយរស់នៅជាមួយកូនតូចៗ ជនពិការ និងប្រជាពលរដ្ឋមានជម្ងឺរ៉ាំរ៉ៃ។
- ជាការសំខាន់ ត្រូវផ្សារភ្ជាប់ទៅនឹងការគាំពារសង្គម ព្រមទាំងយន្តការកំណត់ក្រុមគោលដៅដែលមានស្រាប់ ដូចជានីតិវិធីសម្រាប់ការធ្វើអត្តសញ្ញាណកម្មចំពោះគ្រួសារក្រីក្រដែលធ្វើដោយក្រសួងផែនការរួមជាមួយនឹងទិន្នន័យតាមខេត្តនីមួយៗ[94] ។ នីតិវិធីទាំងនេះ អាចត្រូវបានប្រើប្រាស់ ជាមួយនឹងការកំណត់បន្ថែមនូវផែនទីភូមិ ឬ គ្រួសារ ដើម្បីធានាដល់ការកំណត់ក្រុមគោលដៅដែលសំដៅទៅលើប្រជាជនក្រីក្រ ។
- ការឧបត្ថម្ភធន ត្រូវតែទៅដល់ក្រុមគោលដៅដែលយើងចង់បាន ។ ប្រការនេះទាមទារឲ្យមានភាពច្បាស់លាស់ថា តើនរណាជាជនគោលដៅដែលយើងចង់បាន ហើយថា តើធ្វើយ៉ាងណាទើបការឧបត្ថម្ភធននេះបានទៅដល់ពួកគេបានយ៉ាងល្អបំផុត ។ ភាពខ្វះចន្លោះអាចនឹងកើតមានឡើងតាមរយៈការរាប់បញ្ចូលគ្រួសារដែលមានជីវភាពធូធារ និងមិនបានរាប់បញ្ចូលគ្រួសារក្រីក្រ។

[94] (ក្រសួងផែនការ ឆ្នាំ២០០៨) ត្រូវបានស្គាល់ជាទូទៅថាជា "គម្រោងកំណត់អត្តសញ្ញាណកម្មចំពោះគ្រួសារក្រីក្រ"

ប្រការនេះទាមទារឲ្យមានការត្រួតពិនិត្យដ៏ម៉ត់ចត់ ដើម្បីតាមដានវិធីដែលធានាថា ការឧបត្ថម្ភធនបានទៅដល់ក្រុមគោលដៅដែលយើងចង់បាន ។

- ជាទូទៅ ការវាស់វែងដ៏ប្រសើរនៃការកំណត់ក្រុមគោលដៅតម្រូវឲ្យមានការចំណាយរដ្ឋបាលខ្ពស់ និងគួរធ្វើការថ្លឹងថ្លែងដើម្បីកាត់បន្ថយការចំណាយក្នុងការឧបត្ថម្ភធន ដែលកើតឡើងដោយសារការកំណត់ក្រុមគោលដៅបានត្រឹមត្រូវ ។
- ការឧបត្ថម្ភធនត្រូវតែអនុវត្តក្នុងរបៀបច្បាស់លាស់ និងមានតម្លាភាពដោយហេតុថាការឧបត្ថម្ភធនរួមមានការប្រើប្រាស់ថវិកាសាធារណក្នុងចំនួនដ៏ច្រើននោះ កម្មវិធីឧបត្ថម្ភធនចាំបាច់ត្រូវតែច្បាស់លាស និងមានតម្លាភាព ហើយធានាថា គ្រួសារ ឬ សហគមន៍ដែលមានលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់នឹងទទួលបាននូវការឧបត្ថម្ភធន ហើយត្រូវផ្តល់នូវយន្តការសម្រាប់បណ្តឹងសារទុក្ខដ៏ច្បាស់លាស់ ក្នុងករណីដែលមានការកើតឡើងនូវភាពខុសឆ្គង ។

## ប្រព័ន្ធគាំទ្រការថែទាំ

តាមបទពិសោធន៍ជាសាកល បានបង្ហាញថា ការបណ្តុះបណ្តាលក្រុមប្រើប្រាស់ទឹក និងអនាម័យ និងការផ្តល់ការគាំទ្រ រយៈពេលមួយ ឬ ពីរឆ្នាំ ក្នុងរចនាសម្ព័ន្ធពេលគម្រោងនឹងមិនគ្រប់គ្រាន់ក្នុងការធានាឲ្យបាននូវនិរន្តរភាពរយៈពេលវែងសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងការគ្រប់គ្រងដោយក្រុមប្រើប្រាស់ទឹក និងអនាម័យនោះឡើយ ។ ការគាំទ្រការគ្រប់គ្រងនៅថ្នាក់សហគមន៍គឺជាករណីចាំបាច់ ប្រសិនបើយើងចង់ឲ្យប្រព័ន្ធផ្គត់ផ្គង់ទឹកមាននិរន្តរភាព ។ ការគាំទ្រនេះមិនមែនមានន័យថាជាការទាញយកមុខងារគ្រប់គ្រងពីសហគមន៍នោះទេ ។ ប៉ុន្តែមានន័យថា ជាការផ្តល់ដំបូន្មាន និងការបណ្តុះបណ្តាលបច្ចេកទេស និងគ្រប់គ្រង ដើម្បីឱ្យសហគមន៍អាចគ្រប់គ្រងសកម្មភាពនេះដោយខ្លួនឯងបាន ។ សំខាន់យើងត្រូវតាមដាន ថាតើសហគមន៍គ្រប់គ្រងប្រព័ន្ធផ្គត់ផ្គង់ទឹករបស់គេបានជោគជ័យដែរឬទេ និងដោះស្រាយបញ្ហាដែលមានដោយរបៀបណា [95]។

ប្រព័ន្ធគាំទ្រការថែទាំ នឹងត្រូវប្រព្រឹតទៅក្រោមសមត្ថកិច្ចការិយល័យអភិវឌ្ឍន៍ជនបទស្រុកនីមួយៗ តាមរយៈក្រុមប្រឹក្សាឃុំ-សង្កាត់។ មុខងារសំខាន់ៗនៃប្រព័ន្ធគាំទ្រដែលមានលក្ខណៈជាស្ថាប័ននេះ គឺ[96] ៖

- ជំនួយផ្នែកបច្ចេកទេស ៖ ផ្តល់នូវដំបូន្មាន និងគោលការណ៍ណែនាំចំពោះប្រធានបទមួយចំនួនដើម្បីគាំទ្រដល់ក្រុមប្រើប្រាស់ទឹក និងអនាម័យ ក៏ដូចជាផ្តល់នូវដំបូន្មានឯករាជ ក្នុងករណីដែលទម្រង់ខ្លះត្រូវមានភាគីកណ្តាលមួយចូលពាក់ព័ន្ធ ជាការចាំបាច់ ។
- ការបណ្តុះបណ្តាល ៖ ការបណ្តុះបណ្តាលជាបន្តបន្ទាប់ ត្រូវផ្តល់ជូនដល់សមាជិកក្រុមប្រើប្រាស់ទឹក និងអនាម័យ លើប្រធានផ្សេងៗដោយរាប់បញ្ចូលទាំងការប្រតិបត្តិ និងការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត គណនេយ្យ និងការលើកកម្ពស់អនាម័យ ក៏ដូចជាការកសាងសមត្ថភាពនៅកម្រិតសហគមន៍ ។

[95] ចេញពីសេចក្តីព្រៀងយុទ្ធសាស្ត្រវិស័យរយៈពេលដប់ឆ្នាំ ពីឆ្នាំ២០០១-២០១០ (ក្រសួងអភិវឌ្ឍន៍ជនបទ ឆ្នាំ២០០១)
[96] ប្រភព ៖ Lockwood 2002:22; EHP http://www.ehproject.org (Lockwood, 2004)

- ការត្រួតពិនិត្យនិងការប្រមូលព័ត៌មាន៖ការត្រួតពិនិត្យជាប្រចាំនៃដំណើរការរបស់ប្រព័ន្ធព្រមទាំងការផ្ដល់យោបល់លើព័ត៌មានសម្រាប់សកម្មភាពត្រូវកែតម្រូវ ។
- ការសម្របសម្រួល និងការជួយសម្រួល ៖ ជួយបង្កើតនូវការផ្សាភ្ជាប់រវាងរចនាសម្ព័ន្ធគ្រប់គ្រងសហគមន៍ និងអង្គភាពខាងក្រៅ ដែលអាចជាវិស័យរដ្ឋ ឬឯកជន ។
- ការធានារកបានគ្រឿងបន្លាស់សម្រាប់ស្នប់អណ្ដូង នៅទីផ្សារក្នុងមូលដ្ឋាន ។

ឆន្ទៈនយោបាយគឺជាកត្តាសំខាន់ ក្នុងការបង្កើតប្រព័ន្ធគាំទ្រការប្រតិបត្តិនិងថែទាំឱ្យបានជោគជ័យ ដូច្នេះហិរញ្ញវត្ថុ នឹងត្រូវបានគេយកចិត្តទុកដាក់ផ្ដល់គ្រប់គ្រាន់សម្រាប់ការសម្រេចបានអត្រាគ្របដណ្ដប់ថ្មីៗ ។ ការបរាជ័យនៃសេវាផ្គត់ផ្គង់ទឹកស្អាតមួយចំនួន នាពេលកន្លងមក គួរតែជាក្ដីបារម្ភដ៏ធំមួយ នៅថ្នាក់ជាតិ ។ ផ្ទុយទៅវិញ ការយកចិត្តទុកដាក់ខ្លាំងមានតែនៅលើការស្ដារឡើងវិញនូវសំណង់ផ្គត់ផ្គង់ទឹក ជាជាងការដោះស្រាយបញ្ហាប្រឈមធំៗ ក្នុងការបន្តដំណើរការផ្គត់ផ្គង់ទឹកឱ្យបានជោគជ័យ ។ ចាំបាច់ត្រូវមានការខិតខំប្រឹងប្រែងជាច្រើនទៀត ដើម្បីបង្កើនការយល់ដឹងថ្នាក់នយោបាយលើបញ្ហាទាំងនេះ។ សូចនាករជោគជ័យក្នុងបញ្ហានេះ គឺការបែងចែកហិរញ្ញវត្ថុប្រចាំឆ្នាំឲ្យបានគ្រប់គ្រាន់នៅក្នុងថវិកាជាតិ សម្រាប់ចំណាយចរន្តលើប្រព័ន្ធប្រតិបត្តិការ និងថែទាំដែលបានបង្កើតឡើង ។

### ប្រព័ន្ធត្រួតពិនិត្យគុណភាពទឹក

កិច្ចការទទួលខុសត្រូវសម្រាប់ការផ្គត់ផ្គង់ទឹកជនបទ ដកស្រង់ពីឯកសារបទដ្ឋានគុណភាពទឹកបរិភោគ ឆ្នាំ២០០៤ ដូចមាននៅក្នុងតារាងទី ១២ ខាងក្រោម ។

**តារាងទី ១២ ៖ ការទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យគុណភាពទឹក**

| ការទទួលខុសត្រូវ | កិច្ចការ និងប្រតិភូកម្ម |
|---|---|
